មជ្ឈមណ្ឌលត្រាជូត្រេននីង
Traju Training Center

# នីតិវិធីព្រហ្មទណ្ឌកម្ពុជា

**ដោយ ចក សម្បត្តិ ព្រះរាជអាជ្ញារង និងជាអនុប្រធានសមាគមសាលាត្រាជូ**
**នៅមជ្ឈមណ្ឌលត្រាជូត្រេននីង**
**កែប្រែចុងក្រោយ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥**

# គន្ថនិទ្ទេសនៃមេរៀន


- រដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ជាតិ លិខិតតូបករណ៍អន្តរជាតិ
- ឯកសារ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- Code de procédure pénale, Dalloz 2021
- Code pénal, Dalloz 2021
- François Fourment, Procédure pénale, Paradigme 2011
- Serge Guinchard et Jacques Buisson, Procédure pénale, Litec 4ème édition 2008
- Frédéric Desportes et Laurence Lazerges-Cousquer, traité de procédure pénale, ECONOMICA 3ème édition 2013
- Olivier MICIELS et Géraldine FALQUE, procédure pénale, Université de Liège 2ème édition 2013-2014
- Michèle-Laure Rassat, procédure pénale, ellipses 3ème édition 2017
- Yves Mayaud, droit pénal général, puf 7ème édition 2021
- Jean Larguier et Philippe Conte, procédure pénale, Dalloz 25ème édition 2019
- Corinne RERAULT-BRAHINSKY, procédure pénale, Gualino19ème édition 2018-2019
- J. Pradel et A. Varinard, les grands arrêts de la procédure pénale, Dalloz 9ème édition 2016
- Jean Pradel, droit pénal général, Cujas 22ème édition 2019
- Emmanuel DREYER et Olivier MOUSSET, procédure pénale, LGDJ 2ème édition 2019

# ច្បាប់ល្បើកថ្មី ដោយ ក្រមង៉ុយ៖

ចេះច្បាប់បាវាំង កុំភ្លេចសង្ខំ កត្តញ្ញូខន្តី
កុំឆ្មើងហួសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្តី
យកឧបេក្ខា។

កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហោ
កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំស្អប់ខាងណា
សច្ចាយកត្រង់។

# ច្បាប់ល្បើកថ្មី ដោយ ក្រមង៉ុយ៖

| | | |
|---|---|---|
| លួងលោមពិសោធ | កុំឆបញ្ឆោត | បញ្ចូលឱ្យបង់ |
| ឱ្យបែកឱ្យបាក់ | ពាក្យសត្យពាក្យសង្ឃ | កូនអើយផ្ចូត់ផ្ចូង់ |
| | តំរង់ស្មារតី។ | |
| កុំភ្លើនឃើញប្រាក់ | កុំភ្លើភ្លាត់សក្តិ | ធ្លាក់ទៅអវចី |
| កាន់ធម៌ទសពិធ | រឹតឡើងរាសី | គាប់ពីលោកិយ៍ |
| | ដល់បរលោកនាយ។ | |

# ច្បាប់ល្បើកថ្មី ដោយ ក្រមង៉ុយ៖

អ្នកក្តីជាភ្លើង កុំកាត់ជាន់ជើង អ្នកម្ខាងមើលងាយ
ថៅក្រមជាទឹក រំលឹករំលាយ កុំជេរកុំវាយ
បង្ខំនាំខុស។

ចោរលួចចោរប្លន់ រឺចោរស្ម័គ្រស្មន់ តណ្ហាស្រីប្រុស
កុំស្អប់ខាងណេះ បញ្ជេះខាងណោះ លួងលោមបញ្ចុះ
បញ្ចូលចិត្តក្តី។

# ច្បាប់ល្បើកថ្មី ដោយ ក្រមង៉ុយ៖

| | | |
|---|---|---|
| មិនគាប់ប្រសើរ | របងវាដើរ | អ្នកម្ខាងវាក្តៅ |
| កើតក្តីកើតក្តាំ | អស់ខោអស់អាវ | ខឹងអស់ញាតិផៅ |
| | ពីព្រោះចំការ។ | |
| ឯងប្តឹងវា ត | ក្តីទាល់តែក្រ | អស់ឆ្នាំងអស់ចាន |
| របស់ក៏ខាត | របរក៏ខាន | ដឹងអស់ប៉ុន្មាន |
| | ទំរាំចាញ់ឈ្នះ។ | |

# ច្បាប់គោរ៍កាលថ្មី ដោយ ក្រមង៉ុយ៖

យល់ឆ្ងាយកុំណាយជិត ទោះយល់ជិតកុំអាលខំ

មិនជាក់មើលឱ្យចំ ក្រែងច្រឡំសជាខ្មៅ។

# របៀបមើលសញ្ញាប្រើក្នុងមេរៀន

- ១-
  - ១-១
    - ១-១-១
      - ១-១-១-១

# មាតិកា

សេចក្តីផ្តើម

ភាគទី១ - គោលការណ៍មូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌ

ភាគទី២ - ការស៊ើបអង្កេត

ភាគទី៣ - បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

ភាគទី៤ - ការស៊ើបសួរ

ភាគទី៥ - ការជំនុំជម្រះ

ភាគទី៦ - អាជ្ញាអស់ជំនុំ

ភាគទី៧ - បណ្តឹងក្រោយអាជ្ញាអស់ជំនុំៈ បណ្តឹងសើរើរឿងក្តី

ភាគទី៨ - នីតិវិធីបង្ខំ ( អនីតិជនប្រព្រឹត្តបទល្មើស )

ភាគទី៩ - ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ

# សេចក្ដីផ្ដើម

# សំណួរ

- អ្វីជានីតិវិធីព្រហ្មទណ្ឌ ?
- ហេតុអ្វីចាំបាច់មាននីតិវិធីព្រហ្មទណ្ឌ ?
- នីតិវិធីព្រហ្មទណ្ឌអនុវត្តនៅពេលណា ?
- អ្នកណាជាអ្នកអនុវត្ត ? អ្នកណាដែលពាក់ព័ន្ធ ?
- ការអនុវត្តដូចម្តេច ?

# ដើម្បីផ្តន្ទាទោសជនល្មើសច្បាប់

មខ១ មខ២ ក្រមនីតិវិធីព្រហ្មទណ្ឌ



# នីតិវិធីព្រហ្មទណ្ឌប្រៀបដូចជាស្ពាន

បទល្មើស



ទោស

# និយមន័យនៃនីតិវិធីព្រហ្មទណ្ឌ

- មាត្រា១៖ *ក្រមនីតិវិធីព្រហ្មទណ្ឌមានគោលបំណងកំណត់អំពីវិធានទាំងឡាយដែល ត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។*

# តួនាទីនិងសារៈសំខាន់នៃនីតិវិធីព្រហ្មទណ្ឌ

- នីតិវិធីព្រហ្មទណ្ឌគឺជាការអនុវត្តជាក់ស្តែងនូវនីតិព្រហ្មទណ្ឌតាមរយៈការស្វែងរកជនល្មើសនៃបទល្មើសនិងការជំនុំជម្រះលើជនទាំងនោះ ដែលធ្វើឱ្យមានការជួបគ្នារវាងបទល្មើស និងទោស (ក្នុងករណីមានការផ្តន្ទាទោស)។
- សារសំខាន់នៃនីតិវិធីព្រហ្មទណ្ឌ៖
  - ទាក់ទងនឹងមុខងារដំណើរការក្តី៖ នីតិវិធីព្រហ្មទណ្ឌជាប់ទាក់ទងយ៉ាងជិតស្និតទៅនឹងនីតិព្រហ្មទណ្ឌ ជានីតិវិធីរដ្ឋប្បវេណីដែលមិនជាប់ទាក់ទងជិតស្និតនឹងនីតិរដ្ឋប្បវេណី។
  - ករណីមិនមានដំណើរការក្តី៖ នីតិវិធីព្រហ្មទណ្ឌជាមធ្យោបាយក្នុងការការពារពលរដ្ឋ ប្រឆាំងទៅនឹងជនល្មើស (អ្នកប្រព្រឹត្តល្មើសនឹងត្រូវផ្តន្ទាទោស) និងប្រឆាំងនឹងការរំលោភអំណាចទៅលើសេរីភាពបុគ្គលឯកជន។

# ខ្លឹមសារនៃនីតិវិធីព្រហ្មទណ្ឌ

- នីតិវិធីគ្រប់ដណ្តប់លើលក្ខន្តិកៈនិងការរៀបចំតួអង្គផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ និងតួនាទីរបស់តួអង្គទាំងនោះក្នុងការបង្ក្រាបបទល្មើស
- វិធានដែលទាក់ទងនឹងដំណើរការនៃចំណាត់ការព្រហ្មទណ្ឌ។
- ការពារសង្គមតាមរយៈការផ្តន្ទាទោសជនល្មើស។
- ការពារសេរីភាពបុគ្គលឯកជនដោយផ្តន្ទាទោសតែជនល្មើស។
- ដោយឡែក ផ្នែកអនុវត្តទោសគឺជានីតិស្វយ័តមួយទៀត។

# គំនូសបំព្រួញនីតិវិធីព្រហ្មទណ្ឌ



# គំនូសបំព្រួញនីតិវិធីព្រហ្មទណ្ឌ



# យុត្តិធម៌ព្រហ្មទណ្ឌ

- យុត្តិធម៌ព្រហ្មទណ្ឌ
  - សារធាតុ
    - នីតិព្រហ្មទណ្ឌទូទៅ
    - នីតិព្រហ្មទណ្ឌពិសេស
  - ទម្រង់
    - នីតិវិធីព្រហ្មទណ្ឌ

# គន្លាក់នៃការសិក្សានីតិវិធីព្រហ្មទណ្ឌ



# អត្ថិភាពនៃបទល្មើស

- អំពើល្មើស
  - កំហុសរដ្ឋប្បវេណី
  - កំហុសរដ្ឋបាល
  - កំហុសសីលធម៌ ឬប្រពៃណី
  - កំហុសព្រហ្មទណ្ឌ (ឧក្រិដ្ឋ មជ្ឈិម និងលហុ)។
- ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ
  - ច្បាប់ចែងកំណត់អំពើល្មើស និងទោស
  - ចេតនាប្រព្រឹត្តបទល្មើស
  - អំពើល្មើស។

# អត្ថិភាពនៃបទល្មើស

- ❖ផ្នែកច្បាប់ការបែងចែងអំពើល្មើសជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ / រូបវន្តបុគ្គល និងនីតិបុគ្គល។
- ❖ប្រយោជន៍នៃការកំណត់បទល្មើស និងប្រភេទបុគ្គលប្រព្រឹត្តបទល្មើស៖
  - ❑ព្រហ្មទណ្ឌសារធាតុ៖ ការប៉ុនប៉ង ការសមគំនិត ការព្យួរទោស។ល។
  - ❑ផ្នែកច្បាប់ព្រហ្មទណ្ឌនីតិវិធី៖
    - ➢សមត្ថកិច្ចច្បាប់ (បទឧក្រិដ្ឋ ឬ មជ្ឈិម អាចជាសមត្ថកិច្ចច្បាប់កម្ពុជា ឬ ច្បាប់បរទេស / ច្បាប់យុត្តិធម៌អនីតិជន ឬក្រម)
    - ➢សមត្ថកិច្ចតុលាការ (សាលាឧក្រិដ្ឋ សាលាមជ្ឈិម សាលាលហុ / តុលាការកម្ពុជា ឬតុលាការបរទេស / តុលាការយោធា)
    - ➢ការចោទប្រកាន់ (RI/CI/CD)
    - ➢អាជ្ញាយុកាលនៃបទល្មើស
    - ➢កិច្ចស៊ើបអង្កេត (ការឃាត់ខ្លួន) និង កិច្ចស៊ើបសួរ (ការឃុំខ្លួន) ព្រមទាំងការជំនុំជម្រះ។ល។

# ការវិវត្តនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

- **ក្រមពិភាក្សាព្រហ្មទណ្ឌកម្ពុជា និងរៀបចំតុលាការ** បោះពុម្ពដោយរោងពុម្ពប្រូតិចតូរ៉ា ឆ្នាំ១៩១២ (សំណៅជាភាសាបារាំង)៖ មិនទាន់មានស្ថាប័នអយ្យការ ដោយបណ្តឹងអាជ្ញាអនុវត្តដោយជនរងគ្រោះ មេឃុំ នគរបាល។ ក្រមនេះទទួលយកប្រព័ន្ធចៅក្រមស៊ើបសួរ ( **សភាចារបុរស** )។
- **ក្រមនីតិវិធីសម្រាប់វិស័យព្រហ្មទណ្ឌ** បោះពុម្ពដោយរោងពុម្ពប្រូតិចតូរ៉ា ឆ្នាំ១៩៣៨ (សំណៅជាភាសាបារាំង)៖ ចាប់ផ្តើមមានស្ថាប័នអយ្យការ និងរក្សានូវប្រព័ន្ធចៅក្រមស៊ើបសួរ ( **សភាចារបុរស** ) ដដែល។

# ការវិវត្តនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

❖ **ក្រមពិភាក្សាព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៦២៖** វិសោធនកម្មទៅលើក្រមឆ្នាំ១៩៣៨ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណាព្យាបាលបារាំង។ (ប្រើប្រាស់រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥)។ ក្រមនេះនៅរក្សានូវប្រព័ន្ធចៅក្រមស៊ើបសួរ (**សភាចារបុរស**) ដដែល។

❖ **ច្បាប់ស្ដីពីនីតិវិធីជំនុំជំរះផ្នែកព្រហ្មទណ្ឌឆ្នាំ១៩៨៩** (បែបសង្គមនិយម) មានចំនួនត្រឹមតែ ៧៨ មាត្រា។ ក្នុងអំឡុងពេលនេះ មិនមាននីតិវិធីបណ្ដឹងឧទ្ធរណ៍នោះទេ ដោយសារថា សាលាឧទ្ធរណ៍ទើបតែបង្កើតនៅឆ្នាំ១៩៩២ (សមត្ថកិច្ចទូទាំងប្រទេស)។ ម៉្យាងទៀត មិនមានវត្តមាននៃប្រព័ន្ធចៅក្រមស៊ើបសួរនោះទេ ដោយមានតែស្ថាប័នអយ្យការ និងចៅក្រមជំនុំជម្រះ។ ច្បាប់នេះផ្ដល់តម្លៃខ្លាំងទៅលើសណ្ដាប់ធ្នាប់។

# ការវិវត្តិនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

- **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣** (បែបសង្គមនិយម)។ ច្បាប់នេះបានទទួលយកមកវិញនូវប្រព័ន្ធចៅក្រមស៊ើបសួរ (**ចៅក្រមស៊ើបអង្កេត**)។ ច្បាប់នេះផ្តល់តម្លៃខ្លាំងទៅលើសណ្តាប់ធ្នាប់។

- **ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧** និង**ច្បាប់វិសោធនកម្មឆ្នាំ២០១៣**។ បង្កើតបាននូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទំនើបថ្មីមួយដែលធានាការពារសិទ្ធិសេរីភាពរបស់បុគ្គលឯកជនស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ក្រមនេះនៅរក្សាទុកប្រព័ន្ធ**ចៅក្រមស៊ើបសួរ**ដដែល ហើយដែលយកទៅប្រើនៅ **អ.វ.ត.ក** ផងដែរ។ ក្រសួងយុត្តិធម៌កំពុងដំណើរការវិសោធនកម្មក្រមឆ្នាំ២០០៧ នេះ។

# ប្រភពនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

❖ **រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣៖** ម៣១ (ទទួលស្គាល់និងគោរពវិធានសិទ្ធិមនុស្សអន្តរជាតិ។ វិសាលភាពត្រឹមណា?) ម៣៨ (សិទ្ធិការពារខ្លួន) ម៤០ ម១២៨ថ្មី ដល់ ម១៣១ថ្មី (សាលាជម្រះក្តី)។ មាត្រា៣១៖

- ❑ តើវិធានសិទ្ធិមនុស្សអន្តរជាតិទាំងអស់ត្រូវយកមកអនុវត្តដោយផ្ទាល់នៅកម្ពុជាឬទេ (Monism)? សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ៩២ ឆ្នាំ២០០៧៖ ចៅក្រមកម្ពុជាជំនុំជម្រះក្តីដោយផ្អែកលើច្បាប់ទាំងជាតិ និងអន្តរជាតិ។
- ❑ ឬត្រូវសភាកម្ពុជាផ្តល់សច្ចាប័ន (Dualism)? ឧទាហរណ៍ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនមានពិការភពដែលកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ២០១២។

# ប្រភពនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

## ❖ លិខិតបទដ្ឋានអន្តរជាតិ៖

- ❑ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ១៩៤៨ (ទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣)៖ ម៥ ម៧ ម៨ ម៩ ម១០ ម១១ និងម១២។
- ❑ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ១៩៦៧ (ឆ្នាំ១៩៩១ តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១) ៖ ម៩ ម១០ ម១៤ និងម១៧។
- ❑ អនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៨៩ (ឆ្នាំ១៩៩១)៖ ម១៦ ម៣៧ ម៣៩ និង ម៤០។
- ❑ អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ឆ្នាំ១៩៨៧ (ឆ្នាំ១៩៩១)។

# ប្រភពនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

- អនុសញ្ញាស៊ីដរឆ្នាំ១៩៧៩ (ឆ្នាំ១៩៩២) ៖ មា៣ មា១៥។
- អនុសញ្ញាស្ដីពីសិទ្ធិជនមានពិការភាពឆ្នាំ២០០៦ (ឱ្យសច្ចាប័នឆ្នាំ២០១២)៖ មា៣ (សេរីភាព និងឯករាជ្យ ឬស្វ័យភាពរបស់ជនមានពិការភាព) មា៥ មា១២ មា១៣-១៧។ កុមារអូទីស្សឹម ឬ ដោនស៊ីនដ្រូម?
- សេចក្ដីប្រកាសរបស់អាស៊ានស្ដីពីសិទ្ធិមនុស្ស ឆ្នាំ២០១២៖ មា៥ មា១២ មា១៤ មា២០ មា២១ (ច្បាប់ទន់)។
- សន្ធិសញ្ញាអាស៊ាន និងទ្វេភាគីស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកព្រហ្មទណ្ឌ។ល។

# ប្រភពនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

❖ ច្បាប់

- ❑ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ (**ជាវិធានទូទៅ**)
- ❑ ច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣
- ❑ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២
- ❑ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០
- ❑ ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ ឆ្នាំ២០២០
- ❑ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៥ ។
- ❑ ច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក ឆ្នាំ២០២៥។ល។

# ប្រភពនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា

- បទបញ្ញាៈ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬ សារាចរណែនាំ
- យុត្តិសាស្ត្រ
- ទំនៀមទំលាប់ ?
- លទ្ធិ ?

# តួអង្គក្នុងនីតិវិធីព្រហ្មទណ្ឌ

- ស្ថាប័នតុលាការ៖ ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (ធ្វើអធិបញ្ញាឱ្យចោទប្រកាន់ និងដឹកនាំនយោបាយព្រហ្មទណ្ឌ)
- តួអង្គជំនួយ៖ មេធាវី អាជ្ញាសាលា មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីពន្ធនាគារ អ្នកជំនាញ អ្នកបកប្រែ
- ជនល្មើស (ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត) ឬអ្នកតំណាងជនល្មើស (ករណីនីតិបុគ្គល) និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី (សមាគមមួយចំនួន) ឬ អ្នកតំណាង
- សាក្សី
- អ្នកប្តឹងបរិហារ ភ្នាក់ងារសង្គមកិច្ច ម្ចាស់ដើមនៃវត្ថុចាប់យក។ល។

# យុត្តាធិការព្រហ្មទណ្ឌកម្ពុជា

- ❖ **សាលាដំបូង**
  - ❑ អយ្យការអមសាលាដំបូង
  - ❑ ចៅក្រមស៊ើបសួរ
  - ❑ តុលាការព្រហ្មទណ្ឌ ឬ ចៅក្រមជំនុំជម្រះ
- ❖ **សាលាឧទ្ធរណ៍**
  - ❑ មហាអយ្យការអមសាលាឧទ្ធរណ៍
  - ❑ សភាស៊ើបសួរ និង សភាព្រហ្មទណ្ឌ
- ❖ **តុលាការកំពូល**
  - ❑ មហាអយ្យការអមតុលាការកំពូល
  - ❑ សភាព្រហ្មទណ្ឌ (ទាំងរឿងស៊ើបសួរ និងអង្គសេចក្តី ព្រមទាំងរឿងបត្យាប័ន)




*ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤*

# យុត្តាធិការព្រហ្មទណ្ឌកម្ពុជា

| | |
|---|---|
| **តុលាការកំពូល**<br>សភាព្រហ្មទណ្ឌ | **មហាអយ្យការអម<br>តុលាការកំពូល** |
| **សាលាឧទ្ធរណ៍**<br>សភាព្រហ្មទណ្ឌ-សភាស៊ើបសួរ | **មហាអយ្យការអម<br>សាលាឧទ្ធរណ៍** |
| **សាលាដំបូង**<br>ចៅក្រមស៊ើបសួរ -ចៅក្រមជំនុំជម្រះ | **អយ្យការអមសាលាដំបូង** |

# យុត្តាធិការព្រហ្មទណ្ឌកម្ពុជា

- **យុត្តាធិការព្រហ្មទណ្ឌពិសេស៖** តុលាការយោធា
- **យុត្តាធិការព្រហ្មទណ្ឌវិសាមញ្ញ៖** អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

# សមត្ថកិច្ចនៃយុត្តាធិការព្រហ្មទណ្ឌកម្ពុជា

- **សមត្ថកិច្ចនៃយុត្តាធិការព្រហ្មទណ្ឌ៖** វិធានអាជ្ញាបញ្ញាមិនអាចធ្វើបដិបញ្ញត្តបាន និងអាចលើកឡើងដោយតុលាការ ឬគូភាគីបានគ្រប់ពេលវេលានៃដំណើរការក្តី។
  - *ratione materiæ* សមត្ថកិច្ចសម្ភារៈ ឬ តាមសាច់រឿង (ម២៨៩, ម៣៤២ តុលាការព្រហ្មទណ្ឌ គ្មានសមត្ថកិច្ចសម្រេចអំពីសិទ្ធិកម្មសិទ្ធិ សិទ្ធិភណ្ឌិតលើអចលនវត្ថុ និងឋានៈបុគ្គល)។
  - *ratione loci* សមត្ថកិច្ចដែនដី (ម៣៩, ម១២៣, ម២៩០, ម៥៩៧ ក្រម និងម១៩ ក១ ច្ប.រៀបចំអង្គការតុលាការ)។
  - *ratione temporis* សមត្ថកិច្ចតាមពេលវេលា៖ (ច្បាប់ អ.វ.ត.ក) ការបង្កើតសាលាដំបូងខេត្តកែប ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ សាលាឧទ្ធរណ៍តំបន់។
  - *ratione personæ* សមត្ថកិច្ចលើបុគ្គល៖ (ច្បាប់ អ.វ.ត.ក), រឿងក្តីដែលមានជនល្មើសជានីតិជន និងអនីតិជន។

# សមត្ថកិច្ចនៃយុត្តាធិការព្រហ្មទណ្ឌកម្ពុជា

## ❖ សមត្ថកិច្ចអញ្ញត្រកម្ម៖

- ❑ តុលាការដែលសម្រេចរួមក្រុមនៅតែអាចជំនុំជម្រះបានដដែលចំពោះបទឧក្រិដ្ឋតាមដីការបស់ចៅក្រមស៊ើបសួរដោយសារតុលាការយល់ឃើញថាជាបទមជ្ឈិម ឬ លហុ មព៣៤៨។
- ❑ បទឧក្រិដ្ឋដែលប្តឹងដោយព្រះរាជអាជ្ញា ហើយត្រូវបានកំណត់ទៅជាបទមជ្ឈិម ឬ លហុវិញ នោះចៅក្រមស៊ើបសួរនៅតែមានសមត្ថកិច្ចដដែល ម២៤៧ថ្មី (បញ្ជូនទៅជំនុំជម្រះបទឧក្រិដ្ឋ មជ្ឈិម លហុ។)។
- ❑ ម៣៤៨ ម៣៤៩ តុលាការអាចជំនុំជម្រះតែលើអង្គហេតុនិងបុគ្គលដែលប្តឹងមកចំពោះខ្លួន លើកលែងតែ៖
  - ➢ បញ្ញូលនីតិវិធី ម២៩៩ (លក្ខខណ្ឌ៖ ចំណងរវាងបទល្មើសទៅលើពេលវេលា ទីកន្លែង និងភាពតែមួយនៃការគិតប្រព្រឹត្តបទល្មើស ព្រមទាំងមានភាពមិនអាចបំបែកបាននៃអង្គហេតុ)

# សមត្ថកិច្ចនៃយុត្តាធិការព្រហ្មទណ្ឌកម្ពុជា

- ការផ្ទេរសំណុំរឿងពីតុលាការដែលមានសមត្ថកិច្ចដែនដីទៅតុលាការផ្សេងដែលគ្មានសមត្ថកិច្ចដែនដី។ ឧ. ម១៩ ក១ (អំណាចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីចាំបាច់ដើម្បីប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ) ច្ប.រៀបចំអង្គការតុលាការ។ កុំច្រឡំជាមួយការផ្ទេរសំណុំរឿងពីដែលតុលាការគ្មានសមត្ថកិច្ចដែនដីទៅតុលាការដែលមានសមតកិច្ចដែនដី។ ការប្ដឹងដិតចិត្តចៅក្រមដើម្បីផ្លាស់ប្ដូរចៅក្រម (អត្តវិស័យ និងវត្ថុវិស័យ)។ ការបំពេញសមាសភាពជំនុំជម្រះដោយចៅក្រមពីតុលាការជំនាញផ្សេង ឬ សាលាជម្រះក្ដីផ្សេង ម១៦ ក២ ច្ប.រៀបចំអង្គការតុលាការ។

# សមត្ថកិច្ចនៃយុត្តាធិការព្រហ្មទណ្ឌកម្ពុជា

➢ សមត្ថកិច្ចអញ្ញត្រកម្ម បញ្ហាបន្ទាន់បង្ខំ (ទាក់ទងនឹងមធ្យោបាយការពារក្ដី) ម៣៨២ ដើម្បីយុត្តិធម៌ល្អមួយ យុត្តិធម៌លឿនរហ័ស ចៀសវាងការប្រើយុទ្ធសាស្ត្រពន្យាពេលរបស់គូភាគី នោះចៅក្រមព្រហ្មទណ្ឌមានសិទ្ធិពិនិត្យមើលទៅលើគ្រប់អញ្ញត្រកម្មទាំងអស់ដែលលើកឡើងដោយគូភាគី លើកលែងតែជាសមត្ថកិច្ចរបស់តុលាការជំនាញដទៃ។

# ការដឹកនាំនយោបាយព្រហ្មទណ្ឌ

- ទស្សនទាននូលាយៈ នយោបាយព្រហ្មទណ្ឌគ្រប់ដណ្តប់លើ ៦ ចំណុច គឺ
  - ទី១ ការតាក់តែងច្បាប់ព្រហ្មទណ្ឌ (អង្គសភា/អង្គនីតិប្រតិបត្តិ ម១ក្រមព្រហ្មទណ្ឌ)
  - ទី២ ការបង្ការបទល្មើស
  - ទី៣ ការស្វែងរកជនល្មើស
  - ទី៤ ការចោទប្រកាន់ជនល្មើស
  - ទី៥ ការជំនុំជម្រះ
  - ទី៦ ការអនុវត្តទោស។

# ការដឹកនាំនយោបាយព្រហ្មទណ្ឌ

- ❖ទស្សនទានចង្អៀត៖ នយោបាយព្រហ្មទណ្ឌសំដៅទៅលើការបើក និងអនុវត្តបណ្ដឹងអាជ្ញា៖
  - ❑នយោបាយព្រហ្មទណ្ឌថ្នាក់ជាតិ៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។
  - ❑ថ្នាក់តំបន់៖ មហាអយ្យការអមសាលាឧទ្ធរណ៍តំបន់។
  - ❑ថ្នាក់មូលដ្ឋាន ឬ ខេត្តរាជធានី៖ អយ្យការអមសាលាដំបូងរាជធានី ខេត្ត (សហការជាមួយគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត)។

# រចនាសម្ព័ន្ធនិងមុខងារនៃអង្គអយ្យការ




*សូមអានមាត្រា ២៧ ដល់ ៣៩*
*នៃក្រមនីតិវិធីព្រហ្មទណ្ឌ*

# ប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌកម្ពុជា ?

❖ម៉ូដែល Accusatoire / Adversarial ( ប្រព័ន្ធដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ favorable à l’accusé/in favour of the accused )

- ❑តួនាទីសកម្មរបស់គូភាគី និងតួនាទីអកម្មរបស់ចៅក្រម។
- ❑ចៅក្រមជ្រើសរើសដោយគូភាគី និងអាចប្តឹងជំទាស់បាន។
- ❑ឥស្សរចិត្តរបស់ចៅក្រម l’intime conviction។
- ❑ជនរងគ្រោះជាអ្នកបើកឱ្យមាននីតិវិធីបណ្តឹង។
- ❑លក្ខណៈ៖ ចំពោះមុខ សាធារណៈ និងផ្ទាល់មាត់។

# ប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌកម្ពុជា ?

- ❖ គុណតម្លៃនៃម៉ូដែល Accusatoire / Adversarial៖
  - ❑ គុណសម្បត្តិ៖ ប្រព័ន្ធដែលផ្តល់ការធានាច្រើនដល់ជនជាប់ចោទ (ការជជែកពិភាក្សាដោយសេរីជាមួយនឹងអ្នកប្តឹង)
  - ❑ គុណវិបត្តិ៖ ប្រព័ន្ធដែលលះបង់ចោលនូវប្រយោជន៍នៃការបង្ក្រាប៖
    - ➢ ដោយសារថាគ្មានការចោទប្រកាន់ (ការភ័យខ្លាច ភាពអសកម្ម ផលប្រយោជន៍) នោះបទល្មើសជាច្រើនក្លាយជានិទណ្ឌភាព។
    - ➢ អំណាចក្នុងការស៊ើបអង្កេតសម្រាប់ចៅក្រមគឺខ្វះខាត។

# ប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌកម្ពុជា ?

❖ម៉ូដែល Inquisitoire / Inquisitorial (ប្រព័ន្ធដែលផ្ដល់ប្រយោជន៍ដល់ការបង្ក្រាប favorable à la répression/ in favour of repession )

- ❑តួនាទីអកម្មរបស់គូភាគី និងតួនាទីសកម្មរបស់ចៅក្រមក្នុងការរកភស្តុតាង
- ❑លក្ខណៈ៖ មិនចំពោះមុខ សម្ងាត់ និងសរសេរ។
- ❑ចៅក្រមជាអ្នករាជការសាធារណៈអចិន្ត្រៃយ៍ ដែលគូភាគីត្រូវតែទទួលយក។
- ❑ចៅក្រមជាអ្នកបើកឱ្យមាននីតិវិធីនៃបណ្តឹង។

# ប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌកម្ពុជា ?

❖ គុណតម្លៃនៃម៉ូដែល Inquisitoire / Inquisitorial៖

❑ គុណសម្បត្តិ៖ ប្រព័ន្ធដែលអនុញ្ញាតឱ្យមានការបង្ក្រាបប្រកបដោយថាមពល និងល្បឿនរហ័ស។

❑ គុណវិបត្តិ៖

➢ ប្រព័ន្ធដែលលះបងចោលនូវប្រយោជន៍នៃការការពារក្ដីរបស់ជនល្មើស។

➢ អំណាចចោទប្រកាន់មានតែនៅក្នុងដៃចៅក្រម (អយ្យការ)។

# នីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ ប្រព័ន្ធចម្រុះ

- ដោយសារឥទ្ធិពលនៃវិធានច្បាប់នីតិវិធីបារាំង (បារាំងដែលមានប្រព័ន្ធដើម inquisitorial តាមរយៈ **grande ordonnance criminelle de 1670**) ដែលកម្ពុជាទទួលយកស្ទើរតែទាំងស្រុងតាំងពីឆ្នាំ១៩១២ និងវិធានសិទ្ធិមនុស្សអន្តរជាតិ (អ.ស.ប) ដែលកម្ពុជាទទួលស្គាល់ក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌកម្ពុជាចាប់តាំងពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជាប្រព័ន្ធបែបចម្រុះដែលជាការបញ្ចូលគ្នារវាងម៉ូដែល Inquisitorial (នីតិវិធីស៊ើបសួរ និងតួនាទីរបស់ចៅក្រមស៊ើបសួរក្នុងការស្វែងរកភស្តុតាង ភាពជាម្ចាស់ បណ្តឹងអាជ្ញារបស់អង្គការអយ្យការ) ជាមួយនឹងម៉ូដែល Adversarial (ឥស្សរចិត្តរបស់ចៅក្រមទៅលើភស្តុតាង ការជំនុំជម្រះក្តីជាសាធារណៈ ផ្ទាល់មាត់ និងចំពោះមុខ) ទៅគ្រប់ដំណាក់កាលនៃនីតិវិធី។

# ភាគទី១

## គោលការណ៍មូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌ

# ការរៀបចំស្ថាប័នតុលាការ

## ❖ឯករាជ្យ និងអនាគតិ៖ ការពារសេរីភាពបុគ្គលឯកជន

- ❑ឯករាជ្យពីអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ និងឯករាជ្យពីតុលាការផ្សេងៗ ព្រមទាំងឯករាជ្យពីគូភាគី។
- ❑ឯករាជ្យបុគ្គល និង ឯករាជ្យស្ថាប័ន។
- ❑ឯកភាពនៃចៅក្រមព្រហ្មទណ្ឌ និងចៅក្រមរដ្ឋប្បវេណីក្នុងតុលាការតែមួយ។
- ❑គិតតាំងពីការប្រឡងចូល (ចៅក្រមវិជ្ជាជីវៈ) ការតែងតាំង ការផ្លាស់ប្តូរនិងបញ្ចប់មុខតំណែង។
- ❑ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺជាអ្នកធានានូវឯករាជ្យនិងអនាគតិ។

# ការរៀបចំស្ថាប័នតុលាការ

- **គោលការណ៍ឋានានុក្រមនៃអង្គអយ្យការ៖** តាមច្បាប់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺជានាយឋានានុក្រមនៃអង្គការអយ្យការ (នយោបាយព្រហ្មទណ្ឌ) និងដែលមានសិទ្ធិធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ម៧៥ ច្ប.លក្ខន្តិកចៅក្រមនិងព្រះរាជអាជ្ញា ម២៩ ក្រម។
- អង្គការអយ្យការ៖ ***ស្លាបកាជាទាសី សំដីដោយសេរី* La plûme est serve, mais la parole est libre *។***

**មាត្រា ៣០.–** បណ្ដឹងដោយផ្ទាល់មាត់

ចៅក្រមអយ្យការគ្រប់រូបត្រូវគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម ។

ប៉ុន្តែ នៅពេលសវនាការ ចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការ ដោយសារតែវាចារបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការនោះឡើយ ។

# ការរៀបចំស្ថាប័នតុលាការ

- ❑សេវាយុត្តិធម៌ជាសេវាមិនលំអៀង ដូចនេះកិច្ចរបស់តុលាការគឺស្វែងរកការពិតមិនលំអៀង។
- ❑យន្តការធានាអនាគតិ៖ ការជំនុំជម្រះដោយចៅក្រមជាក្រុមប្រឹក្សា ការប្តឹងជិតចិត្តបណ្តឹងសុំមោឃភាពសាលក្រម ឬសាលដីកា (ម៧៨ច្ប.រៀបចំអង្គការតុលាការ) ការជំនុំជម្រះក្តីជាសាធារណៈ។ល។
- ❑ការកំណត់បទល្មើសដោយអយ្យការមិនតម្រូវឱ្យចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះត្រូវតែគោរពតាមនោះទេ។ នេះជាឯករាជ្យភាពរបស់ចៅក្រម។

# ការរៀបចំស្ថាប័នតុលាការ

❖**គោលការណ៍នៃការបែងចែងមុខងារ៖** គោលការណ៍នេះគឺកើតចេញពីគោលការណ៍នៃការបែងចែងអំណាចទាំងបី។ មុខងារស៊ើបអង្កេត ឬ មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះក្តី ម៥៤ ម២៨៨ (មុខងារចោទប្រកាន់ និងមុខងារជំនុំជម្រះក្តី)ត្រូវបែងចែកដាច់ពីគ្នា បើពុំនោះទេ សាលក្រមត្រូវចាត់ទុកជាមោឃៈ។ ចំណុច១០ នៃសេចក្តីណែនាំរបស់ អ.ស.ប ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា ***មុខងារអយ្យការត្រូវតែចែកឱ្យដាច់ស្រឡះពីមុខងារចៅក្រម*** ។

- ❑ស្ថាប័ននីមួយៗឯករាជ្យពីគ្នានិងមិនអាចបញ្ជាគ្នាទៅវិញទៅមកបានទេ។

# ការរៀបចំស្ថាប័នតុលាការ

- ឧ.ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ ដែលធ្លាប់ស៊ើបអង្កេត ឬ ស៊ើបសួរ មិនអាចក្លាយជាចៅក្រមជំនុំជម្រះក្នុងសំណុំរឿងដដែលនោះទេ។
- នៅបារាំង ក្នុងរឿងក្តីអនីតិជន ចៅក្រមស៊ើបសួរអាចក្លាយជាចៅក្រមជំនុំជម្រះនៃតុលាការអនីតិជនបាន ដោយហេតុផលថាគាត់ស្គាល់អំពីស្ថានភាពអនីតិជននោះច្បាស់លាស់។

# ការរៀបចំស្ថាប័នតុលាការ

❖**យុត្តាធិការ ២ ថ្នាក់ (Principe du double degré de jurisdiction)៖** ការទទួលបាននូវការត្រួតពិនិត្យឡើងវិញលើសេចក្ដីសម្រេចរបស់ថ្នាក់ក្រោម។ យ៉ាងហោចណាស់មានតុលាការខាងលើមួយពិនិត្យ សេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម សំដៅធានាការពារប្រឆាំងនឹងភាពមិនប្រក្រតីនៃការសម្រេចសេចក្ដីរបស់ចៅក្រមជាន់ដំបូង។ ជាអញ្ញត្រកម្ម ក្នុងករណីខ្លះមិនអនុញ្ញាតឱ្យប្ដឹងតវ៉ា ក្នុងករណី អនុញ្ញាតត្រឹមតែប្ដឹងតវ៉ា ឬឧទ្ធរណ៍ ក្នុងករណីខ្លះទៀតអនុញ្ញាតឱ្យតវ៉ា ឬ ប្ដឹងឧទ្ធរណ៍ ឬប្ដឹងសាទុក្ខ។

- ❑នៅបារាំង ក្នុងរឿងប្ដឹងសុំលុបព្រឹត្តិបត្រចោ្ទលទោស តុលាការអនីតិជនសម្រេចក្ដីជាលើកដំបូង និងជាចុងក្រោយ។
- ❑ការសម្រេចធ្វើសវនាការពិភាក្សាដេញដោលជាសម្ងាត់ គឺមិនអាចតវ៉ាបានទេ ម៣១៦។

# ការរៀបចំស្ថាប័នតុលាការ

- សាលាក្តីខ្មែរក្រហម មិនមានអង្គជំនុំជម្រះសាលាឧទ្ធរណ៍ទេ។
- ឱ. ការបង្កើតតុលាការប្រជាជនបដិវត្តខេត្ត-ក្រុង នៅឆ្នាំ១៩៧៩ និងឆ្នាំបន្ទាប់ ការបង្កើតតុលាការកំពូល នៅឆ្នាំ១៩៨៥ និងសាលាឧទ្ធរណ៍នៅឆ្នាំ១៩៩២។
- ឱ. ការសម្រេចលើការប្រគល់វត្ថុចាប់យក ការសម្រេចតម្កល់រឿងទុកឥតចាត់ការដែលអាចតវ៉ាបានតែត្រឹម មហាអយ្យការអមសាលាឧទ្ធរណ៍តែប៉ុណ្ណោះ។
- ម២៤៧ថ្មី ក៨ បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬ ដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃ ការរឹបអូស មានត្រឹមតែសិទ្ធិប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសាលក្រមអង្គសេចក្តី តែមិនមានសិទ្ធិប្តឹងសារទុក្ខទេ។
- ច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកឆ្នាំ២០២៥ អាចតវ៉ាត្រឹមថ្នាក់ឧទ្ធរណ៍ដែលសេចក្តី មស្រេចនៅថ្នាក់នេះសម្រេចបិទផ្លូវតវ៉ា (សុើបអង្កេត ម៦, សុើបសួរ ម៧៨ និងជំនុំជម្រះម៨)។

# ការរៀបចំស្ថាប័នតុលាការ

## ❖ការពឹងពាក់តុលាការ

- ❑ការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច និងបង្កើតឡើងត្រឹមត្រូវតាមច្បាប់
- ❑ការធ្វើបណ្តឹងតវ៉ានានា ដូចជា សិទ្ធិប្តឹងឧទ្ធរណ៍ ប្តឹងសាទុក្ខ។
- ❑គូភាគីមានភាពស្មើគ្នាចំពោះមុខតុលាការ និងច្បាប់
- ❑យុត្តិធម៌ដែលមិនតម្រូវឱ្យបង់សោហ៊ុយ
- ❑សេវាយុត្តិធម៌ដែលនៅកៀក និងងាយស្រួលប្រើប្រាស់
- ❑ជំនួយផ្នែកច្បាប់ និងសេវាជំនួយផ្សេងៗ ដូចជាមេធាវី ការបកប្រែ សង្គមកិច្ច (អនីតិជន)និងផ្សេងៗ
- ❑ជនមានពិការភាព៖ អគារតុលាការបំពាក់គ្រប់គ្រាន់ដោយសម្ភារៈ ផាសុកវត្ថុសម្រាប់ជនមានពិការភាព។ ជនមានពិការភាពជាគូភាគី ឬសាក្សីនៃសំណុំរឿង? កុមារអូទីស្សឹម ឬ ដោនស៊ីនដ្រូម?

# គោលការណ៍សច្ចធារណ៍នៃនិរទោស

## ❖ វិធាននីតិវិធី

- ❑ ហាមឃាត់ការប្រកាសពិរុទ្ធភាពជាមុន
- ❑ គ្មានទោសរហូតដល់មានសាលក្រម ឬសាលដីកាស្ថាពរលើអង្គសេចក្តី
- ❑ អញ្ញត្រកម្ម៖ គោលការណ៍សច្ចធារណ៍នៃពិរុទ្ធភាព។ ឧ. ក្នុងរឿងប្រឆាំងការសម្អាតប្រាក់ ទ្រព្យដែលគ្មានប្រភពច្បាស់លាស់គឺជាទ្រព្យខុសច្បាប់ លើកលែងតែមានភស្តុតាងផ្ទុយ។

# គោលការណ៍សច្ចធារណ៍នៃនិរទោស

## ❖ សិទ្ធិផ្ទែកបុគ្គលភាព

- ត្រូវបានការពាររហូតដល់សាលក្រម ឬសាលដីកាស្ថាពរ។ ករណីបំពានសិទ្ធិនេះ អាចទទួលរងការទាមទារសំណង ឬបង្កើតជាបទល្មើស ដូចជាការប្ដឹងបរិហារបង្អាច់កេរ្តិ៍ ការបំពានការសម្ងាត់ការសើបសួរ។
- គ្មានអ្នកណាអាចត្រូវបានចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន ចោទប្រកាន់ ឬជំនុំជម្រះតាមទំនើងចិត្តនោះទេ។ ពោលគឺត្រូវធ្វើឡើងតាមច្បាប់។

# ការអនុវត្តវិធាននីតិវិធីព្រហ្មទណ្ឌ

- ❖ **គោលការណ៍នីត្យានុកូលភាព៖**
  - ❑ គ្មានដំណើរការក្តីប្រភេទណាមួយនោះទេ បើគ្មានច្បាប់កំណត់។ ក្នុងនីតិវិធីព្រហ្មទណ្ឌ និងការការពារសិទ្ធិសេរីភាព ***អ្វីដែលមិនត្រូវបានអនុញ្ញាតគឺត្រូវបានហាមឃាត់*** (ផ្ទុយពីច្បាប់ព្រហ្មទណ្ឌសារធាតុ ***អ្វីដែលមិនត្រូវបានហាមឃាត់ គឺត្រូវបានអនុញ្ញាត***)។
  - ❑ ការអនុវត្តភ្លាមនៃច្បាប់ព្រហ្មទណ្ឌផ្នែកនីតិវិធី ម១១ ក្រមព្រហ្មទណ្ឌ
  - ❑ ការបកស្រាយច្បាប់ព្រហ្មទណ្ឌផ្នែកនីតិវិធីបែបទូលាយ ពង្រីកន័យ ឬប្រើវិធីប្រដូចប្រសិនបើការបកស្រាយគឺដើម្បីធានាការពារសិទ្ធិសេរីភាពរបស់ជនល្មើស។ ឧ. ការឆែរឆេរលើខ្លួនប្រាណដែលមានចែងតែក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន អាចនឹងត្រូវយកមកអនុវត្តបានចំពោះនីតិជនដែលក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែង។

# ការអនុវត្តវិធាននីតិវិធីព្រហ្មទណ្ឌ

- **គោលការណ៍ស្មើភាព៖**
  - បុគ្គលដែលស្ថិតក្នុងស្ថានភាពដូចគ្នា ត្រូវជំនុំជម្រះដោយតុលាការដូចគ្នា វិធានច្បាប់ដូចគ្នា។ ឧ. មា ក្រម បណ្ដឹងអាជ្ញាអនុវត្តទៅលើគ្រប់បុគ្គលដោយគ្មានការរើសអើង។ លើកលែងការបែងចែករវាងនីតិជន និងអនីតិជន។
  - ការតម្កល់រឿងទុកឥតចាត់ការនាំឱ្យមានភាពមិនស្មើគ្នាចំពោះមុខច្បាប់។
- **គោលការណ៍សមាមាត្រ៖** វិធានការច្បាប់ដែលប្រើត្រូវតែសមាមាត្រទៅតាមទម្ងន់នៃបទល្មើស ឬជនល្មើស។ ឧ. ការឃាត់ខ្លួន ការឃុំខ្លួន ការប្រើប្រាស់ខ្នោះដៃ។ល។

# ការអនុវត្តវិធាននីតិវិធីព្រហ្មទណ្ឌ

- ❖ **គោលការណ៍នៃសេចក្តីថ្លៃថ្នូរ៖**
  - ❑ ហាមឃាត់ការប្រើហិង្សា ទារុណកម្ម ឬ លក្ខខណ្ឌអមនុស្សធម៌។
  - ❑ សិទ្ធិមួយចំនួនទៀតមិនត្រូវបានដកហូត។
  - ❑ ភាពថ្លៃថ្នូរនៅពេលស៊ើបអង្កេត ដូចជាការឆែកឆេរខ្លួនប្រាណ។
  - ❑ អសាធារណៈភាពនៃការពិភាក្សាដេញដោល (បទល្មើសផ្លូវភេទ អនីតិជន)។
  - ❑ ការផ្សព្វផ្សាយលើសារព័ត៌មាន និងបណ្តាញសង្គម។

# ដំណើរការនៃកិច្ចនីតិវិធី

❖ **វិធាននៃភស្តុតាង៖ សេរីភាពនៃភស្តុតាង និងឥស្សរចិត្តរបស់ចៅក្រម**

- ❑ ក្នុងរឿងព្រហ្មទណ្ឌ ភស្តុតាងអាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយ (វត្ថុ លិខិត ស្លាកស្នាម សំដី វីដេអូ រូបភាព ទិន្នន័យឌីជីថល ។ល។)
- ❑ សេរីភាពនៅក្នុងនីត្យានុកូលភាព៖ ភស្តុតាងត្រូវតែស្របច្បាប់ និងទទួលបានដោយស្មោះត្រង់ត្រឹមត្រូវ (នគរបាលចរាចរណ៍ថតចាប់ល្បឿន ការប្រើថ្នាំសណ្តំ) ជាប់ទាក់ទង និងអាចទុកចិត្តបាន។

# ដំណើរការនៃកិច្ចនីតិវិធី

- ❑បន្ទុកនៃភស្តុតាងយោលទៅតាមប្រភេទនៃបុគ្គលៈ
  - ➢អយ្យការស្វែងរកធាតុផ្សំនៃបទល្មើស និងអត្តសញ្ញាណនៃជនល្មើស និងភស្តុតាងដទៃទៀត
  - ➢ជនរងគ្រោះបង្ហាញអំពីការខូចខាតដែលកើតឡើងពីបទល្មើស ដើម្បីទាមទារសំណង
  - ➢ជនល្មើសស្វែងរកភស្តុតាងដោះបន្ទុក។
- ❑បន្ទុកនៃភស្តុតាងគឺជាបន្ទុករបស់អ្នកដាក់ពាក្យប្តឹង លើកលែងច្បាប់ ឬសច្ចធារណ៍តាមផ្លូវតុលាការកំណត់ផ្សេង។
- ❑ក្រមព្រហ្មទណ្ឌមានចែងអំពីបទល្មើសទាក់ទងនឹងបញ្ហាភស្តុតាងដូចជា ក្លែងសក្ខីកម្ម បំផ្លាញ ឬលាក់បំបាំងភស្តុតាង ការបដិសេធមិនចូលខ្លួនតាមការកោះហៅរបស់តុលាការ ជាដើម។

# ដំណើរការនៃកិច្ចនីតិវិធី

- ឥស្សរចិត្តរបស់ចៅក្រម ***intime conviction***៖
  - ក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡ គ្មានច្បាប់ស្ដីពីភស្តុតាងទេ។ គឺផ្តល់ឆន្ទានុសិទ្ធិធំធេងដល់ចៅក្រមក្នុងការវាយតម្លៃតាមករណីនីមួយៗ។ ឧ. ការវាយតម្លៃលើការខូតខាតធម្មតា និងការខូចខាតស្រាល។
  - ប្រព័ន្ធ ***Inquisitorial*** ចៅក្រមសកម្មក្នុងការស្វែងរកភស្តុតាង។
  - អ្វីដែលសំខាន់គឺថា ចៅក្រមជឿជាក់ ឬមិនជឿជាក់ (បន្ទាប់ពីបានធ្វើការផ្ទៀតផ្ទាត់និងវាយតម្លៃលើភស្តុតាង) ក៏ប៉ុន្តែចៅក្រមត្រូវមានសំអាងហេតុ។

# ដំណើរការនៃកិច្ចនីតិវិធី

- ចៅក្រមមិនអាចយកភស្តុតាងខុសច្បាប់មកធ្វើជាសំអាងក្នុងការសម្រេចសេចក្តីនោះទេ។
- ចៅក្រមត្រូវតែគោរពសេរីភាពនៃភស្តុតាង និងតម្លៃស្មើគ្នានៃភស្តុតាង ព្រោះភស្តុតាងមិនមានឋានានុក្រមនោះទេ។
- អ្នកណាខ្លះអាចជាសាក្សី ឬអ្នកផ្តល់ព័ត៌មាន ?
- ចៅក្រមត្រូវប្រុងប្រយ័ត្នចំពោះ សក្ខីកម្មអនាមិក ការផ្តន្ទាទោសដែលផ្អែកតែលើកំណត់ហេតុចម្លើយតែមួយមុខដែលគ្មានមេធាវីការពារ ជាដើម។

# ដំណើរការនៃកិច្ចនីតិវិធី

❖ **គោលការណ៍ជំនុំជម្រះក្ដីក្នុងរយៈពេលមួយសមស្របៈ** ដើម្បីវាយតម្លៃថារឿងក្ដីមួយចំណាយពេលយូរ ឬឆាប់ ឬសមរម្យ ត្រូវពិចារណាលើ ៥ កត្តាយ៉ាងតិចៈ

- ❑ ១ ច្បាប់ (បទឧក្រិដ្ឋត្រូវបើកការស៊ើបសួរ)
- ❑ ២ ទំហំនៃសំណុំរឿង
- ❑ ៣ ឥរិយាបទរបស់តុលាការ ឬ ស្ថាប័នជំនួយតុលាការ
- ❑ ៤ ឥរិយាបទរបស់គូភាគី
- ❑ ៥ ស្ថានភាពផ្សេងៗ ឧបសគ្គផ្នែកច្បាប់ និងផ្នែកអង្គហេតុ ដូចជា ការរីករាលដាលនៃជំងឺកូវីដ (lockdown) បញ្ហាទឹកជំនន់ រញ្ជួយផែនដី ជម្លោះប្រដាប់អាវុធ អភ័យឯកសិទ្ធិសភាជាដើម។

# ដំណើរការនៃកិច្ចនីតិវិធី

- ❖ **សិទ្ធិក្នុងការការពារខ្លួន៖ ចេញមកពីគោលការណ៍សច្ចធារណ៍នៃនិរទោស**
  - ❑ ទទួលព័ត៌មានអំពីបទចោទ និងមូលហេតុចោទតាមភាសាដែលជននោះចេះ
  - ❑ មានពេលវេលា និងសម្ភារៈជារូបវ័ន្ត (ការថតចម្លងឯកសារសំណុំរឿង និងសិទ្ធិចូលមើលសំណុំរឿងដោយខ្លួនឯង?) ដើម្បីរៀបចំការពារខ្លួន
  - ❑ សិទ្ធិនៅស្ងៀមមិនឆ្លើយ
  - ❑ សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង

# ដំណើរការនៃកិច្ចនីតិវិធី

- ឆ្លើយដោះបន្ទុក និងគ្មានការបង្ខិតបង្ខំ
- សិទ្ធិមានមេធាវី (ម២ ក២ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី *ក្នុងរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន។* ពាក្យជនជាប់ចោទ នៅទីនេះមិនសំដៅតែជនល្មើសនៅដំណាក់កាលជំនុំជម្រះនោះទេ គួរតែសំដៅផងដែរទៅដល់ ជនសង្ស័យ ជនត្រូវចោទ ពិរុទ្ធជន និងទណ្ឌិត)។
- ឬ អ្នកបកប្រែ។ល។

# ដំណើរការនៃកិច្ចនីតិវិធី

❖ **សមភាពរវាងគូភាគី និងគោលការណ៍ចំពោះមុខ**

- ❑ មានឱកាសស្មើគ្នាក្នុងការការពារក្តី
- ❑ មានសិទ្ធិប្តឹងតវ៉ា ឬឧបាស្រ័យ
- ❑ មានមេធាវី ( បង់កម្រៃដោយខ្លួនឯង ឬផ្តល់ឱ្យដោយរដ្ឋដោយមិនគិតថ្លៃ *pro bono* )
- ❑ ជាគោលការណ៍ អ្វីដែលមានក្នុងសំណុំរឿងត្រូវឱ្យគូភាគីបានដឹងគ្រប់គ្នា ( សិទ្ធិចូលមើលសំណុំរឿង )
- ❑ ការកោះហៅគូភាគីឱ្យចូលរួមនីតិវិធីរបស់តុលាការ ឬការជូនដំណឹងអំពីការសម្រេចរបស់តុលាការ គឺជាការអនុវត្តគោលការណ៍ចំពោះមុខដើម្បីឱ្យគូភាគីអាចអនុវត្តសិទ្ធិផ្សេងបាន។

# ដំណើរការនៃកិច្ចនីតិវិធី

❖ **សិទ្ធិរបស់ជនរងគ្រោះ៖** កាលណាជនរងគ្រោះក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី នោះគាត់មានសិទ្ធិ៖

- ❑សិទ្ធិទទួលបាននូវវិធានការការពារ
- ❑សិទ្ធិទទួលបាននូវមេធាវីតំណាង
- ❑សិទ្ធិអាចត្រូវបានចោទសួរដោយមានវត្តមានមេធាវី
- ❑សិទ្ធិស្នើសុំឱ្យមានកិច្ចស៊ើបសួរ
- ❑សិទ្ធិប្ដឹងឧទ្ធរណ៍
- ❑សិទ្ធិក្នុងការចូលរួមជាភាគីមួយនៃបណ្ដឹងសាទុក្ខ
- ❑សិទ្ធិគាំទ្របណ្ដឹងអាជ្ញា
- ❑សិទ្ធិទាមទារសំណងការខូចខាត
- ❑សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការជំនុំជម្រះ
- ❑សិទ្ធិកោះហៅសាក្សី
- ❑សិទ្ធិមើលសំណុំរឿង
- ❑សិទ្ធិឆ្លើយតបទៅនឹងអញ្ញត្រកម្ម
- ❑សិទ្ធិសួរសំណួរជនជាប់ចោទ
- ❑សិទ្ធិស្ដាប់ចម្លើយក្នុងសវនាការ
- ❑សិទ្ធិដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ
- ❑សិទ្ធិធ្វើសេចក្ដីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល។

# ដំណើរការនៃកិច្ចនីតិវិធី

- **សាធារណៈភាពនៃការពិភាក្សាដេញដោល និងការវិនិច្ឆ័យក្តី (ប្រជាធិបតេយ្យ)**
  - ការជំនុំជម្រះក្តីធ្វើនៅសវនាការជាសាធារណៈ លើកលែងច្បាប់ចែងផ្សេង (ករណីសភាស៊ើបសួរដែលសវនាការធ្វើក្នុងបន្ទប់ពិភាក្សា និងប្រកាសជាអសាធារណៈ) ឬ បញ្ហាសន្តិសុខ ឬសេចក្តីថ្លៃថ្នូររបស់គូភាគី។
  - សាលក្រមត្រូវប្រកាសជាសាធារណៈ លើកលែងសេចក្តីសម្រេចរបស់អយ្យការ ឬ ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរ ជាដើម (ក៏ប៉ុន្តែគេអាចធ្វើសេចក្តីថ្លែងការណ៍បាន)។
- **សំអាងហេតុនៃសេចក្តីសម្រេចរបស់ចៅក្រម៖** គ្រប់សេចក្តីសម្រេចរបស់តុលាការត្រូវមានសំអាងហេតុ (ទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ ម៣៥៧) លើកលែងដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ម២០៧។ ក្នុងករណីខ្លះ ត្រូវការសំអាងហេតុពិសេស ឧ. ការដោះលែងជនត្រូវចោទជាបន្ទាន់ដោយចៅក្រមស៊ើបសួរ ម២១៥ និង ការដោះលែងជនត្រូវចោទជាអនីតិជនជាបន្ទាន់ដោយចៅក្រមស៊ើបសួរ ម៤១ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។

# ដំណើរការនៃកិច្ចនីតិវិធី

- វិធាន *Non bis in idem* គ្មានការជំនុំជម្រះក្តីពីរដងលើរឿងក្តីតែមួយនិងគូភាគីតែមួយ (សម្រេចឱ្យរួចខ្លួន ឬ ផ្តន្ទាទោស)៖ ពាក់ព័ន្ធនឹងអាជ្ញាអស់ជំនុំ
  - ជាគោលការណ៍ ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំ
  - ជាគោលការណ៍ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរគ្មានអាជ្ញាអស់ជំនុំ
  - ជាអញ្ញត្រកម្ម អាចមានបណ្តឹងសើរើ។ នៅ អ.វ.ត.ក ករណីមេខ្មែរក្រហមលោក អៀង សារី ។
  - ធ្វើយ៉ាងណាចៀសវាងការជំនុំជម្រះក្តីពីរដងលើរឿងក្តីតែមួយនិងមនុស្សតែមួយដែលធ្លាប់ត្រូវបានតុលាការសម្រេចឱ្យរួចខ្លួន ឬ ផ្តន្ទាទោសម្តងរួចហើយ។ វិធានសមត្ថកិច្ចដែនដីក៏បង្ការនូវបញ្ហានេះ។
  - ការដោះស្រាយវិវាទ និងការបែងចែងសមត្ថកិច្ច (ឧ. ដែនដី) របស់តុលាការ ជាដើម គឺដើម្បីជៀងវាងការកាត់ទោសពីដងលើរឿងក្តីតែមួយរវាងគូភាគីដដែល។

# ភាគទី២

## ការស៊ើបអង្កេត

# គំនូសបំព្រួញនីតិវិធីព្រហ្មទណ្ឌ



# អ្វីជាការស៊ើបអង្កេត

❖ការស៊ើបអង្កេតគឺជាវិធានការសាកសួរក្នុងគោលដៅប្រមូលសក្ខីកម្ម ឬធាតុផ្សេងទៀតដែលអនុញ្ញាតឱ្យឈានទៅស្វែងរក**<u>ការពិត</u>**។ Gérald Cornu, Vocabulaire juridique, puf 7ème édition 2005, p 353

❖មាត្រា ២៨ស្ទួន ក្រមពិភាក្សាព្រហ្មទណ្ឌបែលហ្ស៊ិក៖ ការស៊ើបអង្កេត គឺជាបណ្ដុំនៃកិច្ចដែលមានគោលដៅដើម្បីស្វែងរកបទល្មើស ជនល្មើស និងភស្តុតាង និងដើម្បីប្រមូលរាល់ធាតុទាំងឡាយមានប្រយោជន៍ដើម្បីអនុវត្តបណ្ដឹងអាជ្ញា។

# អ្វីជាការស៊ើបអង្កេត?



រូបភាពទាំងនេះយកចេញពីបណ្ដាញអ៊ីនធឺណែត

# អ្វីជាការស៊ើបអង្កេត?








រូបភាពទាំងនេះយកចេញពីបណ្ដាញអ៊ីនធឺណែត

# អ្វីជាការសើបអង្កេត?



រូបភាពទាំងនេះយកចេញពីបណ្ដាញអ៊ីនធឺណែត

# អ្វីជាការសើបអង្កេត?




រូបភាពទាំងនេះយកចេញពីបណ្ដាញអ៊ីនធឺណែត

# គោលដៅដែលត្រូវស៊ើបអង្កេត

មម២៤ ម៩៦ ក្រមព្រហ្មទណ្ឌ

ម១ ម២ ក្រមនីតិវិធីព្រហ្មទណ្ឌ



# គោលដៅដែលត្រូវស៊ើបអង្កេត

**ម២៤ ម៩៦ ក្រមព្រហ្មទណ្ឌ**

**ម១ ម២ ក្រមនីតិវិធីព្រហ្មទណ្ឌ**

- ពិរុទ្ធភាព ទោស និងសំណង ម២
  - ច្បាប់ (កំណត់បទល្មើស ទោស សំណង) (មិនមែនជាកម្មវត្ថុនៃការស៊ើបអង្កេត)
    - ច្បាប់ច្បាស់
    - បើច្បាប់មិនច្បាស់ ចៅក្រមត្រូវបកស្រាយ
      - ច្បាប់មិនច្បាស់មិនមែនជាវិមតិសង្ស័យនោះទេ
  - ជនល្មើស
    - ផ្នែកបុគ្គល
      - -បុគ្គលិកលក្ខណៈ
      - -ស្ថានភាពគ្រួសារ
      - -ស្ថានភាពសង្គម
    - ផ្នែកបេតិកភណ្ឌ
      - -ធនធាន
      - -បន្ទុក
  - អំពើល្មើស
    - ធាតុផ្សំនៃបទល្មើស
      - -ធាតុអត្តនោម័ត
      - -ធាតុសត្យានុម័ត

# នគរបាលយុត្តិធម៌ ( PJ )

- បេសកម្មរបស់នគរបាលយុត្តិធម៌ ម៥៦
  - ជាជំនួយរបស់អំណាចតុលាការ។
  - ធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

# នគរបាលយុត្តិធម៌ ( PJ )

❖ **សមាសភាពរបស់នគរបាលយុត្តិធម៌៖**

- មន្ត្រីនគរបាលយុត្តិធម៌ (OPJ =OFFICIER DE POLICE JUDICIARE )
- ភ្នាក់ងារនគរបាលយុត្តិធម៌ (APJ =AGENT DE POLICE JUDICIAIRE )
- មន្ត្រីសាធារណៈដទៃទៀតដែលច្បាប់ផ្តល់អំណាចឱ្យ ម ៨២។

# នគរបាលយុត្តិធម៌ ( PJ )

- នៅក្រោមការដឹកនាំ និងសម្របសម្រួលដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ ម៥៨។ *អំណាចតុលាការធានាការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ តាមរយៈការត្រួតពិនិត្យមើលប្រក្រតីភាពនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌។*

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចដាក់វិន័យលើនគរបាលយុត្តិធម៌ ម៥៩ ម៦៤ ដល់ ម៦៦។

- ការទទួលបានសម្បទាជា PJ៖ ម៦០ ដល់ ម៦៣។

# នគរបាលយុត្តិធម៌ (PJ)

❖ **សមត្ថកិច្ចផ្នែកសម្ភារៈ៖**

- នគរបាលចរាចរណ៍ ព្រហ្មទណ្ឌ គ្រឿងញៀន ប្រឆាំងអំពើពុករលួយ ផ្លូវថ្នល់ ប្រឆាំងភេរវកម្ម សុខាភិបាល ព្រៃឈើ ជលផល បរិស្ថាន កិច្ចការនារី កសិកម្ម ទូរគមនាគមន៍ គយ ពន្ធដារ មូលបត្រ សំណង់។ល។

# នគរបាលយុត្តិធម៌ ( PJ )

**សមត្ថកិច្ចដែនដី៖** ម៦៧ និង ម៦៨៖

- ❑នៅមណ្ឌលរដ្ឋបាលដែលខ្លួនត្រូវបានចាត់តាំងឱ្យបម្រើការងារ។
- ❑លើកលែងករណីនៅភ្នំពេញ ដែលមានសមត្ថកិច្ចទូទាំងក្រុង។
- ❑ទូទាំងប្រទេស កាលណាមានការអនុញ្ញាតពីព្រះរាជអាជ្ញា កាលណាមានបទល្មើសជាក់ស្ដែង ឬ កាលណាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។

# សមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញា

- **ករណីជនល្មើសជារូបវន្តបុគ្គល៖** ម៣៩
  - ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
  - ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស
  - ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស
- **ករណីនីតិបុគ្គល៖** ម៥៩៧
  - ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
  - ព្រះរាជអាជ្ញានៃទីកន្លែងដែលនីតិបុគ្គលតាំងទីស្នាក់ការ។

# ក្របខណ្ឌនៃការស៊ើបអង្កេត

- ប្រភេទនៃការស៊ើបអង្កេត
  - ការស៊ើបអង្កេតជាក់ស្តែង  ម៨៥ ដល់ ម១១០ ។
  - ការស៊ើបអង្កេតបឋម  ម១១១ ដល់ ម១១៨។
- ភាពមិនលំអៀងរបស់អ្នកស៊ើបអង្កេត៖ ស្វែងរក**<u>ការពិត</u>**។ យោង ម៣៩-៣ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ការស៊ើបអង្កេតធ្វើឡើងទាំងដោះបន្ទុក និងដាក់បន្ទុក។ ចំណុច១៣ នៃសេចក្តីណែនាំរបស់ អ.ស.ប ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា *(ក) ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ អនុវត្តមុខងាររបស់ខ្លួនដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ សាសនា សង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត។ (ខ)ការពារផលប្រយោជន៍សាធារណៈ អំពើជាសត្យានុម័ត យុចិត្តទុកដាក់ឱ្យបានល្អចំពោះជនសង្ស័យ និងជនរងគ្រោះ។*
- ទាំងអយ្យការ និងជនសង្ស័យ មិនទាន់ក្លាយជាភាគីនៃសំណុំរឿងទេ។

# ក្របខណ្ឌនៃការស៊ើបអង្កេត

- ❖ **លក្ខណៈនៃការស៊ើបអង្កេត៖ នីតិវិធី Inquisitoire / Inquisitorial**
  - ❑ ការស៊ើបអង្កេតត្រូវតែសម្ងាត់ ម៨៣ ( ទាំងចំពោះជនសង្ស័យ )។
  - ❑ ការស៊ើបអង្កេតជាលាយលក្ខណ៍អក្សរ ជាទូទៅ( កំណត់ហេតុ )។
  - ❑ ការស៊ើបអង្កេតមិនចំពោះមុខ៖ ជនសង្ស័យ ឬជនរងគ្រោះមិនអាចចូលមើលសំណុំរឿងបានទាំងអស់ ឬស្នើសុំបំពេញកិច្ចណាមួយបានទេ។

# ការដឹងអំពីបទល្មើស

- ការទទួលបានពត៌មានតាម ៣ រូបភាព៖ (active investigation / proactive investigation)
  - ដោយមន្ត្រីនគរបាលយុត្តិធម៌ដោយខ្លួនឯង។
  - **<u>បណ្ដឹងទាមទារ</u>** ម.៦ ដោយជនរងគ្រោះ។ អាចប្ដឹងនៅអយ្យការ ម៤០ ឬ OPJ ម៧១។
  - **<u>បណ្ដឹងបរិហារ</u>** ៖ ដោយតតិយជនក្រៅពីជនរងគ្រោះ។ អាចប្ដឹងនៅអយ្យការ ម៤០ ឬ OPJ ម៧១។
    - ជាកាតព្វកិច្ចត្រូវប្ដឹងបរិហារ៖ អាជ្ញាធរសាធារណៈ ឬ មន្ត្រីគ្រប់រូបនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ម៤២។
    - ដោយ តតិយជន (រួមទាំងសារពត៌មាន) ឬ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ម២៩។

# គំនូសបំព្រួញអំពីការប្ដឹងទៅ OPJ និងព្រះរាជអាជ្ញា

ដើមបណ្ដឹង → អង្គហេតុ និងបុគ្គល → ព្រះរាជអាជ្ញា ឬ OPJ

NB: *ព្រះរាជអាជ្ញា ឬ OPJ អាចពន្លាតដល់អង្គហេតុ និងបុគ្គលដែលមិនមានក្នុងពាក្យប្ដឹង*

# ការសើបអង្កេតជាក់ស្តែង

- បទល្មើសជាក់ស្តែងគឺជាបទល្មើសដែលត្រូវបានពិនិត្យឃើញនៅពេលកំពុងប្រព្រឹត្ត ឬ ភ្លាមៗ ក្រោយពេលប្រព្រឹត្ត(ករណីជនម្នាក់ត្រូវបានគេចាប់បានភ្លាមៗពេលកើតហេតុ ឬករណីបង្ហាញអំពីរយៈពេលមួយខ្លីរវាង អំពើជាតម្រុយជាមួយនឹងបទល្មើស) ដែលស្ថានភាពនេះត្រូវបានចាត់ទុកថា ជាបទល្មើសជាក់ស្តែងនឹងនាំឱ្យមានការកើនឡើងនូវអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ និងក្នុងករណីខ្លះអនុញ្ញាតឱ្យមានការធ្វើបណ្តឹងលឿនរហ័សទៅសាលាមជ្ឈិម។

# ការស៊ើបអង្កេតជាក់ស្តែង

- ផ្តល់អំណាចធំធេងដល់នគរបាលយុត្តិធម៌ប្រើប្រាស់អំណាចស៊ើបអង្កេតជាក់ស្តែង។
- សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ អាយុជីវិតមនុស្ស រូបរាងកាយ ឬ ទ្រព្យសម្បត្តិ ដែលបង្កឡើងដោយបទល្មើស។
- ការប្រមូលភស្តុតាងឱ្យបានរហ័សប្រកបដោយប្រសិទ្ធភាព៖ ឧ. បុគ្គលគ្រប់រូបមានសិទ្ធិចាប់ខ្លួនជនល្មើសដើម្បីប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌។ តែមិនមែនស្វែងរកយុត្តិធម៌តាមផ្លូវ។

# ការស៊ើបអង្កេតជាក់ស្តែង

- មន្ត្រីនគរបាលយុត្តិធម៌អាចដឹងអំពីបទល្មើសជាក់ស្តែងដោយខ្លួនឯង ឬតាមរយៈរបាយការណ៍របស់ភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានដឹងអំពីបទល្មើសជាក់ស្តែង ឬតាមរយៈជនរងគ្រោះ ឬតាមរយៈសាក្សី។
- ក្នុងករណីមានបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា។

# ការសុីបអន្ទោតជាក់ស្តែង

- **លក្ខខណ្ឌនៃបទល្មើសជាក់ស្តែង**៖ ម៨៥ មឥ៦ មឥ៧ និង មឥ៨ ក្រម បទល្មើសមួយជាបទល្មើសជាក់ស្តែង បើកាលណាបទល្មើសនោះជាបទឧក្រិដ្ឋ និងបទមជ្ឈិម។
- ដូច្នេះ មិនមានឡើយ បទលហុជាក់ស្តែង។

# ការស៊ើបអង្កេតជាក់ស្តែង

❖ **លក្ខខណ្ឌនៃបទល្មើសជាក់ស្តែង**៖ម៨៦ និង ម៨៨ ក្រម ស្ថានភាពជាក់ស្តែងមាន ៥ ប្រភេទ៖

- ទី១-បទល្មើសដែលកំពុងប្រព្រឹត្ត
- ទី២- បទល្មើសទើបតែប្រព្រឹត្តរួចភ្លាម
- ទី៣- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រភឹង
- ទី៤- ការរកឃើញមានវត្ថុឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់អំពីការប្រព្រឹត្តបទល្មើសដោយបុគ្គលណាមួយ
- ទី៥- មានការស្នើសុំឱ្យជួយពីអ្នកកាន់កាប់ទីកន្លែង។

# ការស៊ើបអង្កេតជាក់ស្តែង

- ម១០៦ នៃក្រមនីតិវិធីៈថិរវេលានៃការស៊ើបអង្កេតជាក់ស្តែង មិនអាចលើសពី ៧ ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ហើយដែល ថិរវេលានេះរាប់ជាប់គ្នាជានិច្ច ( consécutivement )។
- ក្រោយថិរវេលានេះបានកន្លងផុតទៅ កិច្ចដែលត្រូវធ្វើបន្ទាប់អាចជាការស៊ើបអង្កេតបឋម ឬ ការបើកការស៊ើបសួរ។
- ក្រោយបញ្ចប់កិច្ច OPJ បញ្ជូនកំណត់ហេតុ និង វត្ថុតាងនានា ព្រមទាំងជនល្មើសទៅព្រះរាជអាជ្ញា ម ១០៧។

# ការស៊ើបអង្កេតជាក់ស្តែង

- ❖គោលការណ៍នៃការដឹកនាំការស៊ើបអង្កេតដោយ OPJ ចំពោះបទល្មើសជាក់ស្តែង។
- ❖គោលការណ៍នេះគ្មានចែងក្នុងមាត្រាណាជាក់លាក់នោះទេ តែនៅរាយប៉ាយដូចជា៖
  - ❑ម៥៦ OPJ មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ កំណត់អត្តសញ្ញាណ និង ចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។
  - ❑ម៩៦ ការឃាត់ខ្លួនជនសង្ស័យ ដោយ OPJ។
  - ❑ម៩១ ការឆែកឆេរដោយ OPJ។
  - ❑ម៩៣ ការស្តាប់ចម្លើយជនសង្ស័យដោយ OPJ។

# ការស៊ើបអង្កេតជាក់ស្ដែង

❖OPJ ក៏មានតួនាទីដឹកនាំសកម្មភាពនានារបស់ APJ ហើយ APJ ជួយការងារដល់ OPJ (ម៧៨) ដោយ៖

- ❑ម៧៨៖ APJ ត្រូវរាយការណ៍ទៅ OPJ ។
- ❑ម៨៩ ក១៖ OPJ ត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា ។
- ❑នេះជាអំណាចត្រួតពិនិត្យទៅតាមឋានានុក្រម ម៥៨ ក១។

❖ជាអញ្ញត្រកម្ម៖ ការដឹកនាំការស៊ើបអង្កេតដោយព្រះរាជអាជ្ញា។ មាត្រា៨៩ ក៣ បញ្ញត្តិថា៖ *ប្រសិនបើយល់ថាមានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់ទីកន្លែងកើតហេតុ និង ដឹកនាំការស៊ើបអង្កេត* ។

# ការស៊ើបអង្កេតបឋម

- ❖អាចត្រូវបានធ្វើឡើងដោយ OPJ បើកាលណាលក្ខខណ្ឌនៃស្ថានភាពជាក់ស្តែងមិនបានបំពេញ។
- ❖អាចត្រូវបានធ្វើឡើងដោយ OPJ ដោយឯកឯង ឬ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ម១១១។
- ❖ការស៊ើបអង្កេតមានប្រយោជន៍ពីរ៖
  - ❑ទី១ ជាមូលដ្ឋានដល់ព្រះរាជអាជ្ញា ដើម្បីចំណាត់ការសំណុំរឿង។
  - ❑ទី២ អនុញ្ញាតឱ្យ OPJ ចាប់ផ្តើមការស៊ើបអង្កេតលើបទល្មើសជាក់ស្តែង ប្រសិនបើមានតម្រុយជាក់ស្តែងអំពីចរិតនៃបទល្មើស។

# ការស៊ើបអង្កេតបឋម

❖ការត្រួតពិនិត្យដោយព្រះរាជអាជ្ញាលើការស៊ើបអង្កេតបឋមកើតចេញពីអំណាចទូទៅក្នុងការដឹកនាំ PJ ម៣៧ ម៥៨។

❖ការស៊ើបអង្កេតបឋមធ្វើឡើងដោយ OPJ។ ក្នុងករណីនេះ OPJ ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា យោង ម១១៧ និង ម១០៧។

❖ព្រះរាជអាជ្ញាធ្វើកិច្ចស៊ើបអង្កេតតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗទៀត។

❖ម៣៧ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនេះបានទទួលស្គាល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។

# ការស្រាវជ្រាវ និងការពិនិត្យ

- ម៥០ ក្រម ចែងថា *មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវនិងការពិនិត្យ។*

- ការស្រាវជ្រាវ និងការត្រួតពិនិត្យ លើរាល់បុគ្គល រាល់សហគ្រាសឯកជន ឬសាធារណៈ និងគ្រប់រដ្ឋបាលសាធារណៈជាអំណាចរបស់ OPJ។

- ក្នុងករណីការស៊ើបអង្កេតជាក់ស្តែង ការស្រាវជ្រាវអាចធ្វើដោយ OPJ ឬដោយមានការយល់ព្រមពីព្រះរាជអាជ្ញា ក្នុងករណីការស៊ើបអង្កេតបឋម។

# ការត្រួតពិនិត្យផ្នែកបច្ចេកទេស

- មទ៥ ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន OPJ អាចពឹងទៅបុគ្គលគ្រប់រូបដែលមានមុខជំនាញ។ ប្រសិនបើបុគ្គលនោះមិនមានចុះឈ្មោះ នៅក្នុងបញ្ជីអ្នកជំនាញទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួន ថានឹងជួយដោយភក្តីភាពដល់តុលាការ។
- អ្នកជំនាញវះកាត់វិភាគសាកសព គ្រាប់រំសេវ គ្រឿងញៀន DNA ស្នាមក្រយៅដៃ ឯកសារ សុខាភិបាល វប្បធម៌ សំណង់ ស្ថាបត្យកម្ម គីមីចំណីអាហារ រ៉ែ ថាមពល ព័ត៌មានវិទ្យា សវនកម្ម ពន្ធដារ ថ្នាំពេទ្យ វិកលវិទ្យា កម្មសិទ្ធិបញ្ញា។ល។

# ការត្រួតពិនិត្យផ្នែកបច្ចេកទេស

- ក្នុងករណីការស៊ើបអង្កេតជាក់ស្តែង ជាការសម្រេចរបស់ OPJ (ម៩៥)។ ក្នុងករណីស៊ើបអង្កេតបឋម ***ជាគោលការណ៍*** ជាការសម្រេចរបស់ព្រះរាជអាជ្ញា (ម១១២ និង ម៩៥)។

- អ្នកជំនាញមានកាតព្វកិច្ចគោរពតាមការស្នើសុំរបស់ OPJ ឬ របស់ព្រះរាជអាជ្ញា។

- គោលការណ៍ចំពោះមុខលើលទ្ធផលនៃការត្រួតពិនិត្យផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ។

# ការស្តាប់ចម្លើយ

- ***ជនសង្ស័យ ឬ បុគ្គលដែលអាចផ្តល់ព័ត៌មាន៖*** ក្នុងករណីការស៊ើបអង្កេតជាក់ស្តែង (ម៩៤) និងការស៊ើបអង្កេតបឋម (ម១១៤) OPJ អាចកោះហៅរាល់បុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ឬ បុគ្គលដែលអាចផ្តល់ពត៌មានអំពីរឿងហេតុដើម្បីធ្វើការស្តាប់ចម្លើយ(ដោយមិនមានសម្បថនោះទេ)។

- ចំពោះមុខ OPJ បុគ្គលដែលអាចផ្តល់ព័ត៌មានបានមិនមានឋានៈជាសាក្សីតាមផ្លូវច្បាប់នោះទេ ហើយសក្ខីកម្មក្លែងក្លាយរបស់គាត់មិនបង្កើតជាបទល្មើសព្រហ្មទណ្ឌចែងក្នុងមាត្រា៥៤៥ នៃក្រមព្រហ្មទណ្ឌ (បទផ្តល់សក្ខីកម្មក្លែងក្លាយ ដែលអនុវត្តតែទៅលើសាក្សីដែលបានស្បថផ្តល់ចម្លើយនៅមុខចៅក្រម ឬ OPJ ក្នុងក្របខណ្ឌនៃការស៊ើបសួរជំនួស)

# ការស្តាប់ចម្លើយ

- ច្បាប់កម្ពុជាមិនមានចែងឱ្យច្បាស់អំពីការស្តាប់ចម្លើយជនរងគ្រោះនោះទេ ដោយមានបរិយាយតែអំពីកំណត់ហេតុបណ្តឹងពីបុគ្គលដែលប្តឹងរាយការណ៍តាមមាត្រា៧២ក្រម។
- បុគ្គលដែលត្រូវបានកោះហៅមានកាតព្វកិច្ចចូលបង្ហាញខ្លួន។
- ការស្តាប់ចម្លើយត្រូវមានកំណត់ហេតុ។ យោង ម៤២៩ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង កំណត់ហេតុស្តាប់ចម្លើយត្រូវតែមានសំនួរចំពោះអ្វីដែលឆ្លើយ បើពុំដូច្នេះទេ កំណត់ហេតុនោះនឹងត្រូវរងមោឃភាព។

# ការស្តាប់ចម្លើយ

- យោង ម៧០៦-៧១ និង ម R៥៣-៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ការស្តាប់ចម្លើយអាចពីធ្វើពីចម្ងាយតាមមធ្យោបាយទូរគមនាគមន៍។
- បើជនសង្ស័យជាអនីតិជន ត្រូវមានវត្តមានមេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ម២២ ម២៦ ច្ប.អនីតិជន។
- ការស្តាប់ចម្លើយបុគ្គលជា ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមរបបហិតូបត្ថម្ភ ឬ អនីតិជនដែលដឹងរឿងរ៉ាវ អាចធ្វើបានដែរឬទេ? អនុសញ្ញាស្តីពីការការពារសិទ្ធិជនមានពិការភាព។
- OPJ អាចធ្វើការស្តាប់ចម្លើយដោយតទល់គ្នាបាន។

# ការស្តាប់ចម្លើយ

- ប្រសិនបើបុគ្គលដែលត្រូវបានកោះហៅនោះរឹងទទឹង OPJ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួនបានទាំងក្នុងការស៊ើបអង្កេតជាក់ស្តែង (ម៩៤ ក២) និងការស៊ើបអង្កេតបឋម (ម១១៤)។ បញ្ជាឱ្យចូលខ្លួនអនុញ្ញាតឱ្យ OPJ ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន។ ករណីបុគ្គលនោះនៅក្នុងលំនៅឋាន តើ OPJ អាចចូលចាប់ជនល្មើសបានទេ?
- ការថតជាខ្សែអាត់សម្លេងសម្រាប់ការសួរចម្លើយមួយចំនួន៖ ក្រមមិនមានចែងអំពីការថតជាខ្សែអាត់សម្លេងនោះទេ។ តែការអនុវត្តនៅសាលាក្តីខ្មែរក្រហម គឺមានទាំងថតវីដេអូ និងថតរូបសន្លឹកក្នុងពេលស្តាប់ចម្លើយ។

# ការចាប់ និងថតការឆ្លើយឆ្លង

- យោងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមិនត្រូវបានផ្តល់សិទ្ធិឱ្យចាប់ ឬថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ លើកលែង ម៨៥ ច្ប.គ្រឿងញៀន៖ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចចាប់ឬថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ដូចជាទូរសារ ឬសារតាមអិនធើណែត ជាអាទិ៍។

# ការចាប់ និងថតការឆ្លើយឆ្លង

- យោង ម១០៥ ម១១១ ក្រម OPJ មិនមានសិទ្ធិឱ្យចាប់ ឬ ថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ លើកលែងតែ ម២៧ ច្ប.ប្រឆាំងអំពើពុករលួយ ACU អាចចាប់ ឬ ថតការឆ្លើយឆ្លងតាមទូរស័ព្ទ មើលគណនីធនាគារ ចូលទៅមើលឯកសារអេឡិចត្រូនិច។

# ការចុះទៅលំនៅឋាន

❖ **ការចុះទៅលំនៅឋាន** គឺជាសិទ្ធិរបស់ OPJ ក្នុងការចូលទៅក្នុងលំនៅឋានរបស់ពលរដ្ឋណាម្នាក់ដោយវិធានការបង្ខំ។ ឧ. សិទ្ធិចូលទៅក្នុងលំនៅឋានដើម្បីអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ម១៩២ និងដីកាបង្គាប់ឱ្យចាប់ខ្លួន ម១៩៩ ក្រោយម៉ោង ៦ ព្រឹក និងមុនម៉ោង ៦ ល្ងាច។ ឧ. ១៥ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បើមានការសុំអន្តាគមន៍ និងជាបទល្មើសជាក់ស្ដែង អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចូលទៅទីកន្លែងកើតហេតុ ទោះគ្មានដីកាអនុញ្ញាតពីតុលាការក៏ដោយ។ ឧ. សិទ្ធិចូលក្នុងការដ្ឋានសំណង់របស់មន្ត្រីអធិការកិច្ចសំណង់ ម៦០ ច្បាប់ស្ដីពីសំណង់ និង ប្រការ៨ ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់ ចុះថ្ងៃទី០២ សីហា ២០១៩។

# ការឆែកឆេរ

- **ការឆែកឆេរ** គឺជាសិទ្ធិក្នុងការស្រាវជ្រាវរក**<u>វត្ថុតាង</u>**អំពីការប្រព្រឹត្តបទល្មើសណាមួយ។

- គោលការណ៍នៃភាពមិនអាចរំលោភបំពានបានលើលំនៅឋាន ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋានអន្តរជាតិនានា។

- **ក្នុងករណីបទល្មើសជាក់ស្តែង** ការឆែកឆេរអាចប្រព្រឹត្តទៅបាន ទោះគ្មានការយល់ព្រមពីបុគ្គលដែលកាន់កាប់ទីកន្លែង ក៏ប៉ុន្តែត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។

# ការឆែកឆេរ

- **ក្នុងករណីការស៊ើបអង្កេតបឋមៈ ម១១៣** ជាគោលការណ៍ ការឆែកឆេរអាចប្រព្រឹត្តទៅបានល្ងីកណាមានការព្រមព្រៀងពិតប្រាកដ និងច្បាស់លាស់ពីអ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើជននោះបដិសេធមិនឱ្យឆែរឆេរ ឬអវត្តមាន ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចអាចចេញដីកាអនុញ្ញតឱ្យមានការចុះទៅលំនៅឋាន ឆែរឆេរ និង ចាប់យកវត្ថុតាងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ក្នុងករណីនេះ ព្រះរាជអាជ្ញាដឹកនាំការឆែកឆេរដោយផ្ទាល់។
- ម៨៥ ម៩១ និងម១១៣ ការឆែកឆេរអាចធ្វើបានក្នុងករណីបទឧក្រិដ្ឋ និងបទមជ្ឈិម។ ដូចនេះ ការឆែកឆេរមិនអាចអនុវត្តបានចំពោះបទលហុនោះទេ។

# ការឆែកឆេរ

- **អ្វីទៅជាលំនៅឋាន**? ទីកន្លែងដែលបុគ្គលម្នាក់មានសិទ្ធិក្នុងការនិយាយថាផ្ទះសម្រាប់ខ្ញុំ ឬកន្លែងសម្រាប់ខ្ញុំ។ មិនអាចយកសញ្ញាណលំនៅឋានក្នុងក្រមរដ្ឋប្បវេណីមកបកស្រាយបានទេ ព្រោះ**ស្វ័យភាពនៃនីតិព្រហ្មទណ្ឌ**។
- មិនចាំបាច់ជាលំនៅឋានរបស់ជនសង្ស័យ។
- គោលការណ៍នៃការឆែកឆេរនៅពេលថ្ងៃ៖ ហាមឃាត់ការឆែកឆេរពីម៉ោង ៦ ល្ងាច ដល់ ៦ ព្រឹក។

# ការនែកនេរ

- ជាអញ្ញត្រកម្ម ការឆែរឆេរនៅពេលយប់ ម៩១ ក្នុងករណី៖
  - ចែងក្នុង ម៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្ដែង) នៃក្រមនេះ ។
  - ចែងក្នុង ម៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង) នៃក្រមនេះ។
  - មានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង។
  - ការឆែរឆេរនៅគ្រប់ទីកន្លែងក្នុងពេលដែលបើកចំហដល់សាធារណៈជន។
  - ការឆែរឆេរនៅគ្រប់ទីកន្លែងផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

# ការឆែកឆេរ

- ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់។
- ការឆែកឆេរនៅការិយាល័យមេធាវី ធ្វើឡើងដោយព្រះរាជអាជ្ញា និងនៅចំពោះមុខប្រធានគណៈមេធាវី ប្រតិភូ ឬ មេធាវីសាមី។
- ការឆែកឆេរនៅសហគ្រាសសារព័ត៌មានគឺធ្វើដោយព្រះរាជអាជ្ញា និងមិននៅចំពោះមុខបុគ្គលដែលបម្រើការងារនៅសហគ្រាសសារពត៌មាន។
- ម៥៧-១ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖ ការឆែកឆេរផ្ទេកព័ត៌មានវិទ្យា។

# ការត្រួតពិនិត្យលើនាវា (មិនមែនជាលំនៅឋាន)

- មម២៤៥ ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹកឆ្នាំ២០២៤ មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិបញ្ឈប់នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលកំពុកធ្វើដំណើរតាមផ្លូវទឹកនិងឡើងលើនាវា ដើម្បីត្រួតពិនិត្យបទល្មើស ក្នុងករណីមានភស្តុតាងឬការសង្ស័យដែលជឿជាក់ថា នាវាបានរំលោភលើបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

- មម២៤៧ ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹកឆ្នាំ២០២៤ មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិបញ្ឈប់ និងឡើងលើនាវាបរទេសដែលកំពុងធ្វើដំណើរឆ្លងកាត់នៅតាមផ្លូវទឹកក្នុងដែនដីនៃព្រះរាជណាចក្រកម្ពុជា ដើម្បីធ្វើការពិនិត្យបទល្មើស ដែលបានប្រព្រឹត្តដោយនាវា ឬនៅលើនាវា។

# ការឆែកឆេរលើខ្លួនបុគ្គល

❖ក្រមមិនមានចែងអំពីរបបគតិយុត្តនៃការឆែរឆេរលើខ្លួនបុគ្គលទេ។ មា១៦ ច្ប.អនីតិជន៖ OPJ អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន តែត្រូវមានភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬ មិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីមិនអាចចៀសវាងបាន។ ច្ប.គ្រឿងញៀន មា៧៥ (ការឆែកឆេរលើបុគ្គល) មា៧៦ (ការឆែកឆេរសរីរាង្គដោយប្រើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ)។ មា៥៦ ច្បាប់ស្តីពីគយ ឆែកឆេរនៅជុំវិញខ្លួននិងនៅក្នុងខ្លួនបុគ្គល។

# វិធានការដទៃទៀតក្នុងបទល្មើសគ្រឿងញៀន

- ក្នុងច្បាប់គ្រឿងញៀន OPJ អាចធ្វើកិច្ចដូចជា៖
  - មា៧៨ ការឃ្លាំមើលការឆ្លងកាត់គ្រឿងញៀន
  - មា៧៩ ការប្រគល់ដោយមានការឃ្លាំមើល និងការញុះញុងឱ្យលក់ដោយខុសច្បាប់នូវគ្រឿងញៀន។

# ការបង្វែរអនីតិជន

- ការសម្រេចបង្វែរអនីតិជន ម២៧ ម២៨ (ជំពូក៦) និងមាត្រា ៦០ ដល់ ម៧១ ច្បាប់យុត្តិធម៌អនីតិជន។
- សូមមើល**ភាគទី៨ នីតិវិធីបង្វែរ**។

# ការឃាត់ខ្លួននីតិជន

❖ **OPJ មានអំណាចក្នុងការសម្រេចការឃាត់ខ្លួន៖**

- ❑ ម.៩៦ ក្រម“*ដើម្បីឆ្លើយតបទៅនឹងការចាំបាច់នៃការស៊ើបអង្កេត OPJ អាចឃាត់ខ្លួនជនសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស*” (ករណីបទល្មើសជាក់ស្តែង)។
- ❑ ការបកស្រាយ ម១១១, ម១១៦ ក្រម “*ការឃាត់អាចធ្វើបានដោយ OPJ ដោយឯកឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា*” (ករណីការស៊ើបអង្កេតបឋម)។

# ការឃាត់ខ្លួននីតិជន

❖ **ព្រះរាជអាជ្ញាមានអំណាចត្រួតពិនិត្យលើការឃាត់ខ្លួន ៖**

- ព្រះរាជអាជ្ញាដឹកនាំនគរបាលយុត្តិធម៌។ នៅពេលចាប់ផ្តើមការឃាត់ខ្លួន OPJ ត្រូវរាយការណ៍ភ្លាមតាមគ្រប់មធ្យោបាយជូនព្រះរាជអាជ្ញាអំពីការឃាត់ខ្លួន ម៩៦។
- បើមានភាពចាំបាច់ ការពន្យារពេលឃាត់ខ្លួននឹងត្រូវបានធ្វើតាមការ សម្រេចរបស់ព្រះរាជអាជ្ញាដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុយោង ម៩៦ ក.៣ ក្រម។

# ការឃាត់ខ្លួននីតិជន

- ជាអញ្ញត្រកម្ម ការឃាត់ខ្លួនធ្វើដោយ OPJ តែក្រោមអំណាចត្រួតពិនិត្យរបស់ចៅក្រមស៊ើបសួរ (ដីកាចាត់ឱ្យស៊ើបសួរជំនួស)។
- ដែនអនុវត្តនៃការឃាត់ខ្លួន៖ ការឃាត់ខ្លួនអាចធ្វើបានតែក្នុងករណីបទល្មើសជាបទឧក្រិដ្ឋ ឬបទមជ្ឈិម។ ការពន្យារពេលឃាត់ខ្លួនអាចធ្វើបានតែក្នុងករណីបទឧក្រិដ្ឋ។

# ការឃាត់ខ្លួននីតិជន

- ជនសង្ស័យជាបុគ្គលតែម្នាក់គត់ដែលអាចស្ថិតក្រោមការឃាត់ខ្លួន។ OPJ អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបាន ប្រសិនបើបុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន និង មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញាយោង ម៩៦ ក១ ក្រម។

- **សំអាងហេតុនៃការឃាត់ខ្លួន៖** ម៩៧ មិនបានរំលេចឡើងអំពីមូលហេតុនៃការឃាត់ខ្លួន។ សូមមើល ម១៧ ច្បាប់យុត្តិធម៌អនីតិជន។ ប្រសិនបើជឿជាក់ថា ***អនីតិជនអាចរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬ បង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬ សន្តិសុខសាធារណៈ ឬ ក្នុងគោលបំណងសុវត្ថិភាពអនីតិជននោះ***។ តាមពិតទៅមូលហេតុនៃការឃាត់ខ្លួន គឺដូចគ្នាទៅនឹងមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលចែងក្នុង ម២០៥ ក្រម។

# ការឃាត់ខ្លួននីតិជន

❖**ការឃាត់ខ្លួនលើកដំបូងសម្រាប់ថិរវេលា៤៨ម៉ោង៖** ការឃាត់ខ្លួនមិនអាចមានថិរវេលាលើសពី៤៨ម៉ោង នោះទេ។ ថិរវេលា៤៨ម៉ោង នេះជាថិរវេលាអតិបរមា។

❖**ការពន្យារពេលសម្រាប់ថិរវេលាមិនលើសពី២៤ម៉ោង៖** តែករណីបទឧក្រិដ្ឋមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញានិងមានសំអាងហេតុ។

❖ក្រមបញ្ញត្តិថា “*ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ*”។

# ការឃាត់ខ្លួននីតិជន

❖ម៩៦ ក២ ក្រម៖

| នីតិជន | រយៈពេល | ការពន្យាពេល |
|---|---|---|
| លហុ | មិនអាច | មិនអាច |
| មជ្ឈិម | ៤៨ ម៉ោង | មិនអាច |
| ឧក្រិដ្ឋ | ៤៨ ម៉ោង | ២៤ ម៉ោង |

# ការឃាត់ខ្លួននីតិជន

❖ **ការជូនដំណឹង៖**

- ❑ការសម្រេចអំពីការឃាត់ខ្លួន ថិរវេលា
- ❑ប្រភេទ និងកាលបរិច្ឆេទដែលសន្មតថាបានប្រព្រឹត្តបទល្មើស
- ❑សិទ្ធិជូនដំណឹងដល់សាច់ញាតិ និយោជក សិទ្ធិទទួលបានជំនួយពីគ្រូពេទ្យ សិទ្ធិទទួលបានជំនួយពីមេធាវី (ម៩៨ ករណីបទល្មើសជាក់ស្តែង មេធាវីអាចចូលជួបសន្ទនាជាមួយជនដែលត្រូវបានឃាត់ក្នុងរយៈពេល៣០ នាទី ក្រោយពីត្រូវបានឃាត់ខ្លួនបាន ២៤ ម៉ោង) សិទ្ធិនៅស្ងៀមមិនឆ្លើយ សិទ្ធិមិនឆ្លើយសារភាព សិទ្ធិទទួលបានជំនួយបកប្រែជាយថាហេតុ។
- ❑ការគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គលដែលត្រូវបានឃាត់ខ្លួន។

# ការឃាត់ខ្លួននីតិជន

- ក្រោយការឃាត់ខ្លួន៖ នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនអាចត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញ ឬបញ្ជូនទៅចំពោះមុខព្រះរាជអាជ្ញាតាមសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា នេះយោង ម១០៣។

# ការឃាត់ខ្លួននីតិជន

- ភាពជាលាយលក្ខណ៍អក្សរនៃនីតិវិធីព្រហ្មទណ្ឌ និងកំណត់ហេតុនានានៃការឃាត់ខ្លួន។
- ម៩៧ ម១០២ ដដែលបញ្ញត្តអំពីនិទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុសរុបនៃការឃាត់ខ្លួន។

# ការឃាត់ខ្លួន អនីតិជន

- មរ១៤ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន៖ អនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួននោះទេ តែត្រូវប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់ ហើយអំពើជាបទល្មើសត្រូវបញ្ជូនទៅព្រះរាជអាជ្ញា។
- មរ១៥ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន៖
  - OPJ អាច**<u>ចាប់ខ្លួន</u>**អនីតិជនអាយុចាប់ពី ១៤ ដល់ ក្រោម ១៨ ឆ្នាំ ក្នុងករណីបទមជ្ឈិម ឬឧក្រិដ្ឋជាក់ស្ដែងតែប៉ុណ្ណោះ។
  - ការ**<u>ចាប់ខ្លួន</u>**អនីតិជនអាយុពី ១៤ ដល់ក្រោម ១៦ ឆ្នាំ អាចធ្វើបានតែក្នុងករណីប្រព្រឹត្តបទមជ្ឈិមដោយចេតនា។
  - OPJ ត្រូវរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា។
  - ធានាសេចក្ដីថ្លៃថ្នូរបស់អនីតិជន និងបញ្ជូនទៅ OPJ ជំនាញ។

# ការឃាត់ខ្លួន អនីតិជន

- ❖ម៩៦ ក៥ ក្រម បញ្ញត្តថា “*អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ*”។ ម១៤ ច្បាប់យុត្តិធម៌អនីតិជន៖ OPJ ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់។ ហើយអំពើល្មើសរបស់អនីតិជននេះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា។
- ❖ម១៧ ច្បាប់យុត្តិធម៌អនីតិជន និង ម៩៦ ក្រម៖ OPJ អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ ក្រោម ១៨ ឆ្នាំ។
- ❖លើសពីនេះ អនីតិជនអាយុ ១៤ ដល់ក្រោម ១៦ ឆ្នាំ ការឃាត់ខ្លួនអនីតិជនអាចធ្វើបានក្នុងករណីប្រព្រឹត្តបទល្មើសចេតនា។

# ការឃាត់ខ្លួន អនីតិជន

- មរ១៧ ច្បាប់យុត្តិធម៌អនីតិជន និង ម៩៦ ក្រម៖ OPJ អាចឃាត់ខ្លួន អនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ប្រសិនបើជឿជាក់ថា៖
  - អនីតិជនអាចរត់គេចខ្លួន
  - ឬ បំផ្លាញភស្តុតាង
  - ឬ បង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ
  - ឬ សន្តិសុខសាធារណៈ
  - ឬ ក្នុងគោលបំណងសុវត្ថិភាពអនីតិជននោះ។

# ការឃាត់ខ្លួន អនីតិជន

- ម៩៦ ក្រម និង ម១៧ ច្បាប់យុត្តិធម៌អនីតិជន៖

| អនីតិជន | ឧក្រិដ្ឋ | មជ្ឈិម | លហុ | ការពន្យាពេល |
|---|---|---|---|---|
| x < ១៤ឆ្នាំ | មិនអាច | មិនអាច | មិនអាច | មិនអាច |
| ១៤ឆ្នាំ ≤ x < ១៦ឆ្នាំ | ៣៦ ម៉ោង | ២៤ ម៉ោង (តែបទមជ្ឈិមចេតនា) | មិនអាច | មិនអាច |
| ១៦ឆ្នាំ ≤ x < ១៨ឆ្នាំ | ៤៨ ម៉ោង | ៣៦ ម៉ោង | មិនអាច | មិនអាច |

# ការឃាត់ខ្លួន អនីតិជន

- ❖ម១៧ ច្បាប់យុត្តិធម៌អនីតិជន៖ រាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា បន្ទាប់ពីឃាត់ខ្លួន។
- ❖ម១៨៖ ការជូនព័ត៌មានទៅអ្នកតំណាងដែលច្បាប់បានកំណត់អំពី៖
  - ❑មូលហេតុនៃការចាប់ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស
  - ❑ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ
  - ❑សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ❖ការពិនិត្យពីគ្រូពេទ្យកាលណាមានរបួស ឬបញ្ហាសុខភាព ម១៩។

# ការឃាត់ខ្លួន អនីតិជន

- OPJ មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាជួរទៀយ ក្នុងករណីគ្មានការអនុញ្ញាតជាមុនពីអនីតិជន ដោយមានការពិគ្រោះជាមួយមេធាវី ឬ អ្នកតំណាង ឬអ្នកទំនុកបម្រុង។ បើយល់ព្រម ត្រូវមានកំណត់ហេតុ។
- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជនទៅតាមភេទ។
- ធានាសេចក្តីថ្លៃថ្នូរ និងកិត្តិយស។

# ការចាប់យកវត្ថុ និងឃាត់ទ្រព្យសម្បត្តិ

- **ការចាប់យកវត្ថុតាង** គឺជាសិទ្ធិក្នុងការចាប់យកវត្ថុ ឬ ឯកសារមកដាក់ក្រោមវិធានយុត្តិធម៌ ដោយមានការធ្វើជាបញ្ជីសារពើភ័ណ្ឌ និងបិទស្លាកបោះត្រាលើវត្ថុតាង (ម៩២)។ អនុវត្តតែទៅលើចលនវត្ថុ។ ក្រមមិនមានចែងអំពីអចលនវត្ថុទេ។
- ប្រភេទនៃវត្ថុតាង?

# ការចាប់យកវត្ថុ និងឃាត់ទ្រព្យសម្បត្តិ

- ម៨៩ ច្ប.គ្រឿងញៀន៖ ព្រះរាជអាជ្ញាត្រូវឃាត់ទុកទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ហើយប្ដឹងសុំចៅក្រមស៊ើបសួរ ឬតុលាការ ដើម្បីបង្កកទ្រព្យសម្បត្តិ។

# ការចាប់យកវត្ថុ និងឃាត់ទ្រព្យសម្បត្តិ

- មព១ ច្ប.ប្រឆាំងការសម្អាតប្រាក់ (ថ្មី)៖ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ អាចបង្កកទ្រព្យដែលសង្ស័យពាក់ព័ន្ធនឹងបទល្មើស។ ក្រសួងស្ថាប័នអនុវត្តច្បាប់ ត្រូវតែឃាត់ទុកទ្រព្យនោះ រួចប្តឹងសុំបង្កកទ្រព្យនោះ ដើម្បីតុលាការ ជំនុំជម្រះសម្រេចរឹបអូស។ មើលច្បាប់ស្តីពីប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធប្រល័យលោក។
- ក្រមបរិស្ថាន និងធនធានធម្មជាតិឆ្នាំ២០២៣៖ ម៨១៨ ដល់ ម៨២១ ការចាប់ ការថែរក្សាទុក និងការគ្រប់គ្រង ការលែង ការបំផ្លាញចោល បន្ទុកសោហ៊ុយនៃការថែរក្សា។
- ម១១៩ បើជាវត្ថុគ្រោះថ្នាក់ត្រូវបំផ្លាញចោល៖ គ្រឿងផ្ទុះ គ្រឿងញៀន (ត្រូវដកទុកមួយផ្នែកជាមុន ដើម្បីធ្វើកោសលវិច័យ) ឬទិន្នន័យទូរគមនាគមន៍។

# ការចាប់យកវត្ថុ និងឃាត់ទ្រព្យសម្បត្តិ

❖ព្រះរាជអាជ្ញាអាចប្រគល់វត្ថុដែលចាប់យកទៅម្ចាស់ដើមវិញ បើពុំមានប្រយោជន៍សំដែងការពិត ហើយកម្មសិទ្ធិគ្មានការជំទាស់ ម១១៩ ក្រម។ ករណីមិនព្រមប្រគល់ឱ្យវិញ អាចប្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។

❖ម៥០ ក៤ ច្ប. ផ្លូវថ្នល់ឆ្នាំ២០១៤ *ករណីមិនស្គាល់អត្តសញ្ញាណជនល្មើស មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវស្នើសុំព្រះរាជអាជ្ញាដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសជាសម្បត្តិរដ្ឋ។ ជនមានប្រយោជន៍អាចតវ៉ានឹងសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាទៅតុលាការរដ្ឋប្បវេណី។*

❖ច្បាប់ស្ដីពីការចាត់ចែងជាបណ្ដោះអាសន្នលើវត្ថុចាប់យក ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៥ ម៦ (ការលក់ឡាយឡុងនូវវត្ថុចាប់យកនៅមុនសាលក្រម ឬ សាលដីកាស្ថាពរ)។

# ភាគទី៣

## បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី

# បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

- ជំពូកទី១ ទំនាក់ទំនងនៃបណ្តឹងទាំងពីរ
- ជំពូកទី២ បណ្តឹងអាជ្ញា
- ជំពូកទី៣ បណ្តឹងរដ្ឋប្បវេណី

# ជំពូកទី១

## ទំនាក់ទំនងនៃបណ្តឹងទាំងពីរ

# ទំនាក់ទំនងនៃបណ្តឹងទាំងពីរ

- អ្វីទៅជាបណ្តឹង? សម្រាប់អ្នកទាមទារ បណ្តឹងគឺជាសិទ្ធិដែលត្រូវទទួលស្តាប់អំពីមូលដ្ឋាននៃការទាមទារដើម្បីឱ្យចៅក្រមសម្រេចថាត្រូវឬខុស។ សម្រាប់ភាគីម្ខាងទៀតគឺជាសិទ្ធិក្នុងការពិភាក្សាអំពីមូលកភាពនៃការទាមទារ។

- ភាពខុសគ្នាផ្អែកលើមូលដ្ឋានគតិយុត្តិនៃបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី៖
  - ការបំពានច្បាប់ព្រហ្មទណ្ឌ៖ ការប្រព្រឹត្តបទល្មើសនាំឱ្យមានបណ្តឹងអាជ្ញា។
  - ការបំពានលើសិទ្ធិបុគ្គល៖ ព្យសនកម្មនាំឱ្យមានបណ្តឹងរដ្ឋប្បវេណី។

# ទំនាក់ទំនងនៃបណ្តឹងទាំងពីរ

❖ភាពខុសគ្នាផ្អែកលើគោលបំណងនៃបណ្តឹងទាំងពីរ៖

❑បណ្តឹងអាជ្ញា៖ ពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញពិរុទ្ធភាពនិងផ្តន្ទាទោស មឲ ក្រម។

❑បណ្តឹងរដ្ឋប្បវេណី៖ ជួសជុលការខូចខាតដែលកើតពីអំពើល្មើសដល់ជនរងគ្រោះ មឲ ក្រម។

❖ភាពខុសគ្នាផ្អែកលើលក្ខខណ្ឌអនុវត្តនៃបណ្តឹងទាំងពីរ៖

❑បណ្តឹងអាជ្ញាអនុវត្តដោយតំណាងអយ្យការប្រឆាំងនឹងចារី សហចារី អ្នកសមគំនិត និងអ្នកផ្តើមគំនិត

❑បណ្តឹងរដ្ឋប្បវេណីអនុវត្តដោយជនរងគ្រោះប្រឆាំងនឹងចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងសិទ្ធិវន្ត។ អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី។

# ទំនាក់ទំនងនៃបណ្ដឹងទាំងពីរ

- ការខិតជិតរកគ្នានៃបណ្ដឹងទាំងពីរ (បណ្ដឹងទាំងពីរកើតចេញពីអង្គហេតុតែមួយ)៖
  - ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងទាមទារសំណងនៅចំពោះមុខតុលាការព្រហ្មទណ្ឌ។ សិទ្ធិជ្រើសរើសរវាងយន្តការតុលាការរដ្ឋប្បវេណី និងតុលាការព្រហ្មទណ្ឌ ម២២។ វិធាន ***Electa una via***៖ ដើមបណ្ដឹងដែលអនុវត្តបណ្ដឹងរដ្ឋប្បវេណីនៅមុខតុលាការរដ្ឋប្បវេណីរួចហើយ មិនអាចអនុវត្តបណ្ដឹងនៅមុខតុលាការព្រហ្មទណ្ឌបានទៀតទេ ចំពោះបណ្ដឹងដែលមាន**កម្មវត្ថុតែមួយ មូលហេតុតែមួយ និងភាគីតែមួយ**។
  - បណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនាំឱ្យមានការបើកបណ្ដឹងអាជ្ញា។
  - សេចក្ដីសម្រេចដែលចេញលើបណ្ដឹងអាជ្ញាមានអានុភាពចាប់បង្ខំលើបណ្ដឹងរដ្ឋប្បវេណី។ គោលការណ៍បណ្ដឹងរដ្ឋប្បវេណីរណបបណ្ដឹងអាជ្ញា ម២២ ម២៣ ម២៥ និងម២៦។

# ជំពូកទី២

## បណ្តឹងអាជ្ញា

# គំនូសបំព្រួញបណ្ដឹងអាជ្ញា

អត្ថិភាព
បទល្មើស

→

បណ្ដឹងអាជ្ញា
(ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនា និងការអនុវត្តបណ្ដឹងអាជ្ញា)

→

សាលក្រម ឬ
សាលដីកាស្ថាពរ
អំពីពិរុទ្ធភាពនិងទោស ម២
ម៤៩៧

→

ការអនុវត្តទោស

→

រលត់ទោស

អាយុជីវិតរបស់បណ្ដឹងអាជ្ញា

អាយុជីវិតរបស់ទោស

# ម្ចាស់បណ្ដឹងអាជ្ញា

- ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនាគឺជាការចោទប្រកាន់លើបទល្មើស ម៤។
- បណ្ដឹងអាជ្ញាអាចដាក់ឱ្យមានចលនាដោយ៖
  - អយ្យការ ម១៣១ថ្មី រដ្ឋធម្មនុញ្ញ ម៤ ក្រម ម៧៤ ច្ប. លក្ខន្តិកៈចៅក្រម-ព្រះរាជអាជ្ញា ម៣០ ច្ប. រៀបចំអង្គការតុលាការ (ស្ថាប័នគោល)។
  - ដោយជនរងគ្រោះ ម៥ ក១, ម១៣៩ ម១៤០ និងម១៤១ (ប្ដឹងទៅចៅក្រមស៊ើបសួរ)
  - ដោយមន្ត្រីរាជការ ឬភ្នាក់ងារសាធារណៈដែលច្បាប់បានផ្ដល់អំណាចឱ្យ ម៥ កថា ២។ ខ, ម១៣៤ ច្បាប់ស្ដីពីសារពើពន្ធ ឆ្នាំ១៩៩៧ (និរាករណ៍ឆ្នាំ២០២៣)៖ *ការប្ដឹងចោទប្រកាន់និងការទាមទារដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិពន្ធដារ ត្រូវធ្វើឡើងដោយប្រធាននាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

# លក្ខណៈនៃអង្គការអយ្យការ

- គោលការណ៍នៃភាពមិនអាចប្ដឹងជិតចិត្តបាន ម៥៥៦ ក្រម (ការប្ដឹងជិតចិត្តអាចធ្វើតែចំពោះចៅក្រមអសនៈតែប៉ុណ្ណោះ)។ អយ្យការមិនមែនជាចៅក្រមសម្រាប់ជនល្មើសទេ តែជាភាគី។
- គោលការណ៍នៃការមិនទទួលខុសត្រូវ ម៣០ ក្រម, ម៣១ ម៥១ ម៧០ ច្ប.រៀបចំតុលាការ ម៦ច្ប.លក្ខន្តិកៈចៅក្រម-ព្រះរាជអាជ្ញា។ ទោះបីមានការលើកលែងចោទប្រកាន់ ឬ ឱ្យរួចខ្លួន។
- គោលការណ៍ឋានានុក្រម (ឯកភាព)។ ម៧៥ ច្ប. លក្ខន្តិកៈចៅក្រម-ព្រះរាជអាជ្ញា, ម២៨ ម២៩ ម៣០ ក្រម, ម៣០ ម៣១ ម ៥០ ម៦៩ ច្ប.រៀបចំតុលាការ។
- គោលការណ៍អវិភាគ។ ម៧៥ ច្ប.លក្ខន្តិកៈចៅក្រម-ព្រះរាជអាជ្ញា, ម៣០ ម៥០ ម៦៩ ច្ប.រៀបចំតុលាការ។

# តួនាទីនៃអគ្គការអយ្យការ

❖ម៤ ក្រម ការចាប់ផ្ដើមដំណើរការនៃបណ្ដឹងអាជ្ញាដោយអយ្យការ (សូមមើលផងដែរ ម៣០ ច្ប.រៀបចំតុលាការ និង ម៧៤ ក៤ ច្ប.លក្ខន្តិកៈចៅក្រម-ព្រះរាជអាជ្ញា។)៖

*បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ។*

*អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះ។*

❖អយ្យការ៖

- ❑មិនអាចសម្របសម្រួលលើបណ្ដឹងអាជ្ញា (transiger sur l'action publique)
- ❑មិនអាចដកពាក្យបណ្ដឹង ឬ បោះបង់ចោលបណ្ដឹង
- ❑ក្នុងនាមជាភាគីនៃបណ្ដឹង (លំអៀង) មិនអាចអវត្តមានពីសវនាការបានទេ

# រចនាសម្ព័ន្ធនៃអង្គអយ្យការ




*សូមអានមាត្រា ២៧ ដល់ ៣៩*
*នៃក្រមនីតិវិធីព្រហ្មទណ្ឌ*

# បណ្តឹងអាជ្ញាតាមកាលានុវត្តភាព

- ❖សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាលើចំណាត់ការ៖ ចំណាត់ការក្រោយការស៊ើបអង្កេតចប់សព្វគ្រប់គឺជាការអនុវត្តនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។
  - ❑មិនអាចបង្ខំឱ្យអយ្យការក្នុងការធ្វើអ្វីមួយ
  - ❑មិនអាចបង្វែរអយ្យការកុំឱ្យធ្វើអ្វីមួយនោះទេ។
- ❖ផ្អែកលើគោលការណ៍នេះ ព្រះរាជអាជ្ញាអាចសម្រេច៖
  - ❑បើកការចោទប្រកាន់ (វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនរងគ្រោះ)។
  - ❑តម្កល់រឿងទុកឥតចាត់ការ។
  - ❑ជម្រើសផ្សេងទៀតក្រៅពីការចោទប្រកាន់។

# គំនូសបំព្រួញនៃបណ្តឹងអាជ្ញា

កាលានុវត្តភាពនៃការចោទប្រកាន់៖ ព្រះរាជអាជ្ញាអាច បើកការចោទប្រកាន់ ឬ តម្កល់រឿងទុកឥតចាត់ការ ឬ ជម្រើសផ្សេងទៀត




នីត្យានុកូលភាពនៃការចោទប្រកាន់៖ ព្រះរាជអាជ្ញាត្រូវធ្វើបណ្តឹងអាជ្ញា និង បន្តអនុវត្ត បណ្តឹងអាជ្ញា តាមរយៈការធ្វើបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ ជាដើម(ព្រះរាជអាជ្ញាមិនអាច ដកបណ្តឹងអាជ្ញា)

# ការសម្រេចចោទប្រកាន់

❖ **<u>ការសម្រេចចោទប្រកាន់ ឬការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនា</u>៖ (ម៤៣-៤៩)៖**

- ❑បទឧក្រិដ្ឋ៖ ការបើកការស៊ើបសួរ (**RI**) ម៤៤ ម៤៥ ម១២២។
- ❑បទមជ្ឈិម៖ ការបើកការស៊ើបសួរ (**RI**) ម៤៥ ឬ ការបង្ហាញខ្លួនភ្លាម (**CI**) ម៤៧ ម៤៨ ឬ ការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់(**CD**) ម៤៥ ម៤៦។
- ❑បទលហុ៖ ត្រូវធ្វើតាមការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ (**CD**) ម៤៩។ ឬ ការបើកការស៊ើបសួរ (**RI**)?

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

❖ **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ** ( Réquisitoire introductif =RI ឬ Réquisitoire introductif d’instance/ à fin d’informer/ de soit informé )



# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

- **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ** (Réquisitoire introductif =RI) ម៤៤៖ អង្គហេតុ ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ឬប្រឆាំងនឹងអញ្ញាតជន និងចុះកាលបរិច្ឆេទ និងហត្ថលេខា។
- អនុវត្តចំពោះបទឧក្រិដ្ឋ (ម៤៤ ម១២២ ជាកាតព្វកិច្ច) បទមជ្ឈិម (ម៤៥ ម១២២)។ បទលហុ?
- អនុវត្តចំពោះនីតិជន អនីតិជន (អាយុចាប់ពី១៤ឆ្នាំ) ម២១៣ ម២១៤ និងនីតិបុគ្គល ម៥៩៧។
- បើលេចនូវអង្គហេតុថ្មី (មិនមែនស្ថានទម្ងន់ទោស) ព្រះរាជអាជ្ញាអាចប្តឹងសុំតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ម១២៥។

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

- ❖ **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវតែធ្វើឡើងក្នុងករណី៖**
  - ❑ បទឧក្រិដ្ឋ ម៤៤ ម១២២ (ជាកាតព្វកិច្ច)។
  - ❑ ម៤៨ ម៣០៤៖ ករណីចៅក្រមជំនុំជម្រះដែលទទួលរឿងក្តីតាមរយៈកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌ ម៤៧ក្រម មិនបានបំពេញទេ ឬ ក៏ដោយសារភាពសាំញ៉ាំនៃរឿងទាមទារជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនរឿងទៅព្រះរាជអាជ្ញាវិញ ហើយព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវតែបើកការស៊ើបសួរ។

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

- ក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមជំនុំជម្រះតែម្នាក់គត់ ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្ដឹងនោះបង្កើតបានជាបទឧក្រិដ្ឋ តុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ម៣៤៨ ក្រម ។
- ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវបណ្ដឹង ម៥ ម១៣៩ ក្រម។
- ករណីបទលហុ ម៤៩ ក្រម (លក្ខខណ្ឌ ម៤៦ មិនត្រូវបានបំពេញ) (ការអនុវត្ត)។
- ការទាមទារឱ្យមានការស្រាវជ្រាវបន្ថែម។
- ការចោទប្រកាន់នៅ **អ.វ.ត.ក** គឺធ្វើឡើងតាម RI តែមួយគត់។

# ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ម៤៦ (Citation directe = CD)



# ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

- **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់** ម៤៦ ៖ គឺជាការបញ្ជាចេញដោយ**<u>ព្រះរាជអាជ្ញា</u>**ឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង។ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី ម ២៩២។

- អនុវត្តចំពោះ បទមជ្ឈិម (ជាជម្រើស ម៤៥ ម៤៦) លហុ (ម៤៩ ជាកាតព្វកិច្ច)។

- អនុវត្តចំពោះ នីតិជន អនីតិជន (អាយុចាប់ពី១៤ឆ្នាំ) និងនីតិបុគ្គល ម៥៩៧។

- និទ្ទេសៈ អត្តសញ្ញាណនៃជនជាប់ចោទ សេចក្ដីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ប្រាប់ពីតុលាការ (សាលាលហុ ឬមជ្ឈិម) កាលបរិច្ឆេទ និងម៉ោងពេលសវនាការ និងសិទ្ធិពឹងពាក់មេធាវី។

# នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម

- នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម ម៤៧ ( Comparution immédiate = CI )



# នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម

❖ នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម ម៤៧៖ ជាការបញ្ជារបស់ព្រះរាជអាជ្ញាឱ្យចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង (ជនល្មើសត្រូវបានឃាត់ខ្លួន)។

❖ លក្ខខណ្ឌសារធាតុ មម៤៧៖

❑ បទល្មើសជាក់ស្តែង

❑ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ និងយ៉ាងច្រើន ៥ ឆ្នាំ (សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៖ *បទល្មើសជាបទមជ្ឈិម*)

❑ ជនជាប់ចោទជានីតិជន (មិនអនុវត្តចំពោះអនីតិជន និងនីតិបុគ្គល)

❑ រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន (អំណាចឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា)។

# នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម

❖ លក្ខខណ្ឌទម្រង់ ម៤៨៖

- ❑ ពិនិត្យអត្តសញ្ញាណបុគ្គល
- ❑ ឱ្យដំណឹងដល់ជននោះអំពីអង្គហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ❑ ទទួលចម្លើយរបស់បុគ្គលនោះ បើសាមីខ្លួនចង់និយាយ
- ❑ ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម (ជាដីកាសម្រេច)
- ❑ ប្រាប់សិទ្ធិពឹងពាក់មេធាវី
- ❑ ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពាររហូតដល់សវនាការ
- ❑ អាចលើកសវនាការ ដើម្បីរៀបចំការការពារខ្លួន តែអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន២សប្តាហ៍។ មិនអាចដាក់កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការបាន។
- ❑ សាលាក្រមអង្គសេចក្តីត្រូវតែប្រកាសមិនឱ្យលើស ២ សប្តាហ៍។

# តើការចោទប្រកាន់នេះជាអ្វី ?

❖ម៣២០ ជានីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម ឬជាអ្វីផ្សេង ?

**មាត្រា ៣២០.–** បទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលសវនាការ

ប្រសិនបើមានបទល្មើសបានកើតឡើងនៅក្នុងពេលសវនាការ ប្រធានសវនាការធ្វើកំណត់ហេតុ ពិនិត្យរឿងហេតុនេះ ។

ប្រធានសវនាការអាចបង្គាប់ឱ្យចាប់ និងនាំជនល្មើសភ្លាមជូនព្រះរាជអាជ្ញា ដើម្បីថ្លឹងថ្លែងពីវិធានការដែលត្រូវចាត់ ។

កាលណាបទល្មើសជាបទលហុ ឬ បទមជ្ឈិម តុលាការអាចជំនុំជម្រះជនល្មើសភ្លាម ប្រសិនបើព្រះរាជអាជ្ញាប្តឹងសុំ និងប្រសិនបើជនល្មើសយល់ព្រម ។

# ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ

- មច៥ ម១៣៨ ម១៣៩ ម១៤០៖ គឺ**<u>ជនរងគ្រោះ</u>**នៃបទឧក្រិដ្ឋ ឬបទមជ្ឈិមអាចដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីដាក់បណ្ដឹងអាជ្ញាឱ្យមានចលនា។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចទទួលស្គាល់ពាក្យសុំ ចៅក្រមស៊ើបសួរអាចសម្រេចដាក់ប្រាក់តម្កល់ ម១៤០ និងបញ្ជូនបណ្ដឹងនេះព្រះរាជអាជ្ញាម១៣៩។ ព្រះរាជអាជ្ញា<u>ត្រូវ</u>ប្ដឹងទៅចៅក្រមស៊ើបសួរវិញតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក៏ប៉ុន្តែដីកានេះអាចប្រឆាំងនឹងអញ្ញាតជន ទោះបីបណ្ដឹងរបស់ជនរងគ្រោះប្រឆាំងនឹងបុគ្គលជាក់លាក់ក៏ដោយម១៣៩។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរមិនឱ្យស៊ើបសួរ ហើយចៅក្រមអាចសម្រេចស៊ើបសួរ ឬមិនស៊ើបសួរដោយចេញដីកាសម្រេច ម១៣៩។ (**បណ្ដឹងរដ្ឋប្បវេណីនាំឱ្យកើតមានបណ្ដឹងអាជ្ញា**)
- នេះគឺជាខ្លឹមសារនៃគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់។

# ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ



# ការក្រមិតអំណាចធ្វើបណ្ដឹងអាជ្ញា

❖ **ភាគពូកិច្ចធ្វើបណ្ដឹងអាជ្ញា៖**

❑ ការធ្វើអធិបញ្ញាឱ្យចោទប្រកាន់ពីនាយឋានានុក្រម(មិនអាចអធិបញ្ញាមិនឱ្យចោទប្រកាន់)។

❑ សិទ្ធិរបស់ជនរងគ្រោះ ដោយបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវបណ្ដឹង ដើម្បីធ្វើឱ្យបណ្ដឹងអាជ្ញាមានចលនា ម៥ ម១៣៨ ម១៣៩ ម១៤០។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវតែបើកការចោទប្រកាន់ (តាមការបើកការស៊ើបសួរ) ទោះបីជាព្រះរាជអាជ្ញាធ្លាប់បានសម្រេចតម្កល់រឿងទុកចាត់ការហើយក៏ដោយ។

❑ ការធ្វើស្វ័យបណ្ដឹងក្នុងករណីសភាស៊ើបសួរពន្លាតការស៊ើបសួរចំពោះអង្គហេតុដែលទាក់ទងជាមួយនឹងអង្គហេតុដែលប្ដឹងមកចៅក្រមស៊ើបសួរ ម២៦៣។

# ការក្រមិតអំណាចធ្វើបណ្តឹងអាជ្ញា

❖ **ការហាមឃាត់ក្នុងការធ្វើបណ្តឹងអាជ្ញា៖**

❑ បណ្តឹងអាជ្ញាមិនអាចធ្វើបានដោយមូលហេតុ**អភ័យឯកសិទ្ធិ៖** រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ម៧ ក៣៖ *អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ*។ អភ័យឯកសិទ្ធិគ្រួសារ ម៣៥ ក្រមព្រហ្មទណ្ឌ។

❑ បណ្តឹងអាជ្ញាមិនអាចធ្វើបានទេករណីបុគ្គលណាម្នាក់មានអភ័យឯកសិទ្ធិសភា។ យោង ច្ប.លក្ខន្តិកៈអ្នកតំណាងរាស្ត្រ ម៧ មិនអាចចោទប្រកាន់ពីបទព្រហ្មទណ្ឌបានទេ លើកលែងតែបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង។ ចុះបទលហុ? ចុះវិវាទរដ្ឋប្បវេណី?

# ការក្រិតអំណាចធ្វើបណ្ដឹងអាជ្ញា

- បណ្ដឹងអាជ្ញាចំណុះទៅនឹង**<u>ពាក្យបណ្ដឹងដំបូង</u>**ជាមុនសិន ( système d'accusation privée )៖
  - **<u>ពាក្យបណ្ដឹងពីជនរងគ្រោះ</u>**ករណីបរិហារកេរ្តិ៍ ឬ ប្រមាថជាសាធារណៈ ម៣០៥ ម៣០៧ ម៣០៩ ក្រមព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ មិនមានន័យថា មានពាក្យបណ្ដឹងដំបូងជាមុន នាំឱ្យព្រះរាជអាជ្ញាត្រូវតែធ្វើបណ្ដឹងអាជ្ញានោះទេ។ ម្យ៉ាងទៀត ទោះគ្មានបណ្ដឹងក៏ដោយ ក៏ការបើកការស៊ើបអង្កេតអាចធ្វើបានផងដែរ។ ផ្ទុយទៅវិញ កាលបើការបរិហារកេរ្តិ៍ ឬជេរប្រមាថនេះធ្វើឡើងដោយមូលហេតុដើមកំណើត ជាតិពិន្ទុ ពូជសាសន៍ សញ្ជាតិ ឬ សាសនា នោះព្រះរាជអាជ្ញាអាចចោទប្រកាន់ដោយមិនចាំបាច់មានពាក្យបណ្ដឹងដំបូងជាមុនសិនទេ។
  - ពាក្យបណ្ដឹងពីរដ្ឋបាល៖ ច្បាប់បាំរាំងប្រើក្នុងវិស័យពន្ធដារ (ច្បាប់ស្ដីពីសារពើពន្ធឆ្នាំ ១៩៩៧ និរាករណ៍) និងគយ។

# ការក្រមិតអំណាចធ្វើបណ្ដឹងអាជ្ញា

➢ **<u>ពាក្យបណ្ដឹងពីជនរងគ្រោះ ឬ ពីសិទ្ធិវន្ត ឬ បណ្ដឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើល្មើសបានប្រព្រឹត្ត</u>**៖ ម២១ ក្រមព្រហ្មទណ្ឌកម្ពុជា *ក្នុងករណីដែលមានចែងនៅក្នុងមាត្រា១៩ (បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា២០ (ជនរងគ្រោះជាជនជាតិខ្មែរ) ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្ដឹងរបស់អយ្យការតែប៉ុណ្ណោះ។ ការចោទប្រកាន់ត្រូវតែមានបណ្ដឹងពីជនរងគ្រោះ ឬ ពីសិទ្ធិវន្ត ឬ បណ្ដឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត។*

# ការកម្រិតអំណាចធ្វើបណ្តឹងអាជ្ញា

- បណ្តឹងអាជ្ញាចំណុះទៅនឹង**<u>យោបល់ស្រប</u>** (avis conforme) ឬ កិច្ចនៃអាជ្ញាធរមួយចំនួន៖ ច្បាប់បារាំងប្រើក្នុងវិស័យបទល្មើសពន្ធដារ ( ច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ និរាករណ៍ ) និងបទល្មើសព្រៃឈើជាដើម។
- បណ្តឹងអាជ្ញាចំណុះទៅនឹង**<u>ការដាស់តឿន</u>**៖ ច្បាប់បារាំងប្រើក្នុងវិស័យអនាម័យនិងសន្តិសុខនៃកន្លែងការងារ art L4721-4, C. trav.។
- បណ្តឹងអាជ្ញាមិនអាចធ្វើបានបើមាន**<u>សំណើរមិនឱ្យចោទប្រកាន់ពីជនរងគ្រោះ</u>**ដែលជានីតិជន ប្រសិនបើបទល្មើសជាបទមជ្ឈិមស្រាល ឬបទលហុ ម៣៦ ច្ប.ទប់ស្កាត់ហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

# ការក្រើតអំណាចធ្វើបណ្ដឹងអាជ្ញា

- បណ្ដឹងអាជ្ញាចំណុះទៅនឹង<u>**ដំណោះស្រាយលើបញ្ហាមួយចំនួន**</u> ( questions préjudicielles à l'action  # questions préjudicielles au jugement )៖ ឧ. បណ្ដឹងអាជ្ញាអាចធ្វើបានបន្ទាប់ពីមានសេចក្ដីជាស្ថាពរសម្រេចលើភាពខុសច្បាប់នៃការប្ដឹង (បណ្ដឹងបរិហារបង្កាច់កេរ្ដិ៍)។
- បណ្ដឹងអាជ្ញាមិនអាចធ្វើបានទេ នៅក្នុងករណីជនល្មើសអាយុក្រោម ១៤ឆ្នាំ ម២៧ ច្ប.យុត្តិធម៌អនីតិជន (ត្រូវតម្កល់រឿងទុកឥតចាត់ការ)។
- ការធ្វើបណ្ដឹងអាជ្ញាមិនអាចធ្វើបានទេ ក្នុងករណីបណ្ដឹងអាជ្ញារលត់ ម៧ ក។
- ចំពោះករណី**ការលើកលែងឱ្យរួចផុតពីទោស** ម៥០០ ក្រមព្រហ្មទណ្ឌ តើ

# ការក្រើតអំណាចធ្វើបណ្ដឹងអាជ្ញា

- ❑ចំពោះករណី **ការលើកលែងឱ្យរួចផុតពីទោស** (exemption des peines) ដែលចែងក្នុង ម៥០០ ម៥២៩ ម៥៣៩ ម៥៤៤ ម៥៤៥ ក្រមព្រហ្មទណ្ឌ និង ម៣១ ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន **ការលើកលែងពីការផ្ដន្ទាទោស** (exemption from punishment) ម៤៤ (ជនល្មើសអាយុក្រោម ១៥ឆ្នាំ) ច្បាប់ប្រឆាំងការជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ជាដើម តើព្រះរាជអាជ្ញាត្រូវបានហាមឃាត់មិនឱ្យចោទប្រកាន់? ឬព្រះរាជអាជ្ញាអាចបើកការចោទប្រកាន់បាន? អ្វីទៅជាការលើកលែងឱ្យរួចផុតពីទោស។ ការលើកលែងឱ្យរួចផុតពីទោសនេះសំដៅទៅលើគ្រប់ទោសទាំងអស់ដែលចែងក្នុងក្រមព្រហ្មទណ្ឌ? ឬទាំង**អនុទោស**ផងដែរ?
- ❑ម៨ ច្បាប់ស្ដីពីឯកពន្ធភាព *(បទផិត)*៖ *ក្នុងករណីដែលមានចែងក្នុងមាត្រា៧ខាងលើ ព្រះរាជអាជ្ញាអាចសំរេចមិនធ្វើបណ្ដឹងអាជ្ញាបាន ប្រសិនបើមានបណ្ដឹងរបស់សហព័ទ្ធណាមួយស្នើសុំកុំឱ្យចោទប្រកាន់។* តើព្រះរាជអាជ្ញានៅតែអាចធ្វើបណ្ដឹងអាជ្ញាបានទេ ប្រសិនបើមានសំណើរសុំកុំឱ្យចោទប្រកាន់ពីសហព័ទ្ធ?

# ការតម្កល់រឿងទុកឥតចាត់ការ

- តម្កល់រឿងទុកឥតចាត់ការ គឺជាសេចក្ដីសម្រេចរបស់អង្គការអយ្យការដោយផ្អែកលើគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ក្នុងការមិនបើក ឬ ធ្វើបណ្ដឹងអាជ្ញា។

LEXIQUE DES TERMES JURIDIQUES 2020-2021, DALLOZ ÉDITION 2020

- ការតម្កល់រឿងទុកឥតចាត់ការគឺធ្វើដោយកាលានុវត្តភាព។
- មន្ត្រីនគរបាលយុត្តិធម៌មិនមានអំណាចតម្កល់រឿងទុកឥតចាត់ការ ម៧៥។
- អគ្គព្រះរាជអាជ្ញា ឬ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការបានទេ ម២៩ ក១។

# ការតម្កល់រឿងទុកឥតចាត់ការ

❖ **<u>ការតម្កល់រឿងទុកឥតចាត់ការ</u>** ម៤០ ម៤១ ក្រម៖ មូលហេតុមិនត្រូវបានបញ្ញត្តទេ អាចជាកាតព្វកិច្ចរបស់អយ្យការ ឬមិនមែន ឧ.អនីតិជនក្រោម ១៤ឆ្នាំ ម២៧ ឬការបង្វែរទទួលបានជោគជ័យ ម២៨ ក៥ ច្បស.អនីតិជន ច្បាប់<u>តម្រូវឱ្យ</u>ព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ។ មូលហេតុអាចត្រូវបានចែកចេញ២ប្រភេទគឺ៖

- មូលហេតុផ្នែកបច្ចេកទេស (Ordre technique)៖ គ្មានបទល្មើស រលត់បណ្ដឹងអាជ្ញា មិនទទួលខុសត្រូវព្រហ្មទណ្ឌ ជាដើម ។ល។
- មូលហេតុផ្នែកនយោបាយព្រហ្មទណ្ឌ (Ordre politique)៖ បទល្មើសតូចតាច ការសម្របសម្រួលរបស់គូភាគី ការដកពាក្យបណ្ដឹង ។ល។

# ការតម្កល់រឿងទុកឥតចាត់ការ

- មុនសម្រេចបែបនេះ ព្រះរាជអាជ្ញាបើកការស៊ើបអង្កេត ឬ ស្រាវជ្រាវបន្ថែម។
- ម៤១៖ ត្រូវជូនដំណឹងទៅអ្នកប្ដឹង។ អ្នកប្ដឹងមានរយៈពេល ២ ខែ ដើម្បីធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលអាចសម្រេចតម្កល់ទុកការសម្រេចរបស់ព្រះរាជអាជ្ញាដដែល ឬបង្គាប់ឱ្យចោទប្រកាន់។
- ដីកាសម្រេចតម្កល់រឿងទុកឥតចាត់មិនមានអាជ្ញាអស់ជំនុំទេ ម៤១ ក្រម។ ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការមានលក្ខណៈបណ្ដោះអាសន្ន។

# ការតម្កល់រឿងទុកឥតចាត់ការ

- ការតម្កល់រឿងទុកឥតចាត់ការ មាន ២ ប្រភេទ៖
  - ការតម្កល់រឿងទុកឥតចាត់ការបរិសុទ្ធនិងសាមញ្ញ (ធម្មតា ឬន័យចង្អៀត) និង
  - ការតម្កល់រឿងទុកឥតចាត់ការដោយភ្ជាប់លក្ខខណ្ឌ។ ឧទាហរណ៍ កាលណាការបង្វែរទទួលបានជោគជ័យ ម២៨ ក៥ ច្បាប់ស្តីពីអនីតិជន ច្បាប់តម្រូវឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ។ ការទទួលការព្យាបាលដោយអ្នកញៀនគ្រឿងញៀន ម១០៥ ច្ប.គ្រឿងញៀន នាំឱ្យផ្អាកការចោទប្រកាន់។ បើជោគជ័យអាចតម្កល់រឿងទុកឥតចាត់ការ។ ម១៣ ច្ប.អនីតិជន៖ ជាការសម្រុះសម្រួលដោយ OPJ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ក្នុងករណីបទលហុ។

# ការតម្កល់រឿងទុកឥតចាត់ការ អ.វ.ត.ក

❖ វិធាន ៤៧ ចំណុច៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក

៤. ពាក្យបណ្តឹងទាំងនេះមិនអាចជាប្រភពផ្តើមធ្វើការចោទប្រកាន់ ជាស្វ័យប្រវត្តិអំពីបទឧក្រិដ្ឋបានទេ ហើយសហព្រះរាជអាជ្ញាត្រូវធ្វើការសម្រេចដោយឆន្ទានុសិទ្ធិ ថាតើត្រូវតម្កល់បណ្តឹងទុកឥតចាត់ការ ឬ បញ្ចូលបណ្តឹងនោះទៅក្នុងរឿងដែលការស៊ើបអង្កេតបឋមកំពុងដំណើរការ ឬ បើកការស៊ើបអង្កេតបឋមថ្មី ឬ បញ្ជូនពាក្យបណ្តឹងនោះដោយផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត ។ សហព្រះរាជអាជ្ញា ត្រូវជូនដំណឹងអំពីការសម្រេចដល់អ្នកប្តឹងជាបន្ទាន់ តាមដែលអាចធ្វើទៅបាន និង ក្នុងគ្រប់ករណីទាំងអស់ មិនត្រូវលើសពីរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃចុះពាក្យបណ្តឹង។

វិធានផ្ទៃក្នុង (វិ.លើកទី៨) ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ 64

# ការតម្កល់រឿងទុកឥតចាត់ការ

បទល្មើស → អ្នកប្ដឹង → ការស៊ើបអង្កេត (ព្រះរាជអាជ្ញា) → ការតម្កល់រឿងទុកឥតចាត់ការ → ជូនដំណឹងទៅអ្នកប្ដឹង → ២ ខែ ដើម្បីតវ៉ា → តវ៉ាមកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ → ចេញដីកាសម្រេចរក្សាទុកការតម្កល់ ឬលុបចោល ហើយចោទប្រកាន់

# ជម្រើសផ្សេងទៀតក្រៅពីការចោទប្រកាន់

- នីតិវិធីបង្វែចំពោះអនីតិជន ម២៨ ច្ប.អនីតិជន៖ ១៤ ដល់ ១៨ ឆ្នាំ, បទលហុ ឬមជ្ឈិម, ព្រះរាជអាជ្ញាសម្រេចផ្អាកចោទប្រកាន់ដោយដីកាសម្រេច, ជូនដំណឹងទៅជនរងគ្រោះ ឬអ្នកតំណាង ដើម្បីអនុវត្តការបង្វែរ ហើយបើវិធានការបង្វែរទទួលបានជោគជ័យ ព្រះរាជអាជ្ញា<u>ត្រូវ</u>តម្កល់រឿងទុកឥតចាត់ការ។

- ការទទួលការព្យាបាលដោយអ្នកញៀនគ្រឿងញៀន ម១០៥  ច្ប.គ្រឿងញៀន នាំឱ្យផ្អាកការចោទប្រកាន់។ បើព្យាបាលជោគជ័យ <u>**អាច**</u>តម្កល់រឿងទុកឥតចាត់ការ។

- ការតម្កល់រឿងទុកឥតចាត់ការទាំង២ករណីនេះគឺជាការតម្កល់រឿងទុកឥតចាត់ការដោយមានភ្ជាប់លក្ខខណ្ឌ។

- អគ្គព្រះរាជអាជ្ញា ឬ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាសម្រេចប្រើជម្រើសផ្សេងទៀតបានទេ ម២៩ ក១។

# ជម្រើសផ្សេងទៀតក្រៅពីការចោទប្រកាន់

❖មទ៨ ក្រម ការសម្របសម្រួលជាមួយរដ្ឋ (**រដ្ឋ ឬ ស្ថាប័នរដ្ឋគឺជាភាគីនៃបណ្ដឹង**) (Transaction sur l'action publique) ក៏ជាជម្រើសផ្សេងទៀតក្រៅពីការចោទប្រកាន់ដែរ។ ឧ. ម២២៧ នៃច្បាប់ស្ដីពីសារពើពន្ធ ឆ្នាំ២០២៣ ចែងថា៖

- *១-ការសម្របសម្រួលជាមួយរដ្ឋបាលសារពើពន្ធ តាមរយៈការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់នាំឱ្យ **<u>បណ្ដឹងអាជ្ញារលត់</u>**ចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធយល់ព្រមធ្វើការសម្របសម្រួល រដ្ឋបាលសារពើពន្ធត្រូវធ្វើកំណត់ហេតុអំពីការសម្របសម្រួលនេះ ហើយបញ្ជូនទៅស្ថាប័នអយ្យការ ស្ថាប័នតុលាការដែលមានសមត្ថកិច្ច។* (បណ្ដឹងរបស់រដ្ឋបាលសារពើពន្ធមានលក្ខណៈពាក់កណ្ដាលជាបណ្ដឹងអាជ្ញា ពាក់កណ្ដាលជាបណ្ដឹងរដ្ឋប្បវេណី)

❑ការសម្របសម្រួលជាមួយរដ្ឋតាមច្បាប់ខាងលើនេះ គឺ អនុវត្តទាំងលើបទមជ្ឈិម និងបទលហុ។

# ជម្រើសផ្សេងទៀតក្រៅពីការចោទប្រកាន់

❖ម១៣ ច្ប.អនីតិជន៖ ជាការសម្រុះសម្រួលដោយ OPJ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។ ជា penal mediation / médiation pénale?

**មាត្រា ១៣.- អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការពិនិត្យ និងដោះស្រាយបទលហុ**

អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ។

ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុ នគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ ។

ក្នុងករណីដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នគរបាលយុត្តិធម៌ត្រូវធ្វើរបាយ-ការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ ។

# ជម្រើសផ្សេងទៀតក្រៅពីការចោទប្រកាន់

❖ម២៦ ច្បា.ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ៖ ជាការផ្សះផ្សារ ឬ សម្រុះសម្រួលដោយអាជ្ញាកណ្តាល។ តើមាត្រានេះ មានអានុភាពយ៉ាងណាទៅលើកាលានុវត្តភាពនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា?

**មាត្រា ២៦.–**

ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬ ផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬ បទលហុ ការផ្សះផ្សា ឬ សម្រុះសម្រួលអាចធ្វើទៅបាន តាមការយល់ព្រមពីភាគីទាំងសងខាង ។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយ ដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាលដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

# ជម្រើសផ្សេងទៀតក្រៅពីការចោទប្រកាន់

- មរ១៧ ច្ប.ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ៖ ការផ្សះផ្សារ ឬ សម្រុះសម្រួលមិនអាចធ្វើបានករណីបទឧក្រិដ្ឋ ឬ មជ្ឈិមធ្ងន់ធ្ងរ។

**មាត្រា ១៧.–**

ក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សា ឬ សម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬ មជ្ឈិមធ្ងន់ធ្ងរបានទេ ។

# ករណីច្បាប់បារាំង

## ការអនុវត្តភាពក្នុងច្បាប់បារាំង

# កាលានុវត្តភាពនៅក្នុងច្បាប់បារាំង

❖ កាលានុវត្តភាពនៃក្នុងនីតិវិធីព្រហ្មទណ្ឌបារាំងមាន ៣ គឺ

- ផ្លូវទី១ គឺការចោទប្រកាន់៖ មាន ៧ ប្រភេទ
- ផ្លូវទី២ គឺការតម្កល់រឿងទុកឥតចាត់ការ
- ផ្លូវទី៣ គឺជម្រើសផ្សេងទៀត។

# ការចោទប្រកាន់នៅតុលាការបារាំង

❖**ការចោទប្រកាន់នៅតុលាការបារាំង** មាន ៧ របៀប ហើយប្រែប្រួលទៅតាមប្រភេទនៃបទល្មើស៖

- ❑**ករណីបទឧក្រិដ្ឋ**៖ ត្រូវធ្វើ Le réquisitoire introductif à fin d'informer (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)
- ❑**ករណីបទមជ្ឈិម** អាចជា៖
  - ➢**ការចោទប្រកាន់ចំពោះមុខយុត្តាធិការស៊ើបសួរ**៖ ការបើកការស៊ើបសួរ Le réquisitoire introductif à fin d'informer (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)

# ការចោទប្រកាន់នៅតុលាការបារាំង

## ➢ការចោទប្រកាន់ដោយការបញ្ជូនរឿងទៅយុត្តាធិការជំនុំជម្រះ៖

- La citation directe ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ (ដោយអយ្យការ ដើមបណ្តឹងរដ្ឋប្បវេណី និងមន្ត្រីរាជការសាធារណៈផ្សេងទៀតដែលច្បាប់ផ្តល់អំណាចឱ្យ) បញ្ជូនតាមអាជ្ញាសាលា
- L’avertissement ou la comparition volontaire កោះហៅនិងបង្ហាញខ្លួនដោយស្ម័គ្រចិត្ត ចេញដោយព្រះរាជអាជ្ញា។ ក្នុងករណីមិនបង្ហាញខ្លួណ ព្រះរាជអាជ្ញាចេញ citation directe
- La convocation par officier de police judiciaire ការកោះហៅដោយមន្ត្រីនគរបាលយុត្តិធម៌ (តាមការបង្គាប់ពីព្រះរាជអាជ្ញា) មា៣៩០-១

# ការចោទប្រកាន់នៅតុលាការបារាំង

- La comparution immédiate កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម (បទល្មើសផ្តន្ទាទោសយ៉ាងតិច ៦ ខែ សម្រាប់ករណីស៊ើបអង្កេតជាក់ស្តែង និង យ៉ាងតិច២ឆ្នាំសម្រាប់ករណីស៊ើបអង្កេតបឋម)។

- La comparition sur reconnaissance préalable de culpabilité ការបង្ហាញខ្លួនដោយមានការទទួលស្គាល់ជាមុននូវពិរុទ្ធភាព ម១៨០-១។ អនុវត្តចំពោះនីតិជនបន្ទាប់ពីបានទទួលស្គាល់នូវពិរុទ្ធភាពរបស់ខ្លួន។ អាចធ្វើឡើងបន្ទាប់ពីការស៊ើបអង្កេតជាក់ស្តែង ឬការស៊ើបអង្កេតបឋម។ អនុវត្តចំពោះបទមជ្ឈិម លើកលែងការប៉ះពាល់ដល់រូបរាងកាយនិងបំពានផ្លូវភេទ។ ព្រះរាជអាជ្ញានឹងស្នើមូលទោសមួយឬទោសបន្ថែមដែលចែងសម្រាប់បទមជ្ឈិមនោះ។ ព្រះរាជអាជ្ញាអាចស្នើទោសពន្ធនាគារតិចជាង ឬស្នើ ៣ឆ្នាំ។

# ការចោទប្រកាន់នៅតុលាការជាន់ទី១

❑ **ករណីបទលហុ** អាចជា៖

- ការចោទប្រកាន់ដោយបើកការស៊ើបសួរ (អញ្ញត្រកម្ម) réquisitoire introductif (exceptionnel) ។
- ការចោទប្រកាន់ដោយការបញ្ជូនទៅយុត្តាធិការជំនុំជម្រះ៖
  - La procédure simplifiée de l’ordonnance pénale ម៤៩៥ ដល់ ម៤៩៥-៦ ប្រធានតុលាការមជ្ឈិមប្រកាសទោសដែលមិនមែនជាទោសពន្ធនាគារដោយមិនមានការពិភាក្សាដេញដោលចំពោះមុខ និងសាធារណៈជាមុនលើបណ្ដឹងស្នើសុំដោយ ព្រះរាជអាជ្ញា។
  - L’avertissement ou la comparition volontaire
  - La citation directe

# ការតម្កល់រឿងទុកឥតចាត់ការ (បារាំង)

❖ **ការតម្កល់រឿងទុកឥតចាត់ការ** មាន ២ ប្រភេទ ដូចករណីច្បាប់កម្ពុជា៖

- ការតម្កល់រឿងទុកឥតចាត់ការបរិសុទ្ធនិងសាមញ្ញ (ធម្មតា ឬ ន័យចង្អៀត) និង
- ការតម្កល់រឿងទុកឥតចាត់ការដោយភ្ជាប់លក្ខខណ្ឌ។

# ជម្រើសផ្សេងទៀត ( បារាំង )

- Transaction pénale ( ការសម្របសម្រួលជាមួយរដ្ឋ ) នាំឱ្យរលត់បណ្តឹងអាជ្ញា។
- វិធានការនានាក្នុងមាត្រាក្នុងមាត្រា ៤១-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ( ដាក់កាតព្វកិច្ចលើជនល្មើសដោយព្រះរាជអាជ្ញាផ្ទាល់ ឬ តាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬ អ្នកទទួលប្រតិភូកម្មអំណាច ឬ សន្ទានការី )
  - ឧ. សន្ទានកម្មព្រហ្មទណ្ឌ (ចាត់តាំងសន្ទានការី) តាមការស្នើសុំ ឬការយល់ព្រមពីជនរងគ្រោះ។
  - ឧ. avertissement pénal probatoire (ជំនួស rappel à la loi) ដែលជាការព្រមានជនល្មើសអំពីកាតពកិច្ចដែលច្បាប់ចែង ទោសដែលច្បាប់ចែង សាកល្បង ឆ្នាំសម្រាប់បទមជ្ឈិម និង១ឆ្នាំសម្រាប់បទលហុ។ មិនមានសរសេរចូលក្នុងព្រឹត្តិបត្រថ្កោលទោសទេ តែត្រូវចុះក្នុង Fichier de Traitment des Antécédents Judiciaires (TAJ)។

# ជម្រើសផ្សេងទៀត (បារាំង)

- ស្នើជនល្មើសឱ្យជួសជុលព្យសនកម្ម។
- ស្នើជនល្មើសនៃបទហិង្សាលើសហព័ទ្ធឱ្យរស់នៅក្រៅលំនៅឋាន (បំបែកលំនៅសង្វាស)។ ជនរងគ្រោះទទួលបានវិធានការការពារ។
- ស្នើជនល្មើសមិនឱ្យបង្ហាញខ្លួនមិនលើសពី៦ខែ នៅទីកន្លែងណាមួយ ឬច្រើនដែលកំណត់ ដែលទីកន្លែងនោះបានកើតមានបទល្មើស ឬ ទីកន្លែងដែលជនរងគ្រោះរស់នៅ។
- ក្នុងករណីមិនអនុវត្តវិធានការដែលស្នើទេ ព្រះរាជអាជ្ញាត្រូវតែអនុវត្ត penal composition ឬ បើកការចោទប្រកាន់។
- ការប្រើប្រាស់វិធានការនៅក្នុងមាត្រា៤១-១ នេះមានអានុភាពផ្អាក ឬ ព្យួរ ឬ បង្អង់ (suspension) អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា។

# ជម្រើសផ្សេងទៀត ( បារាំង )

❖ **La composition pénale / penal composition** អាចបកប្រែថា **ការធ្វើសម្បទាន**

- ❑ អនុវត្តតែចំពោះបទមជ្ឈិម និងលហុ។
- ❑ អនុវត្តលើរូបវន្តបុគ្គលអាយុលើស ១៣ ឆ្នាំ និងនីតិបុគ្គល ) អនុវត្តកាតព្វកិច្ចច្រើន
- ❑ បើសម្រេចជោគជ័យគឺមានអានុភាពរលត់បណ្តឹងអាជ្ញា
- ❑ មិនដូចគ្នានឹង La comparition sur reconnaissance préalable de culpabilité ការបង្ហាញខ្លួនដោយមានការទទួលស្គាល់ជាមុននូវពិរុទ្ធភាព ម១៨០-១ នោះទេ។
- ❑ អនុវត្តចំពោះជនល្មើសដែលសារភាពទទួលស្គាល់ថាបានប្រព្រឹត្តបទមជ្ឈិមមួយឬច្រើន ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ឬដាក់ពន្ធនាគារមិនលើសពី ៥ឆ្នាំ ឬបានប្រព្រឹត្តបទលហុ។
- ❑ មិនអនុវត្តចំពោះបទមនុស្សឃាតដោយធ្វេសប្រហែស បទល្មើសសារព័ត៌មាន ឬបទល្មើសនយោបាយ។

# ជម្រើសផ្សេងទៀត (បារាំង)

- ❑វិធានការមានដូចជា (ស្រដៀងគ្នានឹងទោសដែលតុលាការប្រកាស)៖
  - ➢បង់ជូនរតនាគារនូវប្រាក់ពិន័យសម្បទាន។
  - ➢បំពេញការងារជូនសមូហភាពដែនដីដោយមិនយកកម្រៃមិនលើសពី៦០ម៉ោង ឬ ៣០ម៉ោងសម្រាប់បទលហុ ក្នុងរយៈពេលមិនលើសពី ៦ខែ ឬ ៣ខែសម្រាប់បទលហុ។
  - ➢ចុះកម្មសិក្សា ឬ ទទួលការបណ្ដុះបណ្ដាលក្នុងអង្គភាពសុខាភិបាល សង្គម ឬវិជ្ជាជីវៈរយៈពេល៣ខែ ក្នុងរង្វង់អំឡុងពេល១៨ខែ។
  - ➢ប្រគល់ជូនរដ្ឋនូវវត្ថុដែលបម្រើដល់ការប្រព្រឹត្តបទល្មើស ឬផលនៃបទល្មើស។
  - ➢ជួសជុលព្យសនកម្មជូនជនរងគ្រោះ។

# ជម្រើសផ្សេងទៀត (បារាំង)

- នីតិវិធី៖
  - ជនល្មើសអាចមានជំនួយពីមេធាវីមុនទទួលយក composition។ ការទទួលនេះស្មើនឹងការទទួលស្គាល់ពិរុទ្ធភាព ដែលក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថាមិនផ្ទុយនឹងគោលការណ៍សច្ចធារណ៍នៃនិរទោស។
  - ពេលទទួលយក នោះគេនឹងបញ្ជូនទៅប្រធានតុលាការមជ្ឈិម ឬ ប្រធានតុលាការលហុ ឬប្រធានតុលាការអនីតិជន ដើម្បីសម្រេចផ្ដល់សុពលភាព។ ប្រធានតុលាការអាចផ្ដល់សុពលភាព ឬបដិសេធ (បិទផ្លូវតវ៉ា)។ ជាអញ្ញត្រកម្ម មិនចាំបាច់មានការផ្ដល់សុពលភាពពីប្រធានតុលាការ កាលណាបទមជ្ឈិមផ្ដន្ទាទោសមិនលើស៣ឆ្នាំ composition ទាក់ទងតែប្រាក់ពិន័យ ឬ ការប្រគល់វត្ថុដែលមិនលើសពី៣០០០អឺរ៉ូ។

# ជម្រើសផ្សេងទៀត (បារាំង)

- អានុភាពនៃ penal composition៖
  - អាជ្ញាយុកាលត្រូវបាន**កាត់ផ្ដាច់** (interruption) ដោយកិច្ចនេះ។
  - ប្រសិនបើជោគជ័យ នោះនាំឱ្យរលត់បណ្ដឹងអាជ្ញា។ មិនមានការផ្ដន្ទាទោសដោយតុលាការនោះទេ តែត្រូវចុះក្នុងព្រឹត្តិបត្រថ្កោលទោស។
  - ប្រសិនបើបរាជ័យ ដោយសារការមិនទទួលយកដោយជនល្មើស ឬមិនអនុវត្តបានពេញលេញបន្ទាប់ពីបានទទួលយក នោះព្រះរាជអាជ្ញាត្រូវធ្វើបណ្ដឹងអាជ្ញាដើម្បីផ្ដន្ទាទោស។

# ជម្រើសផ្សេងទៀត ( បារាំង )

## ❖ La convention judiciaire d’intérêt public ( ច្បាប់ឆ្នាំ២០១៦ )

- ❑ អនុវត្តដោយព្រះរាជអាជ្ញានៅពេលមិនទាន់មានការបើកបណ្តឹងអាជ្ញា ឬ នៅដំណាក់កាលស៊ើបសួរ។
- ❑ ព្រះរាជអាជ្ញាជាអ្នកស្នើ Convention ដើម្បីដាក់នីតិបុគ្គលឱ្យអនុវត្តកាតព្វកិច្ច ដូចជាបង់ប្រាក់ពិន័យជូនទៅរតនាគារ។
- ❑ ក្នុងករណីបទល្មើសពុករលួយ ជំនួញឥទ្ធិពល បទល្មើសគេចពន្ធ និងបទល្មើសសម្អាតប្រាក់ ព្រមទាំងបទល្មើសពាក់ព័ន្ធ។
- ❑ អនុវត្តតែចំពោះនីតិបុគ្គល។ នីតិបុគ្គលផ្តល់ការយល់ព្រមលើយន្តការនេះតាមរយៈអ្នកតំណាងស្របច្បាប់។
- ❑ សម្រេចផ្តល់សុពលភាពដោយប្រធានតុលាការនីតិរូប tribunal judiciaire។ ការសម្រេចបិទផ្លូវតវ៉ា។ ក៏ប៉ុន្តែ នីតិបុគ្គលអាចដកការយល់ព្រមចេញវិញបាន។ ការសម្រេចផ្តល់សុពលភាពនេះ មិនមែនជាការផ្តន្ទាទោស ឬជាសាលក្រមផ្តន្ទាទោសនោះទេ។ យន្តការនេះមិនមានចុះក្នុងព្រឹត្តបត្រថ្កោលទោសលេខ១នោះទេ។
- ❑ នៅពេលយន្តការនេះត្រូវអនុវត្ត នោះអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាត្រូវបានបង្អង់ ឬ ព្យួរ ឬ ផ្អាក ( suspension )។
- ❑ បើអនុវត្តកាតព្វកិច្ចជោគជ័យទាំងស្រុង នោះនាំឱ្យរលត់បណ្តឹងអាជ្ញា។ បើបរាជ័យ ព្រះរាជអាជ្ញាបើកបណ្តឹងអាជ្ញា។ ក្នុងករណីមានការផ្តន្ទាទោស នឹងមានការអនុវត្តដោយផ្នែកនូវកាតព្វកិច្ចដែលចែងក្នុង convention។

# ការរលត់បណ្ដឹងអាជ្ញា ម៧ ក្រម

- ក្នុងករណីរលត់បណ្ដឹងអាជ្ញា នោះបណ្ដឹងអាជ្ញាលែងអាចត្រូវបានអនុវត្ត ឬ ចាត់ការបន្តទៀតឡើយ ម៧ ក២។ អានុភាពនៃការរលត់គឺ អចិន្ត្រៃយ៍ និង ស្ថាពរ។ ការរលត់បណ្ដឹងអាជ្ញាត្រូវតែធ្វើនៅ**មុន**សាលក្រម ឬសាលដីកាស្ថាពរលើអង្គសេចក្ដី (លើកលែងអាជ្ញាអស់ជំនុំ) បើមូលហេតុនោះកើត**ក្រោយ**សាលក្រម ឬសាលដីកាស្ថាពរលើអង្គសេចក្ដី នោះគឺជាការរលត់ទោស។

# ការរលត់បណ្ដឹងអាជ្ញា ម៧ ក្រម

- **ការរលត់បណ្ដឹងអាជ្ញា មានមូលហេតុទូទៅដែលចែងក្នុងមាត្រា៧ ក្រមៈ**
- **១-មរណភាពនៃជនល្មើស** ៖ មិនផ្ដល់ផលប្រយោជន៍ដល់សហចារី ឬ អ្នកសមគំនិត ឬ អ្នកផ្ដើមគំនិត និងមិនអាចបង្កជាបញ្ហាដល់ការរឹបអូសនានាដែលអាចត្រូវបានធ្វើនៅក្នុងពេលដំណើរការនីតិវិធី។ ផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ អ្នកណាទទួលមរណភាព អ្នកនោះទទួលផលពីការរលត់បណ្ដឹងអាជ្ញា ឯអ្នកនៅរស់រានមានជីវិតនៃអំពើតែមួយជាមួយអ្នកស្លាប់ មិនទទួលផលចំណេញពីមរណភាពរបស់អ្នកដទៃនោះទេ។ ករណីការប្រកាសអំពីការបាត់ខ្លួនតាមបញ្ញត្តិរដ្ឋប្បវេណី? **ការរំលាយនីតិបុគ្គល**?

# ការរលត់បណ្តឹងអាជ្ញា ម៧ ក្រម

❑ការរំលាយនីតិបុគ្គលមិននាំឱ្យរលត់បណ្តឹងអាជ្ញានោះទេ ករណីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ម២៤៨៖

*នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូនគ្នាចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ៖*

*ឃ-កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម។*

# ការលត់បណ្ដឹងអាជ្ញា មព ក្រម

- **២ - ការផុតអាជ្ញាយុកាល (បទល្មើស)៖** អវត្តមានការធ្វើឱ្យមានចលនានៃបណ្ដឹងអាជ្ញាក្នុងអំឡុងពេលមួយដែលគិតរាប់ចាប់ពីការប្រព្រឹត្តបទល្មើស ឬ អវត្តមាននៃការបន្តការអនុវត្ត បណ្ដឹងអាជ្ញា។នៅពេលបណ្ដឹងអាជ្ញារលត់ដោយសារការផុតអាជ្ញាយុកាល បណ្ដឹងរដ្ឋប្បវេណីលែងអាចធ្វើបាននៅចំពោះមុខតុលាការព្រហ្មទណ្ឌទៀតហើយ (ម២៦ ក២) តែវាមិនបានបង្កជាឧបសគ្គដល់ការធ្វើបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការរដ្ឋប្បវេណីនោះទេ។

# ការលត់បណ្ដឹងអាជ្ញា ម៧ ក្រម

- គ្រប់បទល្មើសទាំងអស់ត្រូវផុតអាជ្ញាយុកាលដូចខាងក្រោមនេះ៖
  - បទឧក្រិដ្ឋ ១៥ឆ្នាំ។ លើកលែងតែបទឧក្រិដ្ឋចែងក្នុងច្បាប់ស្ដីពីការប្រឆាំងភេរវកម្ម ឆ្នាំ២០០៧ ឧក្រិដ្ឋកម្មអន្តរជាតិ ម៩ ក្រម ដែលគ្មានអាជ្ញាយុកាល ។
  - បទមជ្ឈិម ៥ឆ្នាំ។ លើកលែងក្នុងករណីដូចខាងក្រោម៖
    - ១ឆ្នាំ ការប្ដឹងបរិហារបង្កាច់កេរ្តិ៍ ម៣១២ ក្រមព្រហ្មទណ្ឌ។
    - ១ឆ្នាំ បទល្មើសច្បាប់ស្ដីពីព្រៃឈើ ថ្នាក់ទី៣ និង ៥ឆ្នាំ សម្រាប់បទល្មើសថ្នាក់ទី២ ម៨៥ ម៩៣។
    - ៣ឆ្នាំ បទល្មើសក្នុងច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ម២៩២។
  - បទលហុ ១ឆ្នាំ។ លើកលែងតែ ៣ឆ្នាំ បទលហុក្នុងច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ម២៩២ និង ៣ខែ ការញុះញង់តាមសារព័ត៌មាន ម១១ ច្បាប់ស្ដីពីរបបសារព័ត៌មាន។

# ការរលត់បណ្តឹងអាជ្ញា មព ក្រម

- មទ១ ចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតចាប់ពីពេលប្រព្រឹត្តបទល្មើស។
  - សាលដីកាតុលាការកំពូលបារាំងចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨៖ **បទឆបោក** (បទមជ្ឈិមដែលពីមុនមានអាជ្ញាយុកាល ៣ ឆ្នាំ) **ដែលអំពើចុងក្រោយប្រព្រឹត្តនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥**។ បន្ទាប់មកនៅថ្ងៃ១១ ខែតុលា ឆ្នាំ២០០៨ ជនរងគ្រោះបានដាក់ពាក្យប្តឹងទៅព្រះរាជអាជ្ញា។ រួចព្រះរាជអាជ្ញាបានបញ្ជូនលិខិតមួយប្រគល់សិទ្ធិជូនអាវុធហត្ថនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨ ដើម្បីស៊ើបអង្កេត។ សំណុំរឿងនេះ ត្រូវបានសាលាឧទ្ធរណ៍សម្រេចថារលត់បណ្តឹងអាជ្ញា។ ជាចុងក្រោយ តុលាការកំពូលបារាំងសម្រេចថាបណ្តឹងអាជ្ញាមិនទាន់រលត់ ដោយសារ**អាជ្ញាយុកាលនៃបទល្មើសចាប់ផ្តើមរាប់ចាប់ពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៥ ហើយបណ្តឹងអាជ្ញានឹងផុតអាជ្ញាយុកាលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨ នៅពាក់កណ្តាលយប់**។
  - ក្នុងនីតិបារាំង អាជ្ញាយុកាលនៃបទល្មើសប្រឆាំងអនីតិជនត្រូវចាប់រាប់ពីពេលអនីតិជននោះទទួលបាននីតិភាព មព (៣) ម៨ (២)(៣) ម៩-១។

# ការរលត់បណ្ដឹងអាជ្ញា ម៧ ក្រម

➢ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង, មាត្រា ៩-១ (វិសោធនកម្មដោយច្បាប់ឆ្នាំ២០១៨, មាត្រា១)៖

*[...]*

*ជាបដិបញ្ញត្តិទៅនឹងផ្នែកទី១នៃមាត្រា ៧ និង ៨ នៃក្រមនេះ ចិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាចំពោះបទល្មើសកំបាំង ឬលាក់បំបាំង**ត្រូវចាប់គិតពីពេលដែលបទល្មើសបានលេចឡើងឬអាចត្រូវបានពិនិត្យឃើញ**ក្នុងលក្ខខណ្ឌនៃដាក់បណ្ដឹងអាជ្ញាឱ្យមានចលនា ឬការអនុវត្តបណ្ដឹងអាជ្ញា ដោយមិនខ្វល់ថាចិរវេលានៃអាជ្ញាយុកាលលើសពី១២ឆ្នាំសម្រាប់បទមជ្ឈិម ឬ ៣០ ឆ្នាំ សម្រាប់បទឧក្រិដ្ឋដែលចាប់រាប់គិតពីពេលដែលបទល្មើសត្រូវបានប្រព្រឹត្តនោះទេ។*

*ត្រូវចាត់ទុកជា**បទល្មើសកំបាំង** កាលណាផ្អែកតាមហេតុផលនៃធាតុផ្សំនៃបទល្មើស បទល្មើសនោះមិនអាចត្រូវបានដឹងដោយជនរងគ្រោះ ឬអាជ្ញាធរតុលាការ។*

*ត្រូវចាត់ទុក**បទល្មើសលាក់កំបាំង** កាលណាចារីប្រព្រឹត្តដោយចេតនានូវរាល់ឧបាយកលដែលមានលក្ខណៈបង្វែរការរកឃើញនៃបទល្មើស។*

# ការលត់បណ្ដឹងអាជ្ញា ម៧ ក្រម

- អាជ្ញាយុកាលត្រូវ**<u>ផ្អាច់</u>** (interruption) ដោយគ្រប់កិច្ចនៃ**ការចោទប្រកាន់** ឬ **កិច្ចស៊ើបសួរ**។ ការបញ្ចប់**កិច្ចចោទប្រកាន់** ឬ **កិច្ចស៊ើបសួរ**នីមួយៗនាំឱ្យចាប់ផ្ដើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល។ ថិរវេលាថ្មីអាចយកទៅជំទាស់បានចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ។ ការផុតអាជ្ញាយុកាលមានអានុភាពចំពោះគ្រប់ជនល្មើសទាំងអស់។
- អ្វីទៅជា កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរ? បញ្ហាពាក្យពេចន៍។ កិច្ចទាំងនោះអាចជា ដីកាកោះហៅ កិច្ចសួរចម្លើយ កិច្ចឆែរឆេរ កោសលវិច័យ លិខិតចោទប្រកាន់ ដីកាដំណោះស្រាយ ជាដើម។

# ការលត់បណ្តឹងអាជ្ញា ម៧ ក្រម

- ក្រមនីតិវិធីព្រហ្មទណ្ឌប៉ែលហ្ស៊ិក មានចែងអំពី**<u>ការផ្តាច់</u>** (interrumption) ដែលចាប់គិតរាប់ថិរវេលាជាថ្មី (ថិរវេលាដំបូង និងថិរវេលាបន្ទាប់) ឬ **<u>ការបង្អង់</u>** (ព្យួរ ឬ ផ្អាក) (suspension) ដែលចាប់រាប់បន្តពីពេលបង្អង់ទុក។
- ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ចាប់តាំងពីច្បាប់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៧ មក (ក្រៅពីការផ្តាច់អាជ្ញាយុកាល) មានចែងអំពី**<u>ការបង្អង់</u>** (ព្យួរ ឬ ផ្អាក) អាជ្ញាយុកាលនៃបទល្មើសដោយចែងថា ម៩-៣៖ ***រាល់ឧបសគ្គផ្នែកច្បាប់ ដែលចែងក្នុងច្បាប់ ឬ រាល់ឧបសគ្គផ្នែកអង្គហេតុដែលមិនអាចជំនះបាននិងប្រហាក់ប្រហែលនឹងប្រធានស័ក្តិដែលធ្វើបណ្តឹងអាជ្ញាមិនអាចមានចលនា ឬមិនអាចអនុវត្តបាន មានអានុភាពបង្អង់អាជ្ញាយុកាល*** ។ (suspension)
- ការផ្តាច់ និង ការបង្អង់ (ព្យួរ ឬ ផ្អាក) បំពេញឱ្យគ្នាទៅវិញទៅមក។
- ការផ្តាច់ ឬបង្អង់អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ផ្តាច់ ឬ បង្អង់អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

# ការលត់បណ្ដឹងអាជ្ញា ម៧ ក្រម

❖ ៣ - **ការលើកលែងទោសជាទូទៅ** (**l’amnastie réelle et personnelle**)៖ ក្នុងករណីដែលការលើកលែងទោសជាទូទៅត្រូវបានធ្វើឡើងនៅ**<u>មុន</u>**ការផ្ដន្ទាទោសជា**<u>ស្ថាពរ</u>**លើជនល្មើស។ គ្រប់ជនល្មើសទទួលប្រយោជន៍ពីមូលហេតុនេះ សម្រាប់ការលើកលែងទោសជាទូទៅផ្អែកសាច់រឿង (réelle)។ **<u>ការលើកលែងទោសជាទូទៅ</u>**គឺរដ្ឋសភាអនុម័តច្បាប់ ម៩០ថ្មី(ពីរ) រដ្ឋធម្មនុញ្ញ (ផ្ទុយពី **<u>ការលើកលែងទោស</u>** ដែលជាព្រះរាជបុព្វសិទ្ធិរបស់ព្រះមហាក្សត្រ ម២៧ រដ្ឋធម្មនុញ្ញ)។

❖ ៤ - **និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ** **(ដោយច្បាស់លាស់ និងដោយតណ្ហីភាព)**៖ លុបចោលនូវអង្គហេតុល្មើសដែលបានប្រព្រឹត្តមុន និងក្រោយការចូលជាធរមាននៃច្បាប់ដែលត្រូវបាននិរាករណ៍ (**<u>មុន</u>**ការផ្ដន្ទាទោសជា**<u>ស្ថាពរ</u>**លើជនល្មើស ម៩ ក្រមព្រហ្មទណ្ឌ)។ គ្រប់ជនល្មើសទទួលប្រយោជន៍នៃមូលហេតុនេះ។ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌអនុវត្តភ្លាម៖ អំពើប្រព្រឹត្តមុនច្បាប់ដែលលុបចោលបទល្មើសមិនអាចត្រូវចោទប្រកាន់បាន ឬ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តត្រូវបញ្ចប់។

# ការលត់បណ្តឹងអាជ្ញា ម៧ ក្រម

- **៥ - អាជ្ញាអស់ជំនុំ៖** ជនដែលត្រូវបានសម្រេចឱ្យរួចខ្លួន ឬ ផ្តន្ទាទោសជាស្ថាពររួចហើយ មិនអាចត្រូវបានចោទប្រកាន់ ឬជំនុំជម្រះសារជាថ្មីចំពោះអំពើដដែលនោះទេ ម១២ ក្រម, ម១៤ (៧) ICCPR និងមាត្រា២០ (៣) សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស។ ជនល្មើសផ្សេងទៀតដែលមិនទាន់ត្រូវបានសម្រេចឱ្យរួចខ្លួន ឬ ផ្តន្ទាទោសជាស្ថាពរ មិនទទួលផលប្រយោជន៍ពីអាជ្ញាអស់ជំនុំរបស់អ្នកដទៃនោះទេ។
- តើព្រះរាជអាជ្ញាមានសិទ្ធិដកបណ្តឹងអាជ្ញាបានដែរឬទេ? នាំឱ្យរលត់បណ្តឹងអាជ្ញា?

# ការលត់បណ្ដឹងអាជ្ញា ម៧ ក្រម

**លុបចោលនូវធាតុណាមួយក្នុងចំណោម៤**



# ការរលត់បណ្ដឹងអាជ្ញា ម៨ ក្រម

❖ មទ៨ មូលហេតុផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញា កាលណា**ច្បាប់ដោយឡែកបានចែងដោយជាក់លាក់** (មូលហេតុដោយឡែកសម្រាប់បទល្មើសមួយចំនួន)៖

- ការសម្របសម្រួលជាមួយរដ្ឋ (**រដ្ឋ ឬ ស្ថាប័នរដ្ឋគឺជាភាគីនៃបណ្ដឹង**) (Transaction avec l'État)។ ឧ. មទ២២៧ នៃច្បាប់ស្ដីពីសារពើពន្ធ ឆ្នាំ២០២៣ ចែងថា៖
  - *១-ការសម្របសម្រួលជាមួយរដ្ឋបាលសារពើពន្ធ តាមរយៈការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់នាំឱ្យ**បណ្ដឹងអាជ្ញារលត់**ចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធយល់ព្រមធ្វើការសម្របសម្រួល រដ្ឋបាលសារពើពន្ធត្រូវធ្វើកំណត់ហេតុអំពីការសម្របសម្រួលនេះ ហើយបញ្ជូនទៅស្ថាប័នអយ្យការស្ថាប័នតុលាការដែលមានសមត្ថកិច្ច។* (បណ្ដឹងរបស់រដ្ឋបាលសារពើពន្ធមានលក្ខណៈពាក់កណ្ដាលជាបណ្ដឹងអាជ្ញា ពាក់កណ្ដាលជាបណ្ដឹងរដ្ឋប្បវេណី)
- ការសម្របសម្រួលជាមួយរដ្ឋតាមច្បាប់ខាងលើនេះ គឺ អនុវត្តទាំងលើបទមជ្ឈិម និងបទលហុ។

# ការលត់បណ្តឹងអាជ្ញា មឺ៨ ក្រម

- ការដកពាក្យបណ្តឹងនៅពេលបណ្តឹងនោះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។ ឧ. បទបរិហារកេរ្តិ៍ និងជេរប្រមាថជាសាធារណៈ ម៣០៩ ក្រមព្រហ្មទណ្ឌ។
- ដោយការបង់ប្រាក់ពិន័យសរុប (ឧ. ការបង់ប្រាក់ពិន័យក្នុងបទល្មើសចរាចរណ៍ផ្លូវគោក ម៨៧ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក) ឬ ប្រាក់ពិន័យសម្របសម្រួល (ម៧៧ ច្បាប់ស្តីពីគយ រដ្ឋបាលគយមានសិទ្ធិសម្របសម្រួលលើការពិន័យជាប្រាក់តែត្រូវធ្វើ<u>មុន</u>សាលក្រមរបស់តុលាការ តែច្បាប់មិនបានចែងថារលត់បណ្តឹងអាជ្ញា)។

# ការរំលត់បណ្តឹងអាជ្ញា មជ៨ ក្រម

មិនបានលុបចោលនូវធាតុណាមួយក្នុងចំណោម៤ លើកលែងការបង់ប្រាក់ពិន័យ។




ការសម្របសម្រួលជាមួយរដ្ឋ

ការដកពាក្យបណ្តឹង

# គំនូសបំព្រួញបណ្ដឹងអាជ្ញា

អត្ថិភាពបទល្មើស → បណ្ដឹងអាជ្ញា (ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនា និងការអនុវត្តបណ្ដឹងអាជ្ញា) → សាលក្រម ឬ សាលដីកាស្ថាពរ អំពីពិរុទ្ធភាពនិងទោស ម២ ម៤៩៧ → ការអនុវត្តទោស → រលត់ទោស

អាយុជីវិតរបស់បណ្ដឹងអាជ្ញា

អាយុជីវិតរបស់ទោស

# គំនូសបំព្រួញការរលត់បណ្ដឹងអាជ្ញា




*NB: គំនូសបំព្រួញខាងលើមិនបញ្ជាក់អំពីលំដាប់លំដោយទេ តែចង់បង្ហាញអំពីការរលត់បណ្ដឹងអាជ្ញា ដែលស្ថិតនៅចន្លោះចាប់ពីអត្ថិភាពបទល្មើសរហូតដល់សាលក្រម ឬសាលដីកាស្ថាពរ*

# ជំពូកទី៣

## បណ្ដឹងរដ្ឋប្បវេណី

# លក្ខខណ្ឌ និងប្រសិទ្ធភាពផ្សេងគ្នា




តុលាការព្រហ្មទណ្ឌ

ព្រះរាជអាជ្ញា / ជនរងគ្រោះ

ជនល្មើស

តុលាការរដ្ឋប្បវេណី

ជនរងគ្រោះ/ ដើមចោទ

ជនល្មើស/ ចុងចម្លើយ



# គោលដៅនៃបណ្តឹងរដ្ឋប្បវេណី

- បើមិនមានបទល្មើសព្រហ្មទណ្ឌទេ នោះមិនមានទេពាក្យថា **បណ្តឹងរដ្ឋប្បវេណី**។ ពាក្យថា បណ្តឹងរដ្ឋប្បវេណី មិនមានប្រើប្រាស់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ ពោលគឺមានតែ បណ្តឹងទាមទារ និងបណ្តឹងដែលមានគោលដៅផ្នែករដ្ឋប្បវេណី។

- ដើម្បីចូលរួមកិច្ចដំណើរការនីតិវិធី ជាពិសេសគាំទ្រដល់ការចោទប្រកាន់របស់អយ្យការ និងទាមទារសំណងការខូចខាត។

# គោលដៅនៃបណ្តឹងរដ្ឋប្បវេណី

- យោង ម២ ក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងរដ្ឋប្បវេណីមានលក្ខណៈ២ គឺ
  - កម្មវត្ថុ៖ ទាមទារសំណងការខូចខាតនិងជំងឺចិត្ត (**ការប្រគល់វត្ថុត្រឡប់មកវិញ ការសំណងជំងឺចិត្ត** និង**សោហ៊ុយនីតិវិធី**)។ ចំនួនទឹកប្រាក់ខ្ចីជំពាក់ ១០ម៉ឺនដុល្លារ និងទឹកប្រាក់សរសេរក្នុងសែកស្អុយ ៤ ម៉ឺនដុល្លារ? ចៅក្រមព្រហ្មទណ្ឌអាចសម្រេចអំពីវិវាទកម្មសិទ្ធិលើអចលនវត្ថុ (ដី) រួចបង្គាប់ឱ្យប្រគល់អចលនវត្ថុ (ដី) នោះទៅជនរងគ្រោះបានឬទេ?
  - មូលហេតុ៖ កើតចេញពីបទល្មើសព្រហ្មទណ្ឌ។

# របបគតិយុត្តនៃបណ្ដឹងរដ្ឋប្បវេណី

❖ របបគតិយុត្តនៃបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមក្រមរដ្ឋប្បវេណី៖

- ❑ម៨ច្ប.អនីតិជន *ការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជនត្រូវអនុវត្តតាម**បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី**។*
- ❑ម២៦ ក្រម *បណ្ដឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាម**វិធាននៃក្រមរដ្ឋប្បវេណី**។*
- ❑ម២២ ក្រម *បណ្ដឹងរដ្ឋប្បវេណីអាចធ្វើបានផងដែរនៅចំពោះមុខ**តុលាការរដ្ឋប្បវេណី**។*
- ❑ម១៤៦ ក្រមព្រហ្មទណ្ឌ *កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណីនិងដែលមានប្រភពចេញមកពីសេចក្ដីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាម**វិធាននៃក្រមរដ្ឋប្បវេណី**។*
- ❑ម២៦៣ ច្បាប់ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹកឆ្នាំ២០២៤ *ក្នុងករណីដែលអំពើល្មើសខាងលើបណ្ដាលឱ្យខូចខាត ឬបាត់បង់ផ្នែកណាមួយនៃនាវាអង្គភាពសាមីត្រូវទទួលខុសត្រូវសងការខូចខាត ឬបាត់បង់នោះស្របតាម**បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី**និងច្បាប់ជាធរមានផ្សេងទៀត។*

# យន្តការដើម្បីធានាសំណង

- ក្នុងនីតិវិធីវិជ្ជមានកម្ពុជា៖ អវត្តមាននៃការរក្សាការពារចេញដោយតុលាការព្រហ្មទណ្ឌ ដើម្បីធានាការអនុវត្តទោសពិន័យជាប្រាក់ និងការសងសំណងនិងជម្ងឺទៅជនរងគ្រោះនោះទេ។

- ជនរងគ្រោះត្រូវប្រើប្រាស់យន្តការ**<u>តុលាការរដ្ឋប្បវេណី</u>**ដើម្បីស្នើសុំដីការរក្សាការពារ និងការអនុវត្តដោយបង្ខំលើទ្រព្យ។

- ម៥៣៣ ក២ ក្រម មានចែងអំពីការបង្ខំរូបរាងកាយដល់ទណ្ឌិត ក្នុងករណីគ្មានការបង់ប្រាក់សំណងនិងជម្ងឺទៅជនរងគ្រោះ ក្រោយពីដើមបណ្តឹងរដ្ឋប្បវេណីប្រើប្រាស់អស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការអនុវត្តលើចលនវត្ថុ ឬអចលនវត្ថុរបស់ទណ្ឌិត។

# យន្តការដើម្បីធានាសំណង

❖ **សិទ្ធិអាទិភាព**របស់ដើមបណ្ដឹងក្នុងការទទួលបាននូវសំណង៖

- មស៣៣ ក៣ ក្រម (ករណីប្រជែងគ្នារវាងប្រាក់ពិន័យ ប្រាក់ពន្ធនីតិវិធី និងប្រាក់សំណងនិងជម្ងឺចិត្ត)
- ម៤៧ ច្បាប់ស្ដីពីការប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ (ករណីប្រជែងគ្នារវាង*ទ្រព្យដែលត្រូវបានរឹបអូសដោយរដ្ឋជាមួយនឹងសំណងលើការខូចខាត និងសំណងបដិទានដល់ជនរងគ្រោះ*)។ សិទ្ធិអាទិភាពក្នុងករណីនេះមិនមានចែងក្នុងក្រមព្រហ្មទណ្ឌចំពោះបទល្មើសទូទៅនោះទេ។

# ម្ចាស់ ឬ ប្រធាននៃបណ្តឹងរដ្ឋប្បវេណី

❖ **ម្ចាស់នៃបណ្តឹងរដ្ឋប្បវេណី៖** គ្រប់បុគ្គលទាំងអស់មិនមែនសុទ្ធតែអាចប្តឹងមកតុលាការព្រហ្មទណ្ឌនោះទេ។ (ខុសគ្នារវាង **ជនរងគ្រោះព្រហ្មទណ្ឌ # ជនរងគ្រោះរដ្ឋប្បវេណី**)

- **ជនរងគ្រោះផ្ទាល់** អនុវត្តនិងចាត់ចែងលើបណ្តឹងរដ្ឋប្បវេណី ដោយអាចលះបង់ សម្របសម្រួល ដកខ្លួន អនុប្បទានទៅតតិយជន ជាដើម ម១៣។
- **អនុប្បទានិក** និងតតិយជនដែលអនុវត្តសិទ្ធិឧបាទេសកម្ម (ក្រុមហ៊ុនធានារ៉ាប់រង) មិនអាចអនុវត្តបណ្តឹងរដ្ឋប្បវេណីនៅមុខតុលាការព្រហ្មទណ្ឌនោះទេ។ នៅបារាំងអាចធ្វើបានដោយបុគ្គលមួយចំនួន តែបណ្តឹងនេះមិនអាចបើកធ្វើបណ្តឹងអាជ្ញានោះទេ (ឧ.ជនរងគ្រោះមានសិទ្ធិធ្វើ CD)។
- **ម្ចាស់បំណុលរបស់ជនរងគ្រោះ** មិនអាចអនុវត្តបណ្តឹងរដ្ឋប្បវេណីនៅមុខតុលាការព្រហ្មទណ្ឌនោះទេ។

# ម្ចាស់ ឬ ប្រធាននៃបណ្តឹងរដ្ឋប្បវេណី

- **ទាយាទរបស់ជនរងគ្រោះ (មរណភាព)៖**
  - ចំពោះបទល្មើសដែលប្រព្រឹត្តនៅ**មុនមរណភាព**របស់ជនរងគ្រោះ៖ ម១៦ ក្រម *ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានចាប់ផ្តើម ឬបន្តបានដោយសិទ្ធិវ័ន្ត*។
  - ចំពោះបទល្មើសដែលប្រព្រឹត្តនៅ**ក្រោយមរណភាព**របស់ជនរងគ្រោះ៖ ឧ. អំពើបរិហារកេរ្តិ៍ទៅលើអ្នកដែលបានស្លាប់ អាចធ្វើបានទេ?
- **សាច់ញាតិរបស់ជនរងគ្រោះ**៖ ប្រពន្ធ ទាយាទ អាចអនុវត្តបណ្តឹងរដ្ឋប្បវេណីតែចំពោះបេតិកភណ្ឌផ្ទាល់ខ្លួនរបស់គាត់ដែលរងការខូចខាតផ្ទាល់ខ្លួន ឧ. ព្យសនកម្មផ្លូវចិត្ត ឬការបាត់បង់អាហារកាតព្វកិច្ច។

# លក្ខខណ្ឌសារធាតុនៃបណ្តឹងរដ្ឋប្បវេណី

❖ **លក្ខខណ្ឌសមត្ថភាព៖** ដើម្បីអាចអនុវត្តបណ្តឹងរដ្ឋប្បវេណីបាន ត្រូវតែមានសមត្ថភាពតាមផ្លូវច្បាប់។ សមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង។

❑ **សមត្ថភាពអាស្រ័យផល៖**

➢ រូបវន្តបុគ្គល

➢ នីតិបុគ្គល៖

- គ្រប់សមាគមដែលបានប្រកាសត្រឹមត្រូវ ម១៧ ម១៨ ម១៩ ក្រម។ ម៨០២
- ក្រមបរិស្ថាននិងធនធានធម្មជាតិ៖ រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគម ឬអង្គការដែលបានចុះបញ្ជី និងបានទទួលស្គាល់ដោយរដ្ឋ។ នីតិបុគ្គលបរទេសត្រូវចុះបញ្ជីនៅកម្ពុជាដែរឬទេ ?

# លក្ខណសារធាតុនៃបណ្ដឹងរដ្ឋប្បវេណី

- **សមត្ថភាពក្នុងការអនុវត្ត៖**
  - ម១៣ អាចធ្វើឡើងដោយជនរងគ្រោះ។
  - ម១៥ អ្នកតំណាង បើសិនជនរងគ្រោះជាអនីតិជន ឬនីតិជនដែលស្ថិតនៅក្រោមរបបច្បាប់ការពារ។
  - ម១៦ ដោយសិទ្ធិវន្តករណីមរណភាពនៃជនរងគ្រោះ។
  - ម១៧-១៩ សមាគមនានា តែត្រូវមានការយល់ព្រមពីជនរងគ្រោះ ឬសិទ្ធិវន្ត។
  - ម១៣៨ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវបណ្ដឹង អាចត្រូវដាក់ពាក្យប្ដឹងដោយមេធាវី។
  - ម២៤៥ ពាក្យសុំនានាអាចធ្វើឡើងដោយមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។
  - ម២៥៣ ពាក្យប្ដឹងសុំមោឃភាពអាចធ្វើឡើងដោយមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

# លក្ខណសារធាតុនៃបណ្ដឹងរដ្ឋប្បវេណី

- ម២៧២ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអាចធ្វើដោយមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។
- ម២៨៦ បណ្ដឹងសុំបិទសំណុំរឿង អាចធ្វើឡើងដោយមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។
- ម៣១៣ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ ដោយត្រូវមានលិខិតប្រគល់សិទ្ធិ។
- ម៣៧២ ថ្មី បណ្ដឹងទាស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី៖ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដោយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្ដឹងទាស់។
- ម៣៧២ ថ្មី បណ្ដឹងទាស់នឹងសាលក្រមដោយដើមបណ្ដឹងរដ្ឋប្បវេណី៖ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដោយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្ដឹងទាស់។

# លក្ខណសារធាតុនៃបណ្តឹងរដ្ឋប្បវេណី

- មព៣៧៦ ដើម្បីធ្វើបណ្ដឹងឧទ្ធរណ៍ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដោយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្ដឹងឧទ្ធរណ៍។
- ម៤១៦ បណ្ដឹងទាស់នឹងសាលដីការបស់សាលាឧទ្ធរណ៍ដោយដើមបណ្ដឹងរដ្ឋប្បវេណី៖ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដោយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្ដឹងទាស់។
- ម៤២២ ដើម្បីធ្វើបណ្ដឹងឧទ្ធរណ៍ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ដោយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្ដឹងសាទុក្ខ។
- ម៨០០ និង ម៨០២ ក្រមបរិស្ថាននិងធនធានធម្មជាតិ៖ ភាគីរងគ្រោះ ក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគម ឬអង្គការដែលបានចុះបញ្ជីនិងបានទទួលស្គាល់។

# លក្ខណៈសារធាតុនៃបណ្តឹងរដ្ឋប្បវេណី

- ការរំលាយនីតិបុគ្គលមិននាំឱ្យរលត់បណ្តឹងអាជ្ញានោះទេ ករណីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ម២៤៨៖

*នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូនគ្នាចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ៖*

*ឃ-កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម។*

# លក្ខណៈសារធាតុនៃបណ្តឹងរដ្ឋប្បវេណី

- មា១៣ បទល្មើសព្រហ្មទណ្ឌបង្កព្យសនកម្មដល់ជនរងគ្រោះដែលអាចជាព្យសនកម្មខាងផ្នែកសម្ភារៈ ខាងផ្នែករូបកាយ ឬ ខាងផ្នែកផ្លូវចិត្ត។

- ផលប្រយោជន៍ដែលខូចខាតបាត់បង់ត្រូវតែស្របច្បាប់។ ឧ.យកប្រាក់សូកប៉ាន់មិនបានសម្រេច រួចម្ចាស់ប្រាក់មកប្តឹងទាមទារសំណងក្រោយអ្នករត់ការបោកប្រាស់។

  - ក្រមរដ្ឋប្បវេណី មា៣៥៥ ១- *ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈក្នុងករណីខាងក្រោមនេះ៖ ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។ ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។*

# លក្ខណសារធាតុនៃបណ្តឹងរដ្ឋប្បវេណី

- ម៤៦ ក៣ ច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ៖ *ជនណាបានបង្កើតកិច្ចសន្យាឱ្យខ្ចី ឬការផ្តល់ផ្សេងទៀតទៅជនដទៃក្នុងគោលដៅធ្វើការលក់-ដូរមនុស្ស ឬ ធ្វើអាជីវកម្មផ្លូវភេទ មិនអាចប្តឹងទាមទារសំណងបដិទានចំពោះការផ្តល់នោះបានទេ។*
- ម៤៥ ច្បាប់ដដែល *កិច្ចសន្យាមួយនឹងត្រូវទុកជាមោឃៈប្រសិនបើកិច្ចសន្យានោះត្រូវបានធ្វើឡើងដោយមានគោលដៅបំពេញនូវអំពើលក់-ដូរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ។*

# លក្ខណសារធាតុនៃបណ្ដឹងរដ្ឋប្បវេណី

❖ម១៣ បណ្ដឹងរដ្ឋប្បវេណីត្រូវធ្វើឡើង ដើម្បីទទួលបានការជួសជុល <u>**ព្យសនកម្ម**</u> (ត្រូវបែងចែងគ្នារវាង **ជនរងគ្រោះព្រហ្មទណ្ឌ** # **ជនរងគ្រោះរដ្ឋប្បវេណី**) ដែលជា ៖

- ផលវិបាកផ្ទាល់នៃបទល្មើស (**direct**)។
- ព្យសនកម្មផ្ទាល់ខ្លួន (**personnel**) បុគ្គលដែលទទួលរងព្យសនកម្មដោយផ្ទាល់ខ្លួនដែលកើតផ្ទាល់ពីបទល្មើស។
- បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន?

# ចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណី

- មម២១ ចុងចម្លើយគឺ**អ្នកទទួលខុសត្រូវព្រហ្មទណ្ឌ** ដូចជាចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត។ ទាំងរូបវ័ន្តបុគ្គល (ទាំងនីតិជន ឬអនីតិជន អាយុចាប់ពី១៤ឡើង) និងនីតិបុគ្គល។

- **អ្នកដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ**៖ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មម២១ (ក្រមរដ្ឋប្បវេណី មម៧៤៦ អ្នកមានកាតព្វកិច្ចត្រួតពិនិត្យ, មម៧៤៧ និយោជក, មម៧៤៨ នីតិបុគ្គល, មម៧៤៩ មន្ត្រីរាជការ ជាដើម) និង សិទ្ធិវ័ន្តរបស់ជនល្មើស មម២៤ (សវនាការកាត់ក្តីលើអំពើរបស់មនុស្សដែលស្លាប់)។

**មាត្រា ២៤.–** មរណភាពរបស់ជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ ។ ថ្វីត្បិតតែបណ្តឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ ។

# លក្ខណៈទម្រង់នៃបណ្ដឹងរដ្ឋប្បវេណី

❖ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមាន២របៀប៖

❑**តាមផ្លូវអន្តរាគមន៍** ម១៣៧៖ បន្ទាប់ពីការស៊ើបសួរបានបើក។ បណ្ដឹងអាជ្ញានាំឱ្យមានបណ្ដឹងរដ្ឋប្បវេណី។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ អាចធ្វើនៅពេលស៊ើបសួរក៏បានម១៣៧ ឬ នៅពេលជំនុំជម្រះក៏បាន ម៣១១ (តែត្រូវធ្វើនៅមុនពេលដែលព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានលើអង្គសេចក្ដី)។ (**បណ្ដឹងរដ្ឋប្បវេណី កើតក្រោយបណ្ដឹងអាជ្ញា**)

# លក្ខខណ្ឌតម្រង់នៃបណ្ដឹងរដ្ឋប្បវេណី

- **តាមផ្លូវបណ្ដឹង** ម៥ ម១៣៨ ម១៣៩ ម១៤០៖ គឺជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមអាចដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីដាក់បណ្ដឹងអាជ្ញាឱ្យមានចលនា។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចទទួលស្គាល់ពាក្យសុំចៅក្រមស៊ើបសួរអាចសម្រេចដាក់ប្រាក់តម្កល់ ម១៤០ និងបញ្ជូនបណ្ដឹងនេះព្រះរាជអាជ្ញា ម១៣៩។ ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរវិញតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក៏ប៉ុន្តែដីកានេះអាចប្រឆាំងនឹងអញ្ញាតជន ទោះបីបណ្ដឹងរបស់ជនរងគ្រោះប្រឆាំងនឹងបុគ្គលជាក់លាក់ក៏ដោយម១៣៩។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរមិនឱ្យស៊ើបសួរ ហើយចៅក្រមស៊ើបសួរអាចសម្រេចស៊ើបសួរ ឬមិនស៊ើបសួរដោយចេញដីកាសម្រេច ម១៣៩។ (**បណ្ដឹងរដ្ឋប្បវេណីនាំឱ្យកើតមានបណ្ដឹងអាជ្ញា**)

# លក្ខណៈទម្រង់នៃបណ្តឹងរដ្ឋប្បវេណី

- បណ្តឹងរដ្ឋប្បវេណីអាចធ្វើជាលាយលក្ខណ៍ ឬ ផ្ទាល់មាត់។ ក្នុងករណីផ្ទាល់មាត់ ថៅក្រមស៊ើបសួរ ឬថៅក្រមជំនុំជម្រះត្រូវកត់ត្រាក្នុងកំណត់ហេតុ ម១៣៨ ម៣១១។
- ការសម្រេចទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ដោយតុលាការ៖
  - នៅដំណាក់កាលស៊ើបសួរ៖ តាមច្បាប់ ថៅក្រមស៊ើបសួរចេញដីកាសម្រេចទទួលស្គាល់ ឬមិនទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ម១៣៩ ក១ ម២៦៨ ច៤។ តែក្នុងការអនុវត្តជាក់ស្តែងកម្រចេញជាដីកាសម្រេច។ នៅ **អ.វ.ត.ក សហថៅក្រមស៊ើបអង្កេត** ចេញដីកាសម្រេចទទួលស្គាល់ ឬ មិនទទួលស្គាល់។

# លក្ខខណ្ឌទម្រង់នៃបណ្ដឹងរដ្ឋប្បវេណី

- នៅដំណាក់កាលជំនុំជម្រះ៖ តាមច្បាប់ ចៅក្រមជំនុំជម្រះសម្រេចទទួលស្គាល់ ឬ មិនទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណីតាមសាលក្រមនៅពេលប្រកាសសាលក្រមលើរឿងព្រហ្មទណ្ឌ។ បើសម្រេចទទួលស្គាល់ តុលាការសម្រេចអំពីសំណង ជាមួយគ្នានៅក្នុងសាលក្រម មា៣៥៥។ ក្នុងពេលពិភាក្សាដេញដោល តើចៅក្រមជំនុំជម្រះអាចសម្រេចទទួលស្គាល់ ឬបដិសេធបានទេ?

# ការអនុវត្តបណ្តឹងរដ្ឋប្បវេណី

- ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅតុលាការព្រហ្មទណ្ឌ ហើយជនរងគ្រោះមានសិទ្ធិជ្រើសរើសរវាងយន្តការតុលាការព្រហ្មទណ្ឌនិងរដ្ឋប្បវេណី។
  - មព២ កព ក្រម *បណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបានផងដែរនៅចំពោះមុខតុលាការរដ្ឋប្បវេណី។ ក្នុងករណីនេះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិន ដរាបណាមិនទាន់មានសេចក្តីសម្រេចជាស្ថាពរមួយត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។*
  - ក្រមនីតិវិធីរដ្ឋប្បវេណី ម៨៣ *ចំពោះរឿងក្តីដែលតុលាការកំពុងចាត់ការ ភាគីមិនអាចប្តឹងទៀតបានទៀយ។*

# ការអនុវត្តបណ្តឹងរដ្ឋប្បវេណី

❖ **ករណីរឿងក្តីដំណើរការបន្តបន្ទាប់គ្នា៖**

❑ អាជ្ញាអស់ជំនុំរបស់តុលាការរដ្ឋប្បវេណីមិនមានឥទ្ធិពលទៅលើតុលាការព្រហ្មទណ្ឌទេ។ ការផ្តន្ទាទោសអាចធ្វើបានដោយយុត្តាធិការបង្ក្រាប បើទោះបីជាចៅក្រមរដ្ឋប្បវេណីបានបដិសេធការជួសជុលសំណងការខូចខាត។

❑ អាជ្ញាអស់ជំនុំរបស់តុលាការព្រហ្មទណ្ឌទៅលើតុលាការរដ្ឋប្បវេណី។ ចៅក្រមរដ្ឋប្បវេណីត្រូវគោរពតាមសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌ។ សូមមើលអញ្ញត្រកម្មដែលមាននៅ **ភាគ៦ស្តីពីអាជ្ញាអស់ជំនុំ** (ឯកសារមហាសន្និបាតវិស័យយុត្តិធម៌ឆ្នាំ២០២៤)។

# ការអនុវត្តបណ្តឹងរដ្ឋប្បវេណី

❖ករណីរឿងក្តីដំណើរការក្តីស្របពេលជាមួយគ្នា៖

❑អាជ្ញាអស់ជំនុំរបស់តុលាការព្រហ្មទណ្ឌទៅលើតុលាការរដ្ឋប្បវេណី។ ចៅក្រមរដ្ឋប្បវេណីត្រូវ**<u>បង្អង់មិនទាន់សម្រេចសេចក្តី</u>** ដោយត្រូវរង់ចាំសេចក្តីសម្រេចដែលមិនអាចកែប្រែបានរបស់តុលាការព្រហ្មទណ្ឌ។ សូមមើលសមត្ថកិច្ចអញ្ញត្រកម្មដែលមានចែងក្នុងមាត្រា៣៤២ ក្រម ដែលតុលាការព្រហ្មទណ្ឌរង់ចាំការសម្រេចរបស់តុលាការជំនាញផ្សេងទៀត ដើម្បីអាចសម្រេចទៅលើបណ្តឹងអាជ្ញាបាន។

❑ក៏ប៉ុន្តែ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅមុខតុលាការព្រហ្មទណ្ឌ

➢មិនបានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីបាត់បង់សិទ្ធិធ្វើបណ្តឹងឆាប់រហ័ស (ស្នើសុំដីការក្សាការពារ) ក្នុងករណីនេះ បណ្តឹងរដ្ឋប្បណីមិនត្រូវបានដកចេញពីតុលាការព្រហ្មទណ្ឌនោះទេ

➢មិនបានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីបាត់បង់សិទ្ធិធ្វើបណ្តឹងទៅចៅក្រមអនុវត្ត (រដ្ឋប្បវេណី) នោះទេ។

# ការអនុវត្តបណ្ដឹងរដ្ឋប្បវេណី

- លក្ខខណ្ឌនៃការអនុវត្ត**<u>វិធានបង្អង់មិនទាន់សម្រេចសេចក្ដី</u>** ( **la règle du sursis à statuer** ) ៖
  - បណ្ដឹងអាជ្ញាត្រូវតែត្រូវបានដាក់ឱ្យមានចលនានៅចំពោះមុខយុត្តាធិការជំនុំជម្រះ ឬ យុត្តាធិការស៊ើបសួរ។
  - វិធាននេះនៅតែអនុវត្តទោះបីជាបណ្ដឹងទាំងពីរមិនទាក់ទងនឹងភាគីតែមួយដូចគ្នាក៏ដោយ (ករណីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី)។
  - វិធាននេះអនុវត្តតែចំពោះ**បណ្ដឹងរដ្ឋប្បវេណី**ក្នុងន័យចង្អៀតដែលកើតចេញពីបទល្មើស មិនមែនសម្រាប់បណ្ដឹងដែលមានគោលដៅរដ្ឋប្បវេណីនោះទេ។ ឧ. បណ្ដឹងលែងលះបន្ទាប់ពីមានអំពើហិង្សាដោយចេតនា។
  - វិធាននេះមិនអនុវត្តចំពោះការស្នើសុំថវិការដែលផ្ដល់ឱ្យដោយគណៈកម្មការសងសំណងទៅជនរងគ្រោះដោយសារបទល្មើស (បារាំង ម៧០៦-៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ម៤២២-៣ ក្រមធានារ៉ាប់រង)។
  - វិធាននេះមិនអនុវត្តនៅចំពោះមុខយន្តការរក្សាការពារ និងមជ្ឈតការ។
  - ក្នុងកម្រិតអន្តរជាតិ វិធាននេះអាស្រ័យលើសន្ធិសញ្ញា។

# ការអនុវត្តបណ្តឹងរដ្ឋប្បវេណី

❖**ជម្រើសគឺជាសេរីភាព៖** ជនរងគ្រោះមានសេរីភាពក្នុងការជ្រើសរើសយកយន្តការតុលាការព្រហ្មទណ្ឌក៏បាន ឬ តុលាការរដ្ឋប្បវេណីក៏បាន លើកលែងតែ

❑ កាតព្វកិច្ចក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខយុត្តាធិការដទៃទៀត៖

➢ ដោយហេតុថាតុលាការព្រហ្មទណ្ឌគ្មានសមត្ថកិច្ចចំពោះបណ្តឹងរដ្ឋប្បវេណី៖ ករណីដែលទាមទារសំណងការខូចខាតដោយអំពើភេរវកម្មបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលយកដោយតុលាការព្រហ្មទណ្ឌ មម៧០៦-១៦-១ ក២ បណ្តឹងប្រឆាំងនឹងអ្នករដ្ឋការក្នុងរឿងគ្រោះថ្នាក់ការងារ ឬបណ្តឹងទាក់ទងនឹងតុលាការ Cour de Justice de la République។

➢ ករណីបណ្តឹងអាជ្ញារលត់ ដោយសារការផុតអាជ្ញាយុកាល ឬ ការលើកលែងទោសជាទូទៅ ដែលតម្រូវឱ្យជនរងគ្រោះធ្វើបណ្តឹងរដ្ឋប្បវេណីទៅតុលាការរដ្ឋប្បវេណីជាអាទិ៍។

❑ កាតព្វកិច្ចធ្វើបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ៖ បណ្តឹងរដ្ឋប្បវេណីអាចទទួលបានតែចំពោះមុខតុលាការព្រហ្មទណ្ឌតែប៉ុណ្ណោះ៖ បណ្តឹងបរិហារកេរ្តិ៍ជាសាធារណៈប្រឆាំងនឹងអ្នកនយោបាយ អ្នករដ្ឋការ ម៤៦ ច្បាប់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៨១។

# ការអនុវត្តបណ្ដឹងរដ្ឋប្បវេណី

❖**ជម្រើសគឺមិនអាចដកវិញបាន៖** ការមិនអាចលុបវិញបាននៃជម្រើស គឺជាអត្ថន័យនៃវិធាន ***Electa una via, non datur recursus ad alteram*** ។ ជាគោការណ៍ ជម្រើសគឺស្ថាពរ ឬឥតកែប្រែ។ មានការរិតត្បិត ឬព្រំដែនជាច្រើនទៅនឹងការមិនអាចដកវិញបាននូវជម្រើស៖

- ❑វិធាននេះបដិសេធដោយច្បាប់៖ ជនរងគ្រោះនៃអំពើភេរវកម្មអាចទាមទារសំណងនៅមុខតុលាការរដ្ឋប្បវេណី ក៏ប៉ុន្តែជនរងគ្រោះអាចប្ដឹងទៅតុលាការព្រហ្មទណ្ឌដើម្បីបើកបណ្ដឹងអាជ្ញា ឬគាំទ្របណ្ដឹងអាជ្ញា។

- ❑វិធានអនុវត្តតែ**បណ្ដឹងរដ្ឋប្បវេណី**ក្នុងន័យចង្អៀត តែមិនអនុវត្តចំពោះបណ្ដឹងដែលមានគោលដៅរដ្ឋប្បវេណី ដូចជាបណ្ដឹទាមទារការទូទាត់កម្ចីដែលកើតឡើងក្នុងរឿងសែកស្អុយ ទឹកប្រាក់ជំពាក់ ឬទឹកប្រាក់សរសេរក្នុងសែក។

# ការអនុវត្តបណ្តឹងរដ្ឋប្បវេណី

- វិធាននេះអនុវត្តតែទៅលើភាពដូចគ្នា (identité) នៃ**កម្មវត្ថុ** (objet) **មូលហេតុ** (cause) និង**គូភាគី** (parties) នៅក្នុងបណ្តឹងទាំងពីរ។ មិនមានភាពដូចគ្នា ឧទាហរណ៍៖
  - ទាមទារឱ្យសងវត្ថុនៅតុលាការរដ្ឋប្បវេណី និងទាមទារសំណងការខូចខាតនៅតុលាការព្រហ្មទណ្ឌ។
  - ទាមទារលុបចោលដោយសារវិការៈនៃឆន្ទៈនៅតុលាការរដ្ឋប្បវេណី និងទាមទារសំណងការខូចខាតក្នុងបទកំហែងយកមូលនិធិ។
  - ទាមទារការខូចខាតផ្នែកសម្ភារៈនៅតុលាការរដ្ឋប្បវេណី និងទាមទារសំណងការខូចខាតផ្លូវចិត្តនៅតុលាការព្រហ្មទណ្ឌដែលកើតចេញពីអង្គហេតុតែមួយ។
  - បណ្តឹងរបស់និយោជិតសម្រាប់ការបណ្តេញចេញដោយបំពាននៅតុលាការរដ្ឋប្បវេណី និងបណ្តឹងសម្រាប់ការរើសអើងនៅតុលាការព្រហ្មទណ្ឌ។

# ការអនុវត្តបណ្តឹងរដ្ឋប្បវេណី

- វិធាននេះអនុវត្តតែក្នុងឯកទិស៖
  - មិនអាចជ្រើសរើសយន្តការព្រហ្មទណ្ឌបន្ទាប់ពីជ្រើសរើសយន្តការរដ្ឋប្បវេណី។
  - តែអាចជ្រើសរើសយកយន្តការរដ្ឋប្បវេណីបន្ទាប់ពីជ្រើសរើសយន្តការព្រហ្មទណ្ឌ ក្រោយពីការដកខ្លួនមុនការសម្រេចលើអង្គសេចក្តីដោយចៅក្រមព្រហ្មទណ្ឌ។ ការដកខ្លួននេះមិនដកហូតសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនោះទេ។
- វិធាននេះអនុវត្តតែក្នុងករណីជម្រើសត្រូវបានធ្វើឡើងដោយការដឹងអំពីមូលហេតុ។ (ការអនុវត្តកិច្ចសន្យា និងការរំលោភលើទំនុកចិត្ត)។
- វិធាននេះមិនអនុវត្តនៅដំណាក់កាលស៊ើបសួរនោះទេ។ មានន័យថា បន្ទាប់ពីជនរងគ្រោះបានដកពាក្យបណ្តឹងពីតុលាការរដ្ឋប្បវេណី នោះគាត់អាចមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបាន។

# ការអនុវត្តបណ្ដឹងរដ្ឋប្បវេណី

## ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

**មាត្រា ១៧៧.–** ការបង្អង់នីតិវិធីនៃបណ្ដឹង

១-ប្រសិនបើតុលាការមិនអាចបំពេញកិច្ចការរបស់ខ្លួន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ ហេតុផ្សេងទៀត នីតិវិធីនៃបណ្ដឹងត្រូវបានបង្អង់រហូតដល់ហេតុនោះរលត់ ។

២-ប្រសិនបើភាគីមិនអាចបន្តនីតិវិធីនៃបណ្ដឹង ដោយសារឧបសគ្គដែលមានរយៈពេលវែង ហើយមិនអាចប៉ាន់ស្មានបានថា ពេលណាចប់ តុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីនៃបណ្ដឹងនោះ ដោយដីកាសម្រេចបាន ។ ក្នុងករណីនេះ ពេលដែលឧបសគ្គនោះត្រូវបានកន្លងផុតទៅ តុលាការអាចលុបចោលនូវដីកាសម្រេចនោះបាន ។

៣-ប្រសិនបើរឿងក្ដីព្រហ្មទណ្ឌដែលទាក់ទងនឹងអង្គហេតុ ដែលជាមូលដ្ឋាននៃការទាមទារណាមួយក្នុងរឿងក្ដីរដ្ឋប្បវេណី កំពុងត្រូវបានចាត់ការ នោះតុលាការអាចបង្គាប់ឱ្យបង្អង់នូវនីតិវិធីនៃបណ្ដឹងរបស់រឿងក្ដីរដ្ឋប្បវេណីនោះ ដោយដីកាសម្រេចបាន ។ នៅក្នុងករណីនេះ ពេលដែលរឿងក្ដីព្រហ្មទណ្ឌនោះត្រូវបានបញ្ចប់ តុលាការអាចលុបចោលនូវដីកាសម្រេចនោះបាន ។

# ការអនុវត្តបណ្ដឹងរដ្ឋប្បវេណី

❖ចៅក្រមព្រហ្មទណ្ឌមានសមត្ថកិច្ចដើម្បីសម្រេចអំពីបណ្ដឹងរដ្ឋប្បវេណីព្រោះថាកំហុសផ្នែករដ្ឋប្បវេណីនិងព្រហ្មទណ្ឌគឺកើតឡើងព្រមគ្នា ម២៣។

❖គោលការណ៍ឯកភាព ឬ ភាពតែមួយនៃកំហុសព្រហ្មទណ្ឌ និងកំហុសរដ្ឋប្បវេណី (ផ្ទុយពីគោលការណ៍ទ្វិកភាពនៃកំហុសរដ្ឋប្បវេណី និងព្រហ្មទណ្ឌ)

- ❑គ្រប់បទល្មើសព្រហ្មទណ្ឌសុទ្ធតែជាអំពើអនីត្យានុកូល ផ្ទុយទៅវិញ គ្រប់អំពើអនីត្យានុកូលមិនមែនសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌនោះទេ។

# អានុភាពនៃបណ្តឹងរដ្ឋប្បវេណី

- អានុភាពនៃបណ្តឹងរដ្ឋប្បវេណីគឺ ជនរងគ្រោះក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ហើយដើមបណ្តឹងរដ្ឋប្បវេណីក្លាយទៅជាភាគីនៃរឿងក្តីព្រហ្មទណ្ឌ។

- ម៣៥៥ ក២ *បុគ្គលដែលត្រូវផ្តន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គី។* **ការទទួលខុសត្រូវដោយសាមគ្គី សូមមើលមាត្រា៩២១ ដល់ មាត្រា៩៣៧ ក្រមរដ្ឋប្បវេណី។**

- ជនរងគ្រោះមិនមានសិទ្ធិដូចដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

# អានុភាពនៃបណ្តឹងរដ្ឋប្បវេណី

- **សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**
  - សិទ្ធិទទួលបាននូវវិធានការការពារ
  - សិទ្ធិទទួលបាននូវមេធាវីតំណាង
  - សិទ្ធិអាចត្រូវបានចោទសួរដោយមានវត្តមានមេធាវី
  - សិទ្ធិស្នើសុំឱ្យមានកិច្ចស៊ើបសួរ
  - សិទ្ធិប្តឹងឧទ្ធរណ៍
  - សិទ្ធិក្នុងការចូលរួមជាភាគីមួយនៃបណ្តឹងសាទុក្ខ
  - សិទ្ធិគាំទ្របណ្តឹងអាជ្ញា
  - សិទ្ធិទាមទារសំណងការខូចខាត
  - សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការជំនុំជម្រះ
  - សិទ្ធិកោះហៅសាក្សី
  - សិទ្ធិមើលសំណុំរឿង
  - សិទ្ធិឆ្លើយតបទៅនឹងអញ្ញត្រកម្ម
  - សិទ្ធិសួរសំណួរជនជាប់ចោទ
  - សិទ្ធិស្តាប់ចម្លើយក្នុងសវនាការ
  - សិទ្ធិដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ
  - សិទ្ធិធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល។

# ការរលត់បណ្តឹងរដ្ឋប្បវេណីដោយបណ្តឹងអាជ្ញានៅតែមាន

❖ **បណ្តឹងអាជ្ញានៅតែមានជីវិត បន្ទាប់ពីការរលត់បណ្តឹងរដ្ឋប្បវេណី៖**

- **ការសម្រុះសម្រួលលើបណ្តឹងរដ្ឋប្បវេណី។** យុត្តិសាស្ត្របារាំងបង្ហាញថា ការសម្រុះសម្រួលបែបនេះមិនហាមឃាត់ជនរងគ្រោះក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងគោលដៅតែមួយគត់ដើម្បីសហការជាមួយបណ្តឹងអាជ្ញា ហើយការសម្រុះសម្រួលជាមួយអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនហាមឃាត់ក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនល្មើសនោះទេ
- **ការបង់ប្រាក់សំណង៖** យុត្តិសាស្ត្របង្ហាញថា ជនរងគ្រោះដែលត្រូវបានទូទាត់ប្រាក់សំណងទាំងអស់ដោយអ្នកធានារ៉ាប់រងរបស់គាត់ អាចធ្វើបណ្តឹងនៅមុខតុលាការព្រហ្មទណ្ឌនៅពេលដែលអ្នកធានារ៉ាប់រងនោះមិនមានសិទ្ធិធ្វើបណ្តឹងឧបាទេសកម្មចំពោះមុខតុលាការព្រហ្មទណ្ឌប្រឆាំងនឹងជនល្មើស។

# ការលត់បណ្តឹងរដ្ឋប្បវេណីដោយបណ្តឹងអាជ្ញានៅតែមាន

- **អាជ្ញាអស់ជំនុំរបស់តុលាការរដ្ឋប្បវេណី (សាលក្រមរដ្ឋប្បវេណី)។**
- **ការយល់ព្រម**របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើសាលក្រមរបស់សាលាដំបូង។ បណ្តឹងឧទ្ធរណ៍របស់អយ្យការ (ជាការអនុវត្តបណ្តឹងអាជ្ញា) មិនធ្វើឱ្យបណ្តឹងរដ្ឋប្បវេណីរស់ឡើងវិញនោះទេ។
- ករណីបណ្តឹងទាមទារសំណងការខូចខាតមានអាជ្ញាយុកាលទាបជាងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា នោះបណ្តឹងអាជ្ញានៅតែមានជីវិត ម២៦។
- **ការដកពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី** នោះបណ្តឹងអាជ្ញានៅតែមានជីវិតដដែល (លើកលែងបណ្តឹងរបស់ជនរងគ្រោះគឺជាលក្ខខណ្ឌនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា) ដូចនឹងបណ្តឹងរដ្ឋប្បវេណីដែលនៅតែអាចធ្វើនៅមុខតុលាការព្រហ្មទណ្ឌបានដដែល។

# ការមិនរលត់បណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីរលត់បណ្តឹងអាជ្ញា

❖ **បន្ទាប់ពីបណ្តឹងអាជ្ញារលត់ បណ្តឹងរដ្ឋប្បវេណីនៅតែមានជីវិត៖**

❑ បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមក្រមរដ្ឋប្បវេណី ម២៦ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមិនមានឥទ្ធិពលទៅលើអាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណីនោះទេ។ ការផុតអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានតែអានុភាពបង្ខំជនរងគ្រោះដែលមិនទាន់ដាក់បណ្តឹងរបស់ខ្លួនឱ្យដាក់បណ្តឹងចំពោះមុខតុលាការរដ្ឋប្បវេណី។ យន្តការតុលាការព្រហ្មទណ្ឌត្រូវបានបិទសម្រាប់ជនរងគ្រោះ។ គ្មានសាមគ្គីភាពនៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណីនោះទេ។ម២៦អាជ្ញាយុកាលមានសាមគ្គីភាព?

**មាត្រា ២៦.–** អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។ ប៉ុន្តែបណ្តឹងរដ្ឋប្បវេណីនេះមិនអាចធ្វើបានទៀតទេនៅមុខតុលាការព្រហ្មទណ្ឌ ក្រោយការផុតថិរវេលានៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញា ។

# ការមិនលត់បណ្ដឹងរដ្ឋប្បវេណីបន្ទាប់ពីលត់បណ្ដឹងអាជ្ញា

- **ម១០ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖** *នៅពេលបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុវត្តនៅមុខតុលាការព្រហ្មទណ្ឌ នោះបណ្ដឹងនេះត្រូវផុតអាជ្ញាយុកាលតាមវិធាននៃបណ្ដឹងអាជ្ញា។ នៅពេលបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុវត្តនៅមុខតុលាការរដ្ឋប្បវេណី នោះបណ្ដឹងនេះត្រូវផុតតាមវិធាននៃក្រមរដ្ឋប្បវេណី។* ច្បាប់បារាំងប្រកាន់យកសាមគ្គីភាពរវាងអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញានិងបណ្ដឹងរដ្ឋប្បវេណី។

- **ការលើកលែងទោសជាទូទៅ៖** យោង ម១៥១ ក្រមព្រហ្មទណ្ឌ ការលើកលែងទោសជាទូទៅ មូលហេតុរលត់បណ្ដឹងអាជ្ញាមិនបានធ្វើឱ្យរលត់បណ្ដឹងរដ្ឋប្បវេណីនោះទេ។

# ការមិនរលត់បណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីរលត់បណ្តឹងអាជ្ញា

- **មរណៈភាពនៃជនល្មើស** ម២៤៖ បណ្តឹងរដ្ឋប្បវេណីនៅតែមានជីវិតបន្ទាប់ពីបណ្តឹងអាជ្ញារលត់។ ចុះប្រសិនបើជនល្មើសបានទទួលមរណភាពមុនការប្រកាសពិរុទ្ធភាព តើតុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណី (ការកាត់ក្តីក្រោយមរណៈភាព)?

**មាត្រា ២៤.–** មរណភាពរបស់ជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ ។ ថ្វីត្បិតតែបណ្តឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ ។

# ការមិនលត់បណ្ដឹងរដ្ឋប្បវេណីបន្ទាប់ពីលត់បណ្ដឹងអាជ្ញា

- **សាលក្រម** ៖ ប្រសិនបើតុលាការព្រហ្មទណ្ឌខនខានមិនបានសម្រេចលើបណ្ដឹងរដ្ឋប្បវេណី តើជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងថ្មីនៅមុខតុលាការព្រហ្មទណ្ឌដែលបានទេ? ឬ អាចប្ដឹងទៅតុលាការរដ្ឋប្បវេណី? មើលក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ម៧១០ និងម៧១១។
  - សាលក្រមសម្រេចផ្ដន្ទាទោស៖ តុលាការព្រហ្មទណ្ឌនៅតែបន្តមានសមត្ថកិច្ចសម្រេចអំពីសំណង។
  - សាលក្រមសម្រេចឱ្យរួចខ្លួន៖ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍ ហើយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍អាចសម្រេចផ្ដល់សំណងការខូចខាតផ្អែកលើកំហុសរដ្ឋប្បវេណី ទោះបីបណ្ដឹងអាជ្ញារលត់ក៏ដោយ។ សូមមើល **<u>ភាគទី៦ ស្ដីពីអាជ្ញាអស់ជំនុំ</u>** (ឯកសារមហាសន្និបាតវិស័យយុត្តិធម៌ឆ្នាំ ២០២៤)។ នៅតុលាការកំពូលគឺដូចនៅសាលាឧទ្ធរណ៍។

# ភាគទី៤

## ការស៊ើបសួរ

# ការស៊ើបសួរ

- ជំពូកទី១ ការស៊ើបសួរដោយចៅក្រមស៊ើបសួរ
- ជំពូកទី២ សភាស៊ើបសួរ
  - ផ្នែកទី១ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច
  - ផ្នែកទី២ មោឃភាពនៃកិច្ចនីតិវិធី

# ជំពូកទី១

## ការស៊ើបសួរដោយចៅក្រមស៊ើបសួរ

# គោលដៅដែលត្រូវស៊ើបសួរ

**មម២៤ ម៩៦ ក្រមព្រហ្មទណ្ឌ**

**ម១ ម២ ក្រមនីតិវិធីព្រហ្មទណ្ឌ**



# គោលដៅដែលត្រូវស៊ើបសួរ

**មម២៤ ម៩៦ ក្រមព្រហ្មទណ្ឌ**

**ម១ ម២ ក្រមនីតិវិធីព្រហ្មទណ្ឌ**



# តំនូសបំព្រួញនីតិវិធីព្រហ្មទណ្ឌ



# អ្វីជាការស៊ើបសួរ

- **ការស៊ើបសួរ** គឺជាដំណាក់កាលនៃដំណើការរឿងក្តី (ជាកាតព្វកិច្ចករណីបទឧក្រិដ្ឋ ជាជម្រើសករណីបទមជ្ឈិម និងជាអញ្ញត្រកម្មករណីបទលហុ) ដែលក្នុងដំណាក់កាលនោះ ចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវក្នុងគោលដៅកំណត់អត្តសញ្ញាណរបស់ជនល្មើស បញ្ជាក់អំពីបុគ្គលភាព កំណត់អំពីកាលៈទេសៈនិងផលវិបាកនៃបទល្មើស ដើម្បីសម្រេចបន្តទៀតយ៉ាងដូចម្តេចទៅលើបណ្តឹងអាជ្ញា។ (Gérald Cornu, Vocabulaire juridique, puf 7ème édition 2005, p 490)

- មាត្រា ៥៥ ក្រមពិភាក្សាព្រហ្មទណ្ឌបែលហ្សិក៖ ការស៊ើបសួរ គឺជាបណ្តុំនៃកិច្ចដែលមានគោលដៅដើម្បីស្វែងរក ជនល្មើស និងប្រមូលភស្តុតាង និង ចេញវិធានការនានាដើម្បីអនុញ្ញាតឱ្យតុលាការសម្រេចសេចក្តីដោយបានដឹងអំពីមូលហេតុច្បាស់លាស់។

# ការស៊ើបសួរ

- ការស៊ើបសួរសម្រាប់សំណុំរឿងឧក្រិដ្ឋ និងស្មុគស្មាញ។
- ការបើកការស៊ើបសួរអាចជាកាតព្វកិច្ចសម្រាប់បទឧក្រិដ្ឋ ឬ ជាជម្រើសសម្រាប់បទមជ្ឈិម។ បទលហុ?
- វត្តមានរបស់ក្រឡាបញ្ជីចាំបាច់សម្រាប់គ្រប់កិច្ចស៊ើបសួរ ម១២៨។
- ការស៊ើបសួរទាំងដោះបន្ទុក និងដាក់បន្ទុក ម១២៧។
- ការស៊ើបសួរក្នុងដែនសមត្ថកិច្ចនៃសាលាដំបូង ឬ ទូទាំងប្រទេស ម១៣០។

# លក្ខណៈនៃការស៊ើបសួរបច្ចុប្បន្ន

❖លក្ខណៈនៃការស៊ើបសួរ៖ នីតិវិធី Inquisitoire / Inquisitorial (បច្ចុប្បន្ន បានប្រែប្រួលច្រើន)

❑ការស៊ើបសួរត្រូវតែសម្ងាត់ ម១២១ (តែមិនមែនចំពោះគូភាគី ព្រះរាជអាជ្ញា ឬ គូភាគីឯកជន) ហើយភាពសម្ងាត់បញ្ចប់នៅពេលបិទការស៊ើបសួរ។ ព្រះរាជអាជ្ញាយកឯកសារពីសំណុំរឿងមួយទៅដាក់បញ្ចូលក្នុងសំណុំរឿងមួយផ្សេងទៀត។

❑ការស៊ើបសួរជាលាយលក្ខណ៍អក្សរ (មួយផ្នែកធំ) លើកលែងការពិភាក្សាដេញដោលលើរឿងឃុំខ្លួនបណ្ដោះអាសន្ន និងនីតិវិធីនៅចំពោះមុខសភាស៊ើបសួរ។

❑ការស៊ើបសួរមិនចំពោះមុខ៖ ជនសង្ស័យ ឬជនរងគ្រោះមិនអាចចូលមើលសំណុំរឿង អាចស្នើសុំបំពេញកិច្ចណាមួយ មានជំនួយពីមេធាវី សិទ្ធិប្ដឹងឧទ្ធរណ៍ ឬ មោឃភាព។ ចំណែកឯ ព្រះរាជអាជ្ញាត្រូវបានសួរយោបល់រឿងបញ្ហាមួយចំនួន (ការដោះលែងជនត្រូវជាប់) ចូលមើលសំណុំរឿង ចូលរួមកិច្ចស្ដាប់ចម្លើយ ឬកិច្ចស៊ើបសួរណាមួយ អាចស្នើសុំបំពេញកិច្ចស៊ើបសួរណាមួយ ឬធ្វើបណ្ដឹងឧទ្ធរណ៍។

# សមត្ថកិច្ចដែនដី

- **ករណីជនល្មើសជារូបវន្តបុគ្គល៖** ម១២៣
  - ❑ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
  - ❑ចៅក្រមស៊ើបសួរនាទីលំនៅឬទីសំណាក់របស់បុគ្គលដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស
  - ❑ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលត្រូវបានសង្ស័យថាបានព្រឹត្តបទល្មើស
  - ❑ករណីវិវាទសមត្ថកិច្ច តុលាការជាន់ខ្ពស់ជាអ្នកសម្រេច៖ អាចជាសភាស៊ើបសួរ ឬតុលាការកំពូល។
- **ករណីនីតិបុគ្គល៖** ម៥៩៧
  - ❑ចៅក្រមស៊ើបសួរនៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
  - ❑ចៅក្រមស៊ើបសួរនៃទីកន្លែងដែលនីតិបុគ្គលតាំងទីស្នាក់ការ។

# ការស៊ើបសួរ

- ការចាត់តាំងចៅក្រមស៊ើបសួរ
  - ការចាត់តាំងជាដាច់ខាតនូវចៅក្រមស៊ើបសួរ ម៥១
  - ចៅក្រមស៊ើបសួរមិនអាចចូលរួមជំនុំជម្រះលើរឿងព្រហ្មទណ្ឌដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេការជំនុំជម្រះនឹងត្រូវចាត់ទុកជាមោឃៈ ម៥៣។
  - សមាជិកនៃសភាស៊ើបសួរមិនអាចចូលរួមជំនុំជម្រះលើរឿងព្រហ្មទណ្ឌដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេ សាលដីកាត្រូវចាត់ទុកជាមោឃៈ ម៥៤។

# ប្រភពនៃការស៊ើបសួរ

❖ស្របតាមគោលការណ៍នៃការបែងចែករវាងអាជ្ញាធរចោទប្រកាន់ និងអាជ្ញាធរស៊ើបសួរ ចៅក្រមស៊ើបសួរមិនអាចធ្វើបណ្តឹងដោយខ្លួនឯងនោះទេ ពោលគឺចៅក្រមស៊ើបសួរត្រូវតែគេប្តឹងមក (ការចោទប្រកាន់ករណីបទឧក្រិដ្ឋ ឬលហុដែលមិនអាចធ្វើ CD បាន) ឬ អាចប្តឹងមក (បទមជ្ឈិម) (ត្រូវមានបណ្តឹង)។

- ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា RI.
- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង ម៥ ម១៣៨ ម១៣៩។

# ការស៊ើបសួរ

❖ម១២៤ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។

❖ក្រោយពេលធ្វើបណ្ដឹងអាជ្ញា ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌មិនអាចអនុវត្តអំណាចស៊ើបអង្កេតបានទៀតទេ លើកលែងតែក្នុងករណីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសដល់មន្ត្រីនគរបាលយុត្តិធម៌។

❖ក្នុងករណីបណ្ដឹងអាជ្ញាខាងលើអាចទទួលយកបាន ចៅក្រមស៊ើបសួរ**<u>មានកាតព្វកិច្ចត្រូវតែស៊ើបសួរ</u>**។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាសម្រេចមិនស៊ើបសួរក្នុងករណីគ្មានបទល្មើស ឬ ឧបសគ្គផ្នែកច្បាប់ ឧ. ករណីបណ្ដឹងអាជ្ញារលត់ (ដីកានេះ ឃើញមានចែងតែក្នុង ម១៣៩)។

# ការស៊ើបសួរតែលើអង្គហេតុ

❖ការប្តឹងទៅចៅក្រមស៊ើបសួរ (RI)៖ **ការស៊ើបសួរតែទៅលើអង្គហេតុ** (***in rem***) ម១២៥ ពោល គឺ ផ្តោតតែលើអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដើម្បីស្រាវជ្រាវរកអ្នកទទួលខុសត្រូវព្រហ្មទណ្ឌដែលពាក់ព័ន្ធ ទោះបីជាមានឈ្មោះ ឬគ្មានឈ្មោះក្នុងដីកាទាំងពីរនេះក៏ដោយ។

❖ការប្តឹងទៅចៅក្រមស៊ើបសួរគឺមិនមែនចំពោះតែបុគ្គលដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ (***in personam***)។ ការណ៍នេះគឺដើម្បីជៀសវាងការកំណត់ដោយផ្តាច់ការរបស់ព្រះរាជអាជ្ញាទៅលើបុគ្គលដែលប្តឹងមកចៅក្រមស៊ើបសួរ (ធ្វើឱ្យមានភាពមិនស្មើគ្នាចំពោះមុខច្បាប់)។

# ការស៊ើបសួរតែលើអង្គហេតុ

❖បើលេចឡើងនូវអង្គហេតុថ្មី ចៅក្រមស៊ើបសួរជូនដំណឹងទៅព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា <u>**អាច**</u>ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ម១២៥ ឬ ជម្រើសនានានៃការអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ជាដើមដូចជា ប្តឹងបើកការស៊ើបសួរដោយឡែក ធ្វើនីតិវិធីបង្ហាញខ្លួនភ្លាម ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ បើកការស៊ើបអង្កេត តម្កល់រឿងទុកឥតចាត់ការ ផ្ទេរសំណុំរឿងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ឬជម្រើសផ្សេងទៀតជាដើម។ ក៏ប៉ុន្តែ ប្រសិនបើជាអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង នោះចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ។

# ការស៊ើបសួរតែលើអង្គហេតុ

- **<u>អង្គហេតុគឺជាស្នូលនៃការស៊ើបសួរ</u>** (**កម្មវត្ថុនៃបណ្តឹង**)។ ចៅក្រមស៊ើបសួរ **មិនអាចបន្ថយ ឬ បន្ថែម ឬ ផ្លាស់ប្តូរ<u>អង្គហេតុ</u>** (តែសភាស៊ើបសួរអាចពន្លាតការដាក់ឱ្យស្ថិតក្រោមការពិនិត្យដល់បទល្មើសដែលទាក់ទងនឹងបទល្មើសដែលចង្អុលដោយចៅក្រមស៊ើបសួរ ម២៦៣ ក្រម)។ ក៏ប៉ុន្តែ ចៅក្រមស៊ើបសួរអាចបន្ថយ បន្ថែម **<u>ឈ្មោះបុគ្គល</u>**ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរអាចកំណត់បទល្មើសដោយឥស្សរចិត្ត ពីព្រោះថាចៅក្រមស៊ើបសួរឯករាជ្យពីអយ្យការ និងដើមបណ្តឹងរដ្ឋប្បវេណី។
- ព្រះរាជអាជ្ញាមិនអាចប្តឹងសុំចៅក្រមស៊ើបសួរឱ្យកាត់បន្ថយអង្គហេតុដែលបានបើកការស៊ើបសួររួចហើយនោះទេ។

# ការស៊ើបសួរតែលើអង្គហេតុ

ការស៊ើបសួរតែលើអង្គហេតុ



# គំនូសបំព្រួញអំពីការប្តឹងទៅចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញា → RI-អង្គហេតុ (គឺជាស្នូល) → ចៅក្រមស៊ើបសួរ

NB: *ចៅក្រមស៊ើបសួរ មិនអាចបន្ថយ ឬបន្ថែម ឬ ផ្លាស់ប្តូរអង្គហេតុ។ តែអាចបន្ថយ បន្ថែម ឬផ្លាស់ប្តូរឈ្មោះបុគ្គលដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តែសភាស៊ើបសួរអាចពន្យាតការដាក់ឱ្យស្ថិតក្រោមការពិនិត្យដល់បទល្មើសដែលទាក់ទងនឹងបទល្មើសដែលចង្អុលដោយចៅក្រមស៊ើបសួរ ម២៦៣ ក្រម។*

# ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ

- ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ***la mise en examen*** គឺជាអំណាចរបស់យុត្តាធិការស៊ើបសួរ ម១២៦ (ចៅក្រមស៊ើបសួរ) ម២៦៣ (សភាស៊ើបសួរ)។ មិនមែនជាអំណាចរបស់ព្រះរាជអាជ្ញាដូចមានក្នុង RI នោះទេ។ ក៏អាចមានការដាក់ឱ្យស្ថិតក្រោមការពិនិត្យបន្ថែម។
- ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ (ប្តូរពី**ជនសង្ស័យ**ទៅជា**ជនត្រូវចោទ**)៖
  - **លក្ខខណ្ឌគ្រឹះ៖ បុគ្គលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ថាបានចូលរួមប្រព្រឹត្ត** ម១២៦។
  - **លក្ខខណ្ឌទម្រង់៖ កំណត់ហេតុស្តីពី**នីតិវិធីបង្ហាញខ្លួនលើកដំបូង ដើម្បីប្រាប់ពីអំពើល្មើស ឈ្មោះបទចោទ និងសិទ្ធិក្នុងការការពារខ្លួនដល់ជនជាកម្មវត្ថុ ម១៤៣ ម២៤១។ល។ ឬ តាមដីកាបង្គាប់ឱ្យចាប់ខ្លួន (សន្និបាតក្រសួងយុត្តិធម៌ឆ្នាំ២០១៥)។ ចំពោះនីតិបុគ្គល ការចោទប្រកាន់ប្រឆាំងនឹងនីតិបុគ្គលធ្វើឡើងតាមរយៈអ្នកតំណាងស្របច្បាប់នៅពេលចោទប្រកាន់។ កំណត់ហេតុនេះជាកម្មវត្ថុនៃការប្តឹងសុំមោឃភាព មិនមែនប្តឹងឧទ្ធរណ៍នោះទេ។ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យអនុវត្តនៅពេលណាក៏បាន។

# ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ

- គេហៅថា ***ជនត្រូវចោទ*** ឬ ***ជនដែលដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬ ជនដែលដាក់ឱ្យស្ថិតក្រោមការសើុបសួរ*** ***(la personne mise en examen )***។ ក្នុងឋានៈជាចារី សហចារី អ្នកសមគំនិត និងអ្នកផ្ដើមគំនិត ម១២៦។

- ច្បាប់បារាំង ម១១៣-១ បុគ្គលដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងរឿងឱ្យសើុបសួរ ហើយដែលចៅក្រមសើុបសួរមិនបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ អាចត្រូវបានស្ដាប់ចម្លើយជា**<u>សាក្សីដែលមានជំនួយ</u>** (Témoin assisté) ។

# ការស៊ើបសួរ

- ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺមិនមែនជាកាតព្វកិច្ច តែជាអំណាចឆន្ទានុសិទ្ធិ។ ម១២៦ ក១ គួរចែងថា *ចៅក្រមស៊ើបសួរមានអំណាច* (បញ្ហានៃការបកប្រែមាត្រានេះ)។
- ការស៊ើបសួរនៅតែអាចធ្វើបាន ទោះបីជាមិនមាន ឬមិនទាន់មានការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ។
- ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបដិសេធមិនស៊ើបសួរចំពោះបុគ្គលណាម្នាក់បាន ករណីមិនមានបទល្មើស ឬឧបសគ្គផ្នែកច្បាប់។

# កិច្ចស៊ើបសួរ

❖ផ្ដោតលើឯករាជ្យរបស់តុលាការ ចៅក្រមស៊ើបសួរគឺជាអ្នកផ្ដើមគំនិតធ្វើការស៊ើបសួរ ទាំងដាក់បន្ទុក និងដោះបន្ទុក ម១២៧។

❖ការស៊ើបសួរក៏ស្នើឡើងនៅគ្រប់ពេល ដោយ៖

- ❑ម១៣៣ ជនត្រូវចោទមានសិទ្ធិស្នើសុំចៅក្រមឱ្យបំពេញកិច្ចស៊ើបសួរ។
- ❑ម១៣២ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំចៅក្រមឱ្យបំពេញកិច្ចដែលយល់ថាមានប្រយោជន៍។
- ❑ម១៣៤ ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំចៅក្រមឱ្យបំពេញកិច្ចដែលយល់ថាមានប្រយោជន៍។
- ❑ក្នុងករណីទាំងបីនេះ បើមិនបានសម្រេចក្នុងរយៈពេល១ខែ អាចប្ដឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួស។

# កិច្ចស៊ើបសួរ

- ម ១៣១ ចៅក្រមស៊ើបសួរអាចធ្វើកិច្ចស៊ើបសួរដោយឯកឯង ឬតាមដីកាចាត់ឱ្យស៊ើបសួរជំនួសទៅចៅក្រមផ្សេង មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌។
- ម១៣៥ ព្រះរាជអាជ្ញាអាចពិនិត្យមើលសំណុំរឿងគ្រប់ពេល។
- ម១៣៦ ព្រះរាជអាជ្ញាអាចមានវត្តមាននៅគ្រប់កិច្ច។
- ព្រះរាជអាជ្ញាមានសិទ្ធិលើភាគីដទៃដោយសារព្រះរាជអាជ្ញាជាភាគីតំណាងឱ្យរដ្ឋ ឬ ប្រយោជន៍សាធារណៈ។

# កិច្ចស៊ើបសួរ

- ការសួរចម្លើយជនត្រូវចោទ ម១៤៥។ បើជាអនីតិជន ត្រូវមានវត្តមានមេធាវី ម៣២ ម៣៥ ច្ប.អនីតិជន។
- ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ម១៥០។
- ការស្ដាប់ចម្លើយសាក្សី ម១៥៣។
- ការឆែកឆេរ និងការចាប់យកវត្ថុតាង ម១៥៩-១៦១។
- កោសលវិច័យ ម១៦២-១៧១។
- ការស្ដាប់ទូរស័ព្ទ និងថតការសន្ទនា ម១៧២។
- ដីកាចាត់ឱ្យស៊ើបសួរជំនួស ម១៧៣-ម១៨៤។
- និងកិច្ចផ្សេងៗទៀត ដែលមានចែងនៅក្នុងច្បាប់ដទៃទៀត។

# ការសួរចម្លើយជនត្រូវចោទ

- តួនាទីរបស់មេធាវីការពារក្ដីនៅពេលសួរចម្លើយជនត្រូវចោទ៖
  - ម១៤៣ ការបង្ហាញខ្លួនលើកដំបូង ដោយប្រាប់ពីអង្គហេតុ បទចោទ និងសិទ្ធិការពារខ្លួន។
  - ម១៤៥ ការកោះហៅមេធាវីយ៉ាងតិចបំផុត៥ថ្ងៃមុនការសួរចម្លើយ។ ការសួរចម្លើយត្រូវតែធ្វើនៅមុខមេធាវី លើកលែងមេធាវីដែលកោះហៅមិនបានចូលបង្ហាញខ្លួន ជនជាប់ចោទបោះបង់សិទ្ធិមានវត្តមានមេធាវី និងករណីបន្ទាន់ខ្លាចបាត់តម្រុយភស្តុតាង ឬគ្រោះថ្នាក់ដល់ស្លាប់។
  - ម១៤៦ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរដោយមានការអនុញ្ញាតពីចៅក្រម។ អ្នកបកប្រែ។
  - ម១៤៧ ករណីមានពិភាក្សាការតទល់ ម១៤៥ និង ម១៤៦ ត្រូវយកមកអនុវត្តផងដែរ។
  - ម១៤៩ ការប្រាស្រ័យទាក់ទងសន្ទានាជាមួយកូនក្ដី អានលិខិត តែមិនអាចឱ្យលិខិតនៃសំណុំរឿងទៅកូនក្ដី។

# ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

- មុ១៥០ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី។ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវី យ៉ាងតិចបំផុត៥ថ្ងៃមុនការសួរចម្លើយ។ ការសួរចម្លើយត្រូវតែធ្វើនៅមុខមេធាវី លើកលែងមេធាវីដែលកោះហៅមិនបានចូលបង្ហាញខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីបោះបង់សិទ្ធិមានវត្តមានមេធាវី និងករណីបន្ទាន់ខ្លាចបាត់តម្រុយភស្តុតាង ឬគ្រោះថ្នាក់ដល់ស្លាប់។
- មុ១៤៦ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរដោយមានការអនុញ្ញាតពីចៅក្រម។ អ្នកបកប្រែ។
- មុ១៥០ មុ១៥១ ត្រូវយកមកអនុវត្តក្នុងករណីការពិភាក្សាដេញដោល ឬតទល់។

# ការសួរចម្លើយសាក្សី

- មស១៥៣ ថៅក្រមអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបសម្រាប់សំដែងឱ្យឃើញការពិត។ សាក្សីអាចត្រូវបានស្តាប់ចម្លើយដោយមាន ឬ គ្មានវត្តមានជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ សាក្សីដែលកោះហៅមកត្រូវតែចូលបង្ហាញខ្លួន បើពុំនោះអាចថៅក្រមនឹងចេញដីកាបញ្ជាឱ្យចូលខ្លួនចំពោះសាក្សីនោះ។ ម១៥៥ អ្នកបកប្រែ។
- ម១៥៤ សាក្សីត្រូវធ្វើសម្បថ លើកលែងបុគ្គលមួយចំនួនចែងក្នុង ម១៥៦។
- ១៥៧ សាក្សីដែលមានតម្រុយពិរុទ្ធភាពមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។ ថៅក្រមត្រូវអនុវត្តនីតិវិធី ម១៤៣ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតក្រោមការពិនិត្យ។
- ម១៥៨ ថៅក្រមអាចចុះទៅដល់ទៅកន្លែងរបស់សាក្សី កាលបើគាត់ឈឺ ឬមិនអាចធ្វើដំណើរបាន។

# ការឆែកឆេរ

- ១៥៩ ចៅក្រមធ្វើការឆែរឆេរនៅចំពោះអ្នកកាន់កាប់ទីកន្លែង ឬមុខសាក្សីពីរនាក់។ ការឆែកឆេរមិនអាចចាប់ផ្ដើមមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាច លើកលែងការឆែរនៅកន្លែងចំហដល់សាធារណជន និងទីកន្លែងផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

- ការឆែកឆេរអនុវត្តដោយចៅក្រមស៊ើបសួរ ម១៥៩ ឬដោយ OPJ តាមដីកាចាត់ឱ្យស៊ើបសួរជំនួស ម១៨១។

- ការឆែរឆេរនៅការិយាល័យមេធាវីអនុវត្តដូចគ្នានឹងការឆែរឆេរនៅដំណាក់កាលស៊ើបអង្កេត ក៏ប៉ុន្តែក្រមមិនបានបរិយាយជាពិសេសអំពីការឆែរឆេរនៅសហគ្រាសសារព័ត៌មានដូចនៅដំណាក់កាលស៊ើបអង្កេត។

# ការចាប់យកវត្ថុតាង

- ម១៦០ ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាពីលើ ដោយត្រូវបង្ហាញដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ព្រមទាំងធ្វើបញ្ជីសារពើភ័ណ្ឌ។

- ម១៦១ ចៅក្រមស៊ើបសួរអាចប្រគល់វត្ថុចាប់យកទៅម្ចាស់ដើមវិញ កាលណាកម្មសិទ្ធិគ្មានការជំទាស់ ក្រោយពីទទួលមតិពីព្រះរាជអាជ្ញា។ ជូនដំណឹងអំពីដីកានេះដល់អ្នកប្តឹងសុំ និងមេធាវីអ្នកប្តឹងប្រសិនបើមាន។ ក៏ប៉ុន្តែ មិនគួរប្រគល់សងទៅឱ្យអ្នកសុំវិញ កាលណាអាចបង្កជាឧបសគ្គដល់ការសំដែងឱ្យឃើញការពិត។ បើជាវត្ថុគ្រោះថ្នាក់ ឬវត្ថុដែលកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងវិញទេ ដោយត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។ ចៅក្រមស៊ើបសួរចេញដីកាសម្រេចរឹបអូស ?

# ការចាត់ចែងជាបណ្តោះអាសន្នលើវត្ថុតាង

- ច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្នលើវត្ថុចាប់យក ថ្ងៃទី០១ ខែមីនា ឆ្នាំ ២០២៥ មឲ (ការលក់ឡាយឡុងនូវវត្ថុចាប់យកនៅមុនសាលក្រម ឬ សាលដីកាស្ថាពរ)
  - ចៅក្រមស៊ើបសួរអាចផ្តើម ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬបុគ្គលមានប្រយោជន៍

# ការបង្កកទ្រព្យសម្បត្តិ

- អំណាចបង្កកទ្រព្យសម្បត្តិរបស់ចៅក្រមស៊ើបសួរ៖
  - ម៣១ ច្ប.ប្រឆាំងការសម្អាតប្រាក់ (ថ្មី)៖ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ អាចបង្កកទ្រព្យដែលសង្ស័យពាក់ព័ន្ធនឹងបទល្មើស។ ក្រសួងស្ថាប័នអនុវត្តច្បាប់ ត្រូវតែឃាត់ទុកទ្រព្យនោះ រួចប្ដឹងសុំបង្កកទ្រព្យនោះ ដើម្បីតុលាការជំនុំជម្រះសម្រេចរឹបអូស។ មើលច្បាប់ស្ដីពីប្រឆាំង ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធប្រល័យលោក។
  - ម៩០ ច្ប.គ្រឿងញៀន៖ ចៅក្រមស៊ើបសួរ ឬតុលាការអាចបញ្ជាដោយឯកឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញាឱ្យបង្កកទ្រព្យសម្បត្តិ ប្រសិនបើពិនិត្យឃើញថា មានមូលហេតុសមហេតុផល និងសង្ស័យថាទ្រព្យនោះជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬ បម្រុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

# កោសលវិច័យ

- ម១៦២ កោសលវិច័យអាចធ្វើទ្បើងដោយចៅក្រមស៊ើបសួរដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។
- ម១៦៣ បញ្ជីអ្នកជំនាញថ្នាក់ទៀតរៀបចំដោយក្រសួងយុត្តិធម៌ និងស្បថនៅសាលាឧទ្ធរណ៍។
- ម១៦៤ ម១៦៥ ចៅក្រមស៊ើបសួរចេញដីកាចាត់តាំងអ្នកជំនាញទោះមានឬគ្មានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិ។
- ម១៧០ កោសលវិច័យបន្ថែម និងប្រតិកោសលវិច័យ។
- អ្នកជំនាញត្រូវតែបំពេញការងារតាមការបង្គាប់ ម១៦៥ និងក្រោមការត្រួតពិនិត្យរបស់ចៅក្រម ម១៦៦។
- អ្នកជំនាញត្រូវសរសេររបាយការណ៍ និងដាក់ជូនតុលាការតាមកាលកំណត់ ម១៦៥ ម១៦៦ ម១៦៨។
- ម១៧១ សោហ៊ុយជាបន្ទុករដ្ឋ លើកលែងអ្នកស្នើសុំក្រៅពីអាជ្ញាធររដ្ឋដែលត្រូវបង់សោហ៊ុយ។

# ការស្តាប់ទូរស័ព្ទជាអាទិ៍ និងការថតការសន្ទនា

- ម១៧២ ចៅក្រមអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ដូចជាទូរសារ ឬសារតាមអិនធើណែត។ ចៅក្រមអាចសុំឱ្យតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត។ អង្គភាពសាធារណៈ ឬមន្ត្រីរាជការដែលចាត់តាំងត្រូវបំពេញការងារតាមការស្នើសុំរបស់ចៅក្រម រួចត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលបានថត។ កិច្ចនេះអាចអនុវត្តតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ម១៧២ ម១៨៣។

# ការបង្ខែរអនីតិជន

- ការសម្រេចបង្វែរអនីតិជន ម៣៨ (ជំពូក៧) និងមាត្រា ៦០ ដល់ មម៧១ ច្បាប់យុត្តិធម៌អនីតិជន។
- សូមមើល**ភាគទី៨ នីតិវិធីបង្វែរ**។

# ការស៊ើបសួរជំនួស

- ដីកាចាត់ឱ្យស៊ើបសួរជំនួសធ្វើនៅពេលដែលចៅក្រមមិនអាចមានលទ្ធភាពបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង។ កិច្ចនោះអាចធ្វើនៅក្នុងដែនដីជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលជាអ្នកប្រគល់ ឬ ក្រៅដែនដីជាសមត្ថកិច្ចរបស់គាត់បាន ម១៧៣ ក្រម។ ក៏មានផងដែរ ការស៊ើបសួរជំនួសអន្តរជាតិ (ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ)។
- មានតែកិច្ចដែលចាំបាច់តែប៉ុណ្ណោះទើបអាចជាកម្មវត្ថុនៃកិច្ចស៊ើបសួរជំនួស។
- ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវតែបញ្ជាក់អំពីកិច្ចជាក់លាក់ដែលត្រូវធ្វើ (មិនអាចមានលក្ខណៈទូទៅទេ) ហើយមានទំនាក់ទំនងផ្ទាល់ជាមួយនឹងបទល្មើសដែលចោទប្រកាន់ ម១៧៤ ក្រម។ ច្បាប់កម្ពុជាមិនមានបញ្ជាក់ចិរវេលានៃការអនុវត្តដីកានេះទេ តែចៅក្រមស៊ើបសួរអាចដកហូតដីកានោះបានគ្រប់ពេល ម១៧៤។
- ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវធ្វើជាលាយលក្ខណ៍អក្សរ ម១៧៤ ក្រម។

# ការស៊ើបសួរជំនួស

- ❖ម១៧៣ ក្រម ចៅក្រមស៊ើបសួរ អាចប្រគល់សិទ្ធិដើម្បីបំពេញកិច្ចស៊ើបសួរឱ្យទៅ៖
  - ❑ចៅក្រមស៊ើបសួរនៃតុលាការរបស់ខ្លួន ឬចៅក្រមស៊ើបសួរនៃតុលាការផ្សេង៖ ចៅក្រមទទួលសិទ្ធិប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ម១៧៤ (មិនអាចប្រគល់នូវអំណាចដែលគ្មានចែងក្នុងច្បាប់)។ ក្រមបារាំង១៨០៨ មិនមានចែងពីដីកានេះទេ តែឆ្នាំ១៩៣០ តុលាការកំពូលអនុញ្ញាត។
  - ❑មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌៖ ប្រើប្រាស់អំណាចដែលមានចែងក្នុង ម១៧៨ ដល់ ម១៨៤ ក្រម និងក្នុងដែនសមត្ថកិច្ច លើកលែងករណីពន្លាតសមត្ថកិច្ចដែនដី ម១៧៧៖
    - ➢ការស្រាវជ្រាវ និងការពិនិត្យ ម១៧៨

# ការស៊ើបសួរជំនួស

- ការស្តាប់ចម្លើយសាក្សី។ បើមានតម្រុយពិរុទ្ធភាពលើសាក្សី ត្រូវបញ្ឈប់ការស្តាប់ចម្លើយសាក្សីនោះ រួចរាយការណ៍ជូនចៅក្រមស៊ើបសួរ។ សាក្សីត្រូវចូលឆ្លើយ ហើយក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរចេញដីកាបញ្ជាឱ្យចូលខ្លួន។
- មិនអាចសួរចម្លើយជនត្រូវចោទ និងស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។ ម១៨០ក្រម
- ការឆែកឆេរនិងការចាប់យកវត្ថុតាង ម១៨១
- ការឃាត់ខ្លួន ម១៨២
- ការស្តាប់ទូរស័ព្ទ ជាអាទិ៍ ម១៨៣។

# វិធានការនិរន្តរាយ

❖ដើម្បីធានាឱ្យកិច្ចស៊ើបសួរប្រព្រឹត្តទៅដោយរលូន ចៅក្រមស៊ើបសួរមានអំណាច៖

- ការឃាត់ខ្លួន (ដីកាចាត់ឱ្យស៊ើបសួរជំនួស)
- ចេញដីកាបង្គាប់ឱ្យចូលខ្លួន ម១៨៦
- ចេញដីកាបង្គាប់ឱ្យនាំខ្លួន ម១៨៩
- ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ម១៩៥
- អាចសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ ម ២០៣, ម២០៤, ម២០៥
- ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនត្រូវចោទ ម ២២២
- ការបង្កកទ្រព្យសម្បត្តិ ម៩០ ច្ប.ត្រួតពិនិត្យគ្រឿងញៀន និងម៣១ ច្ប.ប្រឆាំងការសម្អាតប្រាក់។ល។

# ដីកាបង្គាប់ឱ្យចូលខ្លួន

- គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលខ្លួននៅមុខចៅក្រមស៊ើបសួរ ម១៨៦។
- អាចចេញទៅលើ ជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ម១៨៦។
- អាចចេញក្នុងករណី បទឧក្រិដ្ឋ បទមជ្ឈិម ឬ លហុ។

# ដីកាបង្គាប់ឱ្យចូលខ្លួន

- ❖ លក្ខខណ្ឌនៃការចេញដីកានិងការអនុវត្ត៖
  - ❑ចុះនិទ្ទេស ម១៨៧៖ អត្តសញ្ញាណបុគ្គលពាក់ព័ន្ធ បទល្មើសនិងច្បាប់ ពេលវេលា និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួន និងឈ្មោះ ឋានៈរបស់ចៅក្រម កាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រម។
  - ❑OPJ, APJ ឬ អាជ្ញាសាលា គឺជាអ្នកអនុវត្ត ម១៨៨។

# ដីកាបង្គាប់ឱ្យនាំខ្លួន

- គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ម១៩០។
- អាចចេញទៅលើ ជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ម១៩០។
- អាចចេញក្នុងករណី បទឧក្រិដ្ឋ បទមជ្ឈិម។ លហុ?
- បុគ្គលអាចត្រូវបានឃុំខ្លួន ម១៩៣ ម១៩៤។ បទលហុពិន័យជាប្រាក់ ?

# ដីកាបង្គាប់ឱ្យនាំខ្លួន

- លក្ខខណ្ឌនៃការចេញដីកានិងការអនុវត្តៈ
  - ចុះនិទ្ទេស ម១៩១។
  - OPJ ជាអ្នកអនុវត្ត តែមិនអាចចូលលំនៅឋានចន្លោះម៉ោង ៦ យប់ ដល់ម៉ោង ៦ ព្រឹក បានទេ ម១៩២។
  - នាំទៅបង្ហាញខ្លួនមុខចៅក្រមស៊ើបសួរក្រោយពីចាប់ខ្លួន ម១៩៣។
  - បើត្រូវបានឃុំខ្លួន រយៈពេលនេះត្រូវរាប់ក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន។ ម១៩៤។

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

- គឺជាបញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះ យកទៅឃុំក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ។
- អាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

❖ លក្ខខណ្ឌចេញដីកា និងការអនុវត្ត៖

- ❑ បទឧក្រិដ្ឋ ឬបទមជ្ឈិម ម១៩៦។
- ❑ បុគ្គលដែលពាក់ព័ន្ធ **មិនដឹងស្ថិតនៅទីណា** ឬ**នៅក្រៅដែនដីកម្ពុជា** ម១៩៦។
- ❑ ចៅក្រមត្រូវសួរយោបល់ព្រះរាជអាជ្ញាមុនចេញដីកា, ចៅក្រមចេញដីកាដោយមានចែងមូលហេតុ, ព្រះរាជអាជ្ញាធានារ៉ាប់រងផ្សព្វផ្សាយដីកា ម១៩៧។
- ❑ OPJ ជាអ្នកអនុវត្ត តែមិនអាចចូលក្នុងលំនៅឋាន ចន្លោះម៉ោង ៦ យប់ ដល់ ៦ ព្រឹក។
- ❑ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវតែទទួលយកបុគ្គលដែលត្រូវបានចាប់ ម២០១។
- ❑ ថិរវេលានៃការឃុំខ្លួនត្រូវរាប់បញ្ចូលក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ម២០២។

# ការឃុំខ្លួនបណ្ដោះអាសន្ន

- ម ២០៣ ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព (នេះជាគោលការណ៍សច្ចធារណ៍នៃនិរទោស ឬសម្មតថាគ្មានទោស)។
- ម ២០៣ ការឃុំខ្លួនបណ្ដោះអាសន្នជាអញ្ញត្រកម្ម តែក្នុងករណីពិសេសតែប៉ុណ្ណោះ។

# ការឃុំខ្លួនបណ្ដោះអាសន្ន

## ❖ លក្ខខណ្ឌសារធាតុ ម២០៤-២០៥៖

- ជនត្រូវចោទ។ ជនដែលមានតម្រុយពិរុទ្ធភាព ?
- មិនអាចអនុវត្តចំពោះអនីតិជនក្រោម ១៤ ឆ្នាំ ម២១២។
- អាចអនុវត្តបានតែក្នុងករណី បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ ឆ្នាំ។ លើកលែងករណីគេចវេះដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ម២៣០ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នបានទោះបីជាទោសដែលច្បាប់ចែងក្រោម ១ ឆ្នាំក៏ដោយ។ ហេតុអ្វីកំណត់យកចាប់ពី១ឆ្នាំ ?

# ការឃុំខ្លួនបណ្តោះអាសន្ន

- **មូលហេតុចាំបាច់៖**
  - បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។
  - រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬ កុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ ឬ**អ្នកសមគំនិត។ អ្នកផ្តើមគំនិត** ?
  - រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

# ការឃុំខ្លួនបណ្ដោះអាសន្ន

- ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ការពារសន្តិសុខឱ្យជនត្រូវចោទ។
- ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូលច្របល់ដែលបណ្ដាលមកពីបទល្មើស។
- អនីតិជន៖ ត្រូវគិតពីសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ម៣៩ ច្ប.អនីតិជន។

# ការឃុំខ្លួនបណ្ដោះអាសន្ន

- ❖ **លក្ខខណ្ឌទម្រង់ ម២០៦-ម៖**
  - ❑ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ (auto-saisine) ជាអ្នកផ្ដួចផ្ដើមគំនិត។
  - ❑ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ។
  - ❑ជនត្រូវចោទធ្វើការកត់សម្គាល់ (សវនាការ)។
  - ❑ដីកាសម្រេចមានសំអាងហេតុ។ ដីកាសម្រេចនេះត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

# ការឃុំខ្លួនបណ្តោះអាសន្ន

❑ចិរវេលា ម២០៨ - ម២០៩៖ នីតិជន

| នីតិជន | រយៈពេល | ការពន្យាពេល |
|---|---|---|
| **បទឧក្រិដ្ឋ** | មិនលើស ៦ ខែ | ៦ ខែ ចំនួន ២ ដង |
| **បទមជ្ឈិម** | មិនលើសពី ៤ ខែ | ២ ខែ ចំនួន ១ ដង |
| **បទមជ្ឈិម** | ចិរវេលាមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់ចែង | |
| **ឧក្រិដ្ឋកម្មអន្តរជាតិ** | ១ ឆ្នាំ | ១ ឆ្នាំ ចំនួន ២ ដង |

# ការឃុំខ្លួនបណ្ដោះអាសន្ន

- ថិរវេលា ម២១៣ - ម២១៤៖ **អនីតិជន** (ច្បាប់យុត្តិធម៌អនីតិជនមិនបានបែងចែងមជ្ឈិមចេតនា ឬ អចេតនា ដូចករណីឃាត់ខ្លួនអនីតិជននោះទេ។)

| អនីតិជន | អាយុ (X) | រយៈពេល | ការពន្យាពេល |
|---|---|---|---|
| **បទឧក្រិដ្ឋ** | ១៤ ≤ X < ១៦ | ៤ ខែ | មិនអាច |
| | ១៦ ≤ X < ១៨ | ៦ ខែ | |
| **បទមជ្ឈិម** (មិនតម្រូវថាបទល្មើស ត្រូវតែជាបទមជ្ឈិមចេតនាដូចការឃាត់ខ្លួននោះទេ) | ១៤ ≤ X < ១៦ | ២ ខែ | មិនអាច |
| | ១៦ ≤ X < ១៨ | ៤ខែ | |
| | ថិរវេលាមិនត្រូវលើស ១/២ អប្បបរមានៃទោសដែលច្បាប់ចែងសម្រាប់អនីតិជន។ | | |

# ការឃុំខ្លួនបណ្ដោះអាសន្ន

- មា២៣០ ករណីគេចវេសដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ បើទោះបីជារយៈពេលឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា មា២០៨-មា២១៤ ក៏ដោយ ក៏ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន។
- ថិរវេលាឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីនេះ មិនអាចលើសពី ៤ ខែ សម្រាប់នីតិជន និង ២ខែ សម្រាប់អនីតិជន។

# ការដោះលែងជនត្រូវចោទ

- ចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញាអាចផ្ដើមគំនិត ឬ ជនត្រូវចោទអាចសុំនៅក្រៅឃុំ ម២១៥ ម២១៦ ម២១៧។
- ដាក់ពាក្យសុំនៅគ្រប់ពេលវេលា ម២១៦ ម២១៧។
- ចៅក្រមត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដើម្បីផ្ដល់យោបល់។
- ចៅក្រមសម្រេចយ៉ាងយូរ ៥ ថ្ងៃបន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ម២១៥ ម២១៦ ម២១៧។
- ចៅក្រមជូនដំណឹងអំពីដីកាដល់ព្រះរាជអាជ្ញា និងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ២១៨។

# ការដោះលែងជនត្រូវចោទ

**មាត្រា ២១៧.–** ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជ-អាជ្ញាដើម្បីពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

-៧៧-

ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្ដងទៀត នៅចៅក្រមស៊ើបសួរ ឬ នៅសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្ដីសម្រេចបដិសេធពាក្យសុំលើកមុន ។ ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរ ត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្ដឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

# ការត្រួតពិនិត្យតាមផ្លូវតុលាការ

❖ **លក្ខខណ្ឌសារធាតុ៖** ម២២៣

- ❑ អនុវត្តចំពោះជនត្រូវចោទ (ម១២៦ ម១៤៣) ដែលនៅក្រៅឃុំ
- ❑ គ្រប់ពេលវេលា
- ❑ បទល្មើសចោទប្រកាន់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ៖ លើកលែងបទលហុពិន័យជាប្រាក់ (បរិហារកេរ្តិ៍ជាសាធារណៈ)
- ❑ មិនអាចអនុវត្តបានចំពោះអនីតិជនអាយុតិចជាង ១៤ ឆ្នាំ។
- ❑ កាតព្វកិច្ចមាន ១២ យ៉ាង៖

# ការត្រួតពិនិត្យតាមផ្លូវតុលាការ

| | |
|---|---|
| ១- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ | ៧- មិនត្រូវបើករថយន្ត |
| ២- មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាត | ៨- មិនត្រូវទទួល ឬជួបជាមួយបុគ្គលមួយចំនួន |
| ៣- មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ | ៩- ដាក់ប្រាក់ធានា |
| ៤- ត្រូវចូលបង្ហាញខ្លួននៅ OPJ | ១០- មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននៅអាវុធ ឬប្រគល់អាវុធឱ្យតុលាការ |
| ៥- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ | ១១- ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល |
| ៦- ប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ | ១២- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។ |
| *ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬ សកម្មភាពខាងសហជីព។* | |

# ការត្រួតពិនិត្យតាមផ្លូវតុលាការ

- អនីតិជន៖ ម៤០ ច្ប.អនីតិជន បន្ថែមកាតព្វកិច្ច ៤ ទៀត៖
  - ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីអាណាព្យាបាល
  - ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬ NGO
  - បង្គាប់មិនឱ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
  - វិធានការផ្សេងទៀត ដែលតុលាការយល់ឃើញថាសមស្រប។

# ការត្រួតពិនិត្យតាមផ្លូវតុលាការ

❖ **លក្ខខណ្ឌទម្រង់៖** ម២២៦

- ❑ចៅក្រម ឬព្រះរាជអាជ្ញា ជាអ្នកផ្តើមគំនិត។
- ❑ចិរវេលា អាចរហូតដល់ចប់ការស៊ើបសួរ ឬជំនុំជម្រះ
- ❑អាជ្ញាធរទទួលបន្ទុកអនុវត្ត។
- ❑ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទក្នុងរយៈពេលយ៉ាងខ្លីបំផុត។
- ❑ចៅក្រមមានរយៈពេល ៥ ថ្ងៃ ដើម្បីបដិសេធសំណើសុំ។
- ❑សភាស៊ើបសួរអាចសម្រេចជំនួសចៅក្រមស៊ើបសួរបាន។
- ❑ដីកាសម្រេចត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពអនុវត្តភ្លាមទេ ? បណ្តឹងឧទ្ធរណ៍ផ្អាកអានុភាពអនុវត្តរបស់ដីកាសម្រេចនេះទេ ?

# ការត្រួតពិនិត្យតាមផ្លូវតុលាការ

- ថៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបាន ឬបញ្ចប់គ្រប់ពេលវេលា ម២២៧។
- ព្រះរាជអាជ្ញា ឬជនត្រូវចោទ អាចស្នើសុំបាន។ ហើយចៅក្រមត្រូវសម្រេចយ៉ាងយូរ ៥ ថ្ងៃ។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ឬជនត្រូវចោទ។
- សភាស៊ើបសួរអាចសម្រេចជំនួស។

# ការត្រួតពិនិត្យតាមផ្លូវតុលាការ

❖ករណីគេចវេសពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នបានជាថ្មី ម២៣០។

❖ការឃុំខ្លួនករណីនេះគឺជាអញ្ញត្រកម្មទៅនឹង៖

- ❑មាត្រា ២០៤ បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើស ១ ឆ្នាំ។
- ❑មាត្រា ២០៨ - ម២១៤ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន (ទោះបីរយៈពេលឃុំខ្លួនបណ្ដោះអាសន្នបានប្រើប្រាស់អស់ក៏ដោយ)។ ថិរវេលាឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីនេះ មិនអាចលើសពី ៤ ខែ សម្រាប់នីតិជន និង ២ខែ សម្រាប់អនីតិជន។

# ការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះនីតិបុគ្គល

❖ម៦០១ ចៅក្រមស៊ើបសួរអាចដាក់នីតិបុគ្គលឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ចៅក្រមអាចប្រកាសនូវកាតព្វកិច្ចដូចតទៅ៖

- ❑ដាក់ប្រាក់ធានា ដោយកំណត់ចំនួន ថិរវេលានៃការបង់ និងបែបបទទាំងឡាយ
- ❑មិនត្រូវអនុវត្តសកម្មភាពវិជ្ជាជីវៈមួយចំនួន
- ❑ស្ថិតក្រោមការតាមដានរបស់តុលាការក្នុងថិរវេលាមិនលើសពី៦ ខែ។

❖សេចក្ដីសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបណ្ដាលឱ្យមានការចាត់តាំងអាណត្តិគាហកខាងតុលាការម្នាក់ ដែលមានបេសកកម្មត្រូវបានបញ្ជាក់ដោយចៅក្រមស៊ើបសួរ។

# ការជូនដំណឹងពិនិត្យការស៊ើបសួរ

- មង៤៦ កាលណាយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។
- មង៤៦៖ ព្រះរាជអាជ្ញា (ម១៣២) និងជនត្រូវចោទ(ម១៣៣) ឬ ដើមបណ្តឹងរដ្ឋប្បវេណី (ម១៣៤) អាចស្នើសុំឱ្យចៅក្រមបំពេញកិច្ចស៊ើបសួរថ្មីទៀត បើយល់ឃើញថាចាំបាច់។
- ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកាសន្និដ្ឋានស្ថាពរទៅចៅក្រមស៊ើបសួរវិញ ១៥ថ្ងៃ ករណីជនត្រូវចោទជាប់ឃុំខ្លួន និង ១ខែ ករណីនៅក្រៅឃុំ គិតពីពេលទទួលបានសំណុំរឿង។ ចុះករណីអញ្ញាតជន? ច្បាប់បាំងចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយ ដោយគ្មានដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា។
- **អ.វ.ត.ក** និងការអនុវត្តនៅតុលាការកម្ពុជា៖ ទោះបីជាគ្មានច្បាប់ចែងក៏ដោយ (មង៤៦) ក៏ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ចម្លើយតបបាន (សមភាពរវាងគូភាគី និងចំពោះមុខ)។

# ដីកាដំណោះស្រាយ

- មឲ២៤៧ថ្មី ក១ ដីកាដំណោះស្រាយគឺបិទបញ្ចប់ការស៊ើបសួរ។
- ដីកាដំណោះស្រាយដកហូតសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។
- មឲ២៤៧ថ្មី ក១ ក៣ ដីកាដំណោះស្រាយ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ (ទាំងមូល ឬ មួយផ្នែក) ឬដីកាលើកលែងការចោទប្រកាន់ (ទាំងមូល ឬ មួយផ្នែក)។
- **ដីកាបញ្ជូនទៅជំនុំជម្រះ៖** មឲ២៤៧ថ្មី ក២ បើជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ មានតែជនត្រូវចោទទេ ទើបអាចត្រូវបានបញ្ជូនទៅជំនុំជម្រះ។

# ដីកាដំណោះស្រាយ

❖ **ដីកាសម្រេចលើកលែងការចោទប្រកាន់៖**

- ❑អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ មជ្ឈិម ឬលហុ ម២៤៧ថ្មី ក៣ ។
- ❑ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ម២៤៧ថ្មី ក៣ ។
- ❑គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ម២៤៧ថ្មី ក៣។
- ❑ករណីដែលបណ្តឹងអាជ្ញារលត់ ម២៤៧ថ្មី ក៣ ។
- ❑ករណីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ?

# ដីកាដំណោះស្រាយ

- **សហចៅក្រមស៊ើបអង្កេត** នៃ **អ.វ.ត.ក** សម្រេចលើកលែងការចោទប្រកាន់ដោយមូលហេតុតុលាការ **<u>ខ្វះយុត្តាធិការបុគ្គល</u>**លើ **អ៊ឹម ចែម**។ **យឹម ទិត្យ** និង **អោ អាន** មានដីកាដំណោះស្រាយលើកលែងចោទប្រកាន់ (ខ្វះយុត្តាធិការបុគ្គល)ផង និងបញ្ជូនទៅជំនុំជម្រះផង។ បញ្ហាយុត្តាធិការគឺជាវិធានអាជ្ញាបញ្ញា ដែលតុលាការត្រូវពិនិត្យមុនគេ។
- ក្នុងការអនុវត្ត៖ តុលាការសម្រេចលើកលែងការចោទប្រកាន់លើបទហិង្សាក្នុងគ្រួសារប្រសិនបើមានសំណើពីជនរងគ្រោះជានីតិជន ក្នុងករណីបទលហុ ឬមជ្ឈិមស្រាល។ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះម៣៦៖ *ការចោទប្រកាន់ជាបទល្មើសពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសជាបទមជ្ឈិមស្រាល ឬ បទលហុ*។ ការមិនអាចចោទប្រកាន់បានអាចជាមូលហេតុនៃដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ទេ?

# ដីកាដំណោះស្រាយ

- ច្ប.យុត្តិធម៌អនីតិជន៖
  - ម៣៨ ក៣ តម្រូវឱ្យចៅក្រមត្រូវតែចេញដីកាសម្រេចលើកលែងការចោទប្រកាន់ករណីនីតិវិធីបង្វែរទទួលបានជោគជ័យ ទោះបីជាបានប្រព្រឹត្តបទល្មើស។ ជនរងគ្រោះឬ អ្នកតំណាងស្របច្បាប់អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ចាប់តាំងពីការផ្ដើមនីតិវិធីបង្វែរនិងផ្អាកនីតិវិធីការស៊ើបសួរ។
  - ម ៣៩ ក៣ ករណីអនីតិជនត្រូវបានរកឃើញថាមានអាយុក្រោម ១៤ ឆ្នាំ តម្រូវឱ្យចៅក្រមត្រូវតែចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ទោះបីជាបានប្រព្រឹត្តបទល្មើស។ ជនគ្រោះឬ អ្នកតំណាងស្របច្បាប់អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។

# ដីកាដំណោះស្រាយ

- ដីកាដំណោះស្រាយ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ម២៤៧ថ្មី ក៦។

- ករណីលើកលែងការចោទប្រកាន់ ដោយមូលហេតុអត្តសញ្ញាណរបស់បុគ្គលមិនត្រូវបានស្គាល់ ឬក្នុងករណីជននោះមរណភាព ចៅក្រមស៊ើបសួរត្រូវប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើស ម២៤៧ថ្មី ក៧។

# ដីកាដំណោះស្រាយ

- មប២៤៧ថ្មី ក៥ កាលណាអង្គហេតុច្រើន ចៅក្រមអាចចេញដីកា ដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរអង្គហេតុផ្សេងទៀត។ (ដីកាសម្រេចបំបែកសំណុំរឿង)

- មប២៤៧ថ្មី ក៥ ករណីជនត្រូវចោទមិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្ត បទល្មើស ចៅក្រមលើកលែងការចោទប្រកាន់។ ករណីជនសង្ស័យ? ករណីនៅសាលាក្តីខ្មែរក្រហម និងតុលាការបារាំង ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយលើកលើងការចោទប្រកាន់លើជនសង្ស័យដែលរងបណ្តឹងពីព្រះរាជអាជ្ញា ទោះបីជាជននេះមិនមែនជនជាប់ចោទក៏ដោយ (ជាការអនុវត្តនូវគោលការណ៍សច្ចធារណ៍នៃនិរទោស)។

# ដីកាដំណោះស្រាយ

- ដីកាដំណោះស្រាយលើកលែងចោទប្រកាន់៖ ការលើកលែងចោទប្រកាន់ #ការសម្រេចឱ្យរួចខ្លួន
  - ប្រសិនបើជាដីកាដំណោះស្រាយលើកលែងចោទប្រកាន់ដោយផ្អែកលើ**<u>អង្គហេតុ</u>** នោះដីកាដំណោះស្រាយនេះមានអាជ្ញាអស់ជំនុំដោយអន្លើ (តែចំពោះបុគ្គលដែលទទួលផលប្រយោជន៍) និងបណ្តោះអាសន្ន ព្រោះអាចបើកស៊ើបសួរឡើងវិញតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ម២៥១ (មុខចៅក្រមស៊ើបសួរ) ម២៦៥ (មុខសភាស៊ើបសួរ) ក្រម។ ឧ. ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ដោយមូលហេតុ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ឬ ជនដែលប្រព្រឹត្តបទល្មើសនោះនៅតែគេមិនស្គាល់ ម២៤៧ ថ្មី។

# ដីកាដំណោះស្រាយ

- ប្រសិនបើជាដីកាដំណោះស្រាយលើកលែងចោទប្រកាន់ដោយផ្អែកលើ**<u>អង្គច្បាប់</u>** នោះដីកាដំណោះស្រាយនេះមានអាជ្ញាអស់ជំនុំដាច់ខាត (គ្រប់បុគ្គលទាំងអស់អាចលើកឡើងបាន) និងអចិន្ត្រៃយ៍។ ឧ. ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ដោយមូលហេតុ ការលើកលែងទោសជាទូទៅ អាជ្ញាយុកាល អំពើមិនបង្កើតជាបទល្មើស ម២៤៧ថ្មី ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ អាចមានផងដែរមូលហេតុការខ្វះយុត្តាធិការបុគ្គល។

# អានុភាពនៃដីកាដំណោះស្រាយ

- មប៤៩ ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន លើកលែងមានសេចក្តីសម្រេចផ្សេងដែលអាចពន្យាពេលឃុំខ្លួនបាន ៤ ខែ រហូតដល់ពេលសវនាការ។
- មប៤៩ ដីកាដំណោះស្រាយបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ លើកលែងមានសេចក្តីសម្រេចផ្សេងដែលពន្យាពេលរហូតដល់ពេលសវនាការ។
- ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់អនីតិជន នាំឱ្យមានការដោះលែងអនីតិជននោះ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ម៤២ ក២ ច្បា.យុត្តិធម៌អនីតិជន។

# អានុភាពនៃដីកាដំណោះស្រាយ

- ម២៥៦ ដីកាដំណោះស្រាយស្តាពរលុបលាងមោឃភាពនៃកិច្ចនីតិវិធី ដោយមិនអាចលើកឡើងអំពីមោឃភាពនៅចំពោះមុខតុលាការជំនុំជម្រះទៀតបានឡើយ។
- ដីកាបង្គាប់ឱ្យចាប់ខ្លួនអស់អានុភាព ឬ នៅបន្តទៀត? ម១៧៩ ក២ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង នៅពេលមានដីកាដំណោះស្រាយ នោះដីកាបង្គាប់ឱ្យចាប់ខ្លួននៅមានអានុភាពអនុវត្តដដែល។ ការអនុវត្តនៅកម្ពុជា ដីកានេះនៅមានអានុភាពអនុវត្តរហូតដល់ដំណាក់កាលជំនុំជម្រះ។
- ម១៧៩ ក២ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង នៅពេលមានដីកាដំណោះស្រាយ នោះដីកាស្រាវជ្រាវ និងដីកាបង្គាប់ឱ្យនាំខ្លួនបញ្ឈប់អានុភាព។

# ជំពូកទី២

## សត្វាស៊ើបសួរ ( សាលាឧទ្ធរណ៍ )

# សភាស៊ើបសួរ



សភាព្រហ្មទណ្ឌនៃតុលាការកំពូល
សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
ចៅក្រមស៊ើបសួរ
បទល្មើស
ការស៊ើបសួរ
ការស៊ើបអង្កេត
(ព្រះរាជអាជ្ញា)
ការជំនុំជម្រះ

# សភាស៊ើបសួរ

- សមត្ថកិច្ចក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។
- សមត្ថកិច្ចក្នុងការជំនុំជម្រះលើពាក្យប្តឹងសុំមោឃភាពកិច្ច ឬលិខិតនៃនីតិវិធី។
- ដីកាសម្រេចដែលអាចប្តឹងឧទ្ធរណ៍បាន មិនអាចប្តឹងមោឃភាពបានឡើយ ម២៥៣ ក៦។

# ផ្នែកទី១

## បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

❖ **ដីកាសម្រេចដែលអាចរងបណ្តឹងឧទ្ធរណ៍ (ដែលមានចែងក្នុងក្រម)៖**

- ❑ម២៦៦ ទទួលបណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការប្រឆាំងនឹង**គ្រប់ដីកាសម្រេច**របស់ចៅក្រមស៊ើបសួរ។ តើដីកាសម្រេចទាំងនោះមានអ្វីខ្លះ?
- ❑ម២៦៧ បណ្តឹងឧទ្ធរណ៍ដោយជនត្រូវចោទ (មានកំណត់)។
- ❑ម២៦៨ បណ្តឹងឧទ្ធរណ៍ដោយដើមបណ្តឹងរដ្ឋប្បវេណី (មានកំណត់)។
- ❑ម១៦១ បណ្តឹងសុំប្រគល់វត្ថុដែលចាប់យកនៅពេលស៊ើបសួរ អ្នកសុំមិនអាចប្តឹងឧទ្ធរណ៍បានទេ។
- ❑ម២៦៩ បណ្តឹងសុំប្រគល់វត្ថុដែលចាប់យកនៅពេលចេញដីកាដំណោះស្រាយ អ្នកសុំប្រគល់វត្ថុអាចប្តឹងឧទ្ធរណ៍បាន។

# បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

**មាត្រា ២៦៧.-** បណ្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ

ជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ :

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៣ (ការស្នើសុំឱ្យបំពេញកិច្ចដេះឃជនត្រូវចោទ)

-ដីកាមិនព្រមប្រគល់វត្ថុដែលចាប់ឱ្យទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសល្លវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសល្លវិច័យ;

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ សុំឱ្យធ្វើប្រតិកោសលវិច័យដូចដែលមានចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០ (ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ) និង

-ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចដែលមានចែងក្នុងផ្នែកទី ៥ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងផ្នែកទី ៧ ស្តីពីការត្រួតពិនិត្យតាមផ្លូវតុ-លាការនៃជំពូកទី ៣ ស្តីពីវិធានការនិរន្តរាយ ក្នុងមាតិកាទី ១ នៃគន្ថីនេះ និង មាត្រា ២៤៩ (សេច-ក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ ។

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

**មាត្រា ២៦៨.-** បណ្តឹងឧទ្ធរណ៍ចំពោះដីកាបេស់ចៅក្រមស៊ើបសួរ ដោយដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ :

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៤ (ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី)

-ដីកាមិនព្រមស៊ើបសួរដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា)

-ដីកាកំណត់ចំនួនប្រាក់កក់ ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក)

-ដីកាប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

-ដីកាផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងមាត្រា ១៩១ (បណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលា)

-ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យក ទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ សុំឱ្យធ្វើប្រតិកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០ (ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ)

-ដីកាដំណោះស្រាយដូចដែលមានចែងក្នុងមាត្រា ២៤៧ (ដីកាដំណោះស្រាយ)នៃក្រមនេះ ។

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

- **ដីកាសម្រេចដែលអាចរងបណ្តឹងឧទ្ធរណ៍ (ដែលគ្មានចែងក្នុងក្រម)៖**
  - ច្បា.អនីតិជន ដីកាសម្រេចបង្វែរបស់ចៅក្រមស៊ើបសួរ ម៤៣ និង ដីកាសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ម៣៨ ក១។ ជនជាប់ចោទ ឬជនរងគ្រោះ ឬព្រះរាជអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍ដែរឬទេ?
  - ដីកាសម្រេចបង្កកទ្រព្យសម្បត្តិ ម៩០ ច្បា.ត្រួតពិនិត្យគ្រឿងញៀន ម៣១ ច្បា.ប្រឆាំងការសម្អាតប្រាក់ និង ម៤ ម៥ ច្បា. ប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយអាវុធប្រល័យលោក។ ជនជាប់ចោទ ឬជនរងគ្រោះ មានសិទ្ធិប្តឹងឧទ្ធរណ៍ដែរឬទេ?

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

- ច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកឆ្នាំ២០២៥ ម៧។ (អាចប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ)។
- ដីកាសម្រេចបដិសេធមិនបើកទីតាំងដែលត្រូវឆែរឆេរនិងសម្រេចបិទទីតាំងណាមួយនៅដំណាក់កាលស៊ើបអង្កេត?
- ម៨៧ ច្បាប់ត្រួតពិនិត្យគ្រឿងញៀន សេចក្តីសម្រេចបិទគ្រឹះស្ថានអាជីវកម្មលើគ្រឹះស្ថានជាបណ្តោះអាសន្ន អាចធ្វើឡើងសម្រាប់រយៈពេលយ៉ាងយូរ ៦ ខែ យ៉ាងច្រើន។ សេចក្តីសម្រេចនេះត្រូវយកទៅអនុវត្តភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។

# បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

- **ម២៧០ រយៈប្ដឹងឧទ្ធរណ៍៖**
  - អគ្គព្រះរាជអាជ្ញា៖ ១ ខែ គិតពីពេលប្រកាសដីកា
  - ព្រះរាជអាជ្ញា៖ ៥ ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកា
  - ដើមបណ្ដឹងរដ្ឋប្បវេណី ជនត្រូវចោទ និងបុគ្គលតាម ម២៦៩៖ ៥ ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកា។
- **ទីកន្លែងប្ដឹង៖** ម២៧២ អាចប្ដឹងនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង (បច្ចុប្បន្នត្រូវ ប្ដឹងនោះលេខាធិការដ្ឋានសាលាដំបូង) ឬ ម២៥៧ អាចប្ដឹងដោយផ្ទាល់នៅសភាស៊ើបសួរ។

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

## ❖អានុភាពជារួមនៃបណ្តឹងឧទ្ធរណ៍៖

❑**អានុភាពផ្អាក**ការអនុវត្តសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ **លើកលែងតែ (ការអនុវត្តភ្លាម ឬបណ្តោះអាសន្ន)៖**

- ➢ការដោះលែងអនីតិជននៅក្រៅឃុំ ដោយសារអាយុក្រោម ១៤ ឆ្នាំ ម៣៩ ក៣ និងករណីបន្ទាន់ ម៤១ ក១ ព្រមទាំងករណីចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ម៤២ ក២ ច្ប.អនីតិជន ។
- ➢ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ម២០៦។
- ➢ដីកាសម្រេចដាក់កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ជាដើម មានអានុភាពអនុវត្តភ្លាម ឬ ផ្អាកដោយបណ្តឹងឧទ្ធរណ៍ ?

# បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

- ម២៧៦ ករណីចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទ៖
  - ជននោះត្រូវរក្សាទុកក្នុងពន្ធនាគាររហូតផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា (លើកលែងព្រះរាជអាជ្ញាយល់ព្រមម២៧៦ និងករណីអនីតិជន គឺទី១ការសម្រេចដោះលែងភ្លាម ម៤១ ក១ និងទី២ ដីកាដំណោះស្រាយលើកលែងចោទប្រកាន់ដែលបណ្តាលឱ្យមានការដោះលែងភ្លាម ម៤២ ក២ ច្ប. យុត្តិធម៌អនីតិជន)។
  - បើមានបណ្តឹងឧទ្ធរណ៍ ជននោះត្រូវរក្សទុកក្នុងពន្ធនាគាររហូតដល់សភាស៊ើបសួរសម្រេចអំពីបណ្តឹងឧទ្ធរណ៍។ ម២៧៨ ករណីបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន សភាស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរ។
- ម៨៧ ច្បាប់ត្រួតពិនិត្យគ្រឿងញៀន ការបិទគ្រឹះស្ថានអាជីវកម្មលើគ្រឹះស្ថានជាបណ្តោះអាសន្ន អាចធ្វើឡើងសម្រាប់រយៈពេលយ៉ាងយូរ ៦ ខែ យ៉ាងច្រើន។ សេចក្តីសម្រេចនេះត្រូវយកទៅអនុវត្តភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។

# បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

- ទោះបីជាមាន**អានុភាពផ្អាក** ក៏ប៉ុន្តែការសើុបសួរនៅតែបន្ត។ ម២៧៥ **<u>បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច</u>** ណាមួយ (ក្រៅពីដីកាដំណោះស្រាយ) ចៅក្រមសើុបសួរអាចបន្តការសើុបសួររបស់ខ្លួន លើកលែងការសម្រេចផ្សេងរបស់ប្រធានសភាសើុបសួរ។ ម២៧៧ ម២៨១ ប្រសិនបើជាដីកាលើកលែងការចោទប្រកាន់ (ដីកាដំណោះស្រាយដកហូតសមត្ថកិច្ចរបស់ចៅក្រមសើុបសួរ) សភាសើុបសួរត្រូវបន្តការសើុបសួរដោយខ្លួនឯងលើរឿងនោះ ក្រោយពីសម្រេចរួច។

# បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

- **អានុភាពផ្ទេរ**ការស៊ើបសួរ ម២៧១ ម២៧៥។ សភាស៊ើបសួរជាអ្នកមានសមត្ថកិច្ចសម្រេច។ ហើយកិច្ចណាមួយដែលរងបណ្ដឹងឧទ្ធរណ៍ នោះចៅក្រមស៊ើបសួរលែងមានសិទ្ធិសម្រេចទៀតហើយ ( ***វិធានកម្មវត្ថុតែមួយនៃបណ្ដឹងឧទ្ធរណ៍*** l'unique objet de l'appel )។
  - ដោយឡែក ម២៦៨ បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ គឺជាការប្ដឹងទៅសភាស៊ើបសួរនូវបណ្ដឹងរដ្ឋប្បវេណី និងបណ្ដឹងអាជ្ញាផងដែរ ទោះបីមិនមានបណ្ដឹងពីព្រះរាជអាជ្ញាក៏ដោយ។

# អំណាចផ្សេងទៀត

- សភាស៊ើបសួរមានអំណាចពន្លាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដល់បទល្មើសដែលទាក់ទង (ពេលវេលា ការព្រមព្រៀងគ្នា ឬចំណងរវាងអង្គហេតុចំបងនិងបន្ទាប់បន្សំ) ម២៦៣ និងបុគ្គលដែលទាក់ទង ម២៦៤ (លើកលែងមានអាជ្ញាអស់ជំនុំ) ទោះបីជាគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។
- សភាស៊ើបសួរមានអំណាច**<u>សម្រេចជំនួស</u>**ចៅក្រមស៊ើបសួរ (មិនមានបណ្តឹងឧទ្ធរណ៍)៖
  - សភាស៊ើបសួរមានសិទ្ធិសម្រេចជំនួស ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃគិតពីថ្ងៃទទួលពាក្យសុំ ម៧ ច្បាប់ស្តីពីការចាត់ចែងបណ្តោះអាសន្នលើវត្ថុចាប់យក។
  - ពាក្យសុំនៅក្រៅឃុំរបស់ជនជាប់ចោទ សភាស៊ើបសួរអាចសម្រេចជំនួស ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃគិតពីថ្ងៃទទួលពាក្យសុំ ម២១៧។
  - សភាស៊ើបសួរសម្រេចជំនួសផងដែរ ម១៣២ ម១៣៣ ម១៣៤ ម២២៨។

# មុនការពិភាក្សាដេញដោល

- ការជូនដំណឹង៖ ម២៥៨ ក្រោយទទួលសំណុំរឿងដែលល្មមជំនុំជម្រះបាន ប្រធានសភាស៊ើបសួរជូនដំណឹងដោយផ្ទាល់មាត់ទៅអគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃការបើកសវនាការ។ អគ្គព្រះរាជអាជ្ញាជូនដំណឹងបន្តដល់គូភាគី និងមេធាវី។
  - ការជូនដំណឹងដល់ជនត្រូវចោទដែលជាប់ឃុំ អាចផ្ទាល់មាត់ ឬតាមរយៈប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន បើនៅក្រៅឃុំ ធ្វើឡើងផ្ទាល់មាត់ ឬតាមរយៈប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន ឬកងរាជអាវុធហត្ថ ឬអង្គភាពនគរបាល។

# មុនការពិភាក្សាដេញដោល

- ការពិនិត្យសំណុំរឿងនិងសារណា៖ ម២៥៩ អគ្គព្រះរាជអាជ្ញា និងមេធាវី អាចពិនិត្យមើលសំណុំរឿង។

- សារណា៖ ម២៥៩ អគ្គព្រះរាជអាជ្ញា ត្រូវប្រគល់សារណាយោះ◌ាងយូរបំផុត ១ ថ្ងៃមុនសវនាការ។ ចំណែកឯ គូភាគី និងមេធាវី អាចប្រគល់សារណាហើយក្រឡាបញ្ជីចុះទិដ្ឋាការ។ សារណាអាចប្រគល់ជូនរហូតដល់ពេលចាប់ផ្តើមបើកសវនាការ។

# ការពិភាក្សាដេញដោល

❖ ដំណើរការនៃកិច្ចពិភាក្សាដេញដោល ម២៦០៖

- ការពិភាក្សាដេញដោលត្រូវធ្វើក្នុងបន្ទប់ពិភាក្សា (ខុសពីសាលសវនាការ?) (អសាធារណៈ?)។
- ប្រធានសភាស៊ើបសួរអានរបាយការណ៍ រួចអគ្គព្រះរាជអាជ្ញា មេធាវីរបស់គូភាគី ធ្វើការកត់សម្គាល់ដោយសង្ខេប។
- ប្រធានសភាស៊ើបសួរអាចបង្គាប់ឱ្យគូភាគីចូលមកបង្ហាញខ្លួន និងផ្ដល់ភស្ដុតាង។
- សភាស៊ើបសួរធ្វើការពិគ្រោះសម្រេចដោយគ្មានវត្តមានរបស់អគ្គព្រះរាជអាជ្ញា គូភាគី និងមេធាវី។
- **សាលដីកាត្រូវប្រកាសជាអសាធារណៈ** រួចជូនដំណឹងដោយផ្ទាល់មាត់ក្នុងរយៈពេលខ្លីបំផុតដល់អគ្គព្រះរាជអាជ្ញា និងជូនដំណឹងដល់គូភាគី និងមេធាវី។

# ជំពូកទី២

## មោឃភាពនៃកិច្ចនីតិវិធី

# មោឃភាពនៃកិច្ចនីតិវិធី

- មព្វ៧៩ ភាពមិនអាចទទួលយកបាននៃពាក្យប្តឹងសុំ**<u>មោឃភាព</u>**៖
  - ពាក្យប្តឹងសុំគ្មានសំអាងហេតុ
  - ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍បាន
  - ពាក្យប្តឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្តែង។
  - អ្នកដែលអាចប្តឹងសុំមោឃភាពបាន៖ ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ម២៥៣ និងសភាស៊ើបដោយឯកឯង ម២៦១។
  - ដីកាសម្រេចដែលអាចប្តឹងឧទ្ធរណ៍បាន មិនអាចប្តឹងមោឃភាពបានឡើយ ម២៥៣ ក៦។

# មោឃភាពនៃកិច្ចនីតិវិធី

- មព២៨០ អានុភាពនៃមោឃកម្មៈ
  - មោឃកម្មលើកិច្ច ឬលិខិតនៃនីតិវិធីដែលប្ដឹងសុំ។
  - និងអាចមោឃកម្មទៅលើកិច្ច ឬ លិខិតនៃនីតិវិធីផ្សេងទៀត
  - កិច្ច ឬលិខិត ដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង។

# ហេតុភាពនៃកិច្ចនីតិវិធី

- មម២៨១ ក្រោយធ្វើមោឃកម្មរួច សភាស៊ើបសួរអាចៈ
  - ❑បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ
  - ❑ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ឱ្យចៅក្រមស៊ើបសួរម្នាក់ទៀត
  - ❑បន្តការស៊ើបសួរដោយខ្លួនឯង (មម២៨២)។
- ការពិភាក្សាដេញដោលនិងប្រកាសសាលដីកាគឺដូចគ្នានឹងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច។

# អំណាចរបស់ប្រធានសភាស៊ើបសួរ

- មម២៨៣ រ៉ាប់រងលើការប្រព្រឹត្តទៅដ៏ល្អនៃមន្ទីរស៊ើបសួរ និងកុំឱ្យនីតិវិធីយឺតយ៉ាវ។
- អំណាចចុះធ្វើអធិការកិច្ច។
- អំណាចអធិបញ្ជាដល់ចៅក្រមស៊ើបសួរឱ្យបិទសំណុំរឿង។

# ភាគទី៥

## ការជំនុំជម្រះ

# គំនូសបំព្រួញនីតិវិធីព្រហ្មទណ្ឌ



# សាលសវនាការព្រហ្មទណ្ឌ



@រូបភាពពីមេធាវីស្ត្រីខ្មែរ

# សាលសវនាការព្រហ្មទណ្ឌ




@ រូបភាពពី អ.វ.ត.ក

# ការជំនុំជម្រះ

❖ ជំពូកទី១ ការជំនុំជម្រះនៅសាលាដំបូង
 - ❑ ផ្នែកទី១ ការជំនុំជម្រះដំបូង
 - ❑ ផ្នែកទី២ បណ្ដឹងទាស់នឹងសាលក្រមកំបាំងមុខ

❖ ជំពូកទី២ ការជំនុំជម្រះនៅសាលាឧទ្ធរណ៍
 - ❑ ផ្នែកទី១ បណ្ដឹងឧទ្ធរណ៍
 - ❑ ផ្នែកទី២ បណ្ដឹងទាស់នឹងសាលដីកាកំបាំងមុខ

❖ ជំពូកទី៣ ការជំនុំជម្រះនៅតុលាការកំពូល

# ការជំនុំជម្រះ

ព្រះរាជអាជ្ញា (CI និង CD) និង យុត្តាធិការស៊ើបសួរ

-ជនល្មើស
-អំពើល្មើស

ចៅក្រមជំនុំជម្រះ

NB: *បញ្ជូនទៅជំនុំជម្រះបាន គឺ ត្រូវមានជនល្មើស (អ្នកទទួលខុសត្រូវព្រហ្មទណ្ឌ) និងអំពើល្មើស លើកលែង ករណីបញ្ជូនរឹបអូសវត្ថុតាងករណីជនល្មើសមរណភាព ឬមិនត្រូវបានគេស្គាល់ ម២៤៧ថ្មី និង ម៩៦ ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។*

# ការជំនុំជម្រះ

- ការជំនុំជម្រះគឺជាកិច្ចកាត់សេចក្ដីតាមរយៈការពិនិត្យមើលលើរឿងក្ដីដោយផ្ដល់នូវដំណោះស្រាយ បន្ទាប់ពីបានធ្វើការសាកសួរ និងការពិភាក្សាដេញដោល។ (Gérald Cornu, puf 7ème edition 2005)

# គោលដៅដែលត្រូវជំនុំជម្រះ

ម២៤ ម៩៦ ក្រមព្រហ្មទណ្ឌ

ម១ ម២ ក្រមនីតិវិធីព្រហ្មទណ្ឌ



# គោលដៅដែលត្រូវជំនុំជម្រះ

**ម២៤ ម៩៦ ក្រមព្រហ្មទណ្ឌ**

**ម១ ម២ ក្រមនីតិវិធីព្រហ្មទណ្ឌ**

- **ពិរុទ្ធភាព ទោស និងសំណង ម២**
  - ច្បាប់ (កំណត់បទល្មើស ទោស សំណង) (មិនមែនជាកម្មវត្ថុនៃការស៊ើបអង្កេត)
    - ច្បាប់ច្បាស់
    - បើច្បាប់មិនច្បាស់ ចៅក្រមត្រូវបកស្រាយ
      - ច្បាប់មិនច្បាស់មិនមែនជាវិមតិសង្ស័យនោះទេ
  - ជនល្មើស
    - ផ្នែកបុគ្គល
      - -បុគ្គលិកលក្ខណៈ
      - -ស្ថានភាពគ្រួសារ
      - -ស្ថានភាពសង្គម
    - ផ្នែកបេតិកភណ្ឌ
      - -ធនធាន
      - -បន្ទុក
  - អំពើល្មើស
    - ធាតុផ្សំនៃបទល្មើស
      - -ធាតុអត្តនោម័ត
      - -ធាតុសត្យានុម័ត

# ជំពូកទី១

## ការជំនុំជម្រះនៅសាលាដំបូង

# ផ្នែកទី១

## ការជំនុំជម្រះដំបូង

# ការរៀបចំតុលាការជំនុំជម្រះ

- ភាពមិនលំអៀង និងការបែងចែកមុខងារស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ។ (គោលការណ៍នៃការបែងចែកមុខងាររវាងការចោទប្រកាន់ និងការជំនុំជម្រះ)។

- ម២៨៨ ក២៖ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ឬ ជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ។

# ការរៀបចំគូលាការជំនុំជម្រះ

- សមាសភាពជំនុំជម្រះករណី **នីតិជន** ម២៨៩ ម៣៤៨៖
  - ចៅក្រម ៣ រូប <u>ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង នឹងបទឧក្រិដ្ឋ</u>។
  - ចៅក្រមទោល ចំពោះ បទមជ្ឈិម និងលហុ។
- សមាសភាពជំនុំជម្រះករណី **អនីតិជន** ម៤៤ ច្ប.អនីតិជន៖
  - ចៅក្រម ៣ រូប <u>ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង នឹងបទឧក្រិដ្ឋ</u> និង បទមជ្ឈិម
  - ចៅក្រមទោល ចំពោះ បទលហុ។
- សមាសភាពជំនុំជម្រះករណីនីតិបុគ្គល ?

# ការរៀបចំតុលាការជំនុំជម្រះ

- **ករណីជនល្មើសជារូបវន្តបុគ្គល៖** ម២៩០
  - តុលាការនៃទីកន្លែងប្រព្រឹត្តបទល្មើស
  - តុលាការនៃលំនៅដ្ឋានរបស់ជនជាប់ចោទ ឬ
  - តុលាការនៃទីកន្លែងចាប់ខ្លួនជនជាប់ចោទ
  - ករណីវិវាទសមត្ថកិច្ច តុលាការជាន់ខ្ពស់ជាអ្នកសម្រេច៖ អាចជាសាលាឧទ្ធរណ៍ ឬតុលាការកំពូល។

- **ករណីនីតិបុគ្គល៖** ម៥៩៧
  - តុលាការនៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
  - តុលាការនៃទីកន្លែងដែលនីតិបុគ្គលតាំងទីស្នាក់ការ។

# លក្ខណៈជាមូលដ្ឋាននៃសវនាការ

- សាធារណៈភាពនៃសវនាការនិងការដឹកនាំសវនាការ ម៣១៦-ម៣២០ (adversarial)
- ការពិភាក្សាដេញដោលដោយផ្ទាល់មាត់ ម៣២៣-ម៣៣៦ (adversarial)
- ការបង្ហាញខ្លួនដោយផ្ទាល់ខ្លួនរបស់គូភាគី ម៣០០-ម៣១០ (adversarial)
- ការមិនអាចផ្លាស់ប្តូរបាននូវចំណុចវិវាទ ម៣៤៨ ( saisine *in rem* ) រួមទាំងមិនអាច ផ្លាស់ប្តូរជនជាប់ចោទបាន ម៣៤៩
- ការមិនអាចបញ្ឈប់ដំណើរការក្តី (អាចបង្អង់បាន ម៣៤២) ដោយតុលាការមានកាតព្វកិច្ចផ្អែកលទ្ធផល គឺជម្រះរឿងក្តីឱ្យជ្រះស្រឡះ។

# ការប្ដឹងទៅចៅក្រមជំនុំជម្រះក្ដី ម២៩១

## ❖ករណីមានការស៊ើបសួរ

- ❑ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះដោយចៅក្រមស៊ើបសួរ ឬសាលដីកាដោយសភាស៊ើបសួរ។ មើលមាត្រា២៤៧ ថ្មី ផងដែរ បញ្ជូនវត្ថុតាង និងទ្រព្យសម្បត្តិទៅជំនុំជម្រះ។
- ❑ម១៤២ បណ្ដឹងទាមទារឱ្យជួសជុលការខូចខាត នៅពេលការស៊ើបសួរត្រូវបានបើកដោយការប្ដឹងសុំតាំងខ្លួនជាដើម  បណ្ដឹងរដ្ឋប្បវេណីត្រូវបានបិទដោយការលើកលែងការចោទប្រកាន់ជាស្ថាពរ។

# ការប្តឹងទៅចៅក្រមជំនុំជម្រះក្តី ម២៩១

❖ករណីគ្មានការស៊ើបសួរ (បញ្ជូនមកផ្ទាល់ដោយអយ្យការ)

- ❑កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម (CI)
- ❑ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់ (CD)
- ❑ការបញ្ជូនទៅតុលាការព្រហ្មទណ្ឌដើម្បីរឹបអូសទ្រព្យសម្បត្តិ ក្នុងករណីការចោទប្រកាន់មិនអាចធ្វើបាន ដោយសារមរណភាពនៃជនល្មើស ម៩៦ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។
- ❑ករណីមាត្រា ៣២០ តុលាការជំនុំជម្រះជនល្មើសដែលប្រព្រឹត្តបទល្មើសក្នុងពេលសវនាការភ្លាម ប្រសិនបើព្រះរាជអាជ្ញាប្តឹងសុំ និងប្រសិនបើជនល្មើសយល់ព្រម។

# គំនូសបំព្រួញ

## ការបញ្ជូនមកជំនុំជម្រះដោយចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ

បទល្មើស

ការស៊ើបអង្កេត
(ព្រះរាជអាជ្ញា)

ដីកាសន្និដ្ឋាន
បញ្ជូនរឿងឱ្យ
ស៊ើបសួរ

ការស៊ើបសួរ
(ចៅក្រមស៊ើបសួរ
ឬ សភាស៊ើបសួរ)

ការជំនុំជម្រះ
(ចៅក្រម
ជំនុំជម្រះ)

សាលក្រម

# គំនូសបំព្រួញ

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ម៤៦



# គំនូសបំព្រួញ

## នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម ម៤៧-ម៤៨

- បទល្មើស
- ការស៊ើបអង្កេត (ព្រះរាជអាជ្ញា)
- កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាម
- ការជំនុំជម្រះ (ចៅក្រមជំនុំជម្រះ) សាលក្រម

# គំនូសបំព្រួញ

រឹបអូសទ្រព្យសម្បត្តិ ករណីមរណភាពនៃជនល្មើស
ម៩៦ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- បទល្មើស
- ការស៊ើបអង្កេត (ព្រះរាជអាជ្ញា)
- ប្ដឹងសុំរឹបអូសទ្រព្យសម្បត្តិ ដោយសារមរណភាពនៃជនល្មើសក្នុងបទល្មើសគ្រឿងញៀន
- ការជំនុំជម្រះ (ចៅក្រមជំនុំជម្រះ) សាលក្រម

# វិបាកនៃការប្ដឹង

❖ **ទៅលើបុគ្គល៖**

- មាត្រា៣៤៩៖ តុលាការអាចជំនុំជម្រះបុគ្គលដែលបញ្ជូនទៅមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ (មាត្រា៤៣ ការចោទប្រកាន់)។ បើមានលេចតម្រុយពិរុទ្ធភាពលើសាក្សី បុគ្គលនោះអាចនឹងត្រូវជំនុំជម្រះក្រោយពីត្រូវបានចោទប្រកាន់។
- មានន័យថា គេអាចជំនុំជម្រះលើបុគ្គលណាម្នាក់បាន លុះត្រាតែបុគ្គលណាមានបណ្ដឹងអាជ្ញាប្រឆាំងនឹងជននោះតែប៉ុណ្ណោះ។ មិនអាចមានការដោះដូរអ្នកទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។

# វិបាកនៃការប្តឹង

**មាត្រា ៣៤៩.–** ផែននៃការប្ដឹងទៅតុលាការចំពោះបុគ្គល

តុលាការអាចផាកពិន័យបុគ្គលដែលបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ ។

ប្រសិនបើបុគ្គលណាដែលកោះហៅឱ្យចូលទៅចំពោះមុខតុលាការក្នុងឋានៈជាសាក្សី អាចត្រូវចោទប្រកាន់ក្នុងឋានៈជាជនដែលល់ ឬ អ្នកសមគំនិត បុគ្គលនោះនឹងអាចត្រូវផាកពិន័យបានក្រោយពីត្រូវបានចោទប្រកាន់ដូចមានចែងនៅមាត្រា ៤៣ (ការចោទប្រកាន់) តែប៉ុណ្ណោះ ។

# វិបាកនៃការប្ដឹង

- ❖ <u>ទៅលើអង្គហេតុ</u> (កម្មវត្ថុនៃបណ្ដឹង) ម៣៤៨ ក១៖
  - ❑ កាតព្វកិច្ចពិភាក្សាលើ**<u>អង្គហេតុ</u>** តាមគ្រប់វិចារណកិច្ចគតិយុត្តិដែលអាចលើអំពើដែលប្ដឹងមកដោយ  យុត្តាធិការសើុបសួរ ឬព្រះរាជអាជ្ញា
  - ❑ ការហាមឃាត់ការជំនុំជម្រះក្ដីលើអង្គហេតុក្រៅពីការប្ដឹង
  - ❑ កាតព្វកិច្ចជម្រះក្ដីលើបណ្ដុំនៃអង្គហេតុ (កម្មវត្ថុនៃបណ្ដឹង) ដែលជាកាតព្វកិច្ចផ្នែកលទ្ធផល។

# វិបាកនៃការប្តឹង

**មាត្រា ៣៤៨.–** ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ

តុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ កំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម ។

-១២៣-

ក្នុងករណីដែលតុលាការសម្រេចរួមជាក្រុម ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទមជ្ឈិម ឬ បទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល ។

ក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថាអង្គ-ហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទឧក្រិដ្ឋ តុលាការនោះបញ្ជូលសំណុំរឿងជូនព្រះរាជ-អាជ្ញា ដើម្បីបើកការស៊ើបសួរ ។

# ភាគីនៅចំពោះមុខសាលាជម្រះក្តី

## ❖អាជ្ញាធរម្ចាស់បណ្តឹងអាជ្ញា៖

- ❑អយ្យការ។ ក៏ប៉ុន្តែ អាចអវត្តមាន ក្នុងករណីសវនាការលើបណ្តឹងរដ្ឋប្បវេណី។ ឧ. ម២៤។
- ❑អាជ្ញាធរផ្សេងទៀតដែលច្បាប់ផ្តល់អំណាចជូន។ ម្ចាស់បណ្តឹងអាជ្ញាដែលជាមន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈដែលច្បាប់បានផ្តល់អំណាចឱ្យ ម៥ កថា ២។ ឧ, ម១៣៤ ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ (និរាករណ៍ឆ្នាំ២០២៣)៖ *ការប្តឹងចោទប្រកាន់និងការទាមទារដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិពន្ធដារ ត្រូវធ្វើឡើងដោយប្រធាននាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*។

# ភាគីនៅចំពោះមុខសាលាជម្រះក្ដី

❖ **ជនល្មើស ឬជនជាប់ចោទ៖ គោលការណ៍នៃការបង្ហាញខ្លួនដោយផ្ទាល់ខ្លួនរបស់ជនជាប់ចោទ**

❑ ការបង្ហាញខ្លួន ម៣០០។

➢ ករណី CD ចូលបង្ហាញខ្លួនដោយសេរី ម៣០២

➢ ករណី CI មានកងកម្លាំងសាធារណៈអម ម៣០៣

➢ ករណី បញ្ជូនពីយុត្តាធិការស៊ើបសួរ គឺចូលបង្ហាញខ្លួនដោយសេរី លើកលែងតែត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ឬដាក់កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ។

# ភាគីនៅចំពោះមុខសាលាជម្រះក្ដី

- តុលាការអាចបង្គាប់ឱ្យបន្តឃុំខ្លួន រហូតដល់សវនាការចប់ (ម៣០៦)។ ជនជាប់ចោទអាចសុំនៅក្រៅឃុំបាន ឬតុលាការជំនុំជម្រះជាអ្នកផ្ដើមគំនិត ហើយតុលាការសម្រេចតាមពាក្យ បន្ទាប់ពីស្ដាប់ជនជាប់ចោទ ឬ មេធាវី ឬ ព្រះរាជអាជ្ញា។ បើតាមពាក្យសុំ ត្រូវសម្រេចយ៉ាងយូរ ១០ ថ្ងៃបន្ទាប់មានការស្នើសុំ (មាត្រា៣០៧ ក្រម)។
- កាលណាតុលាការសម្រេចដោះលែងឱ្យមានសេរីភាព ជនជាប់ចោទត្រូវនៅរក្សាទុកក្នុងឃុំរហូតដល់ផុតរយៈពេលប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងថៅក្រមសម្រេចឱ្យដោះលែងភ្លាម។ ករណីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញា ជនជាប់ចោទត្រូវរក្សាទុកក្នុងពន្ធនាគាររហូតសាលាឧទ្ធរណ៍សម្រេចអំពីបណ្ដឹងនេះ។ ម៣០៨ ក្រម។

# ភាគីនៅចំពោះមុខសាលាជម្រះក្តី

- ជំនួយនៅពេលបង្ហាញខ្លួន៖ មេធាវី ម៣០០។ មេធាវីត្រូវមានជាដាច់ខាត ករណីបទឧក្រិដ្ឋ ឬកាលណាជនជាប់ចោទជា**<u>អនីតិជន</u>** ម៣០១។
- អវត្តមាននៃជនជាប់ចោទ៖ ចេញដីកាបង្គាប់ឱ្យនាំខ្លួន (ម៣១០) ឬ ទៅសួរជនជាប់ចោទនៅទីកន្លែងដែលជននោះនៅ ប្រសិនបើស្ថានភាពសុខភាព ឬមូលហេតុធ្ងន់ធ្ងរដែលធ្វើឱ្យជនជាប់ចោទអវត្តមាន (ម៣០៩)។

# ភាគីនៅចំពោះមុខសាលាជម្រះក្ដី

## ❖ដើមបណ្ដឹងរដ្ឋប្បវេណី

- ❑ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងពេលសវនាការ និងមុនពេលព្រះរាជអាជ្ញាសន្និដ្ឋានសុំលើអង្គសេចក្ដី ម៣១១។
- ❑ការបង្ហាញខ្លួន និងអាចមានមេធាវីអម និងអាចត្រូវបានតំណាងដោយ មេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ ម៣១៣។
- ❑ទោះបីអវត្តមាន កាលណាតុលាការប្រកាសពិរុទ្ធភាព តុលាការត្រូវតែសម្រេចឱ្យសងការខូចខាត ម៣៥៦។
- ❑ការលះបង់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីតាមវិធានរដ្ឋប្បវេណី។ ឧ. ការដកពាក្យបណ្ដឹង។

# ភាគីនៅចំពោះមុខសាលាជម្រះក្តី

❖ **ភាគីដែលជាប់ពាក់ព័ន្ធ**

- ❑ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ❑ អ្នកធានារ៉ាប់រង
- ❑ អាជ្ញាធរផ្សេងទៀត៖ មន្ត្រីសុខាភិបាល ឬមន្ត្រីនគរបាលជំនាញគ្រឿងញៀន ត្រូវចូលរួមសវនាការ។

# ការពិភាក្សាដេញដោលក្នុងសវនាការ

❖ **ការបើកការពិភាក្សាដេញដោល**

❑ ខ្លឹមសារ និងទម្រង់ការ (ការអានលិខិតចោទប្រកាន់)៖ ការត្រួតពិនិត្យអត្តសញ្ញាណរបស់គូភាគី។

❑ ការត្រួតពិនិត្យមើលលើបណ្តឹងដែលបញ្ជូនមក៖

➢ ការបញ្ជូនផ្នែកអង្គហេតុ ឬ ផ្នែកច្បាប់

➢ ការបញ្ជូនទៅលើផលប្រយោជន៍រដ្ឋប្បវេណី (ម១៤២ បណ្តឹងទាមទារឱ្យជួសជុលការខូចខាត នៅពេលការស៊ើបសួរត្រូវបានបើកដោយការប្តឹងសុំតាងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីត្រូវបានបិទដោយការលើកលែងការចោទប្រកាន់ជាស្ថាពរ

➢ ការបញ្ជូនទៅលើការរឹបអូស ម២៤៧ថ្មី និង ការបញ្ជូនទៅតុលាការព្រហ្មទណ្ឌដើម្បីរឹបអូសទ្រព្យសម្បត្តិ ក្នុងករណីការចោទប្រកាន់មិនអាចធ្វើបាន ដោយសារមរណភាពនៃជនល្មើស ម៩៦ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាដើម។

# ការពិភាក្សាដេញដោលក្នុងសវនាការ

❖ **ការដោះស្រាយក្នុងសមត្ថកិច្ចអញ្ញត្រកម្ម (វិវាទក្រៅពីស្នូលនៃរឿងក្តី) le juge de l'action est le juge de l'exception៖** អញ្ញត្រកម្មគឺជាវិវាទដែលមិនទាក់ទងទៅនឹងអង្គសេចក្តីនៃសំណុំរឿង។ អញ្ញត្រកម្មអាចជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ ឬ របស់តុលាការផ្សេង។ ឧ. គូភាគីលើកអំពីមោឃភាពនៃកំណត់ហេតុសួរចម្លើយដែលមិនទាក់ទងនឹងការជជែកលើសាច់រឿងលួចឬមិនលួច។

- មព៤២ មព៤៣ មព៤៤ តុលាការដែលទទួលបណ្តឹងអាជ្ញាមានសមត្ថកិច្ច ដើម្បីសម្រេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ដែលលើកឡើងដោយគូភាគី មុនការសម្រេចលើអង្គសេចក្តី លើកលែងតែច្បាប់បានបញ្ញត្តផ្សេងពីនេះ។ តុលាការមិនអាចលើកឡើងរឿងអញ្ញត្រកម្មដោយឯកឯងបាននោះទេ លើកលែងតែការលើកឡើងអំពីសមត្ថកិច្ចតុលាការជាដើម។ ឧ. អធម្មនុញ្ញភាពនៃច្បាប់ ការបកស្រាយបទដ្ឋានអន្តរជាតិ ការរលត់បណ្តឹងអាជ្ញាឋានៈបុគ្គល សិទ្ធិប្រត្យក្សអចលនវត្ថុ មោឃភាពនៃអាពាហ៍ពិពាហ៍ សម្បទាខាងរូបកាយរបស់ជនជាប់ចោទចូលរួមកិច្ចនីតិវិធីមោឃភាព ការក្លែងបន្លំម៉ាក។ល។

# ការពិភាក្សាដេញដោលក្តីសវនាការ

- មម៣៨៣ តុលាការត្រូវបង្អង់មិនទាន់សម្រេចលើស្នូលនៃអង្គសេចក្តី (បញ្ហាបង្អង់អាជ្ញាយុកាល?) កាលណាគូភាគីបានលើកបញ្ហាបន្ទាន់បង្ខំដែលការពិនិត្យបញ្ហានេះជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការមួយទៀត (តុលាការរដ្ឋប្បវេណី តុលាការការងារ តុលាការពាណិជ្ជកម្ម ជាដើម)។ បញ្ហាបន្ទាន់បង្ខំអាចនឹងទទួលបានលុះត្រាតែបញ្ហានេះអាចលុបលាងចរិតជាបទល្មើសនៃអំពើដែលចោទប្រកាន់លើជនជាប់ចោទ។ រឿងក្តីរដ្ឋប្បវេណី បញ្ហាទាក់ទងសិទ្ធិកម្មសិទ្ធិ សិទ្ធិភណ្ឌិតលើអចលវត្ថុ (ចំពោះសិទ្ធិភណ្ឌិតលើចលនវត្ថុ តុលាការព្រហ្មទណ្ឌអាចសម្រេចដោយខ្លួនឯងបាន) និងឋានៈបុគ្គលជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការរដ្ឋប្បវេណី។

# ការពិភាក្សាដេញដោលក្នុងសវនាការ

- ម៣៤៥ កាលណាមិនទទួលយកបញ្ហាបន្ទាន់បង្ខំ ការពិភាក្សាដេញដោលត្រូវបន្ត។ កាលណាទទួលការយល់ព្រមដោយតុលាការ តុលាការត្រូវបង្អង់មិនទាន់សម្រេចអង្គសេចក្តី ហើយកំណត់រយៈពេលឱ្យគូភាគីពាក់ព័ន្ធប្តឹងទៅតុលាការមានសមត្ថកិច្ច។ លុះផុតរយៈពេលនេះ ប្រសិនបើភាគីបានប្តឹងទៅតុលាការមានសមត្ថកិច្ចរួចហើយ តុលាការកំណត់រយៈពេលថ្មីមួយទៀត ដើម្បីឱ្យបានសេចក្តីសម្រេចអំពីបញ្ហានេះ។ បើឃើតយ៉ាវគ្មានសេចក្តីសម្រេច និងបណ្តាលមកពីកំហុសរបស់ភាគីពាក់ព័ន្ធ តុលាការព្រហ្មទណ្ឌត្រូវបន្តរឿងក្តីតទៅទៀត។ សេចក្តីសម្រេចរបស់តុលាការជំនាញផ្សេងនឹងបង្ខំឱ្យចៅក្រមព្រហ្មទណ្ឌ**ត្រូវតែ**គោរពតាម (អាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចរបស់តុលាការដទៃដែលមានចំពោះតុលាការព្រហ្មទណ្ឌ)។
- ម៣៤៦ តុលាការមានកាតព្វកិច្ចត្រូវដោះស្រាយបញ្ហាអញ្ញត្រកម្ម។
- ម៣៤៦ តុលាការសម្រេចសេចក្តីអំពីអញ្ញត្រកម្មដោយសាលក្រមដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬបញ្ចូលគ្នា។

# ការពិភាក្សាដេញដោលក្នុងសវនាការ

- **<u>ការពិភាក្សាដេញដោល</u> (ផ្ទាល់មាត់ សាធារណៈ និងចំពោះមុខ)** ម៣២២ - ម៣៤១
  - ម៣២២ ក្រឡាបញ្ជីផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកចូលរួម។ ជនជាប់ចោទ មិនត្រូវទាក់ទងគ្នា។ សាក្សីមិនត្រូវទាក់ទងគ្នា។
  - ម៣២៤ ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមានក្នុងបន្ទប់សវនាការ។
  - ម៣២៥ ប្រធានសវនាការសួរចម្លើយជនជាប់ចោទ ក្រោយតុលាការប្រាប់អំពីអំពើដែលចោទប្រកាន់។ ព្រះរាជអាជ្ញា មេធាវី និងភាគីអាចតាំងសំណួរបាន។

# ការពិភាក្សាដេញដោលក្នុងសវនាការ

- មព២៦ ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី (ការស្បថ មព២៨, ម១៥៦) និងអ្នកជំនាញតាមលំដាប់ដែលគិតថាមានប្រយោជន៍។ ព្រះរាជអាជ្ញា មេធាវី និងភាគីអាចតាំងសំណួរបាន។
- មពព០ អ្នកបកប្រែត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយតុលាការដោយស្មោះត្រង់។
- មពព១ ជន គ ថ្លង់ ត្រូវការអ្នកបកប្រែ។
- មពព២ ការបង្គាប់ឱ្យបង្ហាញវត្ថុតាង។
- មពព៤ គូភាគីអាចដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

# ការពិភាក្សាដេញដោលក្នុងសវនាការ

- មា៣៣៥ នៅចុងការពិភាក្សាដេញដោល ប្រធានសវនាការត្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទធ្វើការកត់សម្គាល់ រួចមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានការពារ ព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ រួចមេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីនិងរបស់ជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន។
- មា៣៣៧ ក្រោយបិទការពិភាក្សាដេញដោល គូភាគីមិនអាចដាក់បណ្តឹងសុំបាន។
- មា៣៣៨ តុលាការអាចចុះទៅកាន់គ្រប់ទីកន្លែងនៃដែនដីជាតិ ក្នុងផលប្រយោជន៍នៃការសម្តែងឱ្យឃើញការពិត។

# ការពិភាក្សាដេញដោលក្នុងសវនាការ

- មា៣៣៨ បើយល់ឃើញថាចាំបាច់ក្នុងការស្រាវជ្រាវថ្មី តុលាការអាចបង្គាប់ឱ្យស្រាវជ្រាវបន្ថែម ។
- មា៣៣៩ ក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ (មិនមែនចាត់តាំងចៅក្រមស៊ើបសួរ ឬបង្វិលរឿងឱ្យចូលដំណាក់កាលស៊ើបសួរវិញទេ) ចៅក្រមនេះអាច (ចេញដីកាឱ្យស៊ើបសួរជំនួសបាន)៖
  - ចុះទៅលើគ្រប់វិសាលភាពនៃដែនសមត្ថកិច្ចតុលាការ ឬលើគ្រប់វិសាលភាពនៃដែនដីជាតិ
  - ស្តាប់ចម្លើយសាក្សី
  - ធ្វើការឆែកឆេរ (ការឆែកឆេរនៅការិយាល័យមេធាវី ឬ អគារសារព័ត៌មាន?)
  - ចាប់យកវត្ថុតាង
  - បង្គាប់ឱ្យធ្វើកោសលវិច័យ។

# ការប្រកាសសាលក្រម

❖កាលណាគ្មានបទល្មើស តុលាការសម្រេចឱ្យ ***រួចខ្លួនពីបទចោទ*** ៖ វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ ម៣៥០ ក្រម ម៤៩ ក១ ច្ប.អនីតិជន។

❑ម៤៩ ច្ប.អនីតិជន ករណីរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស (ទោះបីមានបទល្មើសក៏ដោយ) តុលាការត្រូវសម្រេចឱ្យអនីតិជន***រួចផុតពីបទចោទប្រកាន់*** និងបង្គាប់ឱ្យដោះលែងជាបន្ទាន់ ទោះបីជាមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញា។ ក្នុងករណីអនីតិជននោះបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី កាលណាមានបណ្ដឹងទាមទារពីជនរងគ្រោះ។

❑ករណីមានមូលហេតុ **ការលើកលែងឱ្យរួចផុតពីទោស, ការលើកលែងពីការផ្ដន្ទាទោស** អភ័យឯកសិទ្ធិគ្រួសារ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ តើតុលាការត្រូវសម្រេចឱ្យរួចខ្លួនពីបទចោទ?

# ការប្រកាសសាលក្រម

- កាលណារកឃើញពិរុទ្ធភាព តុលាការសម្រេចផ្តន្ទាទោស ម៣៥០។
  - ម៥២ ក៨ ច្ប.អនីតិជន ករណីអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ជាប់ចោទពីបទលហុ ឬបទមជ្ឈិម ឬមជ្ឈិមមានស្ថានទម្ងន់ទោស កាលណាការបង្វែទទួលបានជោគជ័យ តុលាការត្រូវចេញសាលក្រមឱ្យអនីតិជន ***<u>មិនទទួលខុសត្រូវព្រហ្មទណ្ឌ</u>*** និងសម្រេចដោះលែងដោះលែងភ្លាមទោះបីជាមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ។ តុលាការ (តុលាការព្រហ្មទណ្ឌឬរដ្ឋប្បវេណី?) អាចចេញសាលក្រមអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ។ បើជាតុលាការព្រហ្មទណ្ឌ តើតុលាការត្រូវប្រកាសពិរុទ្ធភាព ដើម្បីសម្រេចសំណងការខូចខាត យោង ម២៣?

# ការប្រកាសសាលក្រម

- ក្នុងសាលក្រមតែមួយ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ម៣៥៥។
- ម៣៥៥ ក២ *បុគ្គលដែលត្រូវផ្ដន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គី។* **ការទទួលខុសត្រូវដោយសាមគ្គី ? សូមមើល មាត្រា៩២១ ដល់ មាត្រា៩៣៧ ក្រមរដ្ឋប្បវេណី។**
- ម១៨៦ ក្រមព្រហ្មទណ្ឌ *ភាគព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណីនិងដែលមានប្រភពចេញមកពីសេចក្ដីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី។*
- តុលាការមានសមត្ថកិច្ចសម្រេចអំពីការប្រគល់វត្ថុដែលចាប់យក ម៣៥៤។

# ការប្រកាសសាលក្រម

- មព៣៥៩ ក្រម សាលក្រមត្រូវប្រកាសនៅក្នុងសវនាការជាសាធារណៈ។
- ម៥៤ ច្ប. អនីតិជន សាលក្រមត្រូវប្រកាសជាអសាធារណៈ នៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច ឬ កំបាំងមុខអនីតិជន ដើម្បីការពារឧត្តមប្រយោជន៍របស់អនីតិជន។

# ប្រភេទនៃសាលក្រម

- ❖ **សាលក្រមចំពោះជនជាប់ចោទ** (ផ្នែកបណ្តឹងអាជ្ញា ឬបណ្តឹងរដ្ឋប្បវេណី)
  - ❑ សាលក្រមចំពោះមុខ (អាស្រ័យតែលើវត្តមានរបស់ជនជាប់ចោទ)៖
    - ➢ **ក្នុងន័យចង្អៀត** មព៣៦០ **សាលក្រមចំពោះមុខ**៖
      - ជនជាប់ចោទចូលបង្ហាញខ្លួនក្នុងសវនាការ
      - ជនជាប់ចោទចាកចេញពីបន្ទប់សវនាការ
      - ករណីជនជាប់ចោទត្រូវបានសួរចម្លើយដូចក្នុង មព៣០៩ (ជនជាប់ចោទមិនអាចចូលបង្ហាញខ្លួនបាន)។

# ប្រភេទនៃសាលក្រម

- **<u>ក្នុងន័យប្រដូច</u>** មព៣៦១ **សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ**
  - ជនជាប់ចោទមិនចូលបង្ហាញខ្លួន តែដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ (CD) ឬបានដឹងអំពីការកោះហៅ (ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ) (ករណី CI គឺចំពោះមុខដោយស្វ័យប្រវត្តិ បើសាលក្រមចេញក្នុង២សប្តាហ៍)។

- **សាលក្រមកំបាំងមុខ** មព៣៦២ (អាស្រ័យតែលើវត្តមានរបស់ជនជាប់ចោទ)៖
  - ជនជាប់ចោទមិនចូលបង្ហាញខ្លួន ហើយមិនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬមិនបានដឹងអំពីការកោះហៅ។

# ប្រភេទនៃសាលក្រម

- ❖ **សាលក្រមចំពោះដើមបណ្ដឹងរដ្ឋប្បវេណី**
  - ❑ **សាលក្រមចំពោះមុខ** ម៣៦៣ ក១៖
    - ➢ ដើមបណ្ដឹងរដ្ឋប្បវេណីចូលបង្ហាញខ្លួន ឬមានអ្នកតំណាងដោយត្រឹមត្រូវ
  - ❑ **សាលក្រមកំបាំងមុខ** ម៣៦៣ ក២៖
    - ➢ ដើមបណ្ដឹងរដ្ឋប្បវេណីមិនចូលបង្ហាញខ្លួន ឬគ្មានអ្នកតំណាងដោយត្រឹមត្រូវ។

# ប្រភេទនៃសាលក្រម

- ❖ **សាលក្រមចំពោះអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី**
  - ❑ **សាលក្រមចំពោះមុខ** ម៣៦៤ ក១
    - ➢ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីចូលបង្ហាញខ្លួន ឬមានអ្នកតំណាងដោយត្រឹមត្រូវ
  - ❑ **សាលក្រមកំបាំងមុខ** ម៣៦៤ ក២ ៖
    - ➢ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនចូលបង្ហាញខ្លួន ឬគ្មានអ្នកតំណាងដោយត្រឹមត្រូវ។

# ការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន

- ជាគោលការណ៍ សាលក្រមព្រហ្មទណ្ឌអាចត្រូវបានអនុវត្ត លុះត្រាណាតែសាលក្រមនោះបានចូលជាស្ថាពរ ម៤៩៧ ក១ ក្រម។
- សាលក្រមមួយចូលជាស្ថាពរ លុះត្រាណាតែលែងអាចត្រូវបានប្ដឹងប្រឆាំងបាន ឬបានប្ដឹងប្រឆាំងអស់រួចរាល់ ឬបានផុតថិរវេលានៃការប្ដឹងប្រឆាំង។
- កាលណាសាលក្រម[អង្គសេចក្ដី]ស្ថាពរ គឺមានអាជ្ញាអស់ជំនុំ (ទាំងផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី)។ ដូចនេះ ***Non bis in idem***។

# ការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន

❖ការអនុវត្តជាបណ្ដោះអាសន្នអាចធ្វើបានទាំងទៅលើសាលក្រមទាំងផ្នែកព្រហ្មទណ្ឌ (រួមទាំងវិធានការនិរន្តកាយ) និងផ្នែករដ្ឋប្បវេណី។

❖ការអនុវត្តបណ្ដោះអាសន្នលើផ្នែកព្រហ្មទណ្ឌ៖

❑ករណីជនជាប់ចោទចូលបង្ហាញខ្លួនដោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ វិធានការនេះត្រូវបញ្ចប់នៅពេលប្រកាសសាលក្រម ម៣៥២។

➢ច្បាប់បារាំង៖ ជនជាប់ចោទអាចត្រូវបានដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ កាលណាតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារដោយគ្មានការព្យួរទោស ឬដោយមានការព្យួរទោសសាកល្បង ម៤៧១ (៣) នៃក្រម។

# ការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន

- កាលណាជនជាប់ចោទមានវត្តមាន បើប្រកាសផ្ដន្ទាទោសដាក់ពន្ធនាគារ ១ ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទោសទេ តុលាការអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ឬបង្គាប់ឱ្យឃុំខ្លួន ម ៣៩៣។ ដីកានេះមានអានុភាពអនុវត្តភ្លាមទោះបីមានបណ្ដឹងឧទ្ធរណ៍ក៏ដោយ ម៣៧០។
  - ច្បាប់បារាំង៖ បែងចែងបញ្ហាខាងលើជា ៣ ករណីខាងក្រោម៖
    - ជនជាប់ចោទចូលបង្ហាញខ្លួនក្រោមការឃុំខ្លួនបណ្ដោះអាសន្ន៖ ប្រសិនបើត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារដោយគ្មានការព្យួរទោសទេ តុលាការអាចសម្រេចតាមរយៈដីកាសម្រេចពិសេស និងមានសំអាងហេតុ ក្នុងការបន្តរក្សាទុកជននោះបន្តទៀត (ដីកាបង្គាប់ឱ្យឃុំខ្លួន)។ ម៤៦៤-១ ក្រម។ ករណីនេះ មិនចាំបាច់ទាល់តែទោសដាក់ពន្ធនាគារដែលតុលាការប្រកាសនោះ មានចិរវេលាយ៉ាងតិច១ឆ្នាំនោះទេ ។

# ការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន

- ក្នុងនីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាមដោយជនជាប់ចោទស្ថិតក្រោមការឃុំខ្លួន លក្ខខណ្ឌនៃទោសយ៉ាងតិច១ឆ្នាំ ខាងលើនេះមិនអនុវត្តនោះទេ (ពោលគឺអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នបន្តបានតាមដីកាបង្គាប់ឱ្យឃុំខ្លួន)។ ម៤៩៧-៤ ក្រម។ មានន័យថា មិនចាំបាច់ទាល់តែទោសដាក់ពន្ធនាគារដែលតុលាការប្រកាសនោះ មានថិរវេលាយ៉ាងតិច១ឆ្នាំនោះទេ។
- ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី៖ ប្រសិនបើតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ ដោយគ្មានការព្យួរទោសសម្រាប់បទល្មើសនៃនីតិរួម តុលាការអាចសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួន។ ដីកាទាំងពីរនៅមានអានុភាព ទោះបីជាមានបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងទាស់។ (ម៤៦៥ ក្រម)។

# ការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន

- ការអនុវត្តបណ្ដោះអាសន្នលើផ្នែករដ្ឋប្បវេណី៖
  - មា៣៥ ក១ វ៣ *កាលណាតុលាការមិនទាន់អាចសម្រេចបានលើផលប្រយោជន៍រដ្ឋប្បវេណីទេ តុលាការអាចបង្អង់ទៅសវនាការពេលក្រោយ និងអាចសម្រេចឱ្យប្រាក់បណ្ដោះអាសន្ន។* ជាការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ?
    - ច្បាប់បារាំង៖ នៅពេលតុលាការប្រកាសអំពីសំណងការខូចខាត តុលាការអាចបង្គាប់ឱ្យមានការបង់ប្រាក់ជាបណ្ដោះអាសន្នមួយផ្នែក ឬទាំងមូលទៅដើមបណ្ដឹងរដ្ឋប្បវេណី ម៤៦៤ (២) (៣) នៃក្រម។ ប្រធានសាលាឧទ្ធរណ៍អាចបញ្ឈប់ការអនុវត្ត។ ករណីសាលាដំបូងបានបដិសេធសំណើ ឬខនខានមិនបានសម្រេច ប្រធានសាលាឧទ្ធរណ៍អាចសម្រេចឱ្យសងជាបណ្ដោះអាសន្នបាន។

# ផ្នែកទី២

## បណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ

# លក្ខខណ្ឌនៃបណ្ដឹងទាស់

## ❖ លក្ខខណ្ឌសារធាតុនៃភាពអាចទទួលយកបាននៃបណ្ដឹងទាស់

- ❑ សេចក្ដីសម្រេចដែលអាចប្ដឹងទាស់បាន៖ ទាំងផ្នែកព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី ម៣៦៩។
- ❑ បុគ្គលដែលអាចប្ដឹងទាស់បាន៖
  - ➢ ពិរុទ្ធជន ម៣៦៥, ម៣៦៩៖ ទាំងផ្នែកព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី។
  - ➢ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តែចំពោះផលប្រយោជន៍រដ្ឋប្បវេណី ម៤១៦ថ្មី។

# លក្ខខណ្ឌនៃបណ្ដឹងទាស់

## ❖ លក្ខខណ្ឌទម្រង់

- ❑ ទម្រង់នៃការប្ដឹងទាស់៖ មព៣៦៦ ពាក្យប្ដឹងជាលាយលក្ខណ៍អក្សរ ធ្វើនៅការិយាល័យក្រឡាបញ្ជីដែលបានប្រកាសសាលក្រម ឬនៅចំពោះព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

# លក្ខណៈនៃបណ្ដឹងទាស់

- ថិរវេលានៃការប្ដឹងទាស់៖
  - ពិរុទ្ធជន មាត្រា៣៦៨ថ្មី៖ ១៥ ថ្ងៃ ផ្ដើមគិតពីពេលទទួលបានសាលក្រម ឬបានដឹងអំពីសាលក្រម។
  - ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី មាត្រា៣៧២ថ្មី៖ ១៥ ថ្ងៃ ផ្ដើមគិតពីពេលទទួលបានសាលក្រម ឬបានដឹងអំពីសាលក្រម។

# អានុភាពនៃបណ្តឹងទាស់

❖ **អានុភាពរំលត់នៃបណ្តឹងទាស់៖** សាលក្រមទាំងមូល ឬផ្នែកដែលរងការប្តឹងទាស់ ត្រូវទុកជាអសារបង់ ម៣៧០(១,៣)។

❖ **អានុភាពព្យួរការអនុវត្តសាលក្រមនៃបណ្តឹងទាស់៖**

- ផ្នែកព្រហ្មទណ្ឌ៖ ការអនុវត្តសាលក្រមត្រូវព្យួរ លើកលែងតែដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព ម៣៧០ (១-២)។
- ផ្នែករដ្ឋប្បវេណី៖ ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីត្រូវព្យួរ ម៣៧០(៣)។

# អានុភាពនៃបណ្តឹងទាស់

❖ ការប្តឹងទៅយុត្តាធិការជំនុំជម្រះ មា៣៧១៖ សំណុំរឿងត្រូវលើកយកមកជំនុំជម្រះនៅមុខតុលាការដដែល (ចៅក្រមដដែល)។

- ❑ករណីមានវត្តមានរបស់អ្នកប្តឹង៖ តុលាការពិនិត្យមើលភាពអាចទទួលយកបាននៃបណ្តឹងទាស់ រួចសម្រេចលើអង្គសេចក្តីជាថ្មីម្តងទៀត។
- ❑ករណីអវត្តមានរបស់អ្នកប្តឹង៖ តុលាការប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ ហើយសាលក្រមដែលគេប្តឹងទាស់ មិនអាចត្រូវបានកែប្រែទេ។ តែអ្នកប្តឹងទាស់នៅមានលទ្ធភាពអាចប្តឹងឧទ្ធរណ៍បាន មា៣៧១ ក្រម។

# ជំពូកទី២

## ការជំនុំជម្រះក្ដីនៅសាលាឧទ្ធរណ៍

# ផ្នែកទី១

## ១-បណ្ដឹងឧទ្ធរណ៍

# បណ្ដឹងឧទ្ធរណ៍

## នីតិវិធីលើសាលក្រមចំពោះមុខ ឬ ចាត់ទុកចំពោះមុខ



# លក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍

- **លក្ខខណ្ឌសារធាតុនៃភាពអាចទទួលយកបាននៃបណ្ដឹង**
  - **សេចក្ដីសម្រេចដែលអាចប្ដឹងឧទ្ធរណ៍** មព៣៧៣៖
    - សាលក្រមលើអង្គសេចក្ដី
    - សេចក្ដីសម្រេច ឬសាលក្រមក្រៅពីអង្គសេចក្ដី មព៣៨៥ និង មព៣៨៦ (សាលក្រមចាត់របៀបកាលណាសាលក្រមនេះបញ្ចប់នីតិវិធី ឬធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្ដី)
    - ព្រមទាំងសេចក្ដីសម្រេចផ្សេងៗ ឧ, មព៣០៨ បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាលើសាលក្រមដែលបង្គាប់ឱ្យដោះលែងជនត្រូវចោទ (តើជនជាប់ចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ឬទេលើសាលក្រមបដិសេធដោះលែងឱ្យមានសេរីភាព? មព៣០៧ និងមព៣០៨)
    - មព៣៥៥ផ្នែកសំណងរដ្ឋប្បវេណី និងការអនុវត្តបណ្ដោះអាសន្ន)។ មព៣១៦ សេចក្ដីសម្រេចបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់មិនអាចតវ៉ាបានទេ។

# លក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍

## ❑បុគ្គលដែលអាចប្ដឹងឧទ្ធរណ៍បាន

- ➢អយ្យការអមសាលាដំបូង និងមហាអយ្យការអមសាលាឧទ្ធរណ៍ ម៣៧៥
- ➢ពិរុទ្ធជន ម៣៧៥។ តើជនជាប់ចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍លើសាលក្រមមុនអង្គសេចក្ដីទេ (ការសុំនៅក្រៅឃុំបណ្ដោះអាសន្ន ម៣០៧ ម៣០៨)?
- ➢ដើមបណ្ដឹងរដ្ឋប្បវេណី ម៣៧៥
- ➢អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ម៣៧៥
- ➢បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការ រឹបអូស ករណី លើកលែងការចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬ ជនត្រូវចោទទទួលមរណភាព ម២៤៧ថ្មី

# លក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍

❖ **លក្ខខណ្ឌទម្រង់**

❑ **ទម្រង់នៃការប្ដឹង៖**

➢ ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីធ្វើបណ្ដឹងឧទ្ធរណ៍នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ម៣៧៦

➢ អគ្គព្រះរាជអាជ្ញា ធ្វើនៅការិយាល័យក្រឡាបញ្ជីសាលាឧទ្ធរណ៍ ម៣៧៩

➢ ករណីពិរុទ្ធជនជាប់ឃុំ អាចធ្វើនៅមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ម៣៧៧។

# លក្ខខណ្ឌនៃបណ្តឹងឧទ្ធរណ៍

- ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវីដែលមានលិខិតប្រគល់សិទ្ធិ ឬតំណាងដោយឪពុកម្តាយ អ្នកអាណាព្យាបាលដែលមិនចាំបាច់មានលិខិតប្រគល់សិទ្ធិ ម៣៧៦។
- ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចត្រូវបានតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ដែលត្រូវមានលិខិតប្រគល់សិទ្ធិ ម៣៧៦។
- ករណីអ្នកប្តឹងមិនចេះអក្សរមិនចេះចុះហត្ថលេខា ត្រូវផ្តិតស្រាមដៃ ម៣៧៨។

# លក្ខខណ្ឌនៃបណ្តឹងឧទ្ធរណ៍

## ❑ ថិរវេលានៃការប្តឹងឧទ្ធរណ៍ចំបង មា៣៨១ មា៣៨២ថ្មី៖

- ព្រះរាជអាជ្ញា ១ ខែ គិតពីពេលប្រកាលសាលក្រម
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ៣ ខែ គិតពីពេលប្រកាសសាលក្រម
- ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ១ ខែ ( សាលក្រមចំពោះមុខ គិតពីពេលប្រកាសសាលក្រម ,  សាលក្រមចាត់ថាចំពោះមុខ គិតពីពេលទទួលដំណឹងសាលក្រម , សាលក្រមកំបាំងមុខ គិតពីពេលផុតកំណត់ប្តឹងទាស់ )។
- បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសករណីលើកលែងការចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬជនត្រូវចោទទទួលមរណភាព មា២៤៧ថ្មី៖ ១ខែ គិតពីពេលប្រកាសសាលក្រម បើបានចូលខ្លួន និង ២ ខែ គិតពីការផ្សាយជាសាធារណៈ បើមិនបានចូលខ្លួន។

# លក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍

- ថិរវេលានៃការប្ដឹងឧទ្ធរណ៍ឧប្បត្តិហេតុ មៈ៣៨៣៖
  - ក្នុងករណីដែលភាគីណាមួយប្ដឹងឧទ្ធរណ៍នៅក្នុង រយៈពេលខាងលើនេះ ភាគីដទៃទៀតមានរយៈពេលបន្ថែម ៧ ថ្ងៃ ដើម្បីធ្វើបណ្ដឹងឧទ្ធរណ៍ឧប្បត្តិហេតុ។ រយៈពេលបន្ថែមនេះ ផ្ដើមគិតពីការផុតរយៈពេលធម្មតា។

# អានុភាពនៃបណ្ដឹងឧទ្ធរណ៍

## ❖ អានុភាពព្យួរ

❑ **អានុភាពព្យួរសេចក្ដីសម្រេចលើបណ្ដឹងអាជ្ញា៖** ជាគោលការណ៍ ការអនុវត្តសេចក្ដីសម្រេចរបស់តុលាការជាន់ដំបូងគឺនៅពេល **សេចក្ដីសម្រេចចូលជាស្ថាពរ។** មានន័យថាផ្លូវនៃបណ្ដឹងដូចជាបណ្ដឹងឧទ្ធរណ៍បានផុតរលត់។ កាលណាមានបណ្ដឹងឧទ្ធរណ៍ សេចក្ដីសម្រេចមិនអាចអនុវត្តបាននោះទេ ពោលគឺសេចក្ដីសម្រេចត្រូវបានព្យួរទុកសិន ម៣៩៨ ក១។

# អានុភាពនៃបណ្តឹងឧទ្ធរណ៍

**មាត្រា ៣៩៨.-** អានុភាពនៃបណ្តឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម

នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន ។

ប៉ុន្តែ ជនជាប់ចោទដែលជាប់ឃុំដែលបានចូលបង្ហាញខ្លួន នៅមុខតុលាការជាន់ដំបូងត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច ។ ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចឱ្យរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាងឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឱ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍ ។

រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ ។

# អានុភាពនៃបណ្តឹងឧទ្ធរណ៍

- ក្នុងករណីខ្លះ សេចក្តីសម្រេចបណ្តឹងអាជ្ញាអាចនៅតែអនុវត្ត ពោលគឺ ***គ្មានអានុភាពព្យួរ* (ការអនុវត្តភ្លាម ឬបណ្តោះអាសន្ន)** ដើម្បីប្រយោជន៍សេរីភាព ឬសម្រួលដល់ការអនុវត្តវិធានការនិរន្តរាយ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។ ករណីគ្មានអានុភាពព្យួរ ***គ្មានអានុភាពព្យួរ* (ការអនុវត្តភ្លាម ឬបណ្តោះអាសន្ន)** នេះ គឺក្នុងករណី៖
  - ទី១ សេចក្តីសម្រេចដោះលែងជនជាប់ចោទ ម៣៩៨ ក២ កាលបើព្រះរាជអាជ្ញាយល់ព្រមក្នុងករណីសម្រេចឱ្យរួចខ្លួន ឬការផ្តន្ទាទោសស្មើឬក្រោមរយៈពេលឃុំខ្លួនបណ្តោះអាសន្ន។ (ករណីអគ្គព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍)
  - ទី២ សាលក្រមរឿងអនីតិជន ដែលបង្គាប់ឱ្យដោះលែងអនីតិជនភ្លាម ម៤៩ ក៣, ម៥២ ក៤ ច្ប,អនីតិជន ។

# អានុភាពនៃបណ្តឹងឧទ្ធរណ៍

- ទី៣ សេចក្តីសម្រេចដកចេញការត្រួតពិនិត្យតាមផ្លូវតុលាការ ម៣៥២។
- ទី៤ ដីកាបង្គាប់ឱ្យឃុំខ្លួន ឬ ដីកាបង្គាប់ឱ្យចាប់ខ្លួន ដែលមានអានុភាពអនុវត្តភ្លាម មៗ៥៣ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។
- ទី៥ ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកដោយចៅក្រមជំនុំជម្រះ (ច្បាប់ឆ្នាំ២០២៥) ម៨ក៣។
- ទី៦ ការអនុវត្តទោសបន្ថែម ឬ ទោសជំនួស (ករណីច្បាប់បារាំង)។
- ទី៧ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង (ករណីច្បាប់បារាំង) ។
- ទី៨ តុលាការប្រកាសអនុវត្តរបបពាក់កណ្តាលសេរីភាព (ករណីច្បាប់បារាំង)។

# អានុភាពនៃបណ្ដឹងឧទ្ធរណ៍

- **អានុភាពព្យួរសេចក្ដីសម្រេចផ្នែកបណ្ដឹងរដ្ឋប្បវេណី** មឞ៣៩៨ ក១ លើកលែងការឱ្យប្រាក់បណ្ដោះអាសន្ន **(ការអនុវត្តភ្លាម ឬបណ្ដោះអាសន្ន)** ដែលសម្រេចក្នុងសាលក្រម ម៣៥៥។
- **អានុភាពផ្ទេរនៃបណ្ដឹងឧទ្ធរណ៍** ម៣៩៧៖ សាលាឧទ្ធរណ៍មានសមត្ថកិច្ចត្រួតពិនិត្យលើគ្រប់អង្គហេតុ និងអង្គច្បាប់ តែនៅក្នុងព្រំដែនកំណត់ដោយលិខិតប្ដឹងឧទ្ធរណ៍ និងតាមឋានៈរបស់អ្នកប្ដឹងឧទ្ធរណ៍។
  - **ដែនកំណត់ទាក់ទងនឹងកម្មវត្ថុនៃសាលក្រម៖**
    - ព្រំដែននៃអង្គហេតុ និងបទចោទ ម៤០១ (អាចកែប្រែបទចោទ ក៏ប៉ុន្តែមិនអាចបន្ថែមធាតុថ្មី ឬអង្គហេតុថ្មីដែលមិនបានដាក់នៅសាលាដំបូងនោះទេ នេះជាអត្ថន័យនៃគោលការណ៍យុត្តាធិការពីថ្នាក់)។
    - ការហាមឃាត់ការទាមទារថ្មីនៅសាលាឧទ្ធរណ៍ (លើកលែង ការបន្ថែមមធ្យោបាយការពារឬតទល់)។

# អានុភាពនៃបណ្តឹងឧទ្ធរណ៍

- **ព្រំដែនកំណត់ដោយលិខិតប្តឹងឧទ្ធរណ៍ ម៣៩៧៖**
  - បណ្តឹងឧទ្ធរណ៍លើសាលក្រមដែលសម្រេចលើបណ្តឹងអាជ្ញា ឬបណ្តឹងរដ្ឋប្បវេណី ម៣៩៧។
- **ដែនកំណត់ដោយសារប្រភេទនៃអ្នកប្តឹងឧទ្ធរណ៍ ម៣៩៩ ម៤០០ ម៤០២៖**
  - ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា ម៤០០៖
    - សាលាឧទ្ធរណ៍អាចសម្រេចដាក់ទម្ងន់ទោស ឬអាចសម្រេចឱ្យរួចខ្លួន
    - សាលាឧទ្ធរណ៍អាចប្រកាសទោសបន្ថែម ដែលដាច់ខាតត្រូវប្រកាស និងដែលខកខានប្រកាសក្នុងសាលក្រម។

# អានុភាពនៃបណ្ដឹងឧទ្ធរណ៍

- ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ម៤០២៖
  - បានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។
  - មិនអាចដាក់ពាក្យប្ដឹងសុំថ្មីដែលមិនបានដាក់ជូនតុលាការពិនិត្យ។
- ជនជាប់ចោទ ម៣៩៩៖
  - សាលាឧទ្ធរណ៍មិនអាចបន្ថែមទម្ងន់ទោស។
  - អាចត្រឹមតែកែប្រែសាលក្រមតែក្នុងន័យអនុគ្រោះដល់ជនជាប់ចោទ។
  - មិនអាចបន្ថែមទោសបន្ថែម។

# អានុភាពនៃបណ្ដឹងឧទ្ធរណ៍

- ករណីសាលាដំបូងភ្លេចប្រកាសទោសបន្ថែមដែលដាច់ខាតត្រូវតែប្រកាស សាលាឧទ្ធរណ៍បដិសេធសាលក្រម ហើយសម្រេចអំពីទោសជាថ្មី។
- មិនអាចបន្ថែមចំនួនទឹកប្រាក់សំណង កាលណាមានតែបណ្ដឹងពីជនជាប់ចោទ (គ្មានបណ្ដឹងពីដើមបណ្ដឹងរដ្ឋប្បវេណី)
- តើជនជាប់ចោទអាចដកពាក្យបណ្ដឹងឧទ្ធរណ៍បានដែរឬទេ? សំណុំរឿងបញ្ជូនត្រឡប់មកសាលាដំបូងវិញ?

# នីតិវិធីនៅសាលាឧទ្ធរណ៍

- ម ៣៩៦ វិធានដែលអនុវត្តនៅតុលាការជាន់ដំបូង ត្រូវយកមកអនុវត្តដូចគ្នាផងដែរនៅសាលាឧទ្ធរណ៍ លើកលែងតែមានចែងក្នុងមាត្រា ៣៨៧ ដល់ មាត្រា៣៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

# ផ្នែកទី២

## បណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ

# នីតិវិធីលើសាលដីកាកំបាំងមុខ

## នីតិវិធីលើសាលដីកាកំបាំងមុខ

សាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ → បណ្ដឹងទាស់ → សាលាឧទ្ធរណ៍ដដែល → សាលដីកាថ្មី → បណ្ដឹងសាទុក្ខ → តុលាការកំពូល

# លក្ខខណ្ឌនៃបណ្តឹងទាស់ចំពោះសាលដីកា

- លក្ខខណ្ឌសារធាតុនៃភាពអាចទទួលយកបាននៃបណ្តឹងទាស់
  - សេចក្តីសម្រេចដែលអាចប្តឹងទាស់បាន៖ ទាំងផ្នែកព្រហ្មទណ្ឌ ឬ ផ្នែករដ្ឋប្បវេណី ម៤១៣។
  - បុគ្គលដែលអាចប្តឹងទាស់បាន៖
    - ពិរុទ្ធជន ម៤១៣,ម៤០៩៖ ទាំងផ្នែកព្រហ្មទណ្ឌ ឬផ្នែករដ្ឋប្បវេណី។
    - ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តែចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ម៤១៦ថ្មី។

# លក្ខខណ្ឌនៃបណ្ដឹងទាស់ចំពោះសាលដីកា

## ❖ លក្ខខណ្ឌទម្រង់

❑ ទម្រង់នៃការប្ដឹងទាស់៖ ម៤១០ ពាក្យប្ដឹងជាលាយលក្ខណ៍អក្សរ ធ្វើនៅការិយាល័យក្រឡាបញ្ជីដែលបានប្រកាសសាលដីកា ឬនៅចំពោះមុខអគ្គព្រះរាជអាជ្ញា  អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

# លក្ខខណ្ឌនៃបណ្តឹងទាស់ចំពោះសាលដីកា

- ថិរវេលានៃការប្តឹងទាស់៖
  - ពិរុទ្ធជន ម៤១២៖ ១៥ ថ្ងៃ ផ្តើមគិតពីពេលទទួលបានសាលដីកា ឬបានដឹងអំពីសាលដីកា។
  - ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ម៤១៦៖ ១៥ ថ្ងៃ ផ្តើមគិតពីពេលទទួលបានសាលដីកា ឬបានដឹងអំពីសាលដីកា។

# អានុភាពនៃបណ្ដឹងទាស់

- **អានុភាពរំលត់នៃបណ្ដឹងទាស់៖** សាលដីកាទាំងមូល ឬផ្នែកដែលរងការប្ដឹងទាស់ ត្រូវទុកជាអសារបង់ ម៤១៤។
- **អានុភាពព្យួរនៃបណ្ដឹងទាស់៖**
  - ផ្នែកព្រហ្មទណ្ឌ៖ ការអនុវត្តសាលាដីកាត្រូវព្យួរ លើកលែងតែដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព ម៤១៤។
  - ផ្នែករដ្ឋប្បវេណី៖ការអនុវត្តសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីត្រូវព្យួរ ម៤១៤។

# អានុភាពនៃបណ្តឹងទាស់

❖ការប្តឹងទៅយុត្តាធិការជំនុំជម្រះ ម៤១៥៖ សំណុំរឿងត្រូវលើកយកមកជំនុំជម្រះនៅមុខសាលាឧទ្ធរណ៍ដដែល។

❑ករណីមានវត្តមានរបស់អ្នកប្តឹង៖ តុលាការពិនិត្យមើលភាពអាចទទួលយកបាននៃបណ្តឹងទាស់ រួចសម្រេចលើអង្គសេចក្តីជាថ្មីម្តងទៀត។

❑ករណីអវត្តមានរបស់អ្នកប្តឹង៖ តុលាការប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ ហើយសាលដីកាដែលគេប្តឹងទាស់ មិនអាចត្រូវបានកែប្រែទេ។ តែភាគីអាចប្តឹងសាទុក្ខបាន។

# ជំពូកទី៣

## ការជំនុំជម្រះនៅតុលាការកំពូល៖ បណ្តឹងសាទុក្ខ

# បណ្តឹងសាទុក្ខ

## ❖បណ្តឹងសាទុក្ខ

- បណ្តឹងសាទុក្ខគឺជាបណ្តឹងវិសាមញ្ញ និងផ្អែកអង្គច្បាប់សុទ្ធសាធ ម៤៣៦។ តុលាការកំពូលមិនមែនថៅក្រមអង្គសេចក្តី តែជាថៅក្រមអង្គច្បាប់ លើកលែងតែជំនុំជម្រះដោយសភាពេញអង្គលើបណ្តឹងសាទុក្ខលើកទី២ ដែលតុលាការកំពូល ពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ម៦២ ច្ប. រៀបចំអង្គការតុលាការ ម៤១៩ ម៤២៧ ម៤៣៤ ម៤៣៦ ម៤៤២ ក្រម។

# លក្ខណៈនៃបណ្ដឹងសាទុក្ខ

## នីតិវិធីបណ្ដឹងសាទុក្ខលើសាលដីកាចំពោះមុខ ឬ ចាត់ទុកចំពោះមុខ

សាលដីកាចំពោះមុខរបស់សាលាឧទ្ធរណ៍ → បណ្ដឹងសាទុក្ខ → តុលាការកំពូល

# លក្ខណៈនៃបណ្តឹងសាទុក្ខ

❖ **លក្ខខណ្ឌសារធាតុនៃភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ**

❑ **សេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាន៖** សាលដីការបស់សភាស៊ើបសួរ ដោយគិតទាំងរឿងបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ម៤១៧។

❑ **សេចក្តីសម្រេចដែលមិនអាចប្តឹងសាទុក្ខបាន៖** ចំពោះសាលដីកាសភាស៊ើបសួរដែលបង្គាប់ឱ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះ, សាលក្រមស្ថាពរ, វិធានការសណ្តាប់ធ្នាប់ក្នុងសវនាការ, ដីកាបង្គាប់ឱ្យបំបែកសំណុំរឿង ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យករបស់សភាស៊ើបសួរ និងសភាព្រហ្មទណ្ឌ (ច្បាប់ឆ្នាំ២០២៥) ជាដើម។

# លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ

- **បុគ្គលដែលអាចប្ដឹងសាទុក្ខ៖** ភាពជាភាគីគឺជាលក្ខខណ្ឌចាំបាច់ តែមិនគ្រប់គ្រាន់ ដើម្បីអាចប្ដឹងសាទុក្ខបាននោះទេ ម៤១៨។
  - អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬអមសាលាឧទ្ធរណ៍
  - ជនជាប់ចោទ ឬ ពិរុទ្ធជន (ទាំងផ្នែកព្រហ្មទណ្ឌនិងរដ្ឋប្បវេណី)។ ជនជាប់ចោទ ឬពិរុទ្ធជន អាចប្ដឹងសាទុក្ខបានចំពោះសេចក្ដីសម្រេចឱ្យរួចទោស?
  - បុគ្គលដែលត្រូវគេទាមទារក្នុងករណីបត្យាប័ន
  - ដើមបណ្ដឹងរដ្ឋប្បវេណី
  - អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។
  - អ្នកមានប្រយោជន៍ពាក់ព័ន្ធ ឬម្ចាស់វត្ថុដែលជាកម្មវត្ថុនៃការរឹបអូសគ្មានសិទ្ធិប្ដឹងសាទុក្ខ ម២៤៧ក៨ថ្មី?

# លក្ខណៈនៃបណ្តឹងសាទុក្ខ

- **មូលហេតុនៃបណ្តឹងសាទុក្ខ៖ ម៤១៩**
  - សមាសភាពមិនស្របច្បាប់នៃតុលាការ (ច្បាប់នីតិវិធី)
  - អសមត្ថកិច្ចនៃតុលាការ (ច្បាប់នីតិវិធី)
  - ការរំលោភអំណាច (ច្បាប់នីតិវិធី)
  - ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់ (**ច្បាប់សារធាតុ** និងច្បាប់នីតិវិធី)

# លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ

- ការបំពាន ឬភ្លេចទម្រង់ការដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ (ច្បាប់នីតិវិធី)
- ការមិនបានសម្រេចលើពាក្យប្ដឹងរបស់អយ្យការ ឬភាគី កាលណាពាក្យប្ដឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរនិងមានន័យយ៉ាងច្បាស់លាស់ (ច្បាប់នីតិវិធី)
- ការបំភ្លៃអង្គហេតុ (ច្បាប់នីតិវិធី)
- គ្មានសំអាងហេតុ (ច្បាប់នីតិវិធី)
- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្ដីសម្រេច (ច្បាប់នីតិវិធី)។

# លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ




តុលាការកំពូលពិនិត្យមើលទៅលើទាំងការអនុវត្តច្បាប់ និងទាំងរបៀបដំណើរការក្តី។

ដូចនេះ មូលហេតុនៃបណ្តឹងសារទុក្ខមានទាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌសារធាតុមិនត្រឹមត្រូវ និងការអនុវត្តច្បាប់នីតិវិធីមិនត្រឹមត្រូវ។

# លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ

## ❖ លក្ខខណ្ឌទម្រង់

- **ចិរវេលានៃការប្ដឹងសាទុក្ខ** ម៤២០, ម៤២១៖
  - ១ ខែ ចំពោះសាលដីការរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍
  - ១៥ ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
  - ៥ ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន
  - ភ្លាមៗ ចំពោះសាលដីកាចាត់របៀប បើសាលដីកានេះបញ្ចប់នីតិវិធី។ (**អ្វីជាសាលដីកាបញ្ចប់កិច្ចនីតិវិធី**?)

# លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ

- **ទម្រង់នៃការប្តឹងសាទុក្ខ៖ ម៤២២, ម៤២៣**
  - បណ្តឹងសាទុក្ខត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍
  - ចំពោះជនជាប់ចោទ ឬពិរុទ្ធជន ឬបុគ្គលដែលគេទាមទារក្នុងរឿងបត្យាប័នអាចធ្វើដោយខ្លួនឯង ឬតំណាងដោយមេធាវី ឬឪពុកម្តាយ ឬអ្នកអាណាព្យាបាល។ ចុះជនត្រូវចោទអាចប្តឹងសាទុក្ខបានទេ?
  - ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើដោយខ្លួនឯង ឬតំណាងដោយមេធាវី សហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់។
  - អ្នកប្តឹងចុះហត្ថលេខា ឬស្នាមមេដៃ អមដោយហត្ថលេខារបស់ក្រឡាបញ្ជី។

# អានុភាពនៃបណ្តឹងសាទុក្ខ

❖ **អានុភាពព្យួររបស់បណ្តឹងសាទុក្ខ** **ម៤៣៥**

❑ ក្នុងរយៈពេលមានបណ្តឹងសាទុក្ខ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវបង្អង់សិន។ ច្បាប់មិនបានបញ្ជាក់ទេថា បង្អង់ទាំងផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។

❑ ការអនុវត្តសេចក្តីសម្រេចដែលត្រូវតវ៉ា ត្រូវបង្អង់ក្នុងខណៈដែលតុលាការកំពូលមិនទាន់បានសម្រេច។

➢ លើកលែងតែ ការដាក់ពន្ធនាគារជនជាប់ឃុំ ដីកាបង្គាប់ឱ្យចាប់ខ្លួន ការឃុំខ្លួនបណ្តោះអាសន្ន។ ជាការបកស្រាយ លើកលែងផងដែរ ចំពោះវិធានការបណ្តោះអាសន្ននានាដែលសម្រេចដោយតុលាការ។

# អានុភាពនៃបណ្តឹងសាទុក្ខ

❖ **អានុភាពផ្ទេរ៖ ម៤៣៦** បណ្តឹងសាទុក្ខមានអានុភាពផ្ទេរទៅសភាព្រហ្មទណ្ឌនៃតុលាការកំពូលតែបញ្ហាអង្គច្បាប់តែប៉ុណ្ណោះ។ តុលាការកំពូលមិនពិនិត្យឡើងវិញលើអង្គហេតុនោះទេ លើកលែងករណីម៤៤២។

# នីតិវិធីចំពោះមុខតុលាការកំពូល

- **នីតិវិធីនៅចំពោះមុខតុលាការកំពូល** ម៤២៥-៤៣៨
  - បញ្ជូនសំណុំរឿងទៅតុលាការកំពូល។
  - ភាគីអាចតាំងមេធាវី រហូតដល់មុនមួយថ្ងៃនៃថ្ងៃបើកសវនការ។
  - ក្រឡាបញ្ជីឱ្យដំណឹងទៅគូភាគីអំពីការចុះសំណុំរឿង។ ១០ ថ្ងៃក្រោយ ក្រឡាបញ្ជីឱ្យដំណឹងដល់អ្នកប្ដឹងថាខ្លួនមានថិរវេលា ២០ ថ្ងៃ ដើម្បីដាក់សារណាអំពីមធ្យោបាយខាងច្បាប់។ មេធាវីម្ខាងទៀត មានសិទ្ធិ ២០ ថ្ងៃដូចគ្នាក្នុងការដាក់សារណា។

# សាលដីកាតុលាការកំពូល

❖ **ការសម្រេចសេចក្តី៖** សភាព្រហ្មទណ្ឌនៃតុលាការកំពូលអាច៖

- ❑បដិសេធបណ្តឹងសាទុក្ខទាំងស្រុង ឬមួយផ្នែក ម៤៣៩។
- ❑បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទាំងស្រុង ឬមួយផ្នែក រួចបង្វិលរឿងទៅមុខសាលាឧទ្ធរណ៍ផ្សេងទៀត ឬ ដដែល ក៏ប៉ុន្តែត្រូវមានសមាសភាពខុសពីមុន ម៤៣៩។
  - ➢តុលាការកំពូលប្រកាសបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដោយគ្មានបង្វិលសំណុំរឿងទៅវិញទៀ្បយ កាលណាអំពើដែលចោទប្រកាន់មិនមែនជាបទល្មើស ម៤៤០។
- ❑តុលាការកំពូលអាចមិនបដិសេធសាលដីកា ដោយគ្រាន់តែកែប្រែប្រភេទគតិយុត្តនៃអង្គហេតុជាថ្មីដោយរក្សាទោស និងសំណងនៅដដែល បើកាលណាយល់ឃើញថា អំពើដែលចោទប្រកាន់ជាបទល្មើសផ្សេងតែត្រូវផ្តន្ទាទោសដូចគ្នា ម៤៤១។

# សាលដីកាតុលាការកំពូល

## ❖ សាលដីកាជំនុំជម្រះពេញអង្គ៖

❑ ប្រសិនបើតុលាការទទួលសំណុំរឿងបង្វិលមិនអនុលោមតាមសាលដីកាទីមួយរបស់តុលាការកំពូលទេ ហើយប្រសិនបើមធ្យោបាយដដែលត្រូវបានលើកយកមកធ្វើជាសំអាងសម្រាប់បណ្ដឹងសាទុក្ខលើកទីពីរ តុលាការកំពូលដែលជំនុំជម្រះដោយសភាពេញអង្គនោះ សម្រេចសេចក្ដីលើអង្គហេតុ និងអង្គច្បាប់ ដោយចេញសាលដីកាស្ថាពរមួយ ម៤៤២។

# ភាគទី៦

## អាជ្ញារស់ជំនុំ

# អ្វីជាអាជ្ញាអស់ជំនុំ Res judicata ?

- *ជាគោលការណ៍ សាលក្រមព្រហ្មទណ្ឌអាចត្រូវបានអនុវត្ត លុះត្រាណាតែបានចូលជាស្ថាពរ* ម៤៩៧ ក១ ក្រម។
- *រយៈពេលប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ* ម៤៩៧ ក២ ក្រម។
- សាលក្រមមួយចូលជាស្ថាពរ លុះត្រាណាតែលែងអាចត្រូវបានប្ដឹងប្រឆាំងបាន ឬបានប្ដឹងប្រឆាំងអស់រួចរាល់ ឬបានផុតចិរវេលានៃការប្ដឹងប្រឆាំង។ ម៩១ ក្រមព្រហ្មទណ្ឌ
- កាលណាសាលក្រម ឬសាលដីកាចូលជាស្ថាពរ គឺមានអាជ្ញាអស់ជំនុំ (ទាំងផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី)។ សេចក្ដីសម្រេចដែលមានអាជ្ញាអស់ជំនុំ គឺមិនអាចកែប្រែបានទេ (លើកលែងបណ្ដឹងសើរើ)។
- អាជ្ញាអស់ជំនុំ (ទីដៅនៃបណ្ដឹងអាជ្ញា) គឺជាមូលហេតុនៃការរលត់បណ្ដឹងអាជ្ញា ម៧ក្រម។

# វិសាលភាពនៃអាជ្ញាអស់ជំនុំ

❖អាជ្ញាអស់ជំនុំចងជាកាតព្វកិច្ចដល់គ្រប់ចៅក្រមទាំងអស់ដែលបានទទួលបណ្ដឹងក្រោយៗមក ម១២ ក្រម ម១៤ (៧) ICCPR ។

❖អាជ្ញាអស់ជំនុំបង្កើតជាវិបាក។ ចៅក្រមរដ្ឋប្បវេណីដែលទទួលបណ្ដឹងរដ្ឋប្បវេណីដាច់ដោយឡែកត្រូវរង់ចាំរហូតដល់ចៅក្រមព្រហ្មទណ្ឌចេញសេចក្ដីសម្រេចជាស្ថាពរលើបណ្ដឹងអាជ្ញា ដើម្បីចៅក្រមរដ្ឋប្បវេណីអាចចេញសេចក្ដីសម្រេចបានលើផ្នែករដ្ឋប្បវេណី ម២២ ក្រម។ ការរង់ចាំនេះ គឺត្រូវធ្វើនៅពេលដែលបណ្ដឹងអាជ្ញាត្រូវបានដាក់ឱ្យមានចលនា ដូចនេះ ពាក្យប្ដឹងសាមញ្ញរបស់ជនរងគ្រោះមិនគ្រប់គ្រាន់ដើម្បីឱ្យចៅក្រមរដ្ឋប្បវេណីបង្អង់រឿងក្ដីនោះទេ។

# លក្ខណៈ និងលក្ខខណ្ឌនៃអាជ្ញាអស់ជំនុំ

- **លក្ខណៈ៖** ដោយខុសពីអាជ្ញាអស់ជំនុំនៃសាលក្រមរដ្ឋប្បវេណីដែលមានអាជ្ញាអស់ជំនុំមិនដាច់ខាត ជាគោលការណ៍ អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌមាន៖
  - លក្ខណៈដាច់ខាត៖ អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌមានតម្លៃជា erga omnes (គ្រប់បុគ្គលទាំងអស់ ទាំងភាគី និងមិនមែនភាគីនៃដំណើរការក្តីព្រហ្មទណ្ឌ)។
  - លក្ខណៈអាជ្ញាបញ្ញា៖ អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌអាចត្រូវបានលើកឡើងនៅគ្រប់ពេល។
- **លក្ខខណ្ឌ៖** ត្រូវមានសេចក្តីសម្រេចនៃតុលាការព្រហ្មទណ្ឌដែល**សម្រេចផ្អែកអង្គសេចក្តី** ពោលគឺ **សម្រេចលើបណ្តឹងអាជ្ញា** (តម្កល់រឿងទុកឥតចាត់ការ ដីកាដំណោះស្រាយ សាលក្រមប្រកាសពិរុទ្ធភាព ឬ ឱ្យរួចខ្លួន) និងត្រូវតែលើ**អង្គហេតុតែមួយ**ដែលអង្គហេតុនេះ ត្រូវបានប្តឹងចំពោះមុខថៅក្រមព្រហ្មទណ្ឌ ឬថៅក្រមរដ្ឋប្បវេណី។

# គំនូសបំព្រួញនីតិវិធីព្រហ្មទណ្ឌ



# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែកព្រហ្មទណ្ឌ

❖ ដំណាក់កាលស៊ើបអង្កេត៖

- **ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ** មិនមានអាជ្ញាអស់ជំនុំទេ ម៤១ ក្រម។ មូលហេតុផ្អែកលើច្បាប់ ដូចជាការលើកលែងទោសជាទូទៅ និរាករណ៍ច្បាប់ព្រហ្មទណ្ឌជាដើម ដែលធ្វើឱ្យបណ្តឹងអាជ្ញារលត់មិនអាចបើកបាន តែមិនមានន័យថាដីកាតម្កល់រឿងទុកឥតចាត់ការផ្អែកលើមូលហេតុទាំងនេះមានអាជ្ញាអស់ជំនុំនោះទេ។
- ដីកាចោទប្រកាន់៖
  - ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (RI) មិនមានអាជ្ញាអស់ជំនុំទេ ព្រោះចៅក្រមស៊ើបសួរ មានសិទ្ធិកែប្រែបទចោទដែលកំណត់ដោយព្រះរាជអាជ្ញា។
  - ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះ (CD) និងកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម (CI) មិនមានអាជ្ញាអស់ជំនុំទេ ព្រោះចៅក្រមជំនុំជម្រះមានសិទ្ធិកែប្រែបទចោទដែលកំណត់ដោយព្រះរាជអាជ្ញា ម៣៤៨។
- ដីកាសម្រេចប្រគល់វត្ថុចាប់យក ? តុលាការព្រហ្មទណ្ឌអាចសម្រេចរឹបអូសវត្ថុនោះវិញបានទេ ?

# អាជ្ញារស់ជំនុំនៃសាលាក្រមព្រហ្មទណ្ឌលើផ្នែកព្រហ្មទណ្ឌ

- **ដំណាក់កាលស៊ើបសួរ៖** ដីកាដំណោះស្រាយ
  - **ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ** គ្មានអាជ្ញារស់ជំនុំទេ ពីព្រោះថាចៅក្រមជំនុំជម្រះមានសិទ្ធិកែប្រែបទចោទដែលកំណត់ដោយចៅក្រមស៊ើបសួរ (ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ គឺជាការប្ដឹងអំពីអង្គហេតុល្មើស និងបុគ្គលល្មើសទៅចៅក្រមជំនុំជម្រះ) ម៣៤៨ ម៣៥០ ក្រម។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែកព្រហ្មទណ្ឌ

- **ដីកាដំណោះស្រាយលើកលែងចោទប្រកាន់៖ ការលើកលែងការចោទប្រកាន់ #ការសម្រេចឱ្យរួចខ្លួន**
  - ប្រសិនបើជាដីកាដំណោះស្រាយលើកលែងចោទប្រកាន់ដោយផ្អែកលើ**<u>អង្គហេតុ</u>** នោះដីកាដំណោះស្រាយនេះមានអាជ្ញាអស់ជំនុំដោយអន្លើ និងបណ្ដោះអាសន្ន ព្រោះអាចបើកស៊ើបសួរឡើងវិញតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ម២៥១ ម២៦៥ ក្រម។ ឧ. ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ដោយមូលហេតុ *គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ* ឬ *ជនដែលប្រព្រឹត្តបទល្មើសនោះនៅតែគេមិនស្គាល់* ម២៤៧ ថ្មី។
  - ប្រសិនបើជាដីកាដំណោះស្រាយលើកលែងចោទប្រកាន់ដោយផ្អែកលើ**<u>អង្គច្បាប់</u>** នោះដីកាដំណោះស្រាយនេះមានអាជ្ញាអស់ជំនុំដាច់ខាតនិងអចិន្ត្រៃយ៍។ ឧ. ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ដោយមូលហេតុ ការលើកលែងទោសជាទូទៅ អាជ្ញាយុកាល អំពើមិនបង្កើតជាបទល្មើស ម២៤៧ថ្មី។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែកព្រហ្មទណ្ឌ

- សម្រាប់**អង្គហេតុតែមួយ** ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់មិនបង្កជាឧបសគ្គដល់ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ចំពោះបុគ្គលដែលមិនត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនៅពេលស៊ើបសួរ ឬ ដែលមិនមានឈ្មោះក្នុងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬ ក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (សាលដីកាតុលាការកំពូលបារាំង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨)។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែកព្រហ្មទណ្ឌ

❖ ដំណាក់កាលជំនុំជម្រះ៖ ម៤៤៣ក្រម

❑ *Non bis in idem៖* បុគ្គលម្នាក់ដែលត្រូវបានជំនុំជម្រះរួចហើយ (ទាំងការសម្រេចឱ្យរួចខ្លួន និងការសម្រេចផ្តន្ទាទោស) មិនអាចត្រូវបានចោទប្រកាន់ជាថ្មីសម្រាប់អង្គហេតុដដែលនោះទេ ម១២ ក្រម ម១៤ (៧) ICCPR។

❑ មូលហេតុគតិយុត្តនៃការរលត់បណ្តឹងអាជ្ញា៖ កាលណាមានអាជ្ញាអស់ជំនុំ នោះបណ្តឹងអាជ្ញារលត់ ហើយបង្កឧបសគ្គដល់ការចោទប្រកាន់ ម៧ ក្រម។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែកព្រហ្មទណ្ឌ

## ❑លក្ខខណ្ឌ៖

- ➢សេចក្តីសម្រេចស្ថាពរលែងអាចត្រូវបានប្តឹងប្រឆាំងបាន ឬបានប្តឹងប្រឆាំងអស់រួចរាល់ ឬបានផុតចិរវេលានៃការប្តឹងប្រឆាំង។
- ➢អង្គហេតុតែមួយ និងមនុស្សតែមួយ ៖ វិធាន ***Non bis in idem*** អនុវត្តតែក្នុងករណីភាពតែមួយនៃមនុស្ស និងនៃអង្គហេតុរវាងការចោទប្រកាន់ដំបូង និងការចោទប្រកាន់ជាថ្មី ទោះបីជាស្ថិតក្រោមកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ម១២ ក្រម និង ម១៤ (៧) ICCPR។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែកព្រហ្មទណ្ឌ

- សេចក្តីសម្រេចត្រូវតែចេញដោយតុលាការប្រទេសកម្ពុជា៖ ជាគោលការណ៍ សេចក្តីសម្រេចដែលប្រកាសដោយតុលាការបរទេសមិនអាចហាមឃាត់តុលាការកម្ពុជាក្នុងការចោទប្រកាន់ជាថ្មីនោះទេ ព្រោះសេចក្តីសម្រេចតុលាការបរទេសមិនមានអាជ្ញាអស់ជំនុំនៅក្នុងប្រទេសកម្ពុជាទេ (អធិបតេយ្យរបស់រដ្ឋ) លើកលែងមានកិច្ចព្រមព្រៀងពិសេស ឬ ម២៣ ក្រមព្រហ្មទណ្ឌ (អនុវត្តទោសរួច ឬ ទោសរលត់ដោយផុតអាជ្ញាយុកាល)។
- សេចក្តីសម្រេចនោះគឺជា**សេចក្តីសម្រេចផ្នែកអង្គសេចក្តី**។ ករណីសាលក្រមបដិសេធអំពីភាពអាចទទួលយកបាននៃដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដែលសាលក្រមនេះមិនមានអាជ្ញាអស់ជំនុំនោះទេ បើទោះបីបានចូលជាស្ថាពរក៏ដោយ។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែករដ្ឋប្បវេណី

- ម២២ ក២ ក្រម *បណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបានផងដែរនៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី។ ក្នុងករណីនេះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិន ដរាបណាមិនទាន់មានសេចក្តីសម្រេចជា**ស្ថាពរ**មួយត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។*

- ម២៣ *តុលាការព្រហ្មទណ្ឌនឹងអាចសម្រេចការជួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថា ជនជាប់ចោទត្រូវមានពិរុទ្ធភាពជាមុនសិន។*

- ម៣៥៥ ក្រម *នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។*

- មិនមានច្បាប់ ឬយុត្តិសាស្ត្រកម្ពុជាដែលបានចែងឬពន្យល់អំពីអាជ្ញាអស់ជំនុំលើផ្នែករដ្ឋប្បវេណីនេះទេ។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែករដ្ឋប្បវេណី

- ជាគោលការណ៍ សាលក្រមព្រហ្មទណ្ឌមានអាជ្ញាអស់ជំនុំលើសាលក្រមរដ្ឋប្បវេណី (បណ្តឹងរដ្ឋប្បវេណីរណាបបណ្តឹងអាជ្ញា)។ សាលដីកាតុលាការកំពូលបែលហ្សិក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៨៦៖ *ចៅក្រមរដ្ឋប្បវេណីត្រូវតែគិតគូអ្វីដែលត្រូវបានជំនុំជម្រះយ៉ាងច្បាស់លាស់ និងជាចាំបាច់ដោយចៅក្រមព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអត្ថិភាពនៃអំពើល្មើសដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនល្មើសពាក់ព័ន្ធនឹងការកំណត់បទល្មើសនិងទទ្ធីករណ៍ដែលចៅក្រមព្រហ្មទណ្ឌបានផ្អែកលើ។* ការតម្រូវបែបនេះ គឺដើម្បីចៀសវាងភាពផ្ទុយគ្នារវាងសាលក្រមរដ្ឋប្បវេណី និងសាលក្រមព្រហ្មទណ្ឌ។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែករដ្ឋប្បវេណី

❖ សាលដីកាតុលាការកំពូលប៊ែលហ្ស៊ិក បានបន្ធូរបន្ថយការអនុវត្តគោលការណ៍ខាងលើទាក់ទងនឹងលក្ខណៈដាច់ខាតនៃអាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើសាលក្រមរដ្ឋប្បវេណីចំពោះតតិយជនដែលមិនមែនជាភាគីនៃរឿងក្ដីព្រហ្មទណ្ឌ។ តុលាការកំពូលនេះបានសម្រេចនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ ថា *តាមវិធាន នៅពេលដំណើររឿងក្ដីរដ្ឋប្បវេណី គេមិនអាចអនុញ្ញាតឱ្យមានការបដិសេធប្រឆាំងជាថ្មីទៅនឹងសេចក្ដីសម្រេចដែលបានសម្រេចលើបណ្ដឹងអាជ្ញា ដូចនេះអាជ្ញាអស់ជំនុំនៅក្នុងរឿងក្ដីព្រហ្មទណ្ឌមិនបានហាមឃាត់ភាគីនៃរឿងក្ដីរដ្ឋប្បវេណីហើយដែលមិនមែនជាភាគីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌក្នុងការបដិសេធប្រឆាំងនឹងធាតុនានាដែលកើតចេញអំពីរឿងក្ដីព្រហ្មទណ្ឌ។*

## អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែករដ្ឋប្បវេណី

- ការសម្រេចបែបនេះគឺផ្អែកលើមាត្រា៦នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលធានាចំពោះគ្រប់បុគ្គលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌។ (Article6 Right to a fair trial, European Convention on Human Rights) អាជ្ញាអស់ជំនុំអាចតទល់នឹងតតិយជននៃរឿងក្តីព្រហ្មទណ្ឌបានរហូតទាល់តែមានភស្តុតាងផ្ទុយ។
- បញ្ហារវាងគោលការណ៍ឯកភាពនៃកំហុសព្រហ្មទណ្ឌ និងកំហុសរដ្ឋប្បវេណី និងគោលការណ៍ទ្វិកភាពរវាងកំហុសព្រហ្មទណ្ឌ និងកំហុសរដ្ឋប្បវេណី។

# អាជ្ញាអស់ជំនុំនៃសាលក្រមព្រហ្មទណ្ឌលើផ្នែករដ្ឋប្បវេណី

- យោងសេចក្តីសម្រេចចិត្តមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេស ឆ្នាំ២០២៣ និងកំណត់ទិសដៅការងាជាអាទិភាពបន្ត ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤៖ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងប្តឹងសារទុក្ខនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ដើម្បីធានានូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌក្នុងការទាមទារសំណងជំងឺចិត្តចំពោះព្យសនកម្មដែលខ្លួនបានទទួល ប៉ុន្តែ បណ្តឹងឧទ្ធរណ៍និងបណ្តឹងសាទុក្ខមានអានុភាពតែទៅលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ ។

- នេះបង្ហាញថា នៅពេលដែលតុលាការជាន់ដំបូងសម្រេចឱ្យរួចខ្លួន និងនៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍ឬសាទុក្ខពីអង្គការអយ្យការក៏ដោយ អាជ្ញាអស់ជំនុំនៃរឿងព្រហ្មទណ្ឌ មិនមានអានុភាពលើផ្នែករដ្ឋប្បវេណីនោះទេ។ ដូច្នេះ តុលាការព្រហ្មទណ្ឌជាន់ខ្ពស់នៅតែមានសិទ្ធិសម្រេចលើសំណងជូនជនរងគ្រោះក្នុងរឿងក្តីដែលជនជាប់ចោទត្រូវបានសម្រេចឱ្យរួចខ្លួនដោយតុលាការថ្នាក់ក្រោម។

# ភាគទី៧

## បណ្តឹងក្រោយអាជ្ញាអស់ជំនុំ៖ បណ្តឹងសើរើរឿងក្តី

# គំនូសបំព្រួញបណ្តឹងសើរើរឿងក្តី

អត្ថិភាព
បទល្មើស

បណ្តឹងអាជ្ញា
(ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនា និងការអនុវត្តបណ្តឹងអាជ្ញា)

សាលក្រម ឬ សាលដីកាស្ថាពរ អំពីពិរុទ្ធភាពនិងទោស ម២ ម៤៩៧

ការអនុវត្តទោស

រលត់ទោស

អាយុជីវិតរបស់បណ្តឹងអាជ្ញា

អាយុជីវិតរបស់ទោស

បណ្តឹងសើរើរឿងក្តី

# អ្វីជាបណ្ដឹងសើរើរឿងក្ដី

❖ **វិការៈនៃអង្គហេតុ (ត្រូវសើរើអង្គហេតុ)** ម៤៤៥ ដែលកើតមានលើសាលក្រម ឬសាលដីកាអំពីអង្គសេចក្ដី។

❖ នៅពេលសម្រេចសើរើគឺ មានន័យថាធ្វើការជួសជុល **វិការៈនៃអង្គហេតុរបស់តុលាការ**។

❖ គោលដៅតែមួយគត់នៃបណ្ដឹងសើរើគឺ ធ្វើឱ្យទណ្ឌិតរួចខ្លួនពីបទចោទប្រកាន់វិញ មិនមែនដើម្បីផ្ដន្ទាទោសអ្នកដែលត្រូវបានសម្រេចឱ្យរួចខ្លួននោះទេ។

❖ បណ្ដឹងសើរើនេះគឺជាបណ្ដឹងវិសាមញ្ញមួយដែលត្រូវបានកម្រិតទៅលើតែករណីមួយចំនួនដែលកំណត់ដោយច្បាប់។

# លក្ខណៈនៃបណ្ដឹងសើរើរឿងក្ដី

❖ **សេចក្ដីសម្រេចដែលអាចត្រូវបានប្ដឹងសើរើរឿងក្ដី៖** សាលក្រម ឬ សាលដីកាស្ថាពរលើពិរុទ្ធភាពនិងទោស ហើយដែលមានអាជ្ញាអស់ជំនុំ ម៤៤៣។

❖ **ចិរវេលានៃការប្ដឹង៖** អាចធ្វើបាននៅគ្រប់ពេលវេលា ទោះបីកំពុងអនុវត្តទោស ឬបានអនុវត្តទោសចប់រួចរាល់ក៏ដោយ ម ៤៥៥។

❖ **មូលហេតុនៃប្ដឹងសើរើរឿងក្ដី៖** **វិការៈនៃអង្គហេតុ (ត្រូវសើរើអង្គហេតុ)** ម៤៤៥ មាន៤មូលហេតុគឺ

- ❑ក្រោយការផ្ដន្ទាទោសពីបទមនុស្សឃាត មានតម្រុយថាជនរងគ្រោះនៅរស់រានមានជីវិត
- ❑ជនជាប់ចោទពីរនាក់ត្រូវបានផ្ដន្ទាទោសចំពោះបទល្មើសដដែលនេះដោយការផ្ដន្ទាទោសទាំងពីរនេះមិនចុះសម្រុងគ្នា
- ❑កាលណាសាក្សីត្រូវផ្ដន្ទាទោសពីបទល្មើស ធ្វើជាសាក្សីដោយក្លែងប្រឆាំងនឹងជនជាប់ចោទ
- ❑កាលណាមានអង្គហេតុថ្មី ឬលិខិត ឬភស្ដុតាងថ្មីដែលនាំឱ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត (**ជាមូលហេតុទូទៅ**)។

# លក្ខខណ្ឌនៃបណ្ដឹងសើរើរឿងក្ដី

- **បុគ្គលដែលអាចប្ដឹងសើរើរឿងក្ដី៖** ម៤៤៦
  - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖ មុនប្ដឹងទៅតុលាការកំពូល អាចសុំដល់អគ្គព្រះរាជអាជ្ញា (ឧទ្ធរណ៍) ដែលមានសមត្ថកិច្ចខាងដែនដីឱ្យធ្វើការស្រាវជ្រាវបន្ថែម។
  - ទណ្ឌិត ឬអ្នកតំណាងស្របច្បាប់ ប្រសិនបើទណ្ឌិតនេះជាអសមត្ថជន
  - សហព័ទ្ធ ឪពុក ម្ដាយ កូន ឬ ជាទូទៅ ជនណាដែលមានប្រយោជន៍ខាងសម្ភារៈ ឬ ខាងផ្លូវចិត្តក្នុងការលុបបំបាត់ទណ្ឌកម្មនេះក្នុងករណីដែលទណ្ឌិតបានទទួលមរណភាព ឬបាត់ខ្លួន។
- ការអនុគ្រោះទោស (la grâce ការលើកលែងទោស) និងការលើកលែងទោសជាទូទៅ (l'amnistie) មិនមែនជាឧបសគ្គដល់ការប្ដឹងសើរើទេ ម៤៥៥។

# នីតិវិធីនៅតុលាការកំពូល

- បណ្តឹងសើរើរឿងក្តីត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅក្រឡាបញ្ជីនៃតុលាការកំពូល។

- ក្រឡាបញ្ជីជូនដំណឹងដល់អ្នកប្តឹងថាមានរយៈពេល ៣០ថ្ងៃដើម្បីបំពេញពាក្យប្តឹង និងអាចពន្យាពេលដោយប្រធានតុលាការកំពូល។ ផុតពេលនេះ ប្រធានតុលាការកំពូលចាត់តាំងចៅក្រមរបាយការណ៍ ហើយសំណុំរឿងបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

# នីតិវិធីនៅតុលាការកំពូល

❖ **សភាព្រហ្មទណ្ឌ** (ចៅក្រម ៥ រូប) នៃតុលាការកំពូលសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យប្ដឹងសើរើរឿងក្ដី ម៤៤៩។

❖ ប្រសិនបើ**សភាព្រហ្មទណ្ឌ**ទទួលពាក្យប្ដឹងសើរើ

- ❑ **សភាព្រហ្មទណ្ឌ**អាចសម្រេច**ព្យួរការអនុវត្តទោស** (suspendre l’application des peines) បាន ប្រសិនបើមានមូលហេតុច្បាស់លាស់ ម៤៤៩។ ទណ្ឌិតជាប់ឃុំត្រូវដោះលែង?
- ❑ **សភាព្រហ្មទណ្ឌ**ត្រូវបញ្ជូនសំណុំរឿងនៃបណ្ដឹងសើរើទៅតុលាការកំពូល ដើម្បីជំនុំជម្រះជា**សភាពេញអង្គ** (ចៅក្រមយ៉ាងតិច ៩ រូប មកពីសភាទាំងអស់ ហើយប្រធានតុលាការកំពូលជាអធិបតី) ដើម្បីសម្រេចអំពី**អង្គហេតុ** និង**អង្គច្បាប់** ម៤៥០។

# ការពិភាក្សាដេញដោលនៅតុលាការកំពូល

- ប្រធានតុលាការកំពូលកំណត់កាលបរិច្ឆេទសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ទៅអគ្គព្រះរាជអាជ្ញាដែលនឹងជូនដំណឹងអំពីកាលបរិច្ឆេទនេះដល់អ្នកប្ដឹងសើរើ និងមេធាវី។ ករណីអ្នកប្ដឹងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាក៏ត្រូវជូនដំណឹងដល់ទណ្ឌិត ឬ ដល់គ្រួសារ ម៤៥១។
- ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការសាធារណៈ ម៤៥១។
- តុលាការស្ដាប់សេចក្ដីរាយការណ៍របស់ចៅក្រមរបាយការណ៍ រួចស្ដាប់មេធាវីរបស់អ្នកប្ដឹងសុំ ឬបើអ្នកប្ដឹងសុំជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្ដាប់មេធាវីទណ្ឌិត ឬរបស់ក្រុមគ្រួសារ ឬទណ្ឌិត ម៤៥១។
- តុលាការស្ដាប់សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា។ មេធាវីរបស់អ្នកប្ដឹងអាចនិយាយម្ដងទៀតបាន ម៤៥១។

# ការស្រាវជ្រាវបន្ថែមនៅតុលាការកំពូល

- ប្រសិនបើតុលាការកំពូលយល់ឃើញថា រឿងក្តីល្មមជំនុំជម្រះបាន តុលាការកំពូលសម្រេចពីបណ្តឹងសើរើ តាមសាលដីកាមួយដែលមិនអាចតវ៉ាបាន ម៤៥២។
- បើរឿងក្តីមិនល្មមជំនុំជម្រះបាន តុលាការកំពូលបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ដោយចាត់តាំងចៅក្រម សមាជិកសភាពេញអង្គណាម្នាក់ទទួលបន្ទុក ម៤៥២។
- ចៅក្រមដែលទទួលការចាត់តាំងនេះ មានអំណាចដូចចៅក្រមស៊ើបសួរ លើកលែងតែការឃុំខ្លួនបណ្តោះអាសន្ន និងត្រួតពិនិត្យតាមផ្លូវតុលាការ ម៤៥២។
- កាលណាការស្រាវជ្រាវបានបញ្ចប់ ត្រូវជូនដំណឹងដល់អ្នកប្តឹង ឬមេធាវី ម៤៥២។
- ប្រធានតុលាការកំណត់កាលបរិច្ឆេទសវនាការជាថ្មី ដូចមានចែងក្នុង ម៤៥១។

# សាលដីកាលើបណ្តឹងសើរើរឿងក្តី

❖សាលដីកាត្រូវមានសំអាងហេតុ និងត្រូវប្រកាសនៅពេលសវនាការជាសាធារណៈ ម៤៥៣។

❖ក្រោយពីទទួលបានរឿងក្តីប្តឹងសើរើ សភាពេញអង្គអាចបង្គាប់ឱ្យ**<u>ផ្អាកការអនុវត្តទណ្ឌកម្ម</u>** (surseoir à l’execution de la comdamnation) បានគ្រប់ពេលវេលា ម៤៥៤។ ទណ្ឌិតជាប់ឃុំត្រូវដោះលែង ?

# អានុភាពនៃសាលដីកាដែលសម្រេចឱ្យសើរើ

- សភាពេញអង្គអាចសម្រេចបដិសេធបណ្តឹងសើរើ (តែមិនអាចសម្រេចបន្ថែមទម្ងន់នៃទោសទៅលើអ្នកស្នើសុំបានទេ) ឬ សម្រេចលុបចោលការផ្តន្ទាទោស (ក្លាយជាជនឥតទោសវិញ)។
- សិទ្ធិទទួលបានការជួសជុលការខូចខាតផ្នែកសម្ភារៈនិងផ្លូវចិត្តដែលកើតចេញពីការផ្តន្ទាទោស (ម៣៩ រដ្ឋធម្មនុញ្ញ) ពីការប្រព្រឹត្តខុសរបស់អង្គការរដ្ឋ (តុលាការ) និងសិទ្ធិទាមទារនូវប្រាក់ពិន័យដែលបានបង់រួចព្រមទាំងសិទ្ធិទាមទារត្រឡប់មកវិញនូវសំណងដែលបានបង់ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
- ត្រូវដកចេញពីបញ្ជីថ្កោលទោស ចំពោះការផ្តន្ទាទោសដែលត្រូវបានចាត់ទុកជាអសារបង់ដោយនីតិវិធីនៃបណ្តឹងសើរើ ម៥៤២ ក៥ ក្រម។
- ច្បាប់បារាំង ម៦២៦ (៦)(៧) នៃក្រម ករណីគ្មានទោស អនុញ្ញាតឱ្យអ្នកប្តឹងសើរើអាចស្នើសុំឱ្យផ្សាយសេចក្តីសម្រេចដែលលុបចោលការផ្តន្ទាទោស។

# អានុភាពនៃសាលដីកាដែលសម្រេចឱ្យសើរើ

## ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

**មាត្រា ៣០៧.–** មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)

១-ភាគីអាចស្នើសុំប្តឹងឧបាស្រ័យ តាមបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែលមានមូលហេតុណាមួយដូចរៀបរាប់ខាងក្រោមនេះ :

ជ-បើសាលក្រម ឬ សាលដីកា ឬ សេចក្តីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ឬ ការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ត្រូវបានផ្លាស់ប្តូរ ដោយសារសេចក្តីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ ។

ឈ-បើមានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមាន

# ភាគទី៨

## នីតិវិធីបខ្មែរ ( អនីតិជន )

# តំនូសបំព្រួញនីតិវិធីព្រហ្មទណ្ឌ



# អ្វីជាការបង្វែរ?

❖ការបង្វែរជាវិធានដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ដោយបង្វែរចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ (ដំណាក់កាលស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ) ម ៦០ ច្ប.យុត្តិធម៌អនីតិជន។ នីតិវិធីនេះ ស្រដៀងគ្នាទៅនឹងនីតិវិធី la composition pénale/ penal composition នៅប្រទេសបារាំង។

❖គោលដៅ៖ គឺដើម្បីឱ្យអនីតិជន***មិនទទួលខុសត្រូវព្រហ្មទណ្ឌ*** ម៥២(៨) (ជាប់ក្នុងព្រឹត្តិប័ត្រថ្កោលទោស) ក៏ប៉ុន្តែ ឱ្យអនីតិជនចេះសារភាពទទួលកំហុស និងទទួលខុសត្រូវរដ្ឋប្បវេណីចំពោះជនរងគ្រោះ និងកែប្រែខ្លួន ម២៨ ក៤, ម៣៨ ក២, ម៤៩, ម៥២ ក៣ ។

# អ្វីជាការបន្ទោស?

❖ចំណុច១៩ នៃសេចក្តីណែនាំរបស់ អ.ស.ប ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា៖ នៅបណ្តាប្រទេសដែលព្រះរាជអាជ្ញាត្រូវបានផ្តល់ឱ្យនូវមុខការឆន្ទានុសិទ្ធិដូចជាការសម្រេចថាតើត្រូវធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជនម្នាក់ ឬអត់នោះ ព្រះរាជអាជ្ញាត្រូវតែផ្តោតការពិចារណាជាពិសេសទៅលើចរិត និងភាពធ្ងន់ធ្ងរនៃបទល្មើស កិច្ចការពារពីសង្គម និងបុគ្គលិកលក្ខណៈ និងសាវតារបស់អនីតិជននោះសិន។ ក្នុងការធ្វើសេចក្តីសម្រេចនោះ ព្រះរាជអាជ្ញាត្រូវពិចារណាជាពិសេសអំពីជម្រើសផ្សេងៗដែលអាចមានដើម្បីជំនួសឱ្យការធ្វើបណ្តឹងអាជ្ញាតាមច្បាប់និងនីតិវិធីទាំងឡាយដែលពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន។ ព្រះរាជអាជ្ញាត្រូវព្យាយាមខិតខំឱ្យអស់ពីលទ្ធភាពរបស់ខ្លួនក្នុងការចាត់វិធានការធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជន តែនៅពេលណាដែលចាំបាច់ជាអប្បបរមាប៉ុណ្ណោះ។

# គោលបំណងនៃការបង្វែរ

❖ម ៦២ ច្ប.យុត្តិធម៌អនីតិជន ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

- ❑លើកទឹកចិត្តអនីតិជនឱ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ❑ជំរុញឱ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- ❑លើកទឹកចិត្តឱ្យមានការជួសជុលការខូចខាត ឬ សំណងជំងឺចិត្តដល់ជនរងគ្រោះ
- ❑អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ❑ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- ❑បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស។

# លក្ខណសារធាតុនៃការបង្វែរ

## ❖លក្ខខណ្ឌអប្បបរមាការបង្វែរ៖ ម៦៣

- ❑បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម (រួមទាំងបទមជ្ឈិមមានស្ថានទម្ងន់ទោស ម៣៨ ម៥២)
- ❑មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន
- ❑អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំអភ័យទោសជនរងគ្រោះ
- ❑អនីតិជនយល់ព្រមឱ្យធ្វើការបង្វែ បន្ទាប់ពីបានពិគ្រោះជាមួយភ្នាក់ងារសង្គមកិច្ច ឬ មេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែ។
- ❑អនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ម២៨ (ព្រះរាជអាជ្ញា) ម៥២ (ចៅក្រមជំនុំជម្រះ)។

# លក្ខណសារធាតុនៃការបង្វែរ

❖ **លក្ខណៈវិនិច្ឆ័យការបង្វែរ៖** ម៦៤ អាជ្ញាធរទទួលបន្ទុកការបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម៖

- កាលៈទេសៈនៃបទល្មើស
- ស្ថានភាពនៃបទល្មើស
- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជាអាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត
- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន
- ព្យសនកម្មរបស់ជនរងគ្រោះ
- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម។

# លក្ខខណ្ឌសារធាតុនៃការបង្វែរ

❖ **វិធានការបង្វែរ៖** ម៦៥ នៅពេលបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរ អាចជ្រើសរើសយកវិធានការមួយ ឬច្រើន ឱ្យអនីតិជនបំពេញជាកាតព្វកិច្ច៖

- ❑ ចំណុចមួយ ឬ ច្រើននៃកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការដែលចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ម២២៣។ កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការចំនួន៤តាម ម៤០ ច្ប.អនីតិជន ?
- ❑ ទៅសាលារៀនឱ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ ខែ
- ❑ ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ ខែ
- ❑ តម្រូវឱ្យចូលរួមក្នុងការអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងចិរវេលាមិនលើសពី ៦ ខែ

# លក្ខណសារធាតុនៃការបង្វែរ

- ❑ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ ម៉ោង (សម្រាប់អនីតិជនអាយុចាប់ពី ១៦ឆ្នាំ ឡើងទៅ) ជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ
- ❑ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឱ្យប្រព្រឹត្តបទល្មើសសាជាថ្មី)
- ❑ឱ្យស្នាក់នៅទីកន្លែងណាមួយដែលកំណត់ពេលវេលាជាក់លាក់
- ❑ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ
- ❑វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែ។

❖រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារត្រូវអនុលោមតាមច្បាប់និងអនុសញ្ញាអន្តរជាតិស្តីពីការងារ។

# លក្ខខណ្ឌតម្រង់នៃការបង្វែរ

❖ **ការបង្វែរធ្វើឡើងនៅពេលណា?**

- **អយ្យការ៖** គ្រប់ពេលវេលា តែមុនការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវចេញ**ដីកាសម្រេចផ្អាកការចោទប្រកាន់** ម២៨ ក៣ (បញ្ញាអាជ្ញាយុកាល) ។ ក្នុងករណីនេះ ជនរងគ្រោះអាចទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ម២៨ ក៤ (អញ្ញត្រកម្ម ម២២ និងម២៣?)។
- **ចៅក្រមស៊ើបសួរ៖** គ្រប់ពេលវេលា តែមុនការចេញដីកាដំណោះស្រាយ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរចេញ**ដីកាសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ** ម៣៨ ក១ (បញ្ញាអាជ្ញាយុកាល) ។ ក្នុងករណីនេះ ជនរងគ្រោះអាចទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ម៣៨ ក២ (អញ្ញត្រកម្ម ម២២ និងម២៣?)។

# លក្ខណៈទូទៅនៃការបង្វែរ

- **ចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍៖** គ្រប់ពេលវេលា តែមុនការចេញសាលក្រម ឬ សាលដីកាលើអង្គសេចក្តី ម៥២ ម៥៨។ ក្នុងករណីនេះ ចៅក្រមជំនុំជម្រះត្រូវចេញសាលក្រមបង្អង់រឿងទុក (បញ្ហាអាជ្ញាយុកាល ចាប់រាប់ជាថ្មី ឬរាប់បន្ត?) សិន បន្ទាប់មកពិភាក្សាជាមួយអនីតិជន ឬអ្នកតំណាង ឬអ្នកពាក់ព័ន្ធរៀបចំផែនការបង្វែរ និងឱ្យអនីតិជនផ្តល់ការយល់ព្រមអនុវត្តផែនការបង្វែរ។ ក្នុងករណីសម្រេចបង្វែរ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានការស្នើសុំ ម៥២ (អញ្ញត្រកម្មនៃ ម២២ និង ម២៣ ក្រម?)។

# លក្ខខណ្ឌទម្រង់នៃការបង្វែរ

- **អាជ្ញាធរទទួលបន្ទុកនៃការបង្វែ** ៖ ម៦១
  - តំណាងអង្គការអយ្យការ (អយ្យការសាលាដំបូង ឬ សាលាឧទ្ធរណ៍?)
  - ចៅក្រមស៊ើបសួរ
  - ចៅក្រមជំនុំជម្រះនៃសាលាដំបូង
  - ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ (សភាព្រហ្មទណ្ឌ រួមទាំងសភាស៊ើបសួរ?)
- អ្នកមានសិទ្ធិស្នើសុំការបង្វែរ? ច្បាប់មិនបានបញ្ជាក់ទេថាអ្នកណាមានសិទ្ធិស្នើសុំឬទេ ក៏ប៉ុន្តែ ម៧០ ចែងអំពីការកែប្រែវិធានការបង្វែរ តាមគំនិតផ្តួចផ្តើមរបស់អាជ្ញាធរទទួលបន្ទុកការបង្វែរ ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច។

# លក្ខខណ្ឌទម្រង់នៃការបង្វែរ

❖ **ការរៀបចំផែនការបង្វែរ៖** ម៦៦

❑ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ។ ត្រូវរៀបចំផែនការបង្វែរយ៉ាងយូរ ១ខែ គិតពីពេលទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងស្ថានភាពពិសេស។

❑ ផែនការមានលក្ខណៈជាឯកត្តបុគ្គល (ផ្សេងៗគ្នារវាងអនីតិជនច្រើននាក់) ដោយពិចារណាលើ៖

➢ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់កំណត់ និងជនរងផលប៉ះពាល់នៃអំពើល្មើសអំពីភាពសមស្របនៃផែនការបង្វែរ

➢ សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន

➢ សមាមាត្ររវាងផែនការចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម

➢ អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន។

# លក្ខខណ្ឌទម្រង់នៃការបង្វែរ

- ផែនការបង្វែរត្រូវ៖
  - ផ្តល់អត្ថប្រយោជន៍សម្រាប់អនីតិជន
  - ធ្វើឱ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
  - កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត
  - អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
  - ចៀងវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឱ្យអន្តរាយ ឬធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយអនីតិជន
  - មិនប៉ះពាល់ជាវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា
  - មិនមានការពាក់ព័ន្ធនឹងការដកហូតសិទ្ធិសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ។

# លក្ខខណ្ឌទម្រង់នៃការបង្វែរ

❖ និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ៖ ម៦៧

| | |
|---|---|
| វិធានការបង្វែរណាមួយ និងរយៈពេល | បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាព |
| បញ្ជាក់លម្អិតអំពីសេវា ឬជំនួយដែលត្រូវផ្តល់ឱ្យអនីតិជន | បញ្ជាក់ពីអាជ្ញាធរ ឬ ជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ (អាចជានគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍)។ |
| បញ្ជាក់ឱ្យច្បាស់អំពីបុគ្គល ឬអង្គការដែលផ្តល់សេវានិងជំនួយទាំងនោះ | បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកត្រួតពិនិត្យ តាមដាន និងអនុវត្តផែនការបង្វែរ |
| បញ្ជាក់អំពីគោលបំណងផ្ទាល់ខ្លួនរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ | បញ្ជាក់អំពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ |
| បញ្ជាក់អំពីការទទួលខុសត្រូវរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ | |

# លក្ខខណ្ឌទម្រង់នៃការបង្វែរ

❖**ការជូនដំណឹង** ដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ម២៨ ក៣ ម៣៨ ក២ ច្បាប់យុត្តិធម៌អនីតិជន។

❖**ការប្រគល់អនីតិជន** ទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ម២៨ ក៣ ម៣៨ ក១ ច្បាប់យុត្តិធម៌អនីតិជន។

❖**ការសម្រេចឱ្យអនុវត្តផែនការបង្វែរ**៖ ម៦៨

- ❑ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីពិនិត្យ និងសម្រេច។
- ❑អាជ្ញាធរទទួលបន្ទុកបង្វែរចេញ**ដីកាសម្រេចឱ្យអនុវត្តផែនការបង្វែរ** បើយល់ស្របនឹងផែនការដែលបានបញ្ជូនមក។ ករណីមិនយល់ស្រប អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញ**ដីកាបង្គាប់ឱ្យរៀបចំផែនការបង្វែរជាថ្មី**។ ក្នុងករណីនេះ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេល ១ ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងស្ថានភាពពិសេស។

# លក្ខខណ្ឌទម្រង់នៃការបង្វែរ

❖ **ការអនុវត្តផែនការបង្វែរ៖** ម៦៩

- ❑ ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធានារ៉ាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ។
- ❑ បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬ បរាជ័យ ឬ ឧបសគ្គដែលកើតមាន។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួនផងទៅអាជ្ញាធរទទួលបន្ទុកបង្វែរ។

# ការកែប្រែវិធានការបង្ខំ

❖ **ការកែប្រែវិធានការបង្ខំ៖** មព០

❑ អំឡុងពេលអនុវត្តផែនការបង្ខំ អាជ្ញាធរទទួលបន្ទុកបង្ខំអាចកែប្រែវិធានការបង្ខំបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬ តាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន។

❑ អាជ្ញាធរទទួលបន្ទុកបង្ខំ ត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច។ ក្នុងករណីមិនបានសម្រេចក្នុងថិរវេលានេះទេ ត្រូវចាត់ទុកថាអាជ្ញាធរទទួលបន្ទុកបង្ខំយល់ស្របតាមការស្នើសុំ។

❑ ការកែប្រែផែនការបង្ខំ មិនចាត់ទុកជាការបរាជ័យក្នុងការអនុវត្តផែនការបង្ខំឡើយ (មព១ ក១ **បរាជ័យក្នុងការអនុវត្តវិធានការបង្ខំ**សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្ខំ ឬ នៅក្នុងវិធានការដែលត្រូវបានកែប្រែ មព១ ក១)។

# អានុភាពនៃការបញ្ចប់ការបង្វែរ

| អយ្យការ | ការបង្វែរទទួលបានជោគជ័យ | ការបង្វែរទទួលបរាជ័យ |
|---|---|---|
| | -ម២៨ ក៥ ព្រះរាជអាជ្ញាត្រូវតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើការបង្វែរទទួលបានជោគជ័យ (ទោះបីជាមានបទល្មើសក៏ដោយ)។ | -ព្រះរាជអាជ្ញាកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការ និងមេធាវីអនីតិជន ម៧១ ក៣។ |
| | | -ករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប ព្រះរាជអាជ្ញាត្រូវចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌ ម៧១ ក៧។ |
| | | -បើអនីតិជនចូលបង្ហាញខ្លួន នោះព្រះរាជអាជ្ញាអាចចេញដីកាបង្វែរជាថ្មី (កែប្រែវិធានការ) ម២៨ ក៦, ម៧១ ក៥ ឬ បន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌ ម៧១ ក៥។ |

# អានុភាពនៃការបញ្ចប់ការបង្វែរ

| | ការបង្វែរទទួលបានជោគជ័យ | ការបង្វែរទទួលបរាជ័យ |
|---|---|---|
| ចៅក្រមស៊ើបសួរ | -ម៣៨ ក៣ ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ ក្នុងករណីការបង្វែរទទួលបានជោគជ័យ (ទោះបីជាមានបទល្មើសក៏ដោយ)។ | -ម៧១ ក៣ ចៅក្រមស៊ើបសួរកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការ និងមេធាវីអនីតិជន។ |
| | | -ករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្របចៅក្រមស៊ើបសួរត្រូវចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌ ម៧១ ក៧។ |
| | | -បើអនីតិជនចូលបង្ហាញខ្លួន នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្វែរជាថ្មី (កែប្រែវិធានការ) ម៣៨ ក៤, ម៧១ ក៥ ឬ បន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌ ម៧១ ក៥។ |

# អានុភាពនៃការបញ្ឈប់ការបង្វែរ

| | ការបង្វែរទទួលបានជោគជ័យ | ការបង្វែរទទួលបរាជ័យ |
|---|---|---|
| ចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះ | -ម៥២ ក៨, ម៦១ ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ចេញសាលក្រម ឬ សាលដីកាសម្រេច **ឱ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ** កាលណាការបង្វែរទទួលបានជោគជ័យ (ទោះបីជាមានបទល្មើសក៏ដោយ)។ | -ម៧១ ក៣ ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍កោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការ និងមេធាវីអនីតិជន។ |
| | | -ករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ត្រូវចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌ ម៧១ ក៧។ |
| | | -បើអនីតិជនចូលបង្ហាញខ្លួន នោះចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ចេញដីកាបង្វែរជាថ្មី (កែប្រែវិធានការ) ម៥២ ក៩, ម៧១ ក៥ ឬ បន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌ ម៧១ ក៥។ |

# ភាគទី៩

## ភស្តុតាងក្នុងរឿងក្ដីព្រហ្មទណ្ឌ

# ជំពូកទី១

## គោលការណ៍ទូទៅ

# ផ្នែកទី១

## បន្ទុកនៃភស្តុតាង

# ប្រព័ន្ធនៃភស្តុតាង

- ❖ **វិធាននៃភស្តុតាង៖ ប្រព័ន្ធភស្តុតាងសេរី (ផ្ទុយពីប្រព័ន្ធភស្តុតាងនីត្យានុកូល)**
  - ❑ ក្នុងរឿងព្រហ្មទណ្ឌ ភស្តុតាងអាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយ (វត្ថុ លិខិត ស្លាកស្នាម សំដី វីដេអូ រូបភាព ទិន្នន័យឌីជីថល ។ល។)
  - ❑ សេរីភាពនៅក្នុងនីត្យានុកូលភាព៖ ភស្តុតាងត្រូវតែស្របច្បាប់ និងទទួលបានដោយស្មោះត្រង់ត្រឹមត្រូវ (នគរបាលចរាចរណ៍ថតចាប់ល្បឿន ការប្រើថ្នាំសណ្តំ) ជាប់ទាក់ទង និងអាចទុកចិត្តបាន។

# អ្នកមានបន្ទុកនៃភស្តុតាង

- បន្ទុកនៃភស្តុតាងគឺជាបន្ទុករបស់អ្នកដាក់ពាក្យប្តឹង លើកលែងច្បាប់ ឬសច្ចធារណ៍តាមផ្លូវតុលាការកំណត់ផ្សេង។ នេះគឺដោយសារសច្ចធារណ៍នៃនិរទោស។
- បន្ទុកនៃភស្តុតាងយោលទៅតាមប្រភេទនៃបុគ្គល ៖
  - អយ្យការស្វែងរកធាតុផ្សំនៃបទល្មើស និងអត្តសញ្ញាណនៃជនល្មើស និងភស្តុតាងដទៃទៀត ដោយសារសច្ចធារណ៍នៃនិរទោស។
  - ជនរងគ្រោះបង្ហាញអំពីការខូចខាតដែលកើតឡើងពីបទល្មើស ដើម្បីទាមទារសំណង
  - ជនល្មើសស្វែងរកភស្តុតាងដោះបន្ទុក។

# សច្ចធារណ៍នៃនិរទោស

❖ **គោលការណ៍៖** ជនសង្ស័យឬបុគ្គលដែលត្រូវបានចោទប្រកាន់ ត្រូវសន្មតថាគ្មានទោសរហូតដល់ការរកឃើញនូវពិរុទ្ធភាពជាស្ថាពរ។ **សន្មតថាគ្មានទោស** មិនមែនមានន័យថា **គ្មានទោស** នោះទេ។

- មទ្រា៤ ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ ការបោះពុម្ពផ្សាយលើសារព័ត៌មានលើគ្រប់ទិដ្ឋភាពនៃដំណើការរបស់តុលាការរាប់ទាំងនីតិវិធីទាំងឡាយផង មិនអាចត្រូវបានផ្តន្ទាទោស លើកលែងតែ៖
  - *តុលាការហាមមិនឱ្យបើកចំហរដល់សាធារណជន។*
  - *បញ្ញត្តិដោយមាត្រា១៦ នៃច្បាប់ដែលទាក់ទងនឹងអាថ៌កំបាំងរបស់បុគ្គលម្នាក់នៅក្នុងដំណើរការជំនុំជំរះក្តី។* តាមពិតគឺមាត្រា១៥ មិនមែនមាត្រា១៦ ទេ។
  - *សំណុំរឿងដែលនៅក្នុងការអង្កេតស៊ើបសួររបស់តុលាការនៅឡើយ។*

# សច្ចធារណ៍នៃនិរទោស

មាត្រា ១៩.-

លើកលែងតែមានការអនុញ្ញាតពីតុលាការ សារពត៌មានពុំអាចផ្សាយដំណឹង រូបថត ឬគំនូរ ដែលអាចឲ្យអ្នកអានស្គាល់ឈ្មោះ និងកិនភាគដៃ ៖

- ភាគីក្នុងរឿងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងបិតុភាព អាពាហ៍ពិពាហ៍ រឿងលែងលះប្ដីប្រពន្ធ ឬរឿងអាណាព្យាបាលលើកុមារ
- យុវជនអាយុតិចជាងដប់ប្រាំបីឆ្នាំ (១៨ ឆ្នាំ) ក្នុងរឿងវិវាទរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ
- ស្ត្រីដែលទទួលរងគ្រោះដោយអំពើរំលោភលើរាងកាយ ឬអំពើចាប់បង្ខំសេពសន្ថវៈ ។

ក្នុងករណីដែលសាមីជន ឬអ្នកអាណាព្យាបាលយល់ព្រមជាលាយលក្ខណ៍អក្សរ សារពត៌មានអាចផ្សព្វផ្សាយរឿងនេះបាន លើកលែងតែការផ្សាយនេះ នាំឲ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ ។

បុគ្គលណា ដែលត្រូវសារពត៌មានបំពានសិទ្ធិខាងលើនេះ មានសិទ្ធិប្ដឹងទៅតុលាការដើម្បីទាមទារជម្ងឺចិត្ត ។ ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើនេះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ ពីមួយលានរៀល (១ ០០០ ០០០ រៀល) ទៅប្រាំលានរៀល (៥ ០០០ ០០០ រៀល) ។

# សច្ចធារណ៍នៃនិរទោស

- **ការកម្រិតទៅលើគោលការណ៍៖** សច្ចធារណ៍នៃនិរទោសមិនហាមប្រាមនូវការប្រើវិធានការនិរន្តរាយនានារបស់តុលាការ ឬអាជ្ញាធរ មុនការវិនិច្ឆ័យតាមសាលក្រមនោះទេ។ វិធានការទាំងនោះមានដូចជា ការឃាត់ខ្លួន ការឃុំខ្លួនបណ្ដោះអាសន្ន ការត្រួតពិនិត្យតាមផ្លូវតុលាការ ការបិទគ្រឹះស្ថាន (ទាំងផ្លូវរដ្ឋបាលផងដែរ) ការស្ដាប់ការឆ្លើយឆ្លងតាមទូរស័ព្ទ។

# សច្ចធារណ៍នៃនិរទោស

❖ **សិទ្ធិនានារបស់បុគ្គល (ដែលរងគ្រោះ)៖**

- ❑ម៣១១-៣១៣ ក្រមព្រហ្មទណ្ឌ ជនរងគ្រោះអាចធ្វើបណ្ដឹងពីបទប្ដឹងបរិហារបង្កាច់កេរ្ដិ៍ដែលអាចមានទោសបន្ថែមក្រោមទម្រង់ជាការចុះផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស។
- ❑ម១០ ច្បាប់ស្ដីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ បុគ្គលរងគ្រោះដោយសារសារព័ត៌មានចុះផ្សាយ**<u>ខុសពីការពិត</u>**នាំឱ្យខូចខាតដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរមានសិទ្ធិ៖
  - ➢យន្តការបន្ទាន់៖ ស្នើឱ្យធ្វើការកែតម្រូវ ឬឆ្លើយតបទៅសារព័ត៌មាន
  - ➢យន្តការមិនបន្ទាន់៖ ធ្វើបណ្ដឹងពីបទបរិហារកេរ្ដិ៍ ពីបទមួលបង្កាច់ ឬ ពីបទជេរប្រមាថ ហើយតុលាការអាចសម្រេចបង្គាប់ឱ្យចុះផ្សាយនូវការកែតម្រូវ ឬសងជំងឺចិត្ត ឬ ទាំងពីរ។

# ផ្នែកទី២

## អំណាចនានារបស់ចៅក្រម

# អំណាចស្រាវជ្រាវកេតស្តាង

- ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ (ម៣៣៩) មានតួនាទីសកម្ម (ខុសពីចៅក្រមរដ្ឋប្បវេណី) ប្រើប្រាស់អំណាចទាំងអស់ដែលច្បាប់ផ្តល់ឱ្យក្នុងការស៊ើបអង្កេត ឬស៊ើបសួរស្វែងរកការពិត។ ក៏ប៉ុន្តែមិនអាចបង្ខំឱ្យជនណាម្នាក់ទទួលស្គាល់នូវឯកសារដែលបង្ហាញពីពិរុទ្ធភាពរបស់ខ្លួននោះទេ (សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង ឬ នៅស្ងៀមមិនឆ្លើយ)។

# អំណាចវាយតម្លៃភស្តុតាង

- **គោលការណ៍៖** ម១១០ ម៣១៨ ម៣២១ ក្រមនីតិវិធីព្រហ្មទណ្ឌមានចែងអំពីគោលការណ៍*សេរីភាពនៃភស្តុតាង* (ផ្ទុយពី *ប្រព័ន្ធភស្តុតាងនីត្យានុកូល* le système des preuves légales) និង**គោលការណ៍ឥស្សរចិត្តរបស់ចៅក្រម** ដែលចៅក្រមអាចជឿដោយសេរីទៅលើភស្តុតាងដែលមានក្នុងសំណុំរឿង។ ដូចនេះ ចៅក្រមមិនអាចផ្តន្ទាទោសនរណាម្នាក់ដោយគ្មានភស្តុតាងនោះទេ។

- ភស្តុតាងត្រូវតែស្របច្បាប់និងស្មោះត្រង់ ជាក់ទាក់ទងនិងអង្គហេតុ និងអាចជឿបាន។

# អំណាចវាយតម្លៃភស្តុតាង

❖ **អញ្ញត្រកម្ម៖** ក្រៅពីសេរីភាពនៃភស្តុតាង នីតិវិធីមានកម្ពុជាមានចែងផងដែរ អំពី ***ភស្តុតាងនីត្យានុកូល*** ដែលមាននៅសេសសល់ដូចជា៖

- ❑ បញ្ហាផ្នែករដ្ឋប្បវេណី៖ ប្រើប្រព័ន្ធភស្តុតាងនីត្យានុកូលភាព ឧ. សំបុត្រកំណើត។
- ❑ កម្លាំងភស្តុតាងនៃកំណត់ហេតុមួយចំនួន ម១១០ ក១ និងម១១៨ ក១៖
  - ➢ *តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានតែប៉ុណ្ណោះ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា **ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ**។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់។*
  - ➢ ប្រសិនបើកំណត់ហេតុតែមួយគត់នោះនៅមានវិមតិសង្ស័យ ចៅក្រមសម្រេចដូចម្តេច?

# អំណាចវាយតម្លៃភស្តុតាង

❖ **ការកម្រិតលើការប្រើអំណាចរបស់ចៅក្រម៖**

- **កាតព្វកិច្ចធ្វើសំអាងហេតុនិងសំអាងច្បាប់៖** ចៅក្រមត្រូវវាយតម្លៃភស្តុតាង និងផ្តល់ការពន្យល់ ឬទឡ្ហីករណ៍គាំទ្រការសេចក្តីសម្រេច។
- **ភាពអាចទទួលយកបានភស្តុតាង៖** ដើម្បីឱ្យភស្តុតាងអាចត្រូវបានពិនិត្យដោយចៅក្រម ភស្តុតាង [ដែលដាក់ដោយរាល់បុគ្គលទាំងអស់រាប់ទាំងគូភាគី សាក្សី ឬតតិយជន] ត្រូវតែអាចទទួលយកបានជាមុនសិន។
  - ➢ភាពស្របច្បាប់នៃភស្តុតាង៖ ភស្តុតាងដែលមិនស្របច្បាប់ត្រូវបដិសេធចោល។
  - ➢ភាពស្មោះត្រង់នៃភស្តុតាង ភស្តុតាងដែលទទួលបានដោយមិនស្មោះត្រង់ត្រូវបដិសេធចោល។

# ជំពូកទី២

## មធ្យោបាយនានានៃភស្តុតាង

# ការសារភាព

- **កម្លាំងភស្តុតាងនៃការសារភាព៖** ការសារភាពត្រូវចាត់ទុកថាជា**ក្សត្រីនៃភស្តុតាង**។ នីតិវិជ្ជមានកម្ពុជាមានចែងទទួលស្គាល់អំពីអានុភាពនៃការសារភាពនៅក្នុងនីតិវិធីមួយចំនួនដូចជា ការសម្របសម្រួលជាមួយរដ្ឋ [លើបណ្តឹងអាជ្ញា] (ម៨ក្រម) នីតិវិធីបង្ហែរអនីតិជន ជាដើម។
- ការសារភាពត្រូវទទួលបានតាមរយៈការស្តាប់ចម្លើយ និងស្របច្បាប់។ ភស្តុតាងដែលបានមកតាមរយៈសំណួរនាំមុខ?
  - ម៣៨ រដ្ឋធម្មនុញ្ញ *ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តីតាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។*
  - ម១៤ ចំណុច៣ (ឆ) ICCPR *មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។*
  - ម៣២១ ក្រម *ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ។*

# សាក្សី

❖ អ្នកអាចក្លាយជាសាក្សី៖

❑ បុគ្គលដែលដឹងផ្ទាល់អំពីអង្គហេតុដែលត្រូវបង្ហាញ។ សាក្សីឮគេថា ?

❑ បុគ្គលមានសមត្ថភាពក្នុងការផ្ដល់សក្ខីកម្ម៖

➢ ម១៥៦ អាចជាសាក្សីរួចសម្បថ៖ ឪពុក ម្ដាយ បុព្វញាតិគ្រប់រូប កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូប បងប្អូនប្រុសស្រី បងប្អូនថ្លៃប្រុសស្រី របស់ជនត្រូវចោទ ប្ដី ឬ ប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយ កុមារអាយុតិចជាង១៤ឆ្នាំ។ ករណីជនមានពិការភាព ?

➢ ម៣២៦តុលាការអាចស្ដាប់ចម្លើយមន្ត្រីឬភ្នាក់ងារនគរបាលយុត្តិធម៌ដែលចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈសាក្សី។

➢ ម៥៥៦ ចៅក្រមអាចធ្វើជាសាក្សីបាន ក៏ប៉ុន្តែមិនជំនុំជម្រះរឿងក្ដីដែលខ្លួនធ្វើជាសាក្សីនោះទេ។

# សាក្សី

- ត្រូវតែជាបុគ្គលថ្លៃថ្នូរ ពោល មិនត្រូវជាអ្នករងការផ្តន្ទាទោសដោយតុលាការៈ ម៥៥ ក្រមព្រហ្មទណ្ឌ ការដកហូតសិទ្ធិធ្វើជាសាក្សីដែលទទួលសម្បថនៅមុខតុលាការ។
- មិនត្រូវស្ថិតក្នុងករណីវិសមតិភាព៖
  - ម៩១ សាក្សីពីរនាក់ក្នុងកំណត់ផែកឆេរមិនអាចជាសមាជិកកងកម្លាំងដែលអនុវត្តការឆែកឆេរនោះទេ។
  - ម១៥៧ ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយសាក្សីដែលមានតម្រុយពិរុទ្ធភាពនោះទេ។
  - ម៣១២ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវគេស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនោះទេ។
  - ក្នុងការអនុវត្តនៅតុលាការកម្ពុជា ទណ្ឌិតឬជនដែលតុលាការសម្រេចឱ្យរួចខ្លួននឹងត្រូវកោះហៅក្នុងឋានៈជាសាក្សីដើម្បីមកចូលរួមសវនាការរបស់ជនជាប់ចោទដទៃទៀត។

# សាក្សី

## ❖ កាតព្វកិច្ចរបស់សាក្សី៖

### ❑ កាតព្វកិច្ចចូលបង្ហាញខ្លួន៖

- ➢ នៅដំណាក់កាលស៊ើបអង្កេត គ្មានសញ្ញាណ ***សាក្សី*** នោះឡើយ គឺមានតែ ***អ្នកអាចផ្តល់ព័ត៌មានអំពីរឿងហេតុ*** ខណៈក្រមព្រហ្មទណ្ឌបានចែងអំពីបទបដិសេធក្នុងការចូលខ្លួនក្នុងឋានៈជាសាក្សី។ ការអនុវត្តជាក់ស្តែងគឺអយ្យការចេញដីកាកោះហៅសាក្សី ហើយត្រូវមានកាតព្វកិច្ចចូលបង្ហាញខ្លួន។
- ➢ ការស៊ើបសួរ និងជំនុំជម្រះ៖ សាក្សីមានកាតព្វកិច្ចត្រូវចូលបង្ហាញខ្លួន ម១៥៣ (ដីកាបង្គាប់ឱ្យនាំខ្លួន) ម៣១៥ (ដីកាបង្គាប់ឱ្យនាំខ្លួន) ក្រម ម៥៣៨ ព្រហ្មទណ្ឌ (បទបដិសេធក្នុងការចូលខ្លួន)។

### ❑ កាតព្វកិច្ចធ្វើសម្បថ ម១៥៤ ត្រូវស្បថ ម១៧៩ ម៣២៨(ម១៥៦ រួចពីសម្បថ)

# សាក្សី

- **កាតព្វកិច្ចផ្ដល់ចម្លើយ៖** សម្បថគឺដើម្បីបង្ហាញអំពីភក្ដីភាពក្នុងការផ្ដល់ចម្លើយ៖
  - ការផ្ដល់ចម្លើយគឺត្រូវតែផ្ទាល់មាត់ (សាក្សីអាចអានឯកសារ?)
  - ការផ្ដល់ចម្លើយត្រូវធ្វើឡើងភ្លាម។
  - ការផ្ដល់ចម្លើយតម្រូវឱ្យសាក្សីមិនត្រូវទាក់ទងគ្នានាពេលសវនាការ ម៣២២។
  - ការផ្ដល់ចម្លើយត្រូវតែទាក់ទងនឹងអង្គហេតុដែលចោទប្រកាន់ ឬ ផ្លូវចិត្ត ឬ បុគ្គលភាពរបស់ជនដែលត្រូវចោទប្រកាន់។

# សាក្សី

- កាតព្វកិច្ចផ្ដល់ចម្លើយអនុវត្តដោយគោរពផងដែរនូវកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ។
  - ការមិនប្ដឹងបរិហារអំពីបទឧក្រិដ្ឋ ម៥២៩ ក្រមព្រហ្មទណ្ឌ និងការមិនផ្ដល់ភស្តុតាងនៃភាពគ្មានទោស ម៥៣៩ ក្រមព្រហ្មទណ្ឌ នឹងត្រូវលើកលែងឱ្យរួចផុតពីទោស ចំពោះបុគ្គលដែលច្បាប់តម្រូវឱ្យរក្សាអាថ៌កំបាំងវិជ្ជាជីវៈ។
  - មិនមានបទប៉ះពាល់ដល់ការសម្ងាត់វិជ្ជាជីវៈទេ កាលណាក្នុងឱកាសប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយបានបង្ហាញដល់អាជ្ញាធរតុលាការ រដ្ឋបាល ឬ វេជ្ជសាស្ត្រ អំពីការធ្វើបាបអនីតិជនអាយុយ៉ាងតិច ១៥ ឆ្នាំ ម៣១៥ ក្រមព្រហ្មទណ្ឌ (សូមមើល ម៥៣០)។

# ការការពារសាក្សី

❖វិធានការការពារសាក្សី ឧ.ការលាក់អត្តសញ្ញាណ ឬអាសយដ្ឋានសាក្សី ឬមន្ត្រីនគរបាល ឬការតាំងអត្តសញ្ញាណសាក្សី។ តុលាការសិទ្ធិមនុស្សអឺរ៉ុប ហាមឃាត់ករណីផ្តន្ទាទោសបុគ្គលណាម្នាក់ដោយផ្អែកលើសក្ខីកម្មអនាមិក។

❖**អ.វ.ត.ក៖ កន្លែងស្នាក់នៅរបស់សាក្សី** - វិធានការការពារអាសយដ្ឋាន ឬកន្លែងសាក្សីស្នាក់នៅ ធ្វើឡើងក្នុងគោលបំណងរឹតត្បិតការបង្ហាញខ្លួនរបស់សាក្សីដើម្បីរក្សាសុវត្ថិភាពចៀសផុតពីការគំរាមកំហែងផ្សេងៗ ឬផ្តល់នូវវិធានការឆ្លើយតបដ៏សមស្របចំពោះការគំរាមកំហែងដល់អត្តសញ្ញាណរបស់សាក្សី។

# ការការពារសាក្សី

❖**អ.វ.ត.ក៖ ក្នុងបន្ទប់សវនាការ** អង្គជំនុំជម្រះ អាចចេញវិធានការការពារដែលត្រូវអនុវត្តក្នុងអំឡុងពេលសាក្សីផ្តល់សក្ខីកម្ម ដើម្បីការពារអត្តសញ្ញាណ និងកន្លែងស្នាក់នៅរបស់សាក្សី។ វិធានការទាំងនោះរួមមាន៖

- ការដកចេញនូវឈ្មោះ អាសយដ្ឋាន កន្លែងស្នាក់នៅ និងព័ត៌មានផ្សេងទៀតរបស់សាក្សីដែលអាចនាំឱ្យស្គាល់អត្តសញ្ញាណរបស់សាក្សីបាន (ដីការក្សាការសម្ងាត់ និងហាមបញ្ចេញជាសាធារណៈ)
- ការប្រើឈ្មោះសម្ងាត់(រហស្សនាម)ជំនួសឈ្មោះពិត នៅពេលនិយាយទៅកាន់សាក្សី

# ការការពារសាក្សី

- ការលុបឈ្មោះសាក្សីពីសំណុំឯកសារតុលាការ និងការបិទស្លាកបោះត្រាសម្គាល់ ឬ កោសលុបព័ត៌មានពីកំណត់ហេតុសាធារណៈជាដើម។
- ការបំប្លែងសំឡេងដើម និង/ឬបិទបាំងភិនភាគរបស់សាក្សីពីអេក្រង់ទូរទស្សន៍របស់តុលាការ និង/ឬដាក់អេក្រង់នៅជុំវិញសាក្សីដើម្បីកុំឱ្យសាធារណជនដែលនៅកន្លែងអង្គុយក្នុងបន្ទប់សវនាការអាចសម្គាល់សាក្សីបាន។
- ការរៀបចំនីតិវិធីសវនាការសម្ងាត់ ពោលគឺបិទទ្វារដើម្បីរក្សាការសម្ងាត់។

# សិទ្ធិទទួលបានសាក្សី

- ICCPR ម១៤ ចំណុច៣ (ង) *ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុកនិងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។*
- ម១២៧ ការស្នើបសួរដាក់បន្ទុក និងដោះបន្ទុក។
- ម២៩៧ *សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទត្រូវតែកោះហៅឱ្យចូលរួមក្នុងសវនាការ។*
- ម៣២៤ *ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែមិនបានកោះហៅឱ្យបានត្រឹមត្រូវទេ។*

# តម្លៃនៃការផ្តល់សក្ខីកម្មរបស់សាក្សី

- **សក្ខីកម្មអាចត្រូវបានធ្វើឡើងដោយភូតភរកុហកដោយចេតនា៖** ម៥៤៥ បទផ្តល់សក្ខីកម្មក្លែងក្លាយ បន្ទាប់ពីស្បថនៅមុខតុលាការ ឬ មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស។ ត្រូវរួចផុតពីទោស ប្រសិនបើសាក្សីនេះប្រែក្រឡាស់ដោយឯកឯងនូវសក្ខីកម្ម ហើយនិយាយការពិតមុនសេចក្តីសម្រេចបិទបញ្ចប់កិច្ចនីតិវិធី។
- **សក្ខីកម្មអាចមានការភ័ន្តច្រឡំ៖** សូម្បីតែសាក្សីសុចរិតក៏អាចមានការភ័ន្តច្រឡំ ហើយដែលចៅក្រមមានអំណាចវាយតម្លៃដោយសេរី។

# ភស្តុតាងជាលាយលក្ខណ៍អក្សរ

- សំណេរអាចបង្កើតជាបទល្មើសដូចជាក្លែងឯកសារ ការគម្រាមដោយសំណេរជាដើម។
- កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌មានកម្លាំងភស្តុតាងដែលចៅក្រមត្រូវតែជឿរហូតដល់មានភស្តុតាងផ្ទុយ ម១១០ ក១ និងម១១៨ ក១។
- ការឆ្លើយឆ្លងតាមលិខិត ឬ សារឆ្លើយឆ្លងតាមទូរស័ព្ទអាចក្លាយជាភស្តុតាង។
- ភស្តុតាងជាកិច្ចសន្យា ដែលតាមវិធានរដ្ឋប្បវេណីមួយចំនួនទាមទារនូវលាយលក្ខណ៍អក្សរ។
- របាយការណ៍ហិរញ្ញវត្ថុ ឬសវនកម្មដែលមានបង្ហាញតួលេខ។

# កោសលវិច័យ

- កោសលវិច័យដើម្បីបង្កើតភស្តុតាង ខុសពីកោសលវិច័យលើបុគ្គលភាពទណ្ឌិតដើម្បីទទួលបាននូវការព្យាបាល ជាដើម។
- គ្មានឡើយអ្នកជំនាញកោសលវិច័យរបស់ភាគីចោទប្រកាន់ និងភាគីការពារក្តី។ ការធ្វើកោសលវិច័យគឺមិនចំពោះមុខ ក៏ប៉ុន្តែលទ្ធផលកោសលវិច័យត្រូវតែយកមកពិភាក្សាដេញដោលដោយចំពោះមុខ។
- កោសលវិច័យបន្ថែម និងប្រតិកោសលវិច័យ ម១៧០។

# កោសលវិច័យ

- ❖អ្នកជំនាញត្រូវតែបំពេញការងារតាមការបង្គាប់របស់តុលាការ ម១៦៥ និងក្រោមការត្រួតពិនិត្យរបស់ចៅក្រម ម១៦៦។
- ❖អ្នកជំនាញត្រូវសរសេររបាយការណ៍ និងដាក់ជូនតុលាការតាមកាលកំណត់ ម១៦៥ ម១៦៦ ១៦៨។
- ❖អ្នកជំនាញបកស្រាយនៅសវនាការអំពីលទ្ធផលនៃការរកឃើញ។
- ❖ចៅក្រមមិនត្រូវបានបង្ខំជាប់ជំពាក់ទទួលយកសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញនោះទេ (ឥស្សរចិត្តរបស់ចៅក្រម)។

# សច្ចធារណ៍

❖ **សច្ចធារណ៍តាមផ្លូវច្បាប់ (បង្កើតឡើងដោយច្បាប់)**៖ សច្ចធារណ៍នៃនិរទោស សច្ចធារណ៍នៃការការពារស្របច្បាប់ (ម៣៤ ក្រមព្រហ្មទណ្ឌ) សច្ចធារណ៍នៃពិរុទ្ធភាព ដែលជាទូទៅអាចបដិសេធដោយភស្តុតាងផ្ទុយ។

❖ **សច្ចធារណ៍តាមផ្លូវតុលាការ (បង្កើតឡើងដោយតុលាការ)**៖ ការអនុវត្តនៅតុលាការកម្ពុជា ការទទួលទិញ ឬបញ្ចាំម៉ូតូ ឬរថយន្ត ដោយគ្មានលិខិតសម្គាល់កម្មសិទ្ធិ គឺជាការសង្ស័យអំពីបទទទួលផលចោរកម្ម។ សហព័ទ្ធឬកូនរបស់ជនរងគ្រោះដែលស្លាប់ ត្រូវសន្មតថាមានព្យសនកម្មផ្លូវចិត្ត។

# សូមអរគុណ